# បរិវារស័ព្ទក្នុងភាសា ខ្មែរ



SOS CVC
SOS HGS Angkor SR
LR.Kh.B 06.000469.2/1

សូមថ្លែងអំណរគុណពិសេស ចំពោះលោក ទ្រិញ-ម៉ាញ ប្រធានសមាគមសម្តេច ជួន-ណាត ដែលបានផ្តល់ ឯកសារ និង ជួយណែនាំក្នុងការបោះពុម្ពសៀវភៅនេះ ។

**ស៊ីសុខត្ថិ-ប៉ូរត្នស៊ី**

# សេចក្ដីថ្លែងអំណរគុណ

ជាបឋម ខ្ញុំសូមថ្វាយព្រះកុសល និងថ្លែងអំណរព្រះគុណជាពន្លឹក ចំពោះព្រះភិក្ខុ វិរិយបណ្ឌិតោ **ប៊ុច-ខាត់** ដែលលោកទ្រង់ព្រះមេត្តាជួយពិនិត្យផ្ទៀងផ្ទាត់ ព្រមទាំងជួយផ្ដល់យោបល់ផ្សេងៗ ចំពោះការរៀបរៀងសៀវភៅនេះ ។

លោក **គន់ ឡេវ៉ុន**, លោក **ស៊ុន ម៉េងស្រ៊ុន** អធិការនគរបាលជាតិ, លោក **គឹម ឆុក** និង លោក **ត្លូច គិន** នាយត្រួតនគរបាលជាតិ បានជួយឧបត្ថម្ភដោយពុំញញើត ហ៊ានផ្ដល់យោបល់ផ្សេង ៗ និងកែតម្រូវពាក្យពេចន៍ដ៏មានតម្លៃល្អប្រពៃចំពោះអត្ថបទខ្លះឱ្យបានប្រសើរទៅទៀត ដែលជាកិច្ចធ្វើឱ្យខ្ញុំបំភ្លេចគុណពុំបាន ។

ខ្ញុំសូមគោរព និងអរគុណជាទីបំផុត ចំពោះអស់លោកអ្នកនិពន្ធផ្សេងៗទៀត ជាពិសេសលោក **អិត ឈួន** និង **កែប ច៉ាន់ឌី** ដែលបានអនុញ្ញាតឱ្យខ្ញុំដកស្រង់ នូវពាក្យពេចន៍ខ្លះ ពីក្នុងសៀវភៅដូចមានយោងនៅក្នុងទំព័រឯកសារពិគ្រោះនេះ ។

សំខាន់ទៅទៀត ខ្ញុំសូមថ្លែងអំណរគុណចំពោះលោក **ឌឹក គា**
ដែលបានជួយកែតម្រូវអក្ខរាវិរុទ្ធ លោក **គាឌុលគាដែន** អគ្គនាយ
ក្រុមនគរបាលជាតិ និងលោកស្នងការដើមខ្សែនៃនគរបាលជាតិ **ស៊ុំ សុ**
ប្រធានសមាគមមិត្តប៉ូលីស ដែលបានបញ្ជានិងណែនាំឱ្យខ្ញុំស្រាវជ្រ
ប្រមែប្រមូលនូវពាក្យបរិវារស័ព្ទទាំងអស់នេះ ហើយចងក្រងបានជាសៀ
ភៅ ដើម្បីទុកជាអនុស្សាវរីយ៍ជូនដល់និស្សិតក្មេងៗ ជំនាន់ក្រោយ
បានចេះដឹង និងពិចារណា ទៅអនាគត ។

**ស៊ីសុខគ្គិ – ប៉ូរត្នស៊ី**

# សូមចម្រើនពរ

ក្នុងពេលកំពុងសាងភាសាជាតិ ឱ្យបានប្រសើរ មានលក្ខណៈត្រឹមត្រូវតាមអម្បូរខ្មែរ-មន (ខ.ម.) ដូចដើមវិញនោះ មានការខ្វះខាតបច្ចេកទេសច្រើនណាស់ ។

ក្បួន « **បរិវារសព្ទ** » របស់លោក **ស៊ីសុវត្ថិ-ប៉ូរក្វស៊ី** នេះទោះម្តេចម្តា ជាវិភាគទានមួយដ៏ប្រសើរ ជាមតិមួយជួយបំភ្លឺ ក្នុងការរៀបចំភាសាខ្មែរ ។

សូមលោក **ស៊ីសុវត្ថិ-ប៉ូរក្វស៊ី** មេត្តាជួយតទៅទៀត អាត្មាភាពសូមជូនពរ សូមឱ្យមានសុខភាពបរិបូណ៌ ហើយបន្តការមានប្រយោជន៍សម្រាប់ជាតិ តទៅទៀត ។

អរគុណច្រើនណាស់

វីរិយបណ្ឌិតោ ភិក្ខុ **ប៉ាង ខាត់**

១០កក្កដា ១៩៧២

# សេចក្តីយល់ឃើញ

សៀវភៅ "បរិវារស័ព្ទក្នុងភាសាខ្មែរ" របស់លោក **ស៊ីសុវត្ថិ ប៉ូរក្ខស៊ី** នេះ មានសារៈសំខាន់ណាស់ សម្រាប់ជនជាតិខ្មែរ និងជនបរទេស ដែលត្រូវការសិក្សាភាសាខ្មែរ ។

គួរកត់សម្គាល់ផងដែរថា ធម្មតាការងារអ្វីទាំងអស់ក្នុងលោកនេះ តែងតែមានសេចក្តីឆ្គាំឆ្គងខ្លះ គឺជាទម្លាប់នៃការងាររបស់អ្នកបុថុជ្ជន ។ សុភាសិតបុរាណភាសិត ក៏បានបញ្ជាក់ទុកមកហើយថា «ដំរីជើងបួនគង់មានភ្លាត់ អ្នកប្រាជ្ញចេះស្ទាត់ គង់មានខុស » ។

ប៉ុន្តែ បើមានត្រូវច្រើន ហើយមានខុសតែបន្តិចបន្តួច ក៏គង់អាចប្រែការកើត និងចាត់ទុកថា ជាការងារមួយល្អប្រសើរដោយពិត ។

អ្នកមានចំណេះម្នាក់ៗ ប្រកបដោយគតិបណ្ឌិត ប្រសិនបើមានសេចក្តីព្យាយាមធំដូចលោក **ស៊ីសុវត្ថិ-ប៉ូរក្ខស៊ី** នេះ បានធ្វើការស្រាវជ្រាវអក្សរសាស្ត្រ ជួយលើកស្ទួយអក្សរសាស្ត្រឱ្យថ្កុំថ្កើង បង្ហាញនូវស្នាដៃថ្មីគំនិត ទុកជាកេរ្តិ៍មរតក ឱ្យបច្ឆាជនចេះដឹងតៗទៅផងនោះ ម្ល៉េះសម

ប្រទេសជាតិយើង ពោលគឺសាធារណរដ្ឋខ្មែរ នឹងអាចលូតលាស់ចម្រើនជានិច្ច ខាងផ្នែកវប្បធម៌ ពុំអន់ថយឡើយ ។

ស្នាដៃថ្មីគំនិតដ៏ឧត្ដម របស់អ្នកបញ្ញវ័ន្ត អ្នកវីរិយវ័ន្តនោះ ៗ ជាកេរ្តិ៍ឈ្មោះក្រអូប និងអាចផ្សព្វផ្សាយទៅកាន់គ្រប់ទិសទីឆ្ងាយ មានចិរៈវេលាយូរណាស់ទៅអនាគត ពុំសាបសូន្យសោះឡើយ ។

ភ្នំពេញ ថ្ងៃទី ១៩ មេសា ព.ស. ២៥១៦ / គ.ស. ១៩៧២

គន់ ញឿង

អតីតអ្នកសិក្សាសំស្ក្រឹត-បាលី-ខ្មែរ មន្ត្រីរដ្ឋបាល
ទីប្រឹក្សាវាយការណ៍ ក្រុមប្រឹក្សានៃទីប្រឹក្សាសេដ្ឋកិច្ច
ខុទ្ទកាល័យប្រតិបត្តិប្រធានាធិបតី

**ឯកសារដែលបានពិគ្រោះ**

– វឌ្ឍនធមិឥណ្ឌូនិយម នៃប្រទេសឥណ្ឌូចិន និងប្រទេសឥណ្ឌូនេស៊ី និពន្ធដោយលោក **ស.សឺដេស** បណ្ណាគារ ដឺបូកា ប៉ារីស ឆ្នាំ ១៩៦៤ ។

– ដើម្បីងាយស្គាល់ប្រាសាទនគរវត្ត និពន្ធដោយលោក **ស.សឺដេស** បណ្ណាគារ អាទ្រីយាង មេសុងនឺវ ប៉ារីស ឆ្នាំ ១៩៤៧ ។

– ប្រាសាទបុរាណទាំងអស់ ក្នុងចំណោមប្រាសាទអង្គរវត្ត និពន្ធដោយលោក **ម៉ូរីស.គ្លែស** បណ្ណាគារ អាទ្រីយាង មេសុងនឺវ ប៉ារីស ឆ្នាំ ១៩៦៣ ។

– កំណត់ហេតុលោក **ជីវ តាក្វាន់** ស្ដីអំពីប្រពៃណីអ្នកស្រុកចេនឡា ប្រែពីភាសាចិន មកជាភាសាបារាំង ដោយលោក **ប៉ូល.ប៉េលីយ៉ូ** បណ្ណាគារ អាទ្រីយាង មេសុងនឺវ ឆ្នាំ ១៩៥១ ប្រែពីភាសាបារាំង មកជាភាសាខ្មែរ ដោយលោក **ឱក.គាម** ភ្នំពេញ ឆ្នាំ ១៩៧០ ប្រែពីភាសាចិន មកជាភាសាខ្មែរ ដោយលោក **លី.ធាមតេង** ភ្នំពេញ ឆ្នាំ ១៩៧១ ។

– ប្រាសាទអង្គរនិងប្រទេសកម្ពុជា នៅសតវត្សទី ១៦ ដោយ

ពតិមាន ពរទុយគ្គេ និងអេស្ប៉ាញញ៉ុល និពន្ធដោយលោក **ប៊ែណា-ហ្វី លីប គ្រោលីយេ** បណ្ណាគារ ប្រេស អុយនីវែរស៊ីទែ ប៉ារីស ឆ្នាំ ១៩៥៨ ។

– ព្រឹត្តិការណ៍ជាក់ស្តែង ដោយសង្ខេប នៃប្រទេសកម្ពុជា នៅសតវត្សទី ១៦ និពន្ធដោយបព្វជិតកាតូលីក **សង់-អង់តូនីញ៉ូ** ប្រែពីភាសាអេស្ប៉ាញញ៉ុល មកជាភាសាបារាំង លោក **អង់ត្វាន-កាបាតុង** បណ្ណាគារប៉េដ្រូ ឡាសសូ រាជធានីម៉ាឌ្រីត ឆ្នាំ ១៦០៤ ។

– ស្តេចកន និពន្ធដោយលោក **អាដេម៉ា ឡឺ ខ្លែរ** ទស្សនាវដ្តីប្រទេសឥណ្ឌូចិន ឆមាសទី ២ ព្រៃនគរ ឆ្នាំ ១៩១០ ។

– ឯកលេខនានៃប្រទេសកម្ពុជា និពន្ធដោយលោក **ហ្សេណា-ម៉ូរីសុខ** ហាណូយ ឆ្នាំ ១៩៣១ ។

– ប្រទេសកម្ពុជានៅសម័យដើម និពន្ធដោយលោក **គូស្តាវ-សាណូ** ទស្សនាវដ្តីឥណ្ឌូចិន ខែមិនា-មិថុនា ឆ្នាំ ១៩១៤ ភាគ ២១ និង ២២ ហាណូយ ។

– ទាសភាពនានានៃប្រទេសកម្ពុជាយើង ក្នុងសម័យបុរាណ និពន្ធដោយលោក **អង់ត្វាន-កាបាតុង** ទស្សនាវដ្តី ឥណ្ឌូចិន ភាគ ១២ លេខ ២ ខែ កុម្ភៈ ឆ្នាំ ១៩១០។

– ការធ្វើដំណើរនៃជនជាតិអេស្ប៉ាញ៉ុល មកប្រទេសកម្ពុជា នៅចុងសតវត្សទី ១៦ និពន្ធដោយលោក **ទិកន័រ-ឆារបឺយេ** ទស្សនាវដ្ដីឥណ្ឌូចិន ខែ មិថុនា-សីហា ឆ្នាំ ១៩២២ ។

– ភាសាខ្មែរ និពន្ធដោយលោក **អៀវ-កើស** បណ្ណាគារ មិត្តសេរី ភ្នំពេញ ឆ្នាំ ១៩៦៧ ។

– អរិយធម៌ខ្មែរ-មន និពន្ធដោយលោក **កែប-ទ័រន់ឌី** បណ្ណាគារ អប្សរា ភ្នំពេញ ឆ្នាំ ១៩៧១ ។

– ស្រាវជ្រាវរករកភាសាខ្មែរ បុរាណ និពន្ធដោយលោក **អ៊ិត-ឈុន** ភ្នំពេញ ឆ្នាំ ១៩៧១ ។

– ប្រាសាទអង្គរវត្ត មនុស្សនិងថ្ម និពន្ធដោយលោក **ប៊ែរណា-ហ្វីលីប គ្រោលីយេ** បណ្ណាគារ អារតូ ក្រីណូប ឆ្នាំ ១៩៦៨ ។

– ឯកលេខនា នៃខេត្តកំពត និពន្ធដោយលោក **មេណេទ្រីយេ** ព្រៃនគរ ឆ្នាំ ១៩២៦ ។

– វាក្យស័ព្ទសាសន៍សួច និពន្ធដោយលោក **មួ ហ៊ា** ព្រៃនគរ ឆ្នាំ ១៩០០ ។

– សេចក្ដីលំនាំ ដើម្បីស្គាល់ច្បាស់អង្គរ និពន្ធដោយលោក **ម៉ា-ម័ខថេ** បណ្ណាគារ អាល់ប៊ែព័រតែ ភ្នំពេញ ១៩៦០ ។

– ដើមកំណើតនៃប្រាសាទអង្គរ និពន្ធដោយលោក **លី ហ៊ីណុ** ភ្នំពេញ ឆ្នាំ ១៩៦២ ។ ប្រទេសអាស៊ីផ្នែកអគ្នេយ៍ និពន្ធដោយលោក **ចំរ សឺលីយេ** បណ្ណាគារ ពីការ ប៉ារីស ឆ្នាំ ១៩៦៦ ។

– អង្គរនិងរ៉ូម (Angkor and Rome) ប្រវត្តិសាស្ត្រប្រៀបធៀប និពន្ធដោយលោក **ក្វារិត វេលើស** (Quaritch Wales) រាជធានីឡុងដ្រ៍ ។

– ទាសភាពនៅប្រទេសឥណ្ឌូចិន ជាពិសេស នៅប្រទេសខ្មែរ និងអាណ្ណាម និពន្ធដោយលោក **ប៉ូលុស** (Paulus) ប៉ារីស ១៨៨៦ ។

– សូមមេត្តាអានអារម្ភកថាខ្ញុំ ឱ្យបានច្រើនលើកច្រើនសា ទើបងាយយល់សេចក្ដីដែលខ្ញុំបានសរសេរនៅទំព័រខាងក្រោយនេះ ។

# BIBLIOGRAPHIE

— Les Etats hindouisés d'Indochine et d'Indonésie, par Mr. G. Cœdès. Edts.E. de Boccard, Paris 1964.

—Pour Mieux Comprendre Angkor, par Mr. G.Cœdès. Librairie d'Amérique et d'Orient, Adrien Maisonneuve, Paris, 1947.

—Les Monuments du groupe d'Angkor par Mr. Maurice Glaize. Lib. d'Amérique et d'Orient, Adrien Maisonneuve, Paris, 1963.

— Mémoires sur les Coutumes du Combodge de Tcheou Ta-Kouan, traduites du chinois en français par Mr. Paul Pelliot. Lib. d'Amérique et d'Orient, Adrien Maisonneuve, Paris 1951; traduites du français en cambodgien par Mr. Dik Kéam. Phom-Penh, 1970; tranduites du Chinois en cambodgien par Mr. LY Théam Téng. Phom-Penh, 1971.

— Angkor et Le Cambodge au XVIè. siècle d'après les sources portugaises et espagnoles, par Mr. Bd. P. Groslier, Edts. presses universitaires de France. paris, 1958.

—Relation brève et véridique des événements du royaume du Cambodge au roi Don Philippe d'Espagne par le Fr. Gabriel de San Antonio, traduite de l'espagnol en Français par Mr. Antoine Cabaton. Edts. A. S. Pablo de Valladolid par Pedro Lesso, Madrid, 1604.

— Le Sdach Kan, par Mr. Adhémard Lec'ère, Revue de la Société des Etudes Indochinoises, 2è. semestre 1910.

— Monographie du Cambodge, par Mr. René Morizon. Hanoi, 1931.

—Le Cambodge d'autrefois par Mr.Gustave Janneau. Revue Indochinoise, Mars-Juin 1914, tomes XXI-XXII. Hanoi.

— La Vie domestique au Cambodge par Antoine Cabaton. Revue indochinoise, Tome XII,no-2 mois de Février 1910.

— Voyages des Espagnols au Cambodge à La fin du XVIè. siècle, par Victor Barbier, Revue indochinoise, Juin-Août 1922.

— Essai d'Etudes raisonnées de la langue Cambodgienne par Mr. Iêu Kœus, librairie Mitt Sérey, Phnom-Penh 1967.

— Civilisation Khmère-Mône par Mr.Kêp-Randy, Imprimerie Apsara, Phnom-Penh., 1971.

— Recherche sur le Khmer par Mr. Ith Chhun, Phnom—Penh, 1971.

— Angkor, Hommes et la Pierre par Mr. Bd. P. Groslier, Edts. Arthaud, Crenoble, 1968.

— Monographie de la Province de Kampot, par Mr. Ménétrier, Saigon 1926.

— Vocabulaire Saoch, par Mr. Moura, Saigon 1900.

— Guide d'Angkor par H. Parmentier. Edts, A. Portail, Phnom-Penh 1960.

— L'Origine d'Angkor, par Louis Finot, Phnom-Penh 1962.

— L'Asie du Sud-Est, le Cambodge, par Mr. Boisselier, Edts. Picard, Paris, 1966.

— Angkor and Rome, «A historical comparison» by H.G. Quaritch Wales (London).

— L'Esclavage dans l'Indochine et en particulier au Cambodge et dans l'Annam par Paulus, Paris, 1886.

## អារម្ភកថា

សៀវភៅនេះ ខ្ញុំបានរៀបរៀងឡើង ដើម្បីជាការល្បងសិក្សាពិនិត្យដោយរកហេតុផល នូវការប្រឌិតជាបរិវារស័ព្ទនៃពាក្យនីមួយៗ ក្នុងភាសាខ្មែរយើងសព្វថ្ងៃនេះ ដោយខ្ញុំបានព្យាយាមស្រាវជ្រាវរិះរក អស់រយៈពេលដ៏យូរមកដែរ ក្នុងឯកសារផ្សេងៗ ដូចជាសាស្ត្រាខ្មែរបុរាណក្ដី សិលាចារឹកក្ដី ដែលមានសេចក្ដីបកប្រែជាភាសាខ្មែរសម័យ ដោយអ្នកប្រាជ្ញបារាំងសែសក្ដី តាមសេចក្ដីដំណែដំណាលត ៗ គ្នា ពីអស់លោកព្រឹទ្ធាចារ្យក្ដី ព្រមទាំងធ្វើសេចក្ដីសង្កេតតាមលំនាំទំនៀមទម្លាប់ប្រពៃណីនៃប្រជាពលរដ្ឋខ្មែរយើង តាមតំបន់នានា ដែលស្ថិតនៅឆ្ងាយពីគ្នាផងក្ដី ឃើញថា អស់លោកសាស្ត្រាចារ្យបុរាណខ្មែរយើង លោកបានជ្រើសរើសប្រឌិតផ្សំជាសមាសពាក្យ ឬសមាសនាមមួយបែប (Mots composés) ដោយប្រើពាក្យហែហម យកមកផ្គួរផ្គងភ្ជាប់នឹងពាក្យដើម ធ្វើជាបរិវារ ហើយឱ្យឈ្មោះថា ''បរិវារស័ព្ទ'' ។ ពាក្យមួយគូៗប្រភេទនេះ មានអត្ថរសជ្រៅៗណាស់ ព្រមទាំងមានន័យព្រលំគ្នា ច្បាស់ ប្រាកដ ក្នុងចំណោមសមាសពាក្យ ដែលមានពាក្យដើមមួយម៉ាត់ដូចគ្នា (différence délicate entre les mots du même genre) ។

## តើអ្វីទៅ ដែលគេហៅថា បរិវារស័ព្ទ

បរិវារស័ព្ទគឺ ជា បរិវារ + ស័ព្ទ = ស័ព្ទហែហម ភ្ជាប់នឹងស័ព្ទដើមក្នុងចំណោមសមាសនាមនិមួយៗ ប្រៀបធៀបដូចជាបរិវារ ដើម្បីសម្រួលសម្ដីនិយាយ និងប្រគំសូរសំឡេងពិរោះ ផ្ដួលតាមសំឡេងស័ព្ទដើម ឱ្យមានសភាពជាប់ចុងជួន សម្រួលដល់ត្រចៀកអ្នកស្ដាប់នោះម្យ៉ាង ដើម្បីជាគុណស័ព្ទ ពន្យល់យ៉ាងច្បាស់ នូវលក្ខណៈ ឬគុណសម្បត្តិ នៃពាក្យដើមនោះ ទៀតផង ។

### សមាសនាមប្រភេទនេះ មានពីរយ៉ាង គឺ

ក- ពាក្យដើមផ្សំគ្នានឹងបរិវារស័ព្ទ ដូចជាពាក្យ ទឹកភក់, កន្ទេលខ្នើយ, ប្រាក់កាស, ព្រៃផ្សៃ ។ល។

សមាសនាមដូចខាងលើនេះ សុទ្ធសឹងជាពាក្យមានន័យចំហធំៗទាំងអស់ គឺ ទឹក និង ភក់, កន្ទេល និង ខ្នើយ, ប្រាក់ និង កាស, ព្រៃ និង ផ្សៃ ។ ល ។ ពាក្យថា ផ្សៃ មួយម៉ាត់នេះ ប្រហែលជាអស់លោកអ្នកអានពុំអាចស្គាល់ឡើយ គឺជាពាក្យ ជូនព្រៃភ្នំ ប្រែមកថាសត្វពស់ ។ដូច្នេះ ព្រៃផ្សៃ បានសេចក្ដីថា ព្រៃពស់ ព្រោះស្ទួច កាល

សម័យដើម ប្រទេសយើង មានព្រៃឈើធំៗច្រើនណាស់ ដែលសម្បូណ៌ទៅដោយសត្វព្រៃ ដូចជាសត្វ ពស់-ក្អែបភ្នំ ជាអាទិ៍ ។

ចំពោះពាក្យ ផ្សៃ សូមអានសាវតារខេត្តកំពត ទំព័រ ៤១ និពន្ធដោយលោក ម៉េណេទ្រីយេ (Ménétrier) ផ្សាយចេញពីរោងពុម្ពចុងបូព៌ាប្រទេស ( Extrême-Orient ) នៅព្រៃនគរ ក្នុងឆ្នាំ ១៩២៦ និងសូមអានសៀវភៅ វាក្យស័ព្ទ នៃពាក្យ ស្អូច (Vocabuleier-Saoch) និពន្ធដោយលោក មូរ៉ា (Moura), សៀវភៅនេះ មានតម្កល់ទុកសព្វថ្ងៃនៅបណ្ណាល័យពុទ្ធសាសនបណ្ឌិត ភ្នំពេញ ។

ខ- ពាក្យដើមផ្សំនឹងបរិវារស័ព្ទ ដូចជាពាក្យ សម្លួសម្លុក, ប្ដីសី, បីបាច់, ជាតិជៅ ។ល។

ពាក្យទាំងពីរម៉ាត់ ក្នុងចំណោមសមាសនាមខាងលើនេះ មានតែពាក្យដើមទេ ដែលមានអត្ថន័យចំហ, រីឯបរិវារស័ព្ទវិញ ពុំឃើញមានអត្ថន័យអ្វីគួរឱ្យចាប់អារម្មណ៍ឡើយ តែបើយើងពិចារណាឱ្យជ្រៅជ្រះដើម្បីរិះរកហេតុផលឱ្យសព្វគ្រប់ទៅ យើងអាចរកឃើញគោលដៅសំខាន់ៗនៃបរិវារស័ព្ទទាំងនេះ ដែលមានអត្ថន័យជ្រៅហើយសំខាន់ទៀត

ផង ដោយប្រើជាគុណស័ព្ទ បង្ហាញយ៉ាងច្បាស់ ឱ្យឃើញនូវលក្ខណៈនៃពាក្យដើមនិមួយៗ ។

ដូច្នេះ ខ្ញុំសូមធ្វើអត្ថាធិប្បាយវែកញែក រកហេតុផល ជូនតែបរិវារស័ព្ទ នៃសមាសនាម ក្នុងវគ្គអក្សរ ខ ដែលមានអត្ថន័យលាក់កំបាំងហាក់ដូចជាបញ្ហាមួយ ដែលលោកអ្នកប្រាជ្ញបុរាណចងក្រងជាប្រស្នាទុកឱ្យកូនចៅរិះរកទៅថ្ងៃក្រោយ ។

បរិវារស័ព្ទទាំងនេះ ខ្ញុំបានរៀបរៀងជូនតាមលំដាប់អក្ខរានុក្រម ( Ordre alphabétique ) ព្រមទាំងពន្យល់ន័យមួយៗ នៅទំព័រខាងក្រោយ ។

## បុព្វហេតុដែលបណ្ដាលឱ្យខ្មែរយើង ប្រើបរិវារស័ព្ទ

មុននឹងធ្វើអត្ថាធិប្បាយវែកញែករឿងនេះ ខ្ញុំសូមឆ្លៀតឱកាសជំរាបដោយសង្ខេប នូវប្រពៃណីខ្មែរយើងសម័យបុរាណ ដែលមានសារៈសំខាន់ ទាក់ទងគ្នាជាលំនាំដើម ក្នុងការប្រើបរិវារស័ព្ទ រហូតមកដល់សព្វថ្ងៃនេះ ។

កាលនោះ ប្រទេសខ្មែរយើង ជាមហាប្រទេសមួយក្នុងពិភព-

លោក មានព្រំប្រទល់ធំធេងទូលំទូលាយណាស់ ព្រមទាំងមានប្រទេសរណបយើងជាច្រើនផង ។ អរិយធម៌និងវឌ្ឍនធម៌យើងក្តី សឹងមានពន្លឺរស្មីត្រចះត្រចង់ ប្រកបដោយកិត្តិស័ព្ទនិងឥទ្ធិពលល្បីល្បាញខ្ចរខ្ចារពាសពេញ នៅចុងបូព៌ាប្រទេសនៃទ្វីបអាស៊ីទាំងមូល ។

ធនធានយើងទៀត ក៏សម្បូណ៌ច្រើនជាអនេកប្បការ គ្រាន់តែសម្ភារៈសម្រាប់ភ្ញៀវកិត្តិយសនៅប្រាសាទតាព្រហ្មតែមួយប៉ុណ្ណោះ ឃើញថា យើងមានចានជាច្រើនថុន ធ្វើអំពីមាសសុទ្ធពណ៌ក្រហមឆ្អៅ មានទម្ងន់ទាំងអស់ដល់ទៅប្រាំតោន ប្រកបដោយក្បាច់ចម្លាក់រចនាផ្សេងៗ និងដាំត្បូងពេជ្រទាំងគ្រាប់តូចធំ និងត្បូងពណ៌ឯទៀត ឆ្លុះតាមក្បាច់ផ្កាភ្ញីផ្សេងៗ នៅលើចាននិមួយៗនោះ ។ ៧ ។

ពត៌មានប្រភេទនេះ សូមអានកំណត់ហេតុលោក ជីវ-តាក្វានស្តីអំពីប្រពៃណីអ្នកស្រុកចេនឡា ប្រែពីភាសាចិនមកជាភាសាខ្មែរ ដោយលោក លី - ធាម តេង, ប្រែពីភាសាចិន មកជាភាសាបារាំង ដោយលោក ប៉ូល-ប៉េលីយ៉ូ ប្រែពីភាសាបារាំង មកជាភាសាខ្មែរ ដោយលោកឌឹក-តាម សូមអានសៀវភៅពីរទៀត និពន្ធដោយលោក សឺដេស (G. Cœdès) ដែលមានចំណងជើង:

១. វឌ្ឍនធម៌ឥណ្ឌូនិយម នៃប្រទេសឥណ្ឌូចិន និងប្រទេសឥណ្ឌូនេស៊ី ។

២. សៀវភៅ ដែលមានចំណងជើងថា "ដើម្បីងាយស្គាល់ប្រាសាទអង្គរវត្ត" ។

និងបញ្ចប់ សូមអានសៀវភៅលោក ម៉ូរីស-ក្លែស (Maurice-Glaize) ស្ដីអំពីប្រាសាទបុរាណទាំងអស់ ក្នុងចំណោមប្រាសាទអង្គរវត្ត, ទំព័រ ១៨៤ ។

## របៀបចាត់ថ្នាក់នៃលំដាប់សក្តិមន្ត្រីយោធា

កាលសម័យបុរាណ ប្រទេសខ្មែរយើង រៀបចំចាត់ថ្នាក់មន្ត្រីយោធា តាមលំដាប់កងទ័ពជាតិរ៉ូម៉ាំង (légion romaine) ដែលមេក្រុមនិមួយៗ មានងារជាដេគួរីយ៉ុង (១០) Décurion, សង់ទីរីយ៉ុង (១០០) Centurion, មីល្លីរីយ៉ុង (១.០០០) Millurion គឺនាយត្រួត ១០ នាក់, ១០០ នាក់ និង ១.០០០ នាក់ ។ល។ (សូមអានសៀវភៅ អង្គរ និងប្រទេសរ៉ូម) ។

ចំណែកមន្ត្រីយោធាខ្មែរយើងវិញ មានលំដាប់ថ្នាក់របៀបគ្នាដែរ គឺ នាយរយ នាយត្រួតមនុស្សមួយរយនាក់, នាយពាន់ នាយត្រួត

មនុស្សមួយពាន់នាក់, នាយម៉ឺន នាយត្រួតមនុស្សមួយម៉ឺននាក់, នាយសែន នាយត្រួតមនុស្សមួយសែននាក់ ។

ចំពោះ នាយម៉ឺន និង នាយសែន ដែលមានបណ្តាសក្តិធំពេកទៅ អ្នកនៅក្រោមឱវាទទាំងអំបាលម៉ាន ពុំហ៊ានបន្លឺស័ព្ទស្រដីហៅចំងារថា នាយម៉ឺន ឬ នាយសែន ទេ, ម្ល៉ោះហើយ ពាក្យនាយមួយម៉ាត់នេះបានក្លាយទៅជាពាក្យមួយថ្មីទៀតដែលមានសំឡេងបង្អួរឡើងដោយញញើតញញើមខ្លាចពុំពិរោះគាប់ថា "នាម៉ឺន, នាសែន"[១] ទៅវិញ, រហូតទៅដល់បំបាត់ពាក្យ « នា » នេះ ទៅទៀត ហើយក្លាយទៅជាហៅថាលោកម៉ឺនឯក ឬ ម៉ឺនទោ ។ល ។

## ការចេញដំណើរនៃមន្ត្រីបុរាណ

ការចេញដំណើរនៃមន្ត្រីបុរាណនោះ បើតាមលោកជីវ-តាក្វាន់ និងបព្វជិតកាតូលិក អេស្ប៉ាញ៉ុល ឈ្មោះ សង់-អង់តូញ៉ូ (Le Frère do-

---

១- ត្រង់នេះ សូមអ្នកសិក្សាស្រាវជ្រាវអានវចនានុក្រមខ្មែរ ភាគ ១ ទំព័រ ៥០៤ បោះពុម្ពលើក ទី ៥ ផ្សាយចេញពីពុទ្ធសាសនបណ្ឌិត្យ (ឱ- គាម)

minlcan de San Antonio) ដែលលោកបានធ្វើសេចក្ដីរាយការណ៍ថ្វាយព្រះចៅ ដុង-ហ្វីលីប (Don Philippe) នៃប្រទេសអេស្ប៉ាញក្រោមចំណងជើងថា ព្រឹត្តិការណ៍ជាក់ស្ដែងសង្ខេប នៃប្រទេសកម្ពុជា នៅសតវត្សទី ១៦ (Relation brère et véridipue des évènements du Royaume du Cambodge, traduite de l'Espangnol en français par A. Cabaton), ប្រែពីភាសាអេស្ប៉ាញ៉ុល មកជាភាសាបារាំង ដោយលោក កាបាតុង, បោះពុម្ពផ្សាយនៅរាជធានីម៉ាឌ្រីដ (Madrid) ក្នុងឆ្នាំ ១៦០៤ បានអធិប្បាយថា ÷

ក. នៅសម័យនោះ មន្ត្រីធំៗខ្មែរ នឹងចេញដំណើរទៅណាមកណា រមែងមានក្បួនហែហាមមុខក្រោយ មានពលសេហ៍ សេនា បាវ-ព្រាវ មនុស្សម្នា ប្រកបដោយអាវុធគ្រប់ដៃ និងគ្រឿងប្រដាប់ផ្សេង ៗ តាមលំដាប់ស័ក្តិធំតូចដូចជា:

មន្ត្រីសក្តិ ១០ ហូពាន់ ដែលក្លាយមកពីពាក្យសៀម "ហ៊ូផាន់ (ក្បាលពាន់)" គ្រឿងហែក្បួន ត្រូវមានត្រែស្នែង, ពាក្យរាជស័ព្ទ ហៅថា ព្រះសល្បេង មានកួស់ ៥ ប្រកបទៅដោយពណ៌ក្រហម ឬបៃតងខៀវ ស្របតាមឋានៈមន្ត្រីឆ្វេងស្ដាំ ។ល។ ចំពោះមន្ត្រីមានឋានន្តរសក្តិ

ពី ១០ ពាន់ចុះមក ក្បួនហែហមជាកិត្តិយសមន្ត្រីទាំងនោះ មានចំនួនចុះថយជាលំដាប់ មានក្លស់បាំងពី ៤ ចុះមកមួយ ។ល ។

ខ- ចំពោះព្រះមហាក្សត្រវិញ ក្បួនហែហមធំជាងមន្ត្រី ក្លស់សម្រាប់បាំងជុំវិញ សុទ្ធតែពណ៌ស ឬ លឿង តាមថ្ងៃធំ ឬ តូច ដោយពុំមានកម្រិតចំនួន ព្រមទាំងគ្រឿងប្រដាប់សម្រាប់បាំងពន្លឺព្រះអាទិត្យ និងបក់កម្តៅ ដូចជា បាំងសែន ដែលសៀមហៅថា ប័ងសួន (ប័ងស៊ុរ៍យ), មយូរាឆ័ត្រ, ចាមរ ឬ បៃមន់ ។ល ។ ពាក្យទាំងនេះ សូមមើលវចនានុក្រមខ្មែរ ។

## សំលៀកបំពាក់

សំលៀកបំពាក់មន្ត្រីខ្មែរយើង តែងមានតាមលំដាប់សក្តិជាមន្ត្រីឆ្វេងស្តាំ ដែលប្រកបទៅដោយពណ៌ក្រហម ឬ បៃតង ត្រូវមានមួក មានកំពូលយ៉តមាសដាំពេជ្រ មានសំពត់អាវចរបាប់ទាំងអស់ ព្រមទាំងស្បែកជើង ស្រោមជើង ។

## អក្សរខ្មែរ

អក្សរខ្មែរយើងនោះទៀត ត្រូវមានសភាពជាអក្សរ អ្នកអរិយ-

ប្រទេសមួយ គឺមានសភាពដូចជាសំលៀកបំពាក់ដែរៈ មានសក់ ហាក់ដូចជាមួក, មានតួអក្សរនិងមានជើងអក្សរ ហាក់ដូចជាស្បែកជើង ។

## សម្តីនិយាយ

សម្តីនិយាយនោះសោត ក៏ត្រូវមានបរិវារស័ព្ទហែហមជាលំដាប់ដែរ ។ ម្យ៉ាងវិញទៀត ខ្មែរយើងច្រើនប្រឌិតពាក្យពេចន៍ ដោយពុំមានឫសគល់ ពីបាលី ឬ សំស្ក្រឹត ដើម្បីយកមកប្រើតាមសេចក្តីត្រូវការនៃអ្នកស្រុក ដូចជាអាទិ ពាក្យ "កណ្តុំឆែប . . . ឆា" ដែលអ្នកខ្លះច្រើនភ្លាត់មាត់ នៅវេលាចាក់ក្រឡេកប្រលែងគ្នាលេង ។ បើពុំបានជាគិតយើងស្មានថាជាពាក្យអនុករណៈ ឬ ឧទានស័ព្ទ (Onomatopée) ។ ផ្ទុយទៅវិញ គឺជាពាក្យចំអាស់ មួយបែប, គួរឱ្យកោតសរសើរថ្វីដៃអ្នកប្រាជ្ញបុរាណ ដែលចេះយកពាក្យ "ឆា" មួយម៉ាត់មកដាក់បញ្ឆោត ភ្ជាប់ពីខាងក្រោយបង្អស់ ដើម្បីបង្វែងដានអ្នកផងកុំឱ្យនឹកសង្ស័យរកអត្ថន័យប្រាកដឃើញ ។

ពាក្យនេះ យើងព្យាយាមរើកញែករកហេតុផលទៅ យើងអាចរកឃើញច្បាស់ថា ជាពាក្យគន្លាស់កាត់ មានសេចក្តីថា " កណ្តុំឆែបមួយជួយ" ។ ពាក្យនេះ ខ្ញុំសូមជូនអស់លោកអ្នកអានគន្លាស់ត្រឡប់ទៅវិញខ្លួនឯងទៅចុះ ។

ពាក្យ ''ផ្ទើ'' វិញ ក៏មានលំនាំរបៀបគ្នាដែរ ពោលគឺ ពាក្យ ''ផ្ទើ ផ្ទាក់លើ ។ រីឯពាក្យ ''ក្បាក់'' ដែលជាឈ្មោះកូនជើងពានទំនាប់ ច្រើន ធ្វើអំពីប្រាក់វិញ គឺជាពាក្យ ''ក្បាក់ប្រាន'' បានសេចក្តីថា ''ក្បានប្រាក់'' ។ សូមមើលពាក្យ ចានក្បាន ។

## របៀបដាក់ឈ្មោះឱ្យកូនចៅ

តាមប្រពៃណីខ្មែរយើង នៅសម័យបុរាណ ការដាក់ឈ្មោះឱ្យកូនចៅនិមួយ ៗ គេច្រើនប្រកាន់ណាស់ ។ គេពុំមែនចេះតែដាក់ឈ្មោះឱ្យ ដោយពុំបានរកគ្រូអាចារ្យ ដើម្បីគន់គូរទស្សទាយដោយក្បួនវេទជាមុនឡើយ ។ ផ្ទុយទៅវិញ ការដាក់ឈ្មោះនេះ គេច្រើនតម្រូវ ទៅតាមឫក្សពារ តាមពេលាល្អ ឡើងស័ក ឡើងរាសី សមតាមលំដាប់ ថ្ងៃ ខែ នៃកំណើតទារក ដែលមានអត្ថន័យសំខាន់ស្របតាមគម្ពីបាលី និងស្របតាមសេចក្តីប្រាថ្នានៃមាតាបិតា ចំពោះអនាគតនៃទារកទាំងនោះ ។

នឹងឱ្យឈ្មោះនោះទៀត គេត្រូវកម្រិតចំនួន ព្យាង្គ គឺចំនួនពាក្យ (syllabe) ក្នុងឈ្មោះនិមួយៗ ស្របតាមវណ្ណៈគ្រួសារ ដើម្បីជាវិន័យមួយសម្រាប់សម្គាល់ដោយប្រាកដ នូវអម្បូរ ពូជ ពង្ស នៃគ្រួសារ ដូចតទៅ

ក- ចំពោះព្រះរាជបុត្រព្រះមហាក្សត្រ

ព្រះនាមនិមួយៗ ត្រូវមានពាក្យពី បួនព្យាង្គ ឡើងទៅ ដូចជា ព្រះរាជបុត្រព្រះបាទជ័យវរ្ម័នទី៧ : វិរកុមារ, សុរិយកុមារ ។ ព្រះបរមនាម ព្រះបាទនរោត្តម គឺ រាជាវត្តី, ព្រះបាទ ស៊ីសុវត្ថិ គឺ សេរីសុវត្ថិ ។

ខ- ចំពោះព្រះរាជវង្សានុវង្ស និង មន្ត្រី

ដែលព្រះរាជាតាំងជាក្សត្រពេញអង្គ

ព្រះនាម ត្រូវមានយ៉ាងច្រើនត្រឹមតែបីព្យាង្គ ដូចជា វិរិយៈ, ប៉ូរក្ខស៊ី, ឥន្ទ្រាវង្ស( ក្រុមក្សត្រ); បលិរីណ្ណ, ទេពអរជូន, ពិស្ណុលោក( មន្ត្រីរាជវង្ស) ។

គ- ចំពោះបុត្រមន្ត្រី គហបតី និងមន្ត្រីកិត្តិយស

នាមបុត្រត្រូវមានយ៉ាងច្រើនត្រឹមតែពីរព្យាង្គ ដូចជា សម្បត្តិ, ចំរើន, សុខា, សម្បូរណ៍ ។ល ។

ឃ- ចំពោះបុត្រប្រជារាស្ត្រសាមញ្ញទូទៅ

នាមបុត្រ មានតែមួយព្យាង្គ ឬ មួយម៉ាត់ទេ ពោលគឺ ឈ្មោះ សុខ, សៅ, ម៉ែន, ម៉ុក, ជា, គង់ ។ល ។

បើប្រជារាស្ត្រទាំងនេះ បានឡើងបុណ្យស័ក្តិធ្វើជាមន្ត្រី កាលណា គេគ្រាន់តែបន្ថែមទៅលើឈ្មោះទាំងនោះ នូវគោរមងារ ដូចជាៈ ហ្លួង, ពញា, ឧកញ៉ា ។ល ។

អាស្រ័យ ដូចបានអធិប្បាយខាងលើនេះ សឱ្យឃើញថាៈ ចាប់តាំងពីកិច្ចចេញដំណើរ រហូតដល់សម្តីនិយាយ ព្រមទាំងរបៀបដាក់ឈ្មោះឱ្យកូនចៅទៀត ឃើញថា សុទ្ធតែមានរបៀបជាលំដាប់ថ្នាក់ខ្ពស់ទាប មានបរិវារហែហម ជាកិត្តិយសជាដរាប ។

នៅទីអវសាន ខ្ញុំជឿជាក់ថា សេចក្តីអធិប្បាយទាំងប៉ុន្មានក្នុងសៀវភៅនេះ រមែងមានការឆ្គាំឆ្គងនិងការខ្វះខាត ជាលំដាប់ ។ ដូច្នេះ ខ្ញុំសូមអ្នកអានមេត្តាអភ័យទោស ចំពោះកំហុសដោយអចេតនា សូមជួយរិះគន់និងទូន្មានដោយអនុគ្រោះ ព្រោះខ្ញុំចាប់ផ្តើមសរសេរកូនសៀវភៅតូចនេះ ពុំមែនមានគោលបំណងចាត់ទុកថាជាសៀវភៅវេយ្យាករណ៍ ឬ ក្បួនតម្រាសម្រាប់រៀនក្នុងសាលា ឬ សម្រាប់និស្សិតទូទៅ យកជាលំនាំក្នុងការរៀនសូត្យភាសាសាស្ត្រខ្មែរយើងនោះឡើយ ។

គឺជាសៀវភៅសម្រាប់ស្នើយោបល់ដោយកំសាន្ត កំដរបរិយាកាសជូនលោកអ្នកប្រាជ្ញខាងអក្សរសាស្ត្រខ្មែរ តែប៉ុណ្ណោះ ។

ខ្ញុំសូមបញ្ជាក់ទៀតថា "អារម្ភកថាក្តី, ពាក្យលំនាំក្តី, និងសេចក្តីវែកញែកក្តី" រកហេតុផលឱ្យឃើញចំនុចគោលដៅ បរិវារស័ព្ទខ្មែរយើង

ទាំងប៉ុន្មានទៅក្នុងសៀវភៅនេះ មានទាក់ទងដោយពាក្យសាសនស័ព្ទ, បុរាណស័ព្ទ រាជស័ព្ទ, រាស្ត្រស័ព្ទ ។ ល ។ គ្រាន់តែជាការស្រាវជ្រាវឱ្យឃើញហេតុដើមពីអតីតកាល (le passé) ជាហូរហែមកដល់បច្ចុប្បន្នកាល គឺដៅទៅលើគោល «អក្សរសាស្ត្រ » តែមួយមុខ ពុំមានគំនិតផ្អែកទៅលើទស្សនៈដទៃ លាយឡំដោយនយោបាយជាដើម ដែលឃ្លាតឆ្ងាយពីអក្សរសាស្ត្រនោះសោះឡើយ ។

ស៊ីសុវត្ថិ-ប៉ូរត្នស៊ី

ព. ស. ២៥១៦

គ. ស. ១៩៧២

## ពាក្យលំនាំ

បរិវារស័ព្ទដែលខ្ញុំលើកមកយកវែកញែកជូនខាងក្រោមនេះ បើតាមការសង្កេត ឃើញថា សុទ្ធសឹងជាពាក្យគន្លាស់ចេញជាលំដាប់ គ្រប់មួយវគ្គខ្លីៗ ពីលំនាំពាក្យដើមទាំងអស់ ។

ពាក្យគន្លាស់ទាំងនោះសោត ដូចលោក **អៀវ-កើស** បានអធិប្បាយពន្យល់យ៉ាងក្បោះក្បាយ ក្នុងសៀវភៅ "ភាសាខ្មែរភាគ ២" បោះពុម្ពផ្សាយដោយបណ្ណាគារ មិត្តសេរី ក្នុងឆ្នាំ ១៩៦៧, ពុំមែនចេះតែគន្លាស់ជាឱ្យរាល់ទូទៅ ធ្វើឱ្យមានន័យចាកឆ្ងាយ ពីចំណុចគោលដៅដើមស័ព្ទនៃពាក្យដើមនោះឡើយ គឺគ្រាន់តែគន្លាស់បង្អិលបរិវារស័ព្ទ ឱ្យត្រូវតាមសំឡេងពាក្យដើមវិញ តែប៉ុណ្ណោះ ។

អាស្រ័យហេតុនេះ ខ្ញុំសូមអញ្ជើញអស់លោកអ្នកអាន ចូលរួមវែកញែករកហេតុផល ជាមួយនឹងខ្ញុំ ដូចតទៅនេះ:

**ឧទាហរណ៍ :**

| | | |
|---|---|---|
| សម្ល-សម្លុក | = | សម្លុកបង់ប្រហ គឺសម្លបង់ប្រហុក, |
| បី-បាច់ | = | បាច់លាងអី គឺបីលាងអាចម៍, |
| ថ្នាក់-ថ្នម | = | ថ្នាក់មិនឱ្យអម គឺថ្នមមិនឱ្យអាក់, |
| ទូលំ-ទូលាយ | = | ទូលំធាយ គឺទូលាយធំ, |
| អាចារ្យ-អាចុំ | = | អាចុំគ្រូខា គឺអាចារ្យគ្រូខ្ញុំ ។ល។ |

# ក

**កកិច_កកុច**.- ពាក្យនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា នឹងពាក្យកិច កុកដែរ គឺ បង្ករឿងហេតុដោយមានគំនិតក្រឡេចក្រឡុច ។ អាស្រ័យហេតុនេះ បរិវារស័ព្ទ កកុច អាចគន្លាស់ បានជា ពាក្យ កកុចដោយមានគំនិតក្រឡុចក្រឡេច ពោលគឺ កកិច ដោយមានគំនិតក្រឡេចក្រឡុច ។ អ្នកខ្លះ ប្រើពាក្យនេះថា កកិចកកុក ។

**កកែង_កកោង**.- តាមវចនានុក្រម បានសេចក្តីថា ÷ កិរិយាពុំគាប់បី, កោង, ព្រហើន, ឥតមានលំអុតលំឱន ។ បរិវារស័ព្ទ កកែង អាចគន្លាស់បានជាពាក្យ កកែងធ្វើឫកដូចព្រះស្តោង គឺ កកោង ធ្វើឫកដូចព្រះស្តែង ពោលគឺ សម្តែងឫកដូចអ្នកធំសម្បើម ។

**កក្អាក_កក្អាយ.-** ដែលឮសូរសើចសប្បាយ ។ សើចកក្អាកកក្អាយ ។ល។ បរិវារស័ព្ទ កក្អាយ អាចគន្លាស់បានជាពាក្យ កក្អាយ ដោយសើចសាបាក គឺ កក្អាកដោយសើចសប្បាយ ។

**កក្អិច_កក្អៀក.-** តាមវចនានុក្រម បានសេចក្ដីថា ឮសូរមាត់សើច ច្រើនពុំដាច់ស្នូរ ។ សើចលេងកក្អិចកក្អៀក ។ បរិវារស័ព្ទ កក្អិច អាចគន្លាស់បានជាពាក្យ កក្អិចមិនចេះទៀក គឺ កក្អៀក មិនចេះតិច ពោលគឺ សើចកខិចលេងពុំចេះដាច់ស្នូរ ។

**កខិក_កខក់.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ឈ្លក់ ឬ រង្គោះ ។ សូរឮដោយឈ្លក់ទឹក, ដោយរង្គោះ ។ បរិវារស័ព្ទ ខិក អាចគន្លាស់បានជាពាក្យ កខិកដូចឈ្លក់តក់ គឺ កខក់ដូចឈ្លក់ទឹក ។ អ្នកខ្លះនិយាយជាពាក្យ កខិកកខុប ។

**កខែក_កខោក.-** តាមវចនានុក្រម បានសេចក្ដីថា ÷ សូរឮដោយរបស់ដែលចាស់ចង់បែក មិនជិតស្និទ្ធ ។ បរិវារស័ព្ទ កខែក អាចគន្លាស់បានជាពាក្យ កខែក ឮសូរដូចជាចង់បោក ពោលគឺ កខោក ឮសូរដូចជាចង់បែក ។

កខ្ចិច_កខ្ចក់.- ពាក្យនេះ អ្នកខ្លះនិយាយថា កខ្ចីក កខ្ចក់ ។ ពាក្យទាំងពីរបែបនេះ បានសេចក្ដីដូចគ្នា គឺ កក្រិចមិនស្អាតស្អោកគ្រោក ។ល។ បរិវារស័ព្ទ កខ្ចិក អាចគន្លាស់បានជាពាក្យ កខ្ចិកមិនស្អាតកគ្រក់ ពោលគឺ កខ្ចក់មិនស្អាតកក្រិច ឬ កខ្ចីកដោយប្រឡាក់តក់ គឺ កខ្វក់ដោយប្រឡាក់ទឹក ។

កញ្ជក់_កញ្ជែង.- ចាប់ទាញកន្ត្រាក់ដោយឥតគួរឥតប្រណី ។ បរិវារស័ព្ទ កញ្ជែង អាចគន្លាស់បានជាពាក្យ កញ្ជែងដោយឥតកោតក្រក់ ពោលគឺ កញ្ជក់ដោយឥតកោតក្រែង ។

កណ្ដែង_កណ្ដោច.- តាមវចនានុក្រម បានសេចក្ដីថា ÷ ត្រមោចឯកឯងនៅក្នុងទីស្ងាត់ ឥតមានសូរស័ព្ទអ្វីទៅបណ្ដាលឱ្យភ្ញាក់ផ្អើល ហើយមានតែនាំឱ្យមានសេចក្ដីសង្វេគក្នុងចិត្ត ។ បរិវារស័ព្ទ កណ្ដែង អាចគន្លាស់បានជាពាក្យ កណ្ដែងតែម្នាក់អោច ពោលគឺ កណ្ដោចតែម្នាក់ឯង ។

កន្ដិញ_កន្ដុញ.- បរិវារស័ព្ទ កន្ដិញ អាចគន្លាស់បានជាពាក្យ កន្ដិញរុញ គឺកន្ដុញរិញ ពោលគឺ មនុស្សកន្ដុញរិញ ១ តូចទាប ។ល។

កន្ត្រុក_កន្ត្រាក.- ជនកន្ត្រុកកន្ត្រាក គឺជន កន្ត្រាកពេក, រយីក រយាក, កន្ត្រាកខ្លាំង ។ បរិវារស័ព្ទ កន្ត្រុក អាចគន្លាស់បានជាពាក្យកន្ត្រុកប៉ាក គឺកន្ត្រាកពេក ។

កន្ទឹង_កន្ទាំង.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលមានលំនាំដំណើរកន្ទាំងជើងបន្តិច ។ ដំណើរកន្ទឹងកន្ទាំង ។ ដើរកន្ទឹងកន្ទាំង គឺ ដើរកន្ទេកជើង យោលត្រគាកអឹកអ៊ាកចេញក្បាលពោះធំត្រពឹងពឹង ។ បរិវារស័ព្ទ កន្ទឹង អាចគន្លាស់បានជាពាក្យកន្ទឹងត្រគាកអឹកអ៊ាក ចេញក្បាលពោះត្រពាំង គឺ កន្ទាំងត្រគាកអឹក អ៊ាក ចេញក្បាលពោះត្រពឹង ។

កម្ពី_កម្ពិល.- ពាក្យនេះ ប្រហែលជាក្លាយមកពីពាក្យ កម្ជេញ-កម្ជិល (ខ្ជេញ-ខ្ជិល) ដែលមានន័យប្រហាក់ប្រហែលគ្នា ។ ក្មេងកម្ពីកម្ពិល ។ បរិវារស័ព្ទ កម្ពី អាចគន្លាស់បានជាពាក្យ កម្ពីពុំមានការសម្ពីល គឺ កម្ពិលពុំមានការសម្ពី ពោលគឺ ក្មេងនេះ ខ្ជិល ពុំមានសេចក្តីកោតញញើតខ្លាចក្រែងដល់មាតាបិតា ឬ ចៅហ្វាយនាយឡើយ ចំពោះការរៀនសូត្រ ឬ ចំពោះកិច្ចប្រកបមុខរបរ ។ សូមមើលពាក្យ ខ្ជេញ-ខ្ជិល ។

កម្ទេច_កម្ទី.- តាមវចនានុក្រម បានសេចក្ដីថា ÷ ធ្វើឱ្យខ្ទេច គឺ កម្ទេច ជាធូលី ឬ ជាផេះ ។ល។ បរិវារស័ព្ទ កម្ទី អាចគន្លាស់បាន ជាពាក្យ កម្ទីជាធូលិច គឺ កម្ទេចជាធូលី ។

កន្ទុក_កន្ទៀត.- តាមវចនានុក្រម ពាក្យនេះមានន័យថា÷ កៀនកំបាំង, ទីចង្អៀតកៀនកោះ ។ បរិវារស័ព្ទ កន្ទុក អាចគន្លាស់បានជា ពាក្យ កន្ទុកកៀនសុកមម្រៀត គឺ កន្ទៀតកៀនសុកមម៉ុកពោល គឺ កន្លែងកៀនកោះកខ្វក់មានពីងពាងព័ទ្ធ ។

កាក់_កប.- រកស៊ីកាក់កប គឺ រកស៊ីមិនដែលមានបង់ខាត ។ បរិវារស័ព្ទ កាក់ អាចគន្លាស់បានជាពាក្យ កាក់គ្រប់ដំណប គឺ កបគ្រប់ ដំណាក់ ពោលគឺ ការរកស៊ីនោះបានប្រកបគ្រប់ពេលវេលា គ្រប់ដម្កាក់ ។

កិច្ច_កុក.- បង្ករឿងហេតុដោយរបេញរបុញ ពុតត្បុត ។ ក្មេង កិច្ចកុក គឺ ក្មេងទូរទុក្ខ ។ បរិវារស័ព្ទ កុក អាចគន្លាស់បានជា ពាក្យ កុកដោយទូរទិច្ច គឺ កិច្ចដោយទូរទុក្ខ ពោលគឺ បង្ករឿង ហេតុដោយទូរទុក្ខ ដោយពុតត្បុត ។ អ្នកខ្លះនិយាយជាពាក្យ កិក-កុប; កកិប-កកុប ។

កៀន_កោះ.- កៀន-កោះ គឺ កៀន កន្លៀត, ចន្លោះតូច ។ បរិវារស័ព្ទ កោះ អាចគន្លាស់បានជាពាក្យ កោះចន្លៀន គឺ កៀន ចន្លោះ ។ ពាក្យនេះ បើយើងសរសេរ កៀន-កោស វិញ ទើបសមរម្យជាង ។

កែង_កោង.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមានអាការព្រហើន, ក្រអើតក្រអោង ។ បរិវារស័ព្ទ កោង អាចគន្លាស់បានជាពាក្យ កែងដោយវាយបូកចំខោង គឺ កោងដោយវាយបូកចំខែង ។

កោក_កាក.- សូរព្ទដោយនិយាយ, ដោយជជែកខ្លាំង ឱ្យក្បោះក្បាយច្បាស់លាស់ ។ បរិវារស័ព្ទ កាក អាចគន្លាស់បានជាពាក្យ កាកសូរខ្លាំងដោយវាកវោក គឺ កោកសូរខ្លាំងដោយវូកវាក ។

កោង_កាង.- មនុស្សកោងកាង គឺ មនុស្ស កោងកាច ព្រហើន ។ បរិវារស័ព្ទ កាង អាចគន្លាស់បានជាពាក្យ កាងច្រងេងច្រងោង ពោលគឺ កោងច្រងេង ច្រងាង ។

កំប៉េត_កំប៉ូត.- ព្រៃកំប៉េត កំប៉ូត ។ កំប៉េត ជាបរិវារស័ព្ទ ប្រើជាគុណស័ព្ទ ចង្អុលបង្ហាញថា ព្រៃកំប៉ូតនោះ មានសភាពរកេត

រកួត ពោលគឺ កំប៉េតរកេតរកួត គឺ កំប៉ូតរកូតរកេត ។

**កំប៉ិក_កំប៉ុ.**- ខ្មែរយើងច្រើននិយាយថា ជនកំប៉ិក-កំប៉ុ ។ ពាក្យនេះមានសេចក្ដីថា : ជនតូចតាច ឬ ជនគ្មានបណ្ដាស័ក្ដិអ្វីជាធំដុំនឹងគេ ។ ដូច្នេះ បរិវារស័ព្ទ កំប៉ុ អាចគន្លាស់បានជាពាក្យ កំ-ប៉ុបានសំដិច គឺ កំប៉ិកបានសំដី ពោលគឺ មនុស្សណា មានមាឌល្អិតក្ដី ឬ បុណ្យស័ក្ដិតូចក្ដី ច្រើនបានវោហារណាស់ ដូចអ្នកផងតែងពោលថា : តូចមែនពិតតែបានសំដី ។

**កំប្ញុក_កំប្លែង.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ លេងដោយបទបែបផ្សេង ៗ ដើម្បីអ្នកឯទៀតរោះរាយសប្បាយសើច ។ បរិវារស័ព្ទ កំប្លុក អាចគន្លាស់បានជាពាក្យ កំប្លុកថ្លែង គឺកំប្លែងថ្លុក ។

**កំពឹក_កំពក.**- ដែលមានពក រងិប រដុប ។ បរិវារស័ព្ទ កំពឹក អាចគន្លាស់បានជាពាក្យ កំពឹកស្ពុក គឺ កំពកស្ពឹក ពោលគឺពុំមែនកំពកមានចុងស្រួចឡើយ ។

**កំព្រី_កំព្រា.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ មនុស្សសត្វដែលឥតម្ដាយ ឥតឪពុក ឬ មេបា ។ ជនកំព្រី-កំព្រា ។ល ។

បរិវារស័ព្ទ កំព្រី អាចគន្លាស់បានជាពាក្យ កំព្រីដោយឥតមេជា គឺ កំព្រាដោយឥតមេជី ។

ក្ងិង_ក្ងង់.- តាមវចនានុក្រម បានសេចក្ដីថា ÷ វៀច កោង ក្រវិកក្រវក់ មិនរៀបរយ មិនត្រង់ភ្លឹង ។ បរិវារស័ព្ទ ក្ងិង អាចគន្លាស់បានជាពាក្យ ក្រវិកក្រវក់មិនត្រង់ផ្លង់ ពោលគឺ ក្ងង់ក្រវិក-ក្រវក់ មិនត្រង់ភ្លឹង ។

ក្ងិច_ក្ងក់.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលវៀចកុងចុះ កុងឡើង ។ បរិវារស័ព្ទ ក្ងិច អាចគន្លាស់បានជាពាក្យ ក្ងិចបន្តក់ គឺ ក្ងក់បន្តិច (ចំពោះឈើវៀចក្ងិចក្ងក់) ។ ក្ងិចដោយកលកក់ គឺ ក្ងក់ដោយកលកិច្ច (ចំពោះចិត្តក្ងិចក្ងក់) ។

ក្តារ_ក្តាំង.- ក្តាំង ជាបរិវារស័ព្ទ នៃពាក្យក្តារ ។ ពាក្យក្តាំងនេះ បើយើងប្រើដាច់ដោយឡែកតែឯង អ្នកផងអាចស្ដាប់ពុំបាន តែបើយើងយកពាក្យក្តាំងនេះ មកគន្លាស់ផ្សំជាវគ្គមួយខ្លីដូចជា ក្តាំងក្រាលបិទបារ យើងបានសេចក្ដីថា ក្តារក្រាលបិទបាំង ។

ក្តិព_ក្តាំង.- គេច្រើនពោលពាក្យពុំសមរម្យនេះថា : «អង្គុយ ដួល ឬ ដេក» លេច (ក - ក្តាំង) ។ ក្រៅអំពីសំដីប្រភេទនេះ គេពុំ

ឃើញមានប្រើឡើយ ។ ដូច្នេះ បរិវារស័ព្ទក្តាំង អាចគន្លាស់ បានជាពាក្យ ក្តាំងដូចជាគ្មានអ្វីបាំងបិទ ពោលគឺ (ក.) ដូចជា គ្មានអ្វីបិទបាំង ។

**ក្តិប_ក្តៀប.-** តាមវចនានុក្រម បានសេចក្តីថា ÷ ផ្លែឈើ តូចខ្ចី ឬ តូច ស្តៀត គឺ ធំមិនដល់កំណត់ ។ បរិវារស័ព្ទ ក្តៀប អាចគន្លាស់ បានជាពាក្យ ក្តៀបខ្ចីតូច ដូចជាប់ក្នុងដង្កិប ពោលគឺ ក្តិបខ្ចីតូច ដូចជាប់ក្នុងដង្កៀប ។

**ក្តី_ក្តាំ.-** តាមវចនានុក្រម បានសេចក្តីថា ÷ អធិករណ៍ទូទៅ វិវាទ ធម្មតា ។ល។ កើតក្តីក្តាំនឹងគ្នា ។ បរិវារស័ព្ទ ក្តាំ អាចគន្លាស់ បានជាពាក្យ ក្តាំព្រោះប្រកាន់រៀងខ្លួនតាមចំណើ ពោលគឺ ក្តី ព្រោះប្រកាន់រៀងខ្លួនតាមចំណាំ ។

**ក្តួល_ក្តៅ.-** តាមវចនានុក្រម បានសេចក្តីថា ÷ អួលខ្យល់ ដោយ ទោមនស្សចិត្ត ក្តួលក្តៅក្នុងចិត្ត ។ បរិវារស័ព្ទ ក្តៅ អាចគន្លាស់ បានជាពាក្យ ក្តៅដោយចិត្តហ្មងសួល គឺ ក្តួលដោយចិត្តហ្មង សៅ ឬក្តួលដោយចិត្តម៉ូម៉ៅ ឬក្តួលឆៅ = ក្តៅឆួល ។

ក្តិច_ក្តក់.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលមានមាយាថ្មិកង៉ក់ ដោយក្តក់ចិត្ត ។ មនុស្សក្តិចក្តក់, ឬកក្តិកក្តក់ ។ បរិវារស័ព្ទ ក្តិច អាចគន្លាស់បានជាពាក្យ ក្តិចមាយាដោយកល់កក់ គឺ ក្តក់មាយាដោយកល់កិច្ច ពោលគឺ ក្តិចក្តក់ មាយាដោយកិច្ចកលឧបាយ ។ អ្នកខ្លះនិយាយពាក្យនេះថា: ក្តិកក្តក់ទៅវិញ ។

ក្បាច់_ក្បូរ.- គេច្រើនប្រើពាក្យនេះក្នុងវគ្គ ''មិនដឹងជាក្បាច់ក្បូរអ្វីទេ ! ឬចេះតែក្បាច់ក្បូរណាស់'' ដែលយើងអាចបកស្រាយថា : ពុំមានការចាំបាច់អ្វីឡើយ ! ឬពុំចាំបាច់ទេ !, ដូច្នេះ បរិវារស័ព្ទ ក្បូរ អាចគន្លាស់បានជាពាក្យ ក្បូរចាំដាច់ គឺ ក្បាច់ចាំដូរ ។ ក្នុងចំណុចនេះ សឱ្យឃើញថា : បើមានទម្លាប់ប្រព្រឹត្តការអ្វីមានលំនាំស្រួលធម្មតាហើយ ពុំចាំបាច់ទៅរចនាប្តូរផ្លាសវិធីនោះថែម ឱ្យមានការពិបាកមួយថ្មីទៀតទេ ។

ក្បាល_ក្បូង.- ពាក្យនេះ ខ្មែរយើងច្រើនពោល ដើម្បីចង់និយាយថា: ក្បាលជាឪរាល់ ឬ ក្បាលរយពាន់ ដូចជា ពាក្យចាស់ទុំ បានពោលថា: ក្មេងៗអស់នេះ មកលេងប៉ះក្បាលក្បូងអញ ។ល ។

ក្នុងចំណុចនេះ ខ្មែរយើងចង់និយាយបង្ហាញដោយចិត្តខឹងបន្តិច ព្រោះ: ពាក្យ ក្បូង ដែលប្រើជាបរិវារស័ព្ទនេះ គឺ ក្បូងដូចលលាដ៏ដាល = ក្បាលដូចលលាដ៏ដូង ។ នេះសឱ្យឃើញថា: ក្មេងដែលមកប្រឡែងគ្នាលេងឱ្យប៉ះក្បាលនោះ ហាក់ដូចជាពុំមានសេចក្តីគោរព, ញញើត, កោតខ្លាច ។ម្យ៉ាងវិញទៀត ខ្មែរយើង តាមប្រពៃណីមានសេចក្តីប្រកាន់ណាស់ ចំពោះក្បាលនោះ ។

ក្បិត-ក្បៀប.- តាមវចនានុក្រម គឺ ÷ ប្រិតប្រៀបឱ្យមានរបៀបរៀបរយយ៉ាងហ្មត់ចត់ ។ បរិវារស័ព្ទ ក្បៀប អាចគន្លាស់បានជាពាក្យ ក្បៀបឱ្យមានរបិត គឺ ក្បិតឱ្យមានរបៀប ។

ក្បិត-ក្បៀត.- តាមវចនានុក្រម បានសេចក្តីថា ÷ សំចៃ សំច័យ មិនកញ្ចះកញ្ចាយ ។ ត្រូវខំក្បិតក្បៀតប្រាក់កាស កុំចាយវាយកញ្ចះកញ្ចាយពេក ។ល។ បរិវារស័ព្ទ ក្បិត អាចគន្លាស់បានជាពាក្យ ក្បិតដោយខំបៀត ពោលគឺ ក្បៀតដោយខំបិទ ។

ក្បោះ-ក្បាយ.- ពាក្យនេះ មានអត្ថន័យថា ÷ ច្បាស់លាស់, សំដីក្បោះក្បាយ, វោហារក្បោះក្បាយ, សេចក្តីក្បោះក្បាយ ។ល។

បរិវារស័ព្ទ ក្បាយ អាចគន្លាស់បានជាពាក្យ ក្បាយដោយគ្មានថែមអធិប្បោះ គឺ ក្បោះដោយគ្មានថែមអធិប្បាយ ពោលគឺច្បាស់មែនទែន ដោយគ្មានអ្វីនៅសល់សម្រាប់គ្រូស្នាញអាចអត្ថាធិប្បាយបន្ថែមទៀតឡើយ ។

ក្អេង_ក្អាង.- ក្អាង ជាពាក្យខ្មែរមន បានសេចក្ដីថា ÷ ក្មេង ។ ដោយខ្មែរយើងតាំងពីបុរាណកាលមក មានជាប់ពូជពង្ស លាយគ្នាជាមួយសាសន៍មន បានជាយើងមានទម្លាប់ប្រើពាក្យ ក្អេង និងក្អាង ភ្ជាប់ជាមួយគូ ដើម្បីថា : ក្មេង-ក្មេង ។ បើយើងធ្វើអត្ថាធិប្បាយឱ្យវែងជាងនេះបន្តិចទៅទៀត យើងឃើញថាពាក្យក្អាង នេះ យើងយកមកប្រើជាបរិវារស័ព្ទ នៃពាក្យក្អេង ដើម្បីបង្ហាញថា "ក្អាងអ្នកជិតខេង" ប្រែមកថា "ក្មេងអ្នកជិតខាង" ព្រោះខ្មែរយើងច្រើននិយាយថា : ក្អេងក្អាង មកពីណា មកលេងទីនេះ កំច្រើនម្ល៉េះ ? រឿងនេះ ក្មេងកូនចៅយើងក្ដី ក្មេងកូនចៅអ្នកស្រុកជិតខាងក្ដី ដែលមករត់លេងជាមួយគ្នានោះ ទាល់តែក្មេងទាំងនោះចេះស្គាល់គ្នាជាមិត្តភ័ក្តិជាអាទិ នៅជិតខាងគ្នា ទើបរួមលេងជាមួយគ្នាបាន ។ ដូច្នេះ

ហើយ បានជាយើងយកពាក្យ ក្អេងក្អាង មកជំនួស ក្អេងៗ ទៅវិញ (សូមអានអារ្យធម៌ខ្មែរមន និពន្ធដោយលោក កែប-ប៉ានឌី ទំព័រ ១០៨) ។

ក្រញើ-ក្រញូក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ញីញូក់ ដោយកំហឹង ។ បរិវារស័ព្ទ ក្រញូក អាចគន្លាស់បានជាពាក្យ ក្រញូក ដោយកំហឹងញូក់ញី គឺ ក្រញីដោយកំហឹងញីញូក់ ។

ក្រញើក-ក្រញូក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខ្វី-ខ្វុក ដោយ ឈ្លី-ឈ្លក់ ។ បរិវារស័ព្ទ ក្រញុក អាចគន្លាស់បានជា ពាក្យ ក្រញុកដោយឈ្លី-ឈ្លីក គឺ ក្រញីកដោយឈ្លក់-ឈ្លី ។

ក្រញុក-ក្រញូវ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល មិនរីករាយ, មិនស្លូតបូត ។ មុខ ក្រញុក-ក្រញូវ ។ ល ។ បរិវារស័ព្ទ ក្រញុក អាចគន្លាស់បានជាពាក្យ ក្រញុកដោយទឹក មុខខ្វុកខ្វូវ គឺក្រញូវដោយទឹកមុខខ្វូវ-ខ្វុក ពោល គឺមុខខឹង ចងចិញ្ចើម ។

ក្រញែ-ក្រញូវ.- ដែលមិនរីករាយ, មិនស្លូតបូត ។ ទឹកមុខក្រញែ-ក្រញូវ ។ ល ។ បរិវារស័ព្ទ ក្រញែ អាចគន្លាស់បានជាពាក្យ

ក្រញៃពុំងាយបានល្វរ គឺ ក្រញូវពុំងាយបានល្វៃ ពោលគឺ មុខក្រញៃក្រញូវពុំងាយបានស្រាក ។ អ្នកខ្លះនិយាយថា ÷ ក្រញីវក្រញូវ ។

ក្រញេង-ក្រញោង.- ពាក្យនេះ តាមវចនានុក្រម បានសេចក្ដីថា : មិនរៀបរយ ។ ម្រាមដៃក្រញេងក្រញោង ។ បរិវារស័ព្ទ ក្រញេង អាចគន្លាស់បានជាពាក្យ ក្រញេងពុំរៀបថាង គឺ ក្រញោងពុំរៀបចេង ពោលគឺ ក្រញោងពុំរៀបរយ ។

ក្រញេង-ក្រញេង់.- ជាប់ខ្វេរខ្វង់, លាមិនរួច, ក្រញែង ។ ម្រាមដៃក្រញង់ក្រៀមក្រញង់ ។ បរិវារស័ព្ទ ក្រញែង អាចគន្លាស់បានជាពាក្យ ក្រញែងជាប់ក្រងង់ គឺ ក្រញង់ជាប់ក្រញែង ។

ក្រមុំ-ក្រមាក់.- ពាក្យ ក្រមុំ ក្រមាក់ មានអត្ថន័យប្រហាក់ប្រហែលនឹងពាក្យ ក្រមុំ ក្រម៉ាច់ ដែរ ។ បរិវារស័ព្ទ ក្រមាក់ អាចគន្លាស់ជាពាក្យ ក្រមាក់ជួយទុកដុំ គឺ ក្រមុំជួយទុកដាក់ ពោលគឺ រកប្រពន្ធប្រភេទនេះ ដើម្បីបានជាគ្នាជួយទុកដាក់ថែរក្សារបស់ទ្រព្យ ។

ក្រមុំ_ក្រមាច់.- ពាក្យអ្នកផង ច្រើនពោលទៅរកជនពោះម៉ាយថា : យ៉ាងដូចម្ដេច ក៏ពុំគួររកក្រមុំក្រមាច់មួយមកបានជាគ្នា ។ ល ។ បរិវារស័ព្ទ ក្រមាច់ អាចគន្លាស់បានជាពាក្យ ក្រមាច់ដើម្បីគក់ច្របុំ គឺ ក្រមុំដើម្បីគក់ច្របាច់ ។

ក្រមុំ_ក្រមាប់.- តាមលំនាំបរិវារស័ព្ទ ក្រមាប់ នេះ អស់លោកអ្នកប្រាជ្ញបុរាណប្រហែលជាចង់សម្ដែងថា : ក្រមាប់ប្រសប់ចំណុំ គឺ ក្រមុំប្រសប់ចំណាប់ ពោលគឺ ស្រីក្រមុំគ្រប់ល័ក្ខណ មានតម្រិះវិជ្ជាជ្រៅជ្រះ ហើយប៉ិនប្រសប់ផង ។

ក្រវល់_ក្រវាយ.- តាមវចនានុក្រម បានសេចក្ដីថា ÷ សេចក្ដីព្រួយរសាប់រសល់ ។ យើងមានសេចក្ដីក្រវល់ក្រវាយក្នុងចិត្ត ។ បរិវារស័ព្ទ ក្រវាយ អាចគន្លាស់បានជាពាក្យ ក្រវាយក្នុងចិត្តក្នុងរូបកល់ គឺ ក្រវល់ក្នុងចិត្តក្នុងរូបកាយ ។ អ្នកខ្លះនិយាយពាក្យនេះថា : កង្វាយ-កង្វល់, ខ្វាយ-ខ្វល់ ។

ក្រវិក_ក្រវក់.- តាមវចនានុក្រម បានសេចក្ដីថា ÷ វិកវក់បត់បែន ។ ឈើវៀចក្រវិកក្រវក់ ។ ល ។ បរិវារស័ព្ទ ក្រវិក អាចគន្លាស់បានជាពាក្យ ក្រវិកដ៏ច្រើនសន្ទក់ គឺ ក្រវក់ដ៏ច្រើនសន្ទឹក ។

ក្រវឹង_ក្រវាម.- ពាក្យនេះ អ្នកខ្លះនិយាយថា÷ ក្រវីមក្រវាម ខ្លះទៀត ក្រវែមក្រវាម ។ ពាក្យទាំងបីប្រភេទនេះ មានអត្ថន័យដូចគ្នា គ្រាន់តែមានសំឡេងវាចាខុសគ្នាទៅតាមមជ្ឈដ្ឋានអ្នកធ្លាប់ប្រើ ។ គំនូរក្រវឹងក្រវាម បានសេចក្ដីថា : គំនូរច្បាស់ក្រឡាញដោយ មើលពុំស្គាល់ថាជារាងរូបអ្វី ។ ល ។ ពាក្យនេះ ខ្មែរយើងសព្វ ថ្ងៃយកមកប្រើដើម្បីកត់សម្គាល់ថា ជាគំនូស ឬ ស្នាមប្រឡាក់ ដែលមានសភាពរវាម ។ ដូច្នេះ បរិវារស័ព្ទ ក្រវឹង អាចគន្លាស់ បានជាពាក្យ ក្រវឹងច្រាស់ក្រជាម គឺ ក្រវាមច្រាស់ក្រជឹង ពោលគឺ ស្នាមគំនូសគូរចុះគូរឡើងទៅមុខទៅក្រោយ មាន សភាពរវាមពាសពេញ មើលពុំយល់ថាជារូបអ្វី ។ ក្រជឹង ជា ពាក្យខ្មែរបុរាណ បានសេចក្ដីថា : ច្រវា ចែវ សម្រាប់ចែវ ឬ អុំថយក្រោយ ។ ឧទាហរណ៍:- ចែវក្រជឹង - រត់ច្រាសក្រជឹង គឺ រត់ច្រាស់ទៅខាងក្រោយវិញ ។ ល ។ សូមអានវចនានុក្រម ខ្មែរ ទំព័រ ៧២ ត្រង់ពាក្យ ក្រជឹង ។

ក្រវេ_ក្រវ៉ូ.- គ្រាមភាសានេះ យើងនិយាយក្លាយពីពាក្យ វី-វរ ដែល ក្លាយតពីពាក្យ វឹក-វរ ។ បានសេចក្ដីថា ÷ វវល់, ឈឺឆ្អាល ។

កុំមកក្រវេក្រវូការរបស់គេ គឺ កុំមករវល់ឈឺឆ្អាលចង់ដឹងរឿងហេតុគេ ។ បរិវារស័ព្ទ ក្រវេ អាចគន្លាស់បានជាពាក្យ ក្រវេរឿងហេតុរបស់កូ ពោលគឺ ក្រវូរឿងហេតុរបស់គេ ។ ពាក្យនេះ អ្នកខ្លះនិយាយថា : ក្រវីក្រវរ ។

ក្រវេច_ក្រវៀន.- ឆ្កែដេកតាមក្រវេចក្រវៀនផ្ទះ គឺ ដេកវៀនវង់តាមកៀនកោះ ។ បរិវារស័ព្ទ ក្រវៀន អាចគន្លាស់បានជាពាក្យ ក្រវៀននៅកេច គឺ ក្រវេចនៅកៀន ពោលគឺ ឆ្កែដេកមួយក្រវេចនៅកៀនផ្ទះ ។

ក្រហល់_ក្រហាយ.- ក្រហល់ក្រហាយ ឬ ក្រហាយក្រហល់ មានន័យដូចគ្នាគឺ : ក្ដៅផ្សាពាសពេញក្នុងខ្លួន ។ ល ។ បរិវារស័ព្ទ ក្រហល់ អាចគន្លាស់បានជាពាក្យ ក្រហល់ដាយ គឺ ក្រហាយដល់ ពោលគឺ បរិវារស័ព្ទ ក្រហល់ នេះ ជាគុណស័ព្ទមួយសម្ដែងឱ្យឃើញសភាពថា : ច្រើន, ពេក, ណាស់ ។ ល ។

ក្រហេង_ក្រហួង.- ពាក្យនេះគេច្រើននិយាយថា ÷ ដីឬផ្លូវ ក្រហេងក្រហួង ។ ដូច្នេះ បរិវារស័ព្ទ ក្រហេង អាចគន្លាស់បានសេចក្ដីថា : ក្រហេងមិនរាបថ្ងង គឺ ក្រហួងមិនរៀបធេង

ពោលគឺ គេគ្រាន់តែបង្វិលពាក្យដដែលនេះ ដើម្បីបង្ហាញឱ្យឃើញច្បាស់សភាពដីឬផ្លូវនោះ តើមានរបៀបដូចម្តេច ។

ក្រហេត_ក្រហត.- គេច្រើននិយាយថា : ភ្នែកក្រហេតក្រហត គឺភ្នែករូងខួងជ្រៅដូចជាភ្នែកខ្មោចលង ។ ជញ្ជាំងផ្ទះក្រហេតក្រហត គឺជញ្ជាំងផ្ទះនេះ មានប្រហោងធ្លុះជាច្រើន ។ ដូច្នេះ បរិវារស័ព្ទ ក្រហេត អាចគន្លាស់បានជាពាក្យ ក្រហេតមើលធ្លុះដោយពុំបាច់សង្កត ពោលគឺ ក្រហតមើលធ្លុះដោយពុំបាច់សង្កេត ។

ក្រឡេច_ក្រឡុច.- តាមវចនានុក្រម បានសេចក្តីថា ÷ របេញរបុញមិននឹង មិនប្រាកដ គេចប្រែឱ្យខុសអំពីប្រក្រតីដើម ។ មនុស្សក្រឡេចក្រឡុច គឺ មនុស្សខូច របេញរបុញ ។ បរិវារស័ព្ទក្រឡុច អាចគន្លាស់បានជាពាក្យ ក្រឡុចឱ្យខុសអំពីប្រក្រតីដើមចំណោច ពោលគឺ ក្រឡេចឱ្យខុសពីប្រក្រតីដើមចំណុច ។

ក្រអឹត_ក្រទម.- ដែលសម្តែងឫកពាលឆ្មើងបែបកោង ។ល។ មនុស្សក្រអឹតក្រទម ។ល។ បរិវារស័ព្ទ ក្រទម អាចគន្លាស់បានជាវគ្គមួយថា : ក្រទមដូចមានគេហែហឹត គឺ ក្រទឹតដូចមាន

គេហៅហ៊ឹម ពោលគឺបញ្ចេញឫកពាឆ្មើងក្រទឹត ដើម្បីឱ្យអ្នកផងគោរពកោតខ្លាច ។ ពាក្យដើម ក្រអឹត និងបរិវារស័ព្ទ ក្រទម ពុំមានសំឡេងស្របគ្នាឡើយ ដូចសមាសពាក្យធម្មតា ។

ក្រអឹត_ក្រអោង.- តាមវចនានុក្រម បានសេចក្តីថា ÷ ដែលបញ្ចេញឫកព្រហើន, ឫកកោង ។ល។ បរិវារស័ព្ទ ក្រអោង អាចគន្លាស់បានជាពាក្យ ក្រអោងវាយឫកកឹត គឺ ក្រអឹតវាយឫកកោង ។

ក្រាស់_ក្រែល.- សម្បត្តិ ក្រាស់ក្រែល គឺ សម្បត្តិ គ្រប់គ្រាន់ មិនច្រើនពេក គឺច្រើនល្មម ។ បរិវារស័ព្ទ ក្រែល អាចគន្លាស់បានជាពាក្យ ក្រែលនៅតែដដាស់ គឺ ក្រាស់នៅតែដដែល ពោលគឺ សម្បត្តិនៅមានធូនល្មមតែដដែល ពុំមានកើនឡើង ។

ក្រាស់_ក្រៃ.- ពាក្យ ក្រាស់ក្រែល និង ក្រាស់ក្រៃ សឹងមានន័យប្រហាក់ប្រហែលគ្នា ។ ក្រាស់ក្រៃ មានន័យថា ÷ ច្រើនពេក ។ មនុស្សច្រើនក្រាស់ក្រៃ ឬ សម្បត្តិច្រើនក្រាស់ក្រៃ ។ល។ បរិវារស័ព្ទ ក្រៃ អាចគន្លាស់បានជាពាក្យ ក្រៃផុតវិសាស់ ពោលគឺ ក្រាស់ផុតវិស័យ គឺ ក្រាស់ពេក ។

ក្រី-ក្រ.- ជនក្រីក្រ គឺ ជនខ្សត់លំបាកណាស់ មិនថាតែសម្បត្តិទេ គឺរហូតដល់តម្រិះវិជ្ជាផង ។ល។ ដូច្នេះ បរិវារស័ព្ទ ក្រី មានន័យថា ÷ ក្រីអប្រ គឺ ក្រអប្រិយ ពោលគឺ ជនក្រខ្សត់លំបាកដែលជាជនមិនគួរស្រឡាញ់រាប់អាន ដូចពាក្យក្នុងសាស្ត្រាបុរាណខ្មែរបទរាយ បានសម្ដែងថា : រីជនអប្រិយ ទោះប្រុសទោះស្រី អាប់ឥតលក្ខណា គេច្រើនចៀសវាង ពុំចង់សន្ទនា ព្រោះគេយល់ថា អាប់កើអាប់យស ។ វចនានុក្រមខ្មែរភាគ ២ ទំព័រ ១៦៥២ ។

គ្រី_គ្រោធ.- តាមវចនានុក្រម បានសេចក្ដីថា ÷ ស្ដីឱ្យដោយកំហឹងខ្លាំង ។ ដូច្នេះ បរិវារស័ព្ទ គ្រី អាចគន្លាស់បានជាពាក្យ គ្រីខឹងខ្លាំងដោយបានស្រដោត គឺ គ្រោធខឹងខ្លាំងដោយបានស្រដី ពោលគឺ មានជេរស្ដីជាពាក្យអាសគ្រាម ។ សូមមើលពាក្យគ្រេវគ្រោធ ។

ក្រៀម_ក្រំ.- ពាក្យនេះ មានន័យថា ÷ ខ្ពាំ, ស្ងួត, ស្ងប់, អន់, សៅហ្មង ។ ក្រៀមក្រំខ្លួនឬចិត្ត, ទឹកមុខក្រៀមក្រំ ។ បរិវារស័ព្ទ ក្រំ អាចគន្លាស់បានជាពាក្យ ក្រំដូចគេវាយដៀម ពោលគឺ ក្រៀមដូចគេវាយដំ ។

ក្រៀម_ក្រោះ.- ពាក្យនេះ មានន័យថា ÷ ស្ងួត, ខ្សោះ, ស្វិត, ក្រញង់ ។ អាហារក្រៀមក្រោះ ។ ល ។ បរិវារស័ព្ទ ក្រោះ អាចគន្លាស់បានជាពាក្យ ក្រោះខ្សៀម គឺ ក្រៀមខ្សោះ ។ មុខក្រៀមក្រោះ គឺ ក្រោះមិនស្រៀម ពោលគឺ ក្រៀមមិនស្រស់ ។

ក្រេវ_ក្រោធ.- នៅសម័យបុរាណ ខ្មែរយើងប្រើពាក្យនិមួយៗដោយមានន័យនិងស័ព្ទច្បាស់ប្រាកដពុំមានល្បៀង, បើតាមការសង្កេតទៅឃើញថាៈ គេប្រើពាក្យក្រោធ ដើម្បីកត់សម្គាល់តាមផ្លូវចរិយា, ឯពាក្យ ខឹង វិញ សម្រាប់សម្ដែងបង្ហាញថាៈ អវៈយវៈយើងដែលខឹងនោះ ដូច្នេះ ពាក្យថា អ្នកនេះខឹងនឹងអ្នកនោះណាស់, ពាក្យ ខឹង មួយម៉ាត់នេះ អាចកត់សម្គាល់បានថា : ការឈ្លោះប្រកែកគ្នាម្ដងៗ រមែងជេរបញ្ចោរជាពាក្យអាសគ្រាម ឬ ឱ្យកេរ្តិ៍ខ្មាស់គ្នាទៅវិញទៅមកពុំខានឡើយ ។ អាស្រ័យហេតុនេះហើយ គេនិយាយថា : អ្នកនេះខឹងនឹងអ្នកនោះ ។ ចំពោះពាក្យ ក្រោធវិញ គេច្រើននិយាយនៅកាលនោះថាៈ នាយចៅហ្វាយ បានក្រោធនឹងសហការីលោក ដោយមានកំហុសព្រោះចូលធ្វើការពុំទាន់ពេលវេលា ពោលគឺ នាយចៅ

ហ្វាយមានចិត្តប្រកាន់ច្រឡោត « ខឹង » ដូចពាក្យសម្ដីយើងប្រើសព្វថ្ងៃនេះ ។ ដូច្នេះ បរិវារស័ព្ទ ក្រេវ អាចគន្លាស់បានជាពាក្យ « ក្រេវមួយឆោត » គឺ ក្រោធមួយឆេវ ពោលគឺក្រោធមួយភ្លែត ទោះខ្លាំងណាស់ក្ដី រមែងធាប់បានស្បើយទៅវិញ ដោយមានសេចក្ដីអនុគ្រោះ ។

**ក្លាយ_ឃ្លាត.-** ពាក្យនេះ មានន័យថា ÷ ឃ្លាតដោយប្រែប្រួល, ឃ្លាតចាកឆ្ងាយ ។ បរិវារស័ព្ទ ក្លាយ អាចគន្លាស់បានជាពាក្យ ក្លាយឆ្វៀត គឺ ឃ្លាតឆ្ងាយ ។

❀ ❀

❀

# ខ

**ខ_ខិត ឬ ខង_ខិត.-** តាមវចនានុក្រមខ្មែរ បានសេចក្ដីថា ÷ ប្រកាន់ទុក ចំណាំទុក នូវរបស់អ្វីមួយ ថាជារបស់ខ្លួន ដោយដាក់សញ្ញាជាសម្គាល់ ។ ឃ្មុំនេះ មានគេខខិតហើយ ។ មានអ្នកស្រុកខ្លះប្រើពាក្យ ខ-ខិត នោះថា : ខងខិត វិញ ។ តាមយោបលខ្ញុំផ្ទាល់ ពាក្យ ខងខិត ដូចជាសមរម្យជាងពាក្យ ខ-ខិត ព្រោះបរិវារស័ព្ទ ខង អាចគន្លាស់បានជាពាក្យ ខងទុកជាទ្រព្យមួយក្នុងរបិត គឺ ខិតទុកជាទ្រព្យមួយក្នុងរបងពោលគឺ ជាទ្រព្យជាប់បំណង មានម្ចាស់គេ ហាក់ដូចជាទ្រព្យមួយនៅក្នុងរបងផ្ទះ ។

**ខាប់_ខណ្ឌ** ឬ **ខណ្ឌ_ខាប់**.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលចង្អៀតណែនណាន់ ប៉ុន្តែ មានខណ្ឌជាជួរ ជាសង្កាត់ ដាច់ដោយបែក ដោយឡែកពីគ្នា ។ ទីចង្អៀតខាប់ ខណ្ឌ, មនុស្សច្រើនពាន់ ឈរខាប់ ខណ្ឌតាន់តាប់ ។ បរិវារស័ព្ទ ខាប់ អាចគន្លាស់បានជាពាក្យ ខាប់ច្រើនពាន់ចង្អៀតតាប់ តាន់ គឺ ខណ្ឌច្រើនពាន់ចង្អៀតតាន់តាប់ ។

**ខារ_ខាំង**.- បាមឃាត់, ហួងហែង ។ល។ បរិវារស័ព្ទ ខារ អាច គន្លាស់បានជាពាក្យ ខារហាក់ដូចស្រាស់បន្លាំង គឺ ខាំងហាក់ ដូចស្រាស់បន្លា ពោលគឺ ខារខាំងដោយពេញទំហឹង ។

**ខិត_ខំ**.- ខិត-ខំធ្វើការ គឺខំសង្វាត ប្រឹងប្រែងធ្វើការមិនរួញថយ ។ បរិវារស័ព្ទ ខិត អាចគន្លាស់បានជាពាក្យ ខិតធ្វើការឱ្យអស់ពី ចំ ពោលគឺ ខំធ្វើការឱ្យអស់ពីចិត្ត ។

**ខិត_ខាំង**.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដាក់កំហិត, ខារខាំង ។ល។ បរិវារស័ព្ទ ខិត នេះ អាចគន្លាស់បានជាពាក្យ ខិត ដោយដាក់កំហាំង គឺ ខាំងដោយដាក់កំហិត ពោលគឺ ខាំង ដោយមានកម្រិតវិន័យឬទណ្ឌកម្ម ។

**ខឹង_សំបា.-** សមាសពាក្យនេះ មានន័យចំហទាំងពីរ ។ តាមវចនានុក្រមខ្មែរ ពាក្យ ខឹង ជាកិរិយាស័ព្ទ បានសេចក្ដីថា ÷ កម្រើកចិត្តដោយទោមនស្ស, មានអារម្មណ៍មិនគាប់ចិត្តមកប៉ះពាល់ត្រូវទ្វារទាំងប្រាំមួយ មានចក្ខុទ្វារជាដើម នាំឱ្យក្ដៅក្ដួលចិត្តឡើង ។ សំបា ឬ សម្បា ជាកិរិយាវិសេសនៈប្រើក្នុងសមាស ពាក្យនេះ ជាបរិវារស័ព្ទ បានសេចក្ដីថា ពន្លឺ ឬ រស្មីដែលមានភ្លាមឬបាត់ភ្លាម ។ ពាក្យ ខឹងសំបា បានសេចក្ដីថា ខឹងឆាប់រសាយ, ខឹងភ្លាមបាត់ភ្លាម ក្រោយពេលសម្បូងសង្រូងទេវតា ។ ដូច្នេះ បរិវារស័ព្ទ សំបា ឬ សម្បា អាចគន្លាស់បានជាពាក្យ សំបាសង្រូងរកទេវដូង គឺ សម្បូងសង្រូងរកទេវតា ពោលគឺ ខឹងដល់ទៅសម្បូងសង្រូងរកទេវតាដើម្បីជាប្រធាន ។

**ខូច_ពន្លូច.-** ខ្មែរយើងច្រើននិយាយថា ÷ ក្មេងនេះ ទៅជាខូចពន្លូចអស់ពុំឃើញខំរៀន ។ ល ។ បរិវារស័ព្ទ ពន្លូច អាចគន្លាស់បានជាពាក្យ ពន្លូចទើបបានខែង គឺ បន្លែងទើបបានខូច ពោលគឺក្មេងនេះ ពុំខុស្សាហ៍រៀនសូធ្យ ចូលចិត្តតែប្រឡែងគ្នាលេងនៅសាលា ទើបទៅជាក្មេងពាលខូចពន្លូច ។

ខេ_ខឹង.- ក្តួលក្តៅចិត្តឡើង ដោយពុំដឹងរឿង ។ បរិវារស័ព្ទ ខេ អាច គន្លាស់បានជាពាក្យ ខេទតឹង១ គឺ ខឹងទទេ១ ពោលគឺ ប្រកាន់ ខឹងឡើងដោយពុំដឹងរឿងហេតុអ្វី ឬខេទើបចឹង គឺ ខឹងទើបជេរ ។

ខែ_ខៃ.- កែកុន, ជួសជុល, ដោះស្រាយ ។ល។ បរិវារស័ព្ទ ខែ អាចគន្លាស់បានជាពាក្យ ខែរកគ្រប់ស្ទៀតគ្រប់ថ្លៃ គឺខៃរកគ្រប់ ស្ទៀតគ្រប់ថ្លៃ ពោលគឺ ខៃ-ខៃ រកគ្រប់មធ្យោបាយ ។

ខែង_រ៉ែង.- ដែលក្ខៀវក្លា, អង់អាច ។ ឫកពាខែងរ៉ែងណាស់ ។ បរិវារស័ព្ទ រ៉ែង អាចគន្លាស់បានជាពាក្យ រ៉ែងតែម្នាក់អឹក គឺ ឫកតែម្នាក់ឯង ពោលគឺ ធ្វើឫកខែងតែម្នាក់ឯង ដោយពុំមាន អ្នកផងនិយមយល់ស្របជាមួយផង ។

ខះ_ខំ.- ពាក្យនេះ មានន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ ខិតខំ ។ បរិវារស័ព្ទ ខះ អាចគន្លាស់បានជាពាក្យ ខះណំ គឺ ខំណាស់ ។

ខ្ជរ_ខ្ជាយ.- តាមវចនានុក្រម ពាក្យ ខ្ជរ មានន័យថា ÷ លេចឮពាស ពេញ, រីឯពាក្យ ខ្ជាយ វិញ មានន័យថា : សុសសាយ, ផ្សាយ ទូទៅ ។ រឿងនេះ បែកខ្ជរខ្ជាយហើយ ។ បរិវារស័ព្ទ ខ្ជាយ

អាចគន្លាស់បានជាពាក្យ ខ្ជាយបែកសុស-ស គឺ ខ្ជរបែកសុស-សាយ ។

**ខ្ជាត់_ខ្ជាយ.-** រាត់រាយ, រោយរាយ ។ អង្ករកំពប់ខ្ជាត់ខ្ជាយអស់ ។ បរិវារស័ព្ទ ខ្ជាយ អាចគន្លាស់បានជាពាក្យ ខ្ជាយអន្ទរាត់ គឺ ខ្ជាត់អន្ទរាយ ។

**ខ្ជាប់_ខ្ជួន.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ខ្ជាប់ខ្ជួន គឺខ្ជាប់ណាស់, មាំមួនណាស់ ។ ឧទាហរណ៍: រៀនសូធ្យខ្ជាប់ខ្ជួន ។ ធ្វើការខ្ជាប់ខ្ជួន ។ បរិវារស័ព្ទ ខ្ជួន អាចគន្លាស់បានជាពាក្យ ខ្ជួនតាមលំនាំក្បប់ គឺ ខ្ជាប់តាមលំនាំក្បួន ពោលគឺធ្វើការអ្វីនិមួយ ៗ ទោះបីខ្ជាប់ខ្ជួន ក្ដីតែខុសលំនាំក្បួនតម្រាហើយ ការនោះ រមែងប្រព្រឹត្តទៅ ដោយពុំមានថេរភាពឡើយ ។

**ខ្ជះ_ខ្ជាយ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ចាយវាយទ្រព្យធនឥតសណ្ដាប់ធ្នាប់ ដូចគេជះចោល ។ បរិវារស័ព្ទ ខ្ជាយ អាចគន្លាស់បានជាពាក្យ ខ្ជាយជះចោលដោយរាត់រះ គឺ ខ្ជះជះចោលដោយរាត់រាយ ។ ពាក្យនេះ អ្នកខ្លះនិយាយថា : កញ្ចះកញ្ចាយទៅវិញ ។

**ខ្ជាញ-ខ្ជិល.**- តាមវចនានុក្រម ទំព័រ ៩៣០ បានសេចក្ដីថា ÷ ខ្ជិល កម្ជេញ គឺ ខ្ជិលរងៀករងៀម, ខ្ជិលច្រអូសស្ទើរក្រោកពុំរួច ។ ខ្ជាញខ្ជិល ឡេះ-ឡោះ ។ បរិវារស័ព្ទ ខ្ជាញ អាចគន្លាស់បាន ជាពាក្យ ខ្ជាញរងៀករងៀមកម្ជិល ខ្ជិលរងៀករងៀមកម្ជេញ កម្ជេញ ។ អ្នកខ្លះនិយាយថា : គម្ជេញ គម្ជិលទៅវិញ ។

**ខ្ជោក-ខ្ជាក.**- តាមវចនានុក្រម បានសេចក្ដីថា ÷ អំពីដំណើរចាយវាយ ប្រាក់កាសខ្ជីខ្ជាឥតបើគិត ដូចគេគ្រវាត់គ្រវែងចោល ។ ចាយ វាយខ្ជោកខ្ជាក ។ បរិវារស័ព្ទ ខ្ជាក អាចគន្លាស់បានជាពាក្យ ខ្ជាកដោយគ្រវែងចោលនូវក្រោក គឺ ខ្ជោកដោយគ្រវែងចោល នូវប្រាក់ ។

**ខ្ជី-ខ្ជុក.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ក្រញឹកក្រញុក ដោយ ឈ្លីឈ្លក់ ។ បរិវារស័ព្ទ ខ្ជុក អាចគន្លាស់បានជា ពាក្យ ខ្ជុកដោយឈ្លក់ឈ្លី គឺ ខ្ជីដោយឈ្លីឈ្លក់ ។

**ខ្ជីវ-ខ្ជូវ.**- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលច្រូញក្រញូវ ។ មុខ ខ្ជីវខ្ជូវ , សំពត់ខ្ជីវខ្ជូវ ។ ល ។ បរិវារស័ព្ទ ខ្ជីវ អាចគន្លាស់

បានជាពាក្យ ខ្ញីវដូចមានជំងឺប្រគ្រូវ គឺ ខ្ញូវដូចមានជំងឺប្រគ្រីវ ។

**ខ្ញុក-ខ្ញូវ.**- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលច្រូញរូញចំពាក់ក្រញុកក្រញូវ ។ បរិវារស័ព្ទ ខ្ញុក អាចគន្លាស់បានជាពាក្យ ខ្ញុកដោយច្រូញក្រញុកក្រញូវ គឺ ខ្ញូវដោយច្រូញក្រញូវក្រញុក ។

**ខ្ញរ-ខ្ញ័រ.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលលាន់រំពងញ៉ូរសុសសាយ ដោយបាញ់កាំភ្លើង ឬ ដោយវាយស្គរធំ ជាដើម ។ បាញ់កាំភ្លើងឮខ្ញរខ្ញ័រ ។ល។ បរិវារស័ព្ទ ខ្ញ័រ អាចគន្លាស់បានជាពាក្យ ខ្ញ័រដោយលាន់រំពងញូរ គឺ ខ្ញរដោយលាន់រំពងញ៉ូរ ។

**ខ្ញរ-ខ្ញារ.**- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលលាន់រំពងញ៉ូរសុសសាយ ដោយបាញ់កាំងភ្លើងឬវាយស្គរធំ ជាដើម ។ សូរខ្ញរខ្ញារ, បាញ់ខ្ញរ-ខ្ញារ ។ បរិវារស័ព្ទ ខ្ញារ អាចគន្លាស់បានជាពាក្យ ខ្ញារអស់អគរ គឺ ខ្ញ័រអស់អគារ ។

**ខ្ញេច-ខ្ញី.**- ខ្ញេច-ខ្ញី គឺ ខ្ញេចណាស់ ។ បរិវារស័ព្ទ ខ្ញី អាចគន្លាស់ជាពាក្យ ខ្ញីជាធូលេច ពោលគឺ ខ្ញេចជាធូលី ។

ខ្ចល់_ខ្ចើយ.- ពាក្យ ខ្ចល់-ខ្ចើយ នេះ ជាសមាសពាក្យមួយមានន័យចំហទាំងពីរ ពោលគឺ ខ្ចល់ បានសេចក្ដីថា ÷ របស់សម្រាប់កល់ ។ ពាក្យ ខ្ចើយ បានសេចក្ដីថា ÷ ប្រដាប់សម្រាប់កើយ ។ បើយើងយកពាក្យ ខ្ចល់ មកធ្វើជាបរិវារស័ព្ទ, ពាក្យនេះ អាចគន្លាស់បានថា : ខ្ចល់សម្រាប់កើយ គឺ ខ្ចើយសម្រាប់កល់ ។ រួមសេចក្ដីទៅ ពាក្យគន្លាស់ទាំងពីរវគ្គនេះ មានអត្ថន័យប្រហែលគ្នា ហាក់ដូចជាពាក្យតែមួយម៉ាត់ ។

ខ្ចាន_ខ្ចាប់.- តាមវចនានុក្រម បានសេចក្ដីថា ÷ ពាសពេញ, ណែនណាន់, ដេរដាស់ ។ មនុស្សខ្ចានខ្ចាប់ ។ បរិវារស័ព្ទ ខ្ចាន អាចគន្លាស់បានជាពាក្យ ខ្ចានច្រើន ណែនណាន់ តាន់តាប់ គឺ ខ្ចាប់ច្រើនណែនណាន់ តាប់តាន់ ។

ខ្ចះ_ខ្ចែង.- ខំសង្វាត ។ ខំខ្ចះខ្ចែងធ្វើការ ។ល។ បរិវារស័ព្ទ ខ្ចែង អាចគន្លាស់បានជាពាក្យ ខ្ចែងធ្វើការដោយប្រឹងប្រាស់ ពោលគឺ ខ្ចះធ្វើការដោយប្រឹងប្រែង ។

ខ្ពង់_ខ្ពស់.- តាមវចនានុក្រម បានសេចក្ដីថា ÷ ខ្ពង់ដូចខ្ពងភ្នំ-ថ្កើងថ្កានប្រសើរ ។ ខ្ពង់ខ្ពស់, ឧត្ដម ។ ល ។ បរិវារស័ព្ទ ខ្ពង់ អាចគន្លាស់

បានជាពាក្យ ខ្ពង់ថ្កើងថ្កានដោយមានទំរស់ គឺ ខ្ពស់ថ្កើងថ្កាន ដោយមានទម្រង់ ពោលគឺ ខ្ពង់ខ្ពស់ ថ្កើងថ្កានដោយសមរម្យ ។ បើតាមគ្រាមភាសាវិញ យើងអាចគន្លាស់បានជាពាក្យ ខ្ពង់ផុតជូស គឺ ខ្ពស់ផុតចុង ។

**ខ្មី-ឃ្មាត.**- ពាក្យនេះ គេច្រើនប្រើតែក្នុងពាក្យឃ្លោង ដែលមានន័យថា : ខំប្រឹង ឬ សង្វាតខ្លាំង ។ ខ្មីឃ្មាតធ្វើការ គឺ ខំប្រឹងធ្វើការឱ្យបានឆាប់ក្រៃ ។ បរិវារស័ព្ទ ឃ្មាត អាចគន្លាស់បានជាពាក្យ ឃ្មាតខំប្រឹងធ្វើការកុំឱ្យបង់មាឃ៉ី គឺ ខ្មីខំប្រឹងធ្វើការកុំឱ្យបង់មារយាទ ពោលគឺ ខំសង្វាតព្យាយាមធ្វើការកុំឱ្យខូចកេរ្តិ៍ឈ្មោះ ។

**ខ្ជួល-ខ្ជាញ់.**- ដែលឈើចាប់ ចុកអួល១នេវ១ ។ ឈាមហូរគ្របាញ់ ខ្ជួលខ្ជាញ់តាមមុខរបួស ។ ល ។ បរិវារស័ព្ទ ខ្ជាញ់ អាចគន្លាស់បានជាពាក្យ ខ្ជាញ់ដោយរបួសចាប់ពើត មានឈាមហូរគ្របួល គឺ ខ្ជួលដោយរបួសចាប់ពើត មានឈាមហូរ-គ្របាញ់ ។

ខ្មៅ_ខ្មួល.- ដែលមានពណ៌ខ្មៅ ប្រអូលងងឹតដូចធ្យូង ។ ផ្សែងហុយទ្រលោមខ្មៅខ្មួល ។ ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ខ្មួល អាចគន្លាស់បានជាពាក្យ ខ្មួលងងឹតប្រអៅ គឺ ខ្មៅងងឹតប្រអូល ។

ខ្ទាំង_ខ្ទិល.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមានអាការរនិងរនាំងទាំងកំរោល ។ សម្ដីខ្ទាំងខ្ទិល ។ អ្នកខ្លះនិយាយពាក្យនេះថា : ខ្ទាំងមិល វិញ ។ បរិវារស័ព្ទ ខ្ទិល អាចគន្លាស់បានជាពាក្យ ខ្ទិលដូចទមាំង គឺ ខ្ទាំងដូចទមិឡ ពោលគឺ សម្ដីទាំងកំរោលដូចជនឥតពូជអម្បូរ គឺ សម្ដីដូចទមិឡ-សម្ដីចោរឫស្យា ។

ខ្មោះ_ខ្មួល.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមានក្លិនអាក្រក់ដោយកំពុលចង់ខូច ។ ផ្អកធុំក្លិនខ្មោះខ្មួល, សម្ដីខ្មោះខ្មូរ គឺ សម្ដីច្រឡោះបោះ ពុំមានសេចក្ដីគួរសម ។ បរិវារស័ព្ទ ខ្មូរ អាចគន្លាស់បានជាពាក្យ ខ្មូរដល់ខោះ គឺ ខ្មោះដល់ខួរ ពោលគឺ ធុំក្លិនអាក្រក់ចាក់ដល់ខួរក្បាល ។

**ខ្ជប_ខ្ជាច.-** បច្ចាមិត្រយើង បានចុះចូលខ្ជបខ្ជាចហើយ ។ បរិវារស័ព្ទ ខ្ជប អាចគន្លាស់បានជាពាក្យ ខ្ជបព្រមចុះចូលជារណាច គឺ ខ្ជាចព្រមចុះចូលជារណប ពោលគឺ បច្ចាមិត្រយើង បានចាញ់ ដៃខ្ជបខ្ជាចជារណប ។

**ខ្លាក់_ខ្លប.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលស្របទន់បណ្ដោយ តាមដោយខ្លាច ។ បរិវារស័ព្ទ ខ្លាក់ អាចគន្លាស់បានជាពាក្យ ខ្លាក់ស្របបណ្ដោយតាមដោយគ្មានអប គឺ ខ្លបស្របបណ្ដោយ តាមដោយគ្មានអាក់ ។

**ខ្លាំង_ក្លា.-** ចិត្តខ្លាំងក្លា, សម្ដីខ្លាំងក្លា ។ ល ។ បរិវារស័ព្ទ ក្លា អាច គន្លាស់បានច្រើនវគ្គណាស់ ដោយមានន័យខុសៗគ្នាផង ដូច ជាអាទិ៍ ÷ ក្លាមិនបានកាំង គឺ ខ្លាំងមិនបានការ ។ ក្លាតែវោ ហាំងគឺ ខ្លាំងតែវោហារ ។ ក្លាគ្មានព្រះជេស្តាំង គឺ ខ្លាំងគ្មាន ព្រះជេស្ដា ។ ក្លាជាការសម្ដែងឱ្យហ៊ឺហាំង គឺ ខ្លាំងជាការ សម្ដែងឱ្យហ៊ឺហារ ។ល។ មូលសេចក្ដីទៅឃើញថា មាន តែ ពាក្យគន្លាស់ចុងក្រោយមួយបែបទៀតទេ ដែលមាន

អត្ថន័យសមរម្យជាងគេទាំងអស់ ពោលគឺ ក្លាគ្រប់ប្រការ បានសេចក្ដីថា ខ្លាំងគ្រប់ប្រការ ។

**ខ្វល់_ខ្វាយ.-** ខ្នះខ្នែង, ស្រវាស្រទេញ ។ ខ្វល់ខ្វាយរកស៊ី ។ ខ្វល់ខ្វាយក្នុងការងារ ។ល។ បរិវារស័ព្ទ ខ្វាយ អាចគន្លាស់បានជាពាក្យ ខ្វាយក្នុងរូបកល់ គឺ ខ្វល់ក្នុងរូបកាយ ពោលគឺ ខ្វល់ខ្វាយចិត្តណាស់ក្នុងការរកស៊ី ។ ពាក្យនេះយើងអាចគន្លាស់ផ្សំបានមួយវគ្គទៀតថា : ខ្វាយរកមធ្យោបល់ គឺ ខ្វល់រកមធ្យោបាយដើម្បីដោះស្រាយបញ្ហារកស៊ីធ្វើការ ។ សូមមើលពាក្យក្រវល់-ក្រវាយ ។

**ខ្វាត់_ខ្វែង.-** តាមវចនានុក្រមបានសេចក្ដីថា ÷ ដែលមានទទឹងបណ្ដោយបត់បែន, ពត់ពែន, ក្រវិចក្រវៀន ច្រើនជាន់ច្រើនអន្លើ ។ ផ្លូវឬផ្ទះខ្វាត់ខ្វែង ។ បរិវារស័ព្ទ ខ្វាត់ អាចគន្លាស់បានជាពាក្យ ខ្វាត់ជាសង្វែង គឺ ខ្វែងជាសង្កាត់ ពោលគឺ ផ្លូវឬផ្ទះខ្វាត់ខ្វែងច្រើនខណ្ឌជាសង្កាត់ ។

**ខ្វិច_ខ្វៀន.-** តាមវចនានុក្រម បានសេចក្ដីថា ÷ វៀនជាប់ជាវង់ ។ ដើរខ្វិចខ្វៀនជុំវិញកន្លែងមួយ គឺ ដើរជុំវិញមួយភ្លែត ។ បរិវារ-

ស័ព្ទ ខ្ទិច អាចគន្លាស់បានជាពាក្យ ខ្ទិចជុំវិញមួយរំពៀន គឺ ខ្មៀនជុំវិញមួយរំពេច ពោលគឺ ដើរជុំវិញខ្ទិចខ្មៀនទីនោះយ៉ាងប្រញាប់តែមួយសន្ទុះ ។

ខ្មោក_ខ្វាក.- តាមវចនានុក្រម បានសេចក្ដីថា ÷ សូរឮដោយនិយាយខ្លាំងកោកកាកឥតសំច័យ ឬសូរ ដោយហែកសំពត់ឬស្លឹកឈើផ្សេងៗ ។ បរិវារស័ព្ទ ខ្វាក អាចគន្លាស់បានជាពាក្យ ខ្វាកដោយសូរសម្លេងកាកកោក គឺ ខ្មោកដោយសូរសម្លេងកោកកាក ។

ខ្សិក_ខ្សុល.- តាមវចនានុក្រម បានសេចក្ដីថា ÷ យំអណ្ដឹត-អណ្ដកឆែតឆត, តិច ។ ដែលមានកិរិយារអាក់រអួលក្រសាក់ស្បើយ ។ យំខ្សិកខ្សុល ។ល។ បរិវារស័ព្ទ ខ្សិក អាចគន្លាស់បានជាពាក្យ ខ្សិកដោយរអឹក-រអួល គឺ ខ្សួលដោយរអួលរអឹក ពោលគឺ យំខ្សិកខ្សួលដោយរអឹករអួល ។

ខ្សឹប_ខ្សាវ.- ពាក្យនេះ មានអត្ថន័យប្រហាក់ប្រហែលគ្នានឹងពាក្យខ្សឹបខ្សួលដែរពោលគឺ ខ្សឹបហៅឱ្យមកជិតដើម្បីនិយាយប្រាប់ការអ្វីមួយកុំឱ្យរំខានដល់អ្នកដទៃដែលនៅអង្គុយឬឈរជិតខ្លួន។ ដូច្នេះ បរិវារស័ព្ទ ខ្សាវ អាចគន្លាស់បានជាពាក្យ ខ្សាវហឹបគឺ ខ្សឹបហៅ។

ខ្សិប_ខ្សុល.- តាមវចនានុក្រម បានសេចក្ដីថា ÷ និយាយតិចៗជិតត្រ-

ចៀកដើម្បីមិនឱ្យអ្នកដទៃនៅជិតខាងឮ ។ ពាក្យនេះអ្នកផង ច្រើនពោលថា : តែមានរឿងអ្វីចេះតែនាំគ្នាខ្សឹបខ្សួលនោះ ? បរិវារស័ព្ទ ខ្សួល អាចគន្លាស់បានជាពាក្យ ខ្សួលព្រោះមានការ មិនស្រួប គឺ ខ្សឹបព្រោះមានការមិនស្រួល ពោលគឺ មានការមិន ស្រួលដែលជាអាថិកំបាំង ទើបនាំគ្នាខ្សឹបខ្សួល ។ ពាក្យ ខ្សួល នោះគេពុំសូវឃើញមានប្រើក្រៅអំពីវគ្គមួយ ប្រភេទដែលបាន ជូនក្នុងឧទាហរណ៍នេះ ។

**ខ្សឹប_ខ្សៀវ.-** ពាក្យនេះ មានអត្ថន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ ខ្សឹបខ្សួលដែរ តែមានសភាពរញ្ជៀវបន្តិច ពោលគឺ មានច្រើន គ្នា ព្រោះបរិវារស័ព្ទ ខ្សៀវ អាចគន្លាស់បានជាពាក្យ ខ្សៀវ ដោយរញ៉ឹប គឺ ខ្សឹបដោយរញ្ជៀវ ។

**ខ្សែត_ខ្សត.-** សូរឮដោយកណ្ដស់ ឬ ផ្ដាសាយ, តឹងច្រមុះ ។ ញើសសំបោរខ្សែតខ្សត ។ បរិវារស័ព្ទ ខ្សត អាចគន្លាស់ បានជាពាក្យ ខ្សតដោយឆតឆែត គឺ ខ្សែតដោយឆែតឆត ។ អ្នកខ្លះ និយាយពាក្យនេះថា : ខ្សឹតខ្សតទៅវិញ ។

❀

❀ ❀

# គី

**គគីម_គគឹម.-** កូនក្មេងវារចូលគគីម-គគឹម ។ ល ។ បរិវារស័ព្ទ គគីម អាចគន្លាស់បានជាពាក្យ គគីម ទីម-ទឹម គឺ គគឹម-ទឹមទឹម ពោលគឺ វារចូលទឹមៗ ។

**គគឹក_គគាក់.-** អត្ថន័យក្នុងវចនានុក្រម គឺ ÷ សូរឮដោយខ្យល់ ឬ ដោយទឹកហូរធ្លាក់ ។ បរិវារស័ព្ទ គគាក់ អាចគន្លាស់បានជាពាក្យ គគាក់ដូចស្នូរទឹកហូរធ្លឹក គឺ គគឹកដូចស្នូរទឹកហូរធ្លាក់ ។ ពាក្យនេះ មានន័យនិងលំនាំដូចពាក្យ គ្រឹកគ្រាក់ ឬ គគ្រឹកគគ្រាក់ ។

**គគុក_គគាក់.-** អត្ថន័យក្នុងវចនានុក្រម គឺៈ សូរឮដោយទឹកហូរធ្លាក់ ឬ ទឹកពុះ ។ បរិវារស័ព្ទ គគាក់ អាចគន្លាស់បានជាពាក្យ គគាក់ដូចស្នូរទឹកហូរធ្លុក គឺ គគុកដូចស្នូរទឹកហូរធ្លាក់ ។ ពាក្យនេះមានន័យ និងលំនាំប្រហាក់ប្រហែលគ្នានឹងពាក្យ គ្រុកគ្រាក់ ឬ គគ្រុកគគ្រាក់ ។

**គគុះ_គគុល.-** អត្ថន័យក្នុងវចនានុក្រម គឺ ÷ ដែលសើមរីកពង្វៀច, ដំបៅរីកគគុះគគុល ។ល។ បរិវារស័ព្ទ គគុះ អាចគន្លាស់បានជាពាក្យ គគុះរីកចេញខ្ទុល គឺ គគុលរីកចេញខ្ទុះ ។

**គគុះ_គគា.-** ពាក្យនេះ មានអត្ថន័យប្រហាក់ប្រហែលនឹងពាក្យ គគុះ-គគុល ។ ដំបៅរីកគគុះគគា ។ បរិវារស័ព្ទ គគុះ អាចគន្លាស់បានជាពាក្យ គគាខ្មៀវហុះ គឺ គគុះខ្ទុះហៀវ ។

**គគ្រក់_គគ្រន់.-** ដែលកខ្វក់ណាស់, ដែលស្មោកគ្រោកពេក ។ បើតាមយោបល់ខ្ញុំផ្ទាល់ ខ្មែរយើងប្រហែលជាចង់ប្រដូចពាក្យនេះទៅនឹងពាក្យគ្រាមភាសា ដែលអ្នកស្រុកច្រើននិយាយប្រដូចថា : កខ្វក់ដូចកណ្តុរគ្រុន ពោលគឺ សត្វកណ្តុរនេះ ជាសត្វតូចមួយ កខ្វក់ពេកក្រៃ, រស់នៅតែក្នុងទឹកភក់ ឬ ជ្រាំ, មានមេរោគ

ជាប់ពាសពេញនឹងខ្លួន ដូចជាមេរោគប៉េសជាដើម, ជាសត្វមួយមានសុខភាពមាំមួន ទប់ទល់នឹងមេរោគគ្រប់យ៉ាងបាន ។ ម្យ៉ាងវិញទៀត បើសត្វកណ្ដុរនេះមានជម្ងឺឈឺគ្រុនហើយ យើងអាចសន្និដ្ឋានបានថា : សេចក្ដីសោកគ្រោកនេះ ពិតជាមានទ្វេលើសលប់ក្រៃលែងទៅទៀត ។ ដូច្នេះ បរិវារស័ព្ទ គគ្រន់ អាចគន្លាស់បានជាពាក្យ គគ្រន់ដូចកណ្ដុរគ្រក់ គឺ គគ្រក់ដូចកណ្ដុរគ្រន់ ។ តាមសំដីអ្នកស្រុកខ្លះ គេបានហៅមិត្តភ័ក្តិថា : នែ៎ អាកណ្ដុរគ្រក់ ! ទៅណា ? ។ល។ ពាក្យនេះ ពុំមានខុសន័យដូចខ្ញុំបានជូនខាងលើប៉ុន្មានឡើយ ។

**គគ្រឹង_គគ្រាំង**.- អត្ថន័យក្នុងវចនានុក្រម គឺ : ស្នូរឮដោយវាយគោះ, រលំ, ទម្លាក់, ធ្លាក់អ្វីដូចស្នូរធាក់ជញ្ជាំងជាដើម ។ បរិវារស័ព្ទ គគ្រឹង អាចគន្លាស់បានជាពាក្យ គគ្រឹងភាំង១ គឺ គគ្រាំងភឹង១ ។

**គគ្រិច_គគ្រុក**.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមិនស្អាត, កខ្វក់ពេក ដោយមានជង្គុវចុះ ។ សមាសពាក្យនេះ មានន័យចំហទាំងពីរ ។ យើងអាចយកពាក្យណាធ្វើបរិវារស័ព្ទបានទាំងអស់ ហើយគន្លាស់ត្រឡប់ឡើងបានសេចក្ដីតែមួយ ។

ដូច្នេះ ពាក្យ គគ្រិច អាចផ្សំបានជាវគ្គមួយថា : គគ្រិចដង្កូវចុះ គគ្រុក ពោលគឺ គគ្រុកដង្កូវចុះគគ្រិច ។

**គគ្រីក_គគ្រាក់.-** អត្ថន័យក្នុងវចនានុក្រម គឺ : គ្រីកៗមិនដាច់សូរ ។ បរិវារស័ព្ទ គគ្រាក់ អាចគន្លាស់បានជាពាក្យ គគ្រាក់គ្មានឃើញពេលសម្រីក គឺ គគ្រីកគ្មានឃើញពេលសម្រាក ។

**គគ្រិស_គគ្រូស.-** អត្ថន័យក្នុងវចនានុក្រម គឺ : រឹងរូស ដែលលាន់មាត់ងិះងងូស មិនចង់ធ្វើតាម ។ ជនគគ្រិសគគ្រូស ។ បរិវារស័ព្ទ គគ្រិស អាចគន្លាស់បានជាពាក្យ គគ្រិសដោយរំអ៊ូថា នេះថានោះ គឺ គគ្រុះដោយរំអ៊ូថានោះថានេះ ពោលគឺ គគ្រិស គគ្រូសមិនចង់ធ្វើតាម ដោយលាន់មាត់ងិះងងូស ។

**គគ្រឹក_គគ្រេង.-** តាមវចនានុក្រម បានសេចក្តីថា ÷ ពាក្យសម្រាប់ចម្រើនពាក្យលេង-ពាក្យធ្វើបុណ្យជាដើម ឱ្យប្លែកឡើង ។ លេងល្បែងគគ្រឹកគគ្រេង គឺ លេង ឬ ធ្វើបុណ្យ ដោយមានល្បែងផ្សេងៗ មានភ្លេងជាដើម ទាំងមានមនុស្សក៏ច្រើនផង ។ សមាសពាក្យនេះ មានន័យចំហទាំងពីរ គឺ គគ្រឹក មានន័យថា ÷ សូរសន្ធឹកដើរច្រើនគ្នា, រីឯពាក្យ គគ្រេង វិញ បានសេចក្តីថា :

ស្ទូរព្ទដោយរលកទឹក ។ល។ ដូច្នេះ បើយើងយកពាក្យ គគ្រេង មកធ្វើជាបរិវារស័ព្ទ យើងអាចគន្លាស់បានជាពាក្យ គគ្រេង ដោយមានមនុស្សច្រើនមកលេងបុណ្យស្គាប់ភ្លឹក គឺ គគ្រឹក ដោយមានមនុស្សច្រើនមកលេងបុណ្យស្គាប់ភ្លេង ។

**គគ្រុក_គគ្រាក់.-** ពាក្យនេះ មានអត្ថន័យនិងលំនាំប្រហាក់ប្រហែល នឹងពាក្យ គគ្រឹកគគ្រាក់, ដូច្នេះ សូមអានពាក្យ គគ្រឹកគគ្រាក់ នេះ ។

**គគ្រេង_គគ្រាំ ឬ គគ្រាំ_គគ្រេង.-** អត្ថន័យក្នុងវចនានុក្រម គឺៈ សូរសន្ទឹកដោយលោតទឹកលេង ឬ សូរសន្ទឹកដោយរលកខ្ទប់ ខ្លាំង ។ បរិវារស័ព្ទ គគ្រេង អាចគន្លាស់បានជាពាក្យ គគ្រេង ដូចស្ទូរលោតទឹកលាំ គឺ គគ្រាំដូចស្ទូរលោតទឹកលេង ។

**គឃី_គឃៀវ.-** អត្ថន័យក្នុងវចនានុក្រម គឺៈ ដែលបែកញើសហៀរ-ហូរសស្រាក់ ។ បែកញើសគឃីគឃៀវ ។ បរិវារស័ព្ទ គឃី អាចគន្លាស់បានជាពាក្យ គឃីហូរញើសដោយធ្វើការវក់វា គឺ គឃៀវហូរញើសដោយធ្វើការវក់វី ។

**គន់_គួរ.-** អត្ថន័យក្នុងវចនានុក្រមគឺៈ ពិចារណាដោយក្បួនវេទ មាន

វាយលេខជាដើម ។ ហោរាគន់គូ ។ បរិវារស័ព្ទ គូរ អាច គន្លាស់បានជាពាក្យ គូរតាមវិធីលោកគ្រាន់ គឺ គន់តាមវិធី លោកគ្រូ ។

គន្លាក់_គន្លើន.- អត្ថន័យក្នុងវចនានុក្រម គឺៈ ដែលមានគន្លាស់ច្រើន ដង, ច្រើនសង្កាត់ ។ ផ្លូវរទេះភ្លើងគន្លាក់គន្លើន ។ បរិវារស័ព្ទ គន្លើន អាចគន្លាស់បានជាពាក្យ គន្លើនជាប្រាក់ គឺ គន្លាក់ ជាច្រើន ។

គន្លាស់_គន្លោង.- អត្ថន័យក្នុងវចនានុក្រម គឺ ÷ ដែលគន្លាស់ជាកាព្យ ជាឃ្លោង ។ បរិវារស័ព្ទ គន្លោង អាចគន្លាស់បានជាពាក្យ គន្លោងជាកាព្យឃ្លាស់ គឺ គន្លាស់ជាកាព្យឃ្លោង ។

គន្លិក_គន្លាក់.- អត្ថន័យវចនានុក្រម គឺៈ ដែលរជិបរជុប, ខ្ពស់ទាប ។ បរិវារស័ព្ទ គន្លិក អាចគន្លាស់បានជាពាក្យ គន្លិករជិបរជុបដោយ មានចូកជាក់ គឺ គន្លាក់រជិបរជុបដោយមានចូកជីក ។

គប់_គិត.- អត្ថន័យក្នុងវចនានុក្រម គឺៈ រួមគំនិតគ្នា, គិតគូរគ្នា ។ បរិវារស័ព្ទ គិត អាចគន្លាស់បានជាពាក្យ គិតដោយរួមគំនប់ គឺ គប់ដោយរួមគំនិត ។

គម្រី_គម្រក់.- អត្ថន័យក្នុងវចនានុក្រម គឺៈ ដែលគគ្រក់, ដែលអាក្រក់យកជាការពុំបាន ។ បរិវារស័ព្ទ គម្រី អាចគន្លាស់បានជាពាក្យ គម្រីគេផាត់ចោលក្រៅបញ្ជក់ គឺ គម្រក់គេផាត់ចោលក្រៅបញ្ជី ។

គម្រិង_គម្រាំង.- អត្ថន័យក្នុងវចនានុក្រម គឺៈ ដែលគគ្រឹងគគ្រាំង ។ សាច់គម្រិង គម្រាំង ។ បរិវារស័ព្ទ គម្រិង អាចគន្លាស់បានជាពាក្យ គម្រិងដូចសត្វខ្លាំង គឺ គម្រាំងដូចសត្វខ្លឹង ។ សូមមើលពាក្យ គ្រមិង គ្រមាំង ។

គរ_គោក.- ដែលច្រើនពាសពេញជាគំនរដូចដំបូក ។ បរិវារស័ព្ទ គោក អាចគន្លាស់បានជាពាក្យ គោកដូចដំបិរ គឺ គរដូចដំបូក ។

គាល់_ហៅ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរ គឺ ពាក្យ គាល់ បានសេចក្តីថា : អង្គុយចាំគោរពព្រះមហាក្សត្រ និងពាក្យ ហៅ ប្រែមកថា : ចាំ, ចាំរក្សាឬគាល់ ។ គាល់ហៅ បានសេចក្តីថា : អង្គុយគាល់ប្រចាំការ បម្រើ ។ល។ បរិវារស័ព្ទ ហៅនេះ អាចគន្លាស់បានជាពាក្យអ្វីឡើយពោល គឺ ពាក្យ គាល់ហៅ នេះ បើតាមជនសាមញ្ញយល់វិញ បាន

សេចក្ដីថា : អង្គុយគាល់ប្រចាំការ ក្រែងមានការហៅរក ។

**គិត_គូរ.-** ត្រិះរិះ, ពិចារណា នឹកដល់ ។ បរិវារស័ព្ទ គូរ អាច គន្លាស់បានជាពាក្យ គូរដើម្បីឱ្យចិត គឺ គិតដើម្បីឱ្យធូរ ។

**គឹក_កង.-** អត្ថន័យក្នុងវចនានុក្រម គឺ : ដែលឮសូរកងរំពង, សូរ សន្ធឹកទឹង កង ។ បរិវារស័ព្ទ កង អាចគន្លាស់បានជាពាក្យ កង ស្នូររំពងអឹង គឺ គឹកស្នូររំពងអឹងកង ។

**គុក_គាក់.-** ពាក្យនេះ មានន័យប្រហាក់ប្រហែលដូចពាក្យ គគ្រុក-គគ្រាក់ ។ សូមអានពាក្យ គគ្រុក-គគ្រាក់ ។

**គំរោះ_គំរាម.-** តាមវចនានុក្រម បានសេចក្ដីថា ÷ គំរាមកំហែងឱ្យខ្លាចដោយសម្ដីអសុរោះ, ទ្រគោះឥតគួរឥតសម, បោះបោក ។ សម្ដីគំរោះ គំរាម ។ បរិវារស័ព្ទ គំរោះ អាចគន្លាស់បានជាពាក្យ គំរោះឱ្យខ្លាចដោយសម្ដីអសុរាម គឺ គំរាមឱ្យខ្លាចដោយសម្ដីអសុរោះ ។

**គំរោះ_គំរើយ.-** អត្ថន័យវចនានុក្រម គឺ = អសុរោះ, ទ្រគោះឥតគួរឥតសម, បោះបោក, កញ្ជោកបោកបាច ។ សម្ដីគំរោះ-គំរើយ គឺសម្ដីជម្លើយព្រៃផ្សៃ ។ បរិវារស័ព្ទ គំរើយ អាច

គន្លាស់បានជាពាក្យ គំរើយព្រៃផ្សៃយ៉ាងជម្លោះ គឺ គំរោះព្រៃ ផ្សៃយ៉ាងជម្លើយ ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ គំរោះ-គំរើលវិញ ។ បើដូច្នេះ យើងអាចប្តូរវគ្គថា គំរោះព្រៃផ្សៃ យ៉ាងគំព្រើល ។

**គំហិក_គំហាក.-** អត្ថន័យក្នុងវចនានុក្រមគឺ ÷ ស្រែកសង្រ្កងដាក់ ។ បរិវារស័ព្ទ គំហិក អាចគន្លាស់បានជាពាក្យ គំហិកអសុរោះ ដោយសម្តីប៉ះទង្គិច គឺ គំហាកអសុរោះដោយប៉ះទង្គិច ។ តាម អក្ខរាវិរុទ្ធ ពាក្យ គំហិកនិងទង្គិចខុសសំឡេងគ្នាស្រឡះ ។ សូម មេត្តាយោងតាមសម្លេងគ្រាមភាសាវិញ គឺសម្លេងអ្នកស្រុក ។

**ក្តី_ក្តា.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ អ្នកផងដែលមាន សភាពមិនស្មើ គេឯង ។ បរិវារស័ព្ទ ក្តី អាចគន្លាស់បានជា ពាក្យ ក្តីអលជ្ជា គឺ ក្តាអលជ្ជី ពោលគឺ អ្នកស្និទ្ធស្នាលគ្នា ដូចមិត្ត ភ័ក្តិ ។

**ក្តេរ_ក្តាន់ ឬ ក្តាន់_ក្តេរ.-** អត្ថន័យក្នុងវចនានុក្រម គឺ ÷ រ៉ះរេ គិតលែ លកមើល ។ គិតក្តាន់ ក្តេរ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ក្តាន់ អាចគន្លាស់បានជាពាក្យ ក្តានិរះគិតកុំបីមាន

អកមានភេរ គឺ ត្មេរិះគិតកុំបីមានអកមានភាន់ ពោលគឺ កុំបីមានភាន់ច្រឡំ ។

**គ្រជិប_គ្រជីវ.-** ជ្រួញក្រពិត, ក្រញីវក្រញូវ ។ បរិវារស័ព្ទ គ្រជីវ អាចគន្លាស់បានជាពាក្យ គ្រជីវជ្រួញក្រញូវក្រញិប គឺ គ្រជិបជ្រួញក្រញូវក្រញីវ ពោលគឺ ជ្រួញក្រពិតខ្ញីខ្ញក់ ។

**គ្រជិប_គ្រជួច.-** អត្ថន័យក្នុងវចនានុក្រម គឺ ÷ គ្រជិបច្រើនអន្លើ ។ ស្នាមគ្រជិប គ្រជួច ។ បរិវារស័ព្ទ គ្រជួច អាចគន្លាស់បានជាពាក្យ គ្រជួចដូចមាត់ជាលភ្អែកគ្រិប គឺ គ្រជិបដូចមាត់ជាលភ្អែកគ្រួច ។

**គ្រញ៉ើច_គ្រញ៉ើ ឬ គ្រញេច_គ្រញើ.-** អត្ថន័យក្នុងវចនានុក្រម គឺ : ញេចញី, សង្កត់សង្កិន ។ បរិវារស័ព្ទ គ្រញី អាចគន្លាស់បានជាពាក្យ គ្រញីសង្កត់សង្កិនដោយញីញេច គឺ គ្រញេចសង្កត់សង្កិនដោយញេចញី ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ គ្រ-ញេច គ្រញី ។

**គ្រមិង_គ្រមាំង.-** ពាក្យនេះ មានន័យនិងលំនាំប្រហាក់ ប្រហែលគ្នានឹងពាក្យ គម្រិង គម្រាំង ។ ធំគ្រមិង គ្រមាំង ។ បរិវារស័ព្ទ

គ្រមិង អាចគន្លាស់ជាពាក្យ គ្រមិងធំគម្រលដូចសត្វខ្លាំង គឺ គ្រមាំងធំគម្រលដូចសត្វខ្លឹង ។

**គ្រើស_គ្រវាស.-** គឺ វាត់ដៃវាត់ជើងយ៉ាងខ្លាំង, គ្រវាត់គ្រវែងដោយវាសវាត់ឥតសណ្ដាប់ធ្នាប់ ។ បរិវារស័ព្ទ គ្រើស អាចគន្លាស់បានជាពាក្យ គ្រើសគ្រវាសវាត់ពីសពាស គឺ គ្រវាស វាសវាត់ពាសពីស ពោលគឺ គ្រើស គ្រវាស ពីសពាស បាចសាច ។

**គ្រឹក_គ្រាក់.-** សូមមើលពាក្យ គគ្រឹក គគ្រាក់ ។

**គ្រុក_គ្រាក.-** សូមលើពាក្យ គគ្រុក គគ្រាក់ ។

**គ្រឿង_គ្រូវ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ វត្ថុច្រើនមុខផ្សំគ្នាជាពួកមួយ ។ បរិវារស័ព្ទ គ្រូវ អាចគន្លាស់បានជាពាក្យ គ្រូវគម្រឿង គឺ គ្រឿងគម្រូវ ពោលគឺ គ្រឿងសម្រាប់ផ្សំឱ្យបានជាមួយពួក ។

**គ្រាំ_គ្រា.-** ដែលចាស់ណាស់, ទ្រេមទ្រោម, ទ្រុឌ ទ្រោម ។ បរិវារស័ព្ទ គ្រា អាចគន្លាស់បានជាពាក្យ គ្រាដោយចាស់ជរាំ គឺ គ្រាំដោយចាស់ជរា ។

∴

# ឃ

**ឃោរ_ឃៅ**.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ខ្លាំងក្រៃ, ពន្លឹកគួរខ្លាច, ហៅហ៊ាន, មោះមុត ។ កាចខ្លាំង ឥតមានមេត្តាប្រណី ។ ចិត្តឃោរឃៅ, ចោរឃោរឃៅ ។ បរិវារស័ព្ទ ឃៅ អាចគន្លាស់បានជាពាក្យ ឃៅដោយចិត្តអាស្រូ គឺ ឃោរដោយចិត្តអាស្រូវ ។

**ឃ្លាត_ឃ្លា**.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ឃ្លាតដាច់ស្រឡះ ឃ្លាតឆ្ងាយ, ដាច់សង្វែង ។ បរិវារស័ព្ទ ឃ្លា អាចគន្លាស់បានជាពាក្យ ឃ្លាស់ បានជាពាក្យ ឃ្លាត ដាច់ស្រឡះពីគ្នា គឺ ឃ្លាតដាច់ស្រឡះពីគ្នា ។

**ឃ្លាត-ឃ្លាង.**- តាមវចនានុក្រម បានសេចក្តីថា ÷ ឃ្លាតបែកចេញដូចគេពង្វាង ។ សូមមើលពាក្យឃ្លាងក្នុងពាក្យ ស៊យ ។ បរិវារស័ព្ទ ឃ្លាង អាចគន្លាស់បានជាពាក្យ ឃ្លាង បែកចេញដូចគេពង្វាត គឺ ឃ្លាតបែកចេញដូចគេពង្វាង ។ ពាក្យនេះច្រើនប្រើក្នុងពាក្យកាព្យ ។

**ឃ្លាត-ឃ្លៃ.**- តាមវចនានុក្រម ពាក្យនេះមានន័យថា÷ នឿយ, ល្ហិតល្ហៃ ល្ងីងល្ងើយ, បែកឃ្លាតចេញដាច់សង្វែងឥតសង្ឃឹមថា នឹងបានជួប ឬបានត្រឡប់មកឃើញវិញ ។ល។ ពាក្យ ឃ្លាតឃ្លៃនេះ គេច្រើនប្រើតែក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ឃ្លៃ អាចគន្លាស់បានជាពាក្យ ឃ្លៃចេញដាច់សង្វែងដោយគ្មានល្ហិតល្ហៀត គឺឃ្លាតចេញដាច់សង្វែងដោយគ្មានល្ហិតល្ហៃ ។ ពោលគឺ គ្មានអាល័យ ។

**ល្បៀង-ឃ្លាត.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ល្បៀងឃ្លាតចេញ, ងាកបែរចេញ ។ បរិវារស័ព្ទ ឃ្លៀង អាចគន្លាស់បានជាពាក្យឃ្លៀងងាកបែរចេញដោយចិត្តល្អៀត គឺឃ្លាតងាកបែរចេញដោយចិត្តល្បៀង ។

ឃ្លេង_ឃ្លោង.- ផ្សៀងចុះផ្សៀងឡើងច្រើនដង ។ ទូកត្រូវរលកឃ្លេងឃ្លោង ។ បរិវារស័ព្ទ ឃ្លេង អាចគន្លាស់បានជាពាក្យ ឃ្លេងនាំឱ្យវិលមុខវង់វេង គឺ ឃ្លោងនាំឱ្យវិលមុខវង្វេង ពោលគឺ វិលមុខធេងធោងវង្វេងស្មារតី ។

*

* *

# ង

**ងងឹត_ងងល់**.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ងងឹតព-ពើមដោយពុំមានពន្លឺសោះ ។ បរិវារស័ព្ទ ងងល់ អាចគន្លាស់បានជាពាក្យ ងងល់មើលមិនយិត គឺ ងងឹតមើលមិនយល់ ។

**ងងិះ_ងងូស**.- ពួច្ឆូរដោយកម្ហិលជាពាក្យ ងងិះងងូស គឺ ថ្ងូរដោយមានចិត្តរឹងរូស គគ្រិសគគ្រូស ។ បរិវារស័ព្ទ ងងិះ អាចគន្លាស់បានជាពាក្យ ងងិះរឹងរូសដោយរអ៊ូ គគ្រិសគគ្រូស គឺ ងងូសរឹងរូសដោយរំអ៊ូគគ្រូសគគ្រិស ពោលគឺ ងងិះងងូសមិនចង់ធ្វើតាមដោយរំអ៊ូលាន់មាត់ ថានេះ ថានោះ ។

**ងរ_ងក់**.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ សម្តែងអាការមាយា ។ ងរចុះងរឡើង ដើម្បីឱ្យគេថ្នមទើបសុខចិត្តវិញ ។ ក្មេងងរងក់, ស្រីងរងក់ ។ បរិវារស័ព្ទ ងក់ អាចគន្លាស់បានជាពាក្យង៉ក់មួយសំប៊ រ គឺ ងរមួយសំបក់ ។

**ងប់_ងុល ឬ ងុល_ងប់**.- តាមវចនានុក្រម បានសេចក្តីថា ÷ មុខរឹងជ្រប់ងោក, មុខជជ្រុលមិនងើប ។ បរិវារស័ព្ទ ងុល អាចគន្លាស់បានជាពាក្យ ងុលមុខយ៉ាងកំពុប គឺ ងប់មុខយ៉ាងកំពុល ។

**ងាក_ងែរ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បែរងាកបែរចេញ ។ ងាកងែរចិត្តគំនិត គឺ ងាកប្រែចិត្តគំនិត ដូច្នេះ បរិវារស័ព្ទ ងែរ អាចគន្លាស់បានជាពាក្យ ងែរ ប្រែចិត្តគំនាក គឺ ងាកប្រែចិត្តគំនិត ។

**ង៉ាក_ង៉ើក**.- ដែលបះចុះបះឡើង, ដែលបះប៉ាកប៉ើក ។ រទេះគោបររលាក់ង៉ាកង៉ើក ។ល។ បរិវារស័ព្ទ ង៉ាក អាចគន្លាស់បានជាពាក្យ ង៉ាកដោយរឡើក គឺ រង៉ើកដោយរលាក់ ។

**ងឺ_ងើ.**- សូមមើលពាក្យ រងឹរងើ ។ ពាក្យនេះ អ្នកខ្លះនិយាយថា÷ ងេងើ វិញ ឬ ងងឹងងើ, ពភ្លឹពភ្លើ ឬ ល្ងឹល្ងើ ។

**ងឿក_ង៉ើ.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ងឿកយំង៉ើៗ, យំរម៉ៃ, យំរហែៗ ។ ងឿកក្តិចក្តក់ ។ បរិវារស័ព្ទ ង៉ើ អាចគន្លាស់បានជាពាក្យ ង៉ើយំរហឿកៗ គឺ ងឿកយំរហែៗឬយំរម៉ៃ ។

**ងេក_ងោក.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលគ្រលែងយោលយោគ ។ ដំណើរងេកងោក ។ បរិវារស័ព្ទ ងេក អាចគន្លាស់បានជាពាក្យ ងេកដូចងងុយដូក គឺ ងោកដូចងងុយដេក ។

**ងេង_ងោង.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលច្រើនវង្វេងច្រើនភ័ន្តស្មារតី ។ បរិវារស័ព្ទ ងេង អាចគន្លាស់បានជាពាក្យ ងេងដោយស្មារតីវង់វោង គឺ ងោងដោយស្មារតីវង្វេង ។

**ងោក_ងល់.**- ជនងោកងល់ គឺ ជនងប់មុខជាប់ដៃនឹងអំពើណាមួយ ឬល្បែងណាមួយ ។ល ។ បរិវារស័ព្ទ ងល់ អាចគន្លាស់បានជា

ពាក្យ ងល់ជ្រប់ជ្រោកគឺ ងោកជ្រប់ជ្រុល ពោលគឺ ងោកងប់-

មុខជ្រប់ជ្រុលពេក ។

**ងោក_ងុយ.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ជ្រប់ងោក

ដោយងងុយ ។ លោកតាលោកអស់កម្លាំងងោកងុយណាស់

។ល។ បរិវារស័ព្ទ ងុយ អាចគន្លាស់បានជាពាក្យ ងុយទាំង

អង្គោក គឺ ងោកទាំងអង្គុយ ពោលគឺ ងងុយអស់កម្លាំងណាស់ ។

❀

❀ ❀

# ច

ចង្រ្កឹង_ចង្រ្កាង.- តាមវចនានុក្រមបានសេចក្តីថា ÷ ដែលធំស្កឹងឥត សម , ដេកផ្ងារពោះ បោះដៃ បោះជើងស្រទាង ។ ដេកដួលចង្រ្កឹងចង្រ្កាង, ដេកចង្រ្កឹងចង្រ្កាងផ្ងារពោះធំកំពឹង ។ បរិ-វារស័ព្ទ ចង្រ្កឹង អាចគន្លាស់បានជាពាក្យ ចង្រ្កឹងធំស្កាង គឺចង្រ្កាងធំស្កឹង ពោលគឺ ចង្រ្កឹងចង្រ្កាងផ្ងារពោះធំកំពឹង ។

ចង្អៀត_ចង្អល់.- គឺចង្អៀតពេកទាំងផ្លូវចិត្ត និងទាំងទីលំនៅ ។ បរិវារស័ព្ទ ចង្អល់ អាចគន្លាស់បានជាពាក្យ ចង្អល់តប់ប្រមៀត គឺ ចង្អៀតតប់ប្រមល់ ។

ចចាក_ចចុច.- តាមវចនានុក្រម បានសេចក្ដីថា ÷ និយាយចុចនាយ ចុចអាយរឿយ ៗ ដើម្បីឱ្យគេយល់ស្របតាម ។ ចាំទៅនិយាយចចាកចចុច លមើលក្រែងលកើតការ ។ បរិវារស័ព្ទ ចចាក អាចគន្លាស់បានជាពាក្យ ចចាកសម្ដីគ្នាដោយរាក់តូច គឺចចុចសម្ដីគ្នាដោយរាក់ទាក់ ។

ចចិច_ចចុក.- តាមវចនានុក្រម បានសេចក្ដីថា ÷ អែបអបបញ្ចូលចិត្ត ។ មនុស្សចចិកចចុក គឺ មនុស្សដែលចេះប្រចុបបញ្ចូលចិត្ត តម្រូវចិត្តគេ ។ បរិវារស័ព្ទ ចចិក អាចគន្លាស់បានជាពាក្យ ចចិកអែបអបបញ្ចូលចុក គឺ ចចុកអែបអបបញ្ចូលចិត្ត ។

ចច្រេក_ចច្រក់.- ដើរជជ្រកមមកគ្រប់ច្រកល្ហកដោយមិនមានប្រកាន់ដំណេក ដើរចច្រេកចច្រក់ គឺ ដើរជជ្រកមមក ។ បរិវារស័ព្ទ ចច្រេក អាចគន្លាស់បានជាពាក្យ ចច្រេកគ្រប់ច្រកល្ហក ដោយមិនមានប្រកាន់ដំណេក គឺ ចច្រក់គ្រប់ច្រកល្ហក ដោយមិនមានប្រកាន់ដំណេក។

ចច្រេស_ចច្រាស.- តាមវចនានុក្រម បានសេចក្ដីថា ÷ ស្ទុះស្ទារទៅមក, រត់ច្រាសចុះច្រាសឡើង, ឆ្លេឆ្លា ។ មេមាន់រត់ចច្រេស-

ចម្រាស ។ល។ បរិវារស័ព្ទ ចម្រាស អាចគន្លាស់បានជាពាក្យ ចម្រាសរត់ឆ្វេលឆ្លាផ្លាស់ផ្តេស គឺ ចម្រេសរត់ឆ្វេលឆ្លាផ្តេសផ្លាស ។

**ចន្លោះ_ចន្លាត.**- តាមវចនានុក្រម បានសេចក្តីថា ÷ ទីឆ្លង, ទីជាកណ្តាលនៃប៉ែកទាំងពីរ ។ ចន្លោះចន្លាត របងផ្ទះ, ចន្លោះចន្លាតជញ្ជាំង ។ល។ បរិវារស័ព្ទ ចន្លាត អាចគន្លាស់បានជាពាក្យ ចន្លាតទីកណ្តាលដែលឃ្លាស់ គឺ ចន្លោះទីកណ្តាលដែលឃ្លាត ពោលគឺ ចន្លោះ ទំនេរ រវាងប៉ែកទាំងសងខាង ។

**ចម្គី_ចម្គត.**- មនុស្ស សម្តីចម្គួត គឺមនុស្សឆ្កួត លលា (លេលា) ពិតប្រាកដ ។ បរិវារស័ព្ទ ចម្គី អាចគន្លាស់បានជាពាក្យ ចម្គីពេញទួត គឺ ចម្គួតពេញទី ពោលគឺ ឆ្កួតស៊ប់មែនទែន ។

**ចម្អឹង_ចម្អែង.**- តាមវចនានុក្រម បានសេចក្តីថា ÷ ដែលច្រើនតែឆ្អឹង ។ ម្ហូបចម្អឹងចម្អែង គឺម្ហូបក្រៀមក្រោះ ។ល។ បរិវារស័ព្ទ ចម្អែង នេះ ជាពាក្យនិយាយក្លាយរត់មាត់ ពីពាក្យឆ្អឹងឆ្អែង សូមមើលអត្ថន័យ ពាក្យ ឆ្អឹងឆ្អែង ។

**ចម្រុង_ចម្រើន.**- តាមវចនានុក្រម បានសេចក្តីថា ÷ គឺជួយទំនុកបំរុង

ផ្ដួងផ្ដើមឱ្យបានចម្រើនកើតឡើង ។ បរិវារស័ព្ទ ចម្រុង អាចគន្លាស់បានជាពាក្យ ចម្រុងដោយមានការជួយទំនុកបម្រើន គឺចម្រើនដោយមានការជួយទំនុកបំរុង ។

ចម្រូង_ចម្រាស.- តាមវចនានុក្រម បានសេចក្ដីថា ÷ ពាក្យស្លែង ឬបង្កើតឱ្យមានជាសត្រូវ ។ ពាក្យ ចម្រូវចម្រាស, ការចម្រូងចម្រាស ។ល។ បរិវារស័ព្ទ ចម្រាស អាចគន្លាស់បានជាពាក្យចម្រាស ដោយបានប្រព្រឹត្តអំពើអាមួង គឺ ចម្រូងដោយបានប្រព្រឹត្តអំពើអាម៉ាស ពោលគឺ អំពើអាម៉ាស់មុខ គឺ អំពើអាស្រូវ ។

ចាន_ក្បាន.- សមាសពាក្យនេះ មានន័យចំហទាំងពីរ ។ តាមវចនានុក្រមខ្មែរ ពាក្យ ក្បាន មានន័យថា ÷ ប្រដាប់សម្រាប់ទ្រចាន មានសណ្ឋានដូចក្បាក់ តែ រាក់កំផេល ឥតកំពែងគ្មានឡើងកណ្ដាប់ដូចក្បាក់ទេ ។ ពាក្យនេះ កាលខ្ញុំបានទៅទស្សនាប្រទេសថៃ នៅខេត្តនគររាជសិមា (កូរាត) ពលរដ្ឋខ្មែរ សៀម នៅស្រុកនោះ នៅប្រើពាក្យក្បានតែមួយម៉ាត់នេះនៅឡើយ ដើម្បីហៅឈ្មោះចានមួយប្រភេទ ដូចបានអធិប្បាយខាងលើ ។ ដូច្នេះ បើយើងយកពាក្យ ក្បាន មក

ធ្វើជា បរិវារស័ព្ទ វិញ យើងអាចគន្លាស់ពាក្យនេះបានជាវគ្គមួយ ថា ÷ ក្បានគ្នាតែនឹងចែ ពោលគឺ ក្បែរគ្នាតែនឹងចាន ។ ពាក្យនេះ ប្រហែលជានៅសម័យបុរាណ អស់លោកតាចាស់ទុំ បានបង្កើត ដើម្បីដោះស្រាយឱ្យបានឆាប់រហ័ស នូវសំណួរកូនក្មេង ដែលជាកូនចៅរបស់គាត់នោះ ដែលតែងសួរដេញដោលជាញឹកញយ ដោយសេចក្ដីងឿងឆ្ងល់ ។ ល ។ អាស្រ័យហេតុនេះហើយបានជាវគ្គ ''ក្បែរគ្នាតែនឹងចាន'' នេះមានសភាពដូចជាចម្លើយដោះសារឱ្យផុតមួយគ្រា ១ នូវសំណួរក្មេង ។ ដូចជាពាក្យក្បាក់នោះទៀត ដែលជាកូនជើងពានទំនាប់ ច្រើនធ្វើអំពីប្រាក់ គឺជាពាក្យមួយ មកពីពាក្យគន្លាស់ ''ក្បាក់ប្រាន បានសេចក្ដីថា ÷ ក្បានប្រាក់ '' ។

**ចា_ចែង ឬ ចែង_ចា.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ថ្លាថ្លែង សម្ដែង, ពោលពេញសម្លេងខ្លាំង ១ ច្បាស់លាស់ ។ ពាក្យនេះ គេច្រើនប្រើតែក្នុងពាក្យ និងពំនោលល្ខោន ឬ ពំនោល រឿងរាមកេរ្តិ៍ ។ បរិវារស័ព្ទ ចា អាចគន្លាស់បានជាពាក្យ ចាជាអក្ខារាវែង គឺ ចែងជាអក្ខារា ។

**ចារ_ចែង**.- តាមវចនានុក្រម បានសេចក្ដីថា ÷ និយាយថ្លែងសេចក្ដី ថ្លែងការណ៍ក្បោះក្បាយ ដោយពង្រីកសេចក្ដី ឱ្យទូលំទូលាយ ងាយស្ដាប់ ងាយយល់ ។ ខ្ញុំសូមចារចែងថ្លែងពីធមិ ។ល ។ បរិវារស័ព្ទ ចារ អាចគន្លាស់បានជាពាក្យ ចារដោយនិយាយ ថ្នាក់ែង គឺ ចែងដោយនិយាយថ្លែងការណ៍ ។

**ចិន_ព្រិន**.- សមាសពាក្យនេះ មានពាក្យ ចិន និង បរិវារស័ព្ទ ព្រិន ។ ចិន គឺ ជាជនជាតិមួយ ដែលខ្មែរយើងច្រើនសង្កេតឃើញតាំងពីសម័យបុរាណមកថា ÷ ជាជនជាតិមួយប្រភេទ ចេះសន្សំរកស៊ី មានបានតាំងពីក្រ រហូតបានធ្វើជាអ្នកមាន, ជាសេដ្ឋី គហបតី ។ ដូច្នេះពាក្យ ចិនព្រិននេះ ដែលខ្មែរយើង និយម និយាយហៅជនជាតិចិន ប្រហែលជាខ្មែរយើងចង់ប្រដូចពាក្យ ចិនមួយម៉ាត់នេះ ទៅនឹងពាក្យបាលីចិន (អានថា ÷ ចិន-ណាក់) បានសេចក្ដីថា ÷ សន្សំមានបាន ។ អាស្រ័យហេតុនេះ បរិវារស័ព្ទ ព្រិន អាចគន្លាស់បានជាពាក្យ ព្រិននិងចាក់ គឺ ប្រាក់និងចិន ពោលគឺពាក្យ ប្រាក់ និង ចិន នេះ មានលំនាំដូចពាក្យចាស់បុរាណលោកតែងនិយាយថា ÷ មនុស្សនិងប្រាក់, យ័ក្សនិងសាច់ ឬអាចារ្យនិងតែ, ផ្លែនិងអាមចី ។

**ច្រៀម-ជាំ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលញីកញាប់សាំញាំដដែល១ ជោកជាំ, នាំបណ្ដាលឱ្យធុញទ្រាន់ចិត្ត ។ ខ្ញុំធ្លាប់ទទួលទានចំណីហ្នឹងជោកជាំហើយ ។ បរិវារស័ព្ទ ជាំ អាចគន្លាស់បានជាពាក្យ ជាំដោយចិត្តធុញទ្រៀម គឺ ច្រៀម ដោយចិត្តធុញទ្រាន់ ។

**ចេច-ចូច.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលប៉ុនខាងនិយាយដើមគេ, ដែលប៉ុនខាងពោលពាក្យញុះញង់ ដោយនាំពាក្យសម្ដីទៅមក ។ល។ បរិវារស័ព្ទ ចូច អាចគន្លាស់បានជាពាក្យ ចូច ញុះញង់ ពប្លូចពប្លេក គឺ ចេចញុះញង់ពប្លេកពប្លូច ។ អ្នកខ្លះនិយាយថា ចេកចូចវិញ ។

**ចៃ-ចង់.-** តាមវចនានុក្រម បានសេចក្ដីថា ÷ និយាយច្រំដែល លួងលោម លួងឱ្យព្រម, ឱ្យដោយតាម ដោយផ្លូវស្នេហា ។ បរិវារស័ព្ទ ចៃ អាចគន្លាស់បានជាពាក្យ ចៃលួងឱ្យព្រមដោយតាម ដោយផ្លូវស្នង់ គឺ ចង់លួងឱ្យព្រម ដោយតាម ដោយផ្លូវស្នេហ៍ ។

**ចៃ-ចូវ.-** និយាយស្នើរការណ៍ ឬ ស្នង់ការណ៍ ។ សូមនិយាយចៃចូវឪពុកម្ដាយ ដើម្បីរៀបចំស្ដីដណ្ដឹងកូនស្រី ។ល។ បរិវារស័ព្ទ

ចូវ អាចគន្លាស់បានជាពាក្យ ចូវ ដើម្បីបើកផ្លែ គឺ ចែដើម្បីបើកផ្លូវ ពោលគឺ ចែចូវដើម្បីបើផ្លូវស្តង់ស្ថានការណ៏ ។

**ចែក_ចាយ.**- ពាក្យនេះបានសេចក្តីថា ÷ ចែកឱ្យចាយ ។ ឧទាហរណ៍ : ចែកចាយទ្រព្យសម្បត្តិ ។ល។ បរិវារស័ព្ទ ចាយ អាចគន្លាស់បានជាពាក្យ ចាយ ជាចំណែក គឺ ចែកជាចំណាយ ។

**ចែង_ចាំង.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បញ្ចេញពន្លឺព្រាក១ ។ល។ ពាក្យនេះច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ចែង អាចគន្លាស់បានជាពាក្យ ចែងពន្លឺរស្មីគ្រប់ទឹកគ្លាំង គឺ ចាំងពន្លឺរស្មី គ្រប់ទឹកន្លែង ពោលគឺ ព្រះសូរិយាចាំង ពន្លឺរស្មីគ្រប់ទឹកន្លែង គឺ ព្រះសុរិយាបានរះហើយ ។

**ចំណាប់_ចំណួន.**- ឆើត , ផ្តាច់ , ណាស់ ។ ជាងនេះធ្វើការចំណាប់ចំណួនណាស់ ។ បរិវារស័ព្ទ ចំណួន អាចគន្លាស់បានជាពាក្យ ចំណួនដោយមាំម៉ាប់ គឺ ចំណាប់ដោយមាំមួន ។

**ចំណី_ចំណុក.**- តាមវចនានុក្រម ពាក្យនេះ មានសេចក្តីថា ÷ ចំណី

សម្រាប់ស៊ីចុក មានច្រើនគ្រប់មុខ នេះខ្លះ នោះខ្លះ ។ បរិវារ-ស័ព្ទ ចំណុក អាចគន្លាស់បានជាពាក្យ ចំណុកច្រើនគ្រប់មុំ គឺ ចំណីច្រើនគ្រប់មុខ ។

**ចំណែ_ចំណាំ.-** តាមវចនានុក្រម បានសេចក្តីថា ÷ ដំណើរដែលចាំបានដោយហួរហែ ។ បរិវារស័ព្ទ ចំណែ អាចគន្លាស់បានជាពាក្យ ចំណែបានដោយហួរហាំ គឺ ចំណាំបានដោយហួរហែរ ពោលគឺ ចំណាំបានយ៉ាងពូកែ ។

**ចំពិត_ចំពូង.-** តាមវចនានុក្រម បានសេចក្តីថា ÷ ចំពិតហើយចំពិតទៀតជាច្រើនត្រលប់ ។ល។ ដួលចំពិតចំពួង គឺ ដួលជ្រហិតជ្រហមដូចជាដាំដួង ។ល។ បរិវារស័ព្ទ ចំពូង អាចគន្លាស់បានជាពាក្យ ចំពូងដាំជិត គឺ ចំពិតដាំដួង ពោលគឺ ដួលដាំពិតដាំពូង ។

**ចំពិត_ចំទួយ.-** តាមវចនានុក្រម បានសេចក្តីថា ÷ ពាក្យនេះ មានន័យប្រហាក់ប្រហែលនឹងពាក្យ ចំពិតចំពូង ចំពិតចំទួយដេកពុំឃើញជួយធ្វើការអ្វី ពោលគឺ ដេកលិចកេ្តីខ្មាស់ផង ក៏ពុំមានចាំអារម្មណ៍ឡើយ ។ បរិវារស័ព្ទ ចំទួយ អាចគន្លាស់បានជាពាក្យ

ចំទូយក្តិត ដេកលិចកណ្តិត ពោលគឺ ចំតិតដេកលិច (ក...) ។

**ចំទាស់_ចំទែង.-** ធ្វើឱ្យទាស់ដំណើរ, ឱ្យទាស់ការ ។ កុំមកចំទាស់ចំទែងកិច្ចការរបស់គេ ។ បរិវារស័ព្ទ ចំទែង អាចគន្លាស់បានជាពាក្យ ចំទែងឱ្យមានការខ្វាស់ គឺ ចំទាស់ឱ្យមានការខ្វែង អ្នកនិយាយជំទាស់ជំទែង ។

**ចំទើត_ចំទួយ.-** តាមវចនានុក្រម បានសេចក្តីថា ÷ ថ្ពមលើកខ្ពស់ដូចគេស្ទួយ ។ ចំទើតចំទួយកូនទាល់តែវាបានចិត្តឡើងចាងខូចអស់ ។ល។ បរិវារស័ព្ទ ចំទួយ អាចគន្លាស់បានជាពាក្យ ចំទួយថ្ពមដូចគេស្ទើត ពោលគឺ ចំទើតថ្ពមដូចគេស្ទួយ ។

**ចំទើត_ចំទើង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដើរ ឬឈរដោយចុងជើង ។ ឈរចំទើតចំទើង ។ បរិវារស័ព្ទ ចំទើង អាចគន្លាស់បានជាពាក្យ ចំទើងឈរដោយចុងជើត គឺ ចំទើតឈរដោយចុងជើង ។ អ្នកខ្លះនិយាយជាពាក្យ ជុំទើតជំទើងទៅវិញ ។

**ចំទើង_ចំទែង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យទើសទែង ។ ក្មេងនេះមកចំទើសចំទែងរកជាងធ្វើការពុំកើត ។

បរិវារស័ព្ទ ចំទែង អាចគន្លាស់បានជាពាក្យ ចំទែង ប្រែងចំ យើស គឺ ចំទើសប្រែងចំខែង ។ អ្នកខ្លះនិយាយជាពាក្យ ជំ-ទើសជំទែងទៅវិញ ។

**ចំប៊ី_ចំពើប.-** ជនចំប៊ីចំពើប គឺ ជនសម័យថ្មី , ជនទើបនឹងប្រកប ការងារអ្វីមួយថ្មី ។ល។ ជនចំប៊ីចំពើប ទើបនឹងចូលធ្វើការថ្មី គឺ ជនជំនាន់ថ្មី ។ បរិវារស័ព្ទ ចំប៊ី អាចគន្លាស់បានជាពាក្យ ចំប៊ី ធ្មើប គឺ ចំពើបថ្មី ពោលគឺ ជនជំនាន់ថ្មី ។

**ចំប៊ិច_ចំប៊ី.-** តូចតាច , ខ្សត់ខ្សោយ ជនចំប៊ិចចំប៊ី ។ល។ បរិវារ-ស័ព្ទ ចំប៊ី អាចគន្លាស់បានជាពាក្យ ចំប៊ីមែនតែពុំដែលអិច ពោល គឺ ចំប៊ិចមែនតែពុំដែលអី ។

**ចំពាក់_ចំពិន.-** តាមវចនានុក្រមពាក្យនេះមានន័យថា ÷ ទាក់ទាម, ទាក់ទិន ។ ចំពាក់ប្រាក់គេ, ចំពាក់ចិត្ត ។ល។ បរិវារស័ព្ទ ចំពិន អាចគន្លាស់បានជាពាក្យ ចំពិនជាប់ទិនទាក់ គឺ ចំពាក់ជាប់ ទាក់ទិន ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ជំពាក់ជំពិន ។ ម្យ៉ាង វិញទៀត ចំពិន អាចគន្លាស់បានថា ÷ ចំពិនសាក់ គឺ ចំពាក់ សិន ។ ដោយនិយមតាមសម្លេងរដឹន សម័យបុរាណ ។

**ចំអាស_ចំអួង.**- តាមវចនានុក្រមពាក្យនេះមានន័យថា ÷ ជេរបញ្ចោរលើកអាស, ចំអាសតាមតែរួចពីមាត់ ឥតយោគយល់ ឥតក្រែងរអែង ។ បរិវារស័ព្ទ ចំអួង អាចគន្លាស់បានជាពាក្យ ចំអួងជេរបញ្ចោរដល់ពូជពង្សទាំងហួស គឺ ចំអាសជេរបញ្ចោរដល់ពូជពង្សទាំងហួង ។

**ចំអេស_ចំអាស.**- ជេរជាពាក្យអាសគ្រាម ។ ស្រីនេះ ជេរចំអេសចំអាសខ្លាំងណាស់ ។ បរិវារស័ព្ទ ចំអេស អាចគន្លាស់បានជាពាក្យ ចំអែសជាពាក្យអាម៉ាស់ ឆ្អេសច្រាស់ គឺ ចំអាសជាពាក្យអាម៉ាស់ច្រាស់ឆ្អេស ។

**ចំអែ_ចំអន់.**- តាមវចនានុក្រមបានសេចក្ដីថា ÷ និយាយរំដែលេងឱ្យអន់ចិត្ត ។ ឯងចំអែចំអន់លេងឱ្យអន់ចិត្ត ចូរឯងកុំខឹងអី ! បរិវារស័ព្ទ ចំអែ អាចគន្លាស់បានជាពាក្យ ចំអែរំចន់ គឺ ចំអន់រំដែ ។ ពាក្យ រំដែ ជាពាក្យខ្មែរបុរាណ តាមវចនានុក្រមខ្មែរភាគ២ ទំព័រ ១០៧៤ ពាក្យនេះ មានន័យថា និយាយចំអែចំអន់ ចំានាយ ចំាអាយ ដែពព្រៃ ចំពោះអ្នកដែលឈមមុខគ្នា ដើម្បីសើចលេងសប្បាយ ។ ពាក្យ រំដែ អាចប្រើជំនួសពាក្យ ចំអែចំអន់បានដូចគ្នា ។

**ច្បាស់_ច្បង.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលប្រាកដជាបង ។ ពាក្យនេះ គេច្រើនប្រើនៅក្នុងកាព្យ ។ ឱព្រះច្បាស់ច្បង អាសូរប្អូនផង កុំកាត់អាល័យ ។ល។ បរិវារស័ព្ទ ច្បង អាចគន្លាស់បានជាពាក្យ ច្បងប្រាកដជាបះ ពោលគឺ ច្បាស់ប្រាកដជាបង ។

**ច្បាស់_លាស់ ឬ ច្បាស់_លះ.-** ពាក្យនេះបានសេចក្ដីថា ÷ ច្បាស់ណាស់, ច្បាស់ប្រាកដ ។ សំដីច្បាស់លាស់ ។ល។ បរិវារស័ព្ទ លាស់ អាចគន្លាស់បានជាពាក្យ លាស់មិនអ៊ាក់ គឺ លាក់មិនអស់ ពោលគឺ ដូចជារឿងហេតុនិមួយៗ មានការលាក់លៀមបិទបាំង ដោយនៅសល់ហេតុភេទបន្តិចបន្តួចក្ដី កិច្ចការទាំងនោះ ពុំមានសភាពច្បាស់លាស់ឡើយ, បើសម្ដីនិយាយវិញ គេអាចសន្និដ្ឋានបានថា ÷ មានគំនិតវៀចវេ ភូតកុហក ព្រោះដំណើររឿង ដែលបានអធិប្បាយនោះ មានសភាពពុំច្បាស់លាស់ ។

**ច្បិច_ច្បើម.-** ដែលធ្វើអ្វី ឬ បរិភោគអាហារ ដោយស្ទាក់ស្ទើរ, ដោយញញើតញញើម ។ ធ្វើការច្បិចច្បើម, ស៊ីច្បិចច្បើម

។ល។ បរិវារស័ព្ទ ច្បើម អាចគន្លាស់បានជាពាក្យ ច្បើម ដូចជិនឆ្អិច ពោលគឺ ច្បិចដូចជាជិនឆ្អើម ។

**ប្រកាច_ប្រកូវ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលតាមតែបាន, ដែលធ្វើឱ្យតែរួចពីដៃ, មិនស្អាត, ខ្ជីខ្ជា, មិនត្រឹមត្រូវល្អ ។ ធ្វើការប្រកាចប្រកូវ, ម្ហូបប្រកាចប្រកូវ ។ បរិវារស័ព្ទ ប្រកូវ អាចគន្លាស់បានជាពាក្យ ប្រកូវមិនស្អាតល្អត្រឹមត្រាច់ គឺ ប្រកាចមិនស្អាតល្អត្រឹមត្រូវ ។

**ប្រងាប់_ប្រងិល**.- ដែលត្រឡប់ត្រឡិន ផ្កាប់ផ្ងារច្រើនដង ។ ដួលប្រងាប់ប្រងិល ។ល។ បរិវារស័ព្ទ ប្រងាប់ អាចគន្លាស់បានជាពាក្យ ប្រងាប់ផ្ងិល ពោលគឺ ប្រងិលផ្ងាប់ ។

**ប្រងុក_ប្រងូវ**.- ពាក្យនេះមានន័យថា ÷ អង្គុយ ឬ ឈរស្ងៀមមិនកម្រើក ។ បរិវារស័ព្ទ ប្រងុក អាចគន្លាស់បានជាពាក្យ ប្រងុកស្ងៀមដូចសត្វកូវ គឺ ប្រងូវស្ងៀមដូចសត្វកុក ។

**ប្រងេង_ប្រងាង**.- ដែលទទឹងទទែងពាសពេញ ។ ចោលឈើប្រងេងប្រងាងពេញផ្លូវ ។ល។ បរិវារស័ព្ទ ប្រងេង អាចគន្លាស់បានជាពាក្យ ប្រងេងដួលកក្រាង គឺ ប្រងាងដួលដេកគ្រេង ។

ពោលគឺ គរឈើចោលពាសពេញ ហាក់ដូចជាឈើរលំដួល គ្រេង ។ ពាក្យនេះ យើងអាចគន្លាស់បានមួយយ៉ាងទៀត : ច្រងេងទទឹងទតាង គឺ ច្រងាងទទឹងទទែង ។

ច្របូក-ច្របល់.- តាមវចនានុក្រម បានសេចក្ដីថា ÷ លាយឡំគ្នា, លាយបញ្ចូលច្រឡូកជាមួយគ្នា ។ បរិវារស័ព្ទ ច្របូក អាចគន្លាស់បានជាពាក្យ ច្របូកលាយបញ្ចូលគ្នាច្រឡំច្រឡូល គឺ ច្របល់លាយបញ្ចូលគ្នាច្រឡំច្រឡូក ។

ច្រពីស-ច្រពើស.- ពាក្យនេះមានន័យថា ÷ មិនចូលរបៀបគ្នា ។ ធ្មេញច្រពីសច្រពើស ។ បរិវារស័ព្ទ ច្រពីស អាចគន្លាស់បានជាពាក្យ ច្រពីសរបៀបគ្នាដោយច្របើស គឺ ច្រពើសរបៀបគ្នាដោយច្របីស ពោលគឺ ច្រពីសច្រពើស ដោយប្របេះៗគ្នា គឺ ប្រហាក់ប្រហែលគ្នា ។ ពាក្យនេះ អ្នកខ្លះនិយាយថា ÷ ចំពីសចំពើស វិញ ។

ច្រមិច-ច្រមក់.- ពាក្យនេះ មានន័យថា ÷ តូចតាច, នៅក្មេងណាស់, ដែលនៅតូចក្បៀប, តូចកំប៉ិច ។ កូនក្មេងច្រមិចច្រមក់ ។ បរិវារស័ព្ទ ច្រមិច អាចគន្លាស់បានជាពាក្យ ច្រមិចតូចកំប៉ក់

គឺ ច្រមក់តូចកំប៉ិច ពោលគឺ ច្រមក់តូចក្មេ្បប ។ ពាក្យនេះ អ្នកខ្លះនិយាយថា ÷ ច្រមេកច្រមក់ ឬ រមេករម៉ក ។

ច្រវេប_ច្រវែប.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលមានរង្វះធំ វៀចកំបែប ដូចរង្វះមាត់កង្កែបកូប ។ មុខមាត់ច្រវេប-ច្រវែប ។ បរិវារស័ព្ទ ច្រវេប អាចគន្លាស់បានជាពាក្យ ច្រវេបដោយបបូរមាត់ប៉ែប គឺ ច្រវែបដោយបបូរមាត់ពេប ។ អ្នកខ្លះនិយាយថា ÷ ក្រវេបក្រវែប ឬ ក្រវេកក្រវាប ។

ច្រហេញ_ច្រហាញ់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលហាមាត់ច្រវាបៗ ។ សមាសពាក្យនេះ ជាពាក្យអាស-គ្រាម សាមញ្ញគេឃើញច្រើនប្រើទៅលើស្រីដែលអង្គុយ ឬដេកពុំមានសភាពសមរម្យ ។ បរិវារស័ព្ទ ច្រហេញ អាចគន្លាស់បានជាពាក្យ ច្រហេញលិចចេញស្នាញ់ គឺ ច្រហាញ់លិចចេញស្ទេញ ។

ច្រហេញ_ច្រហាំង.- ពាក្យនេះ មានលំនាំដូចច្រហេញច្រហាញ់ដែរ បានសេចក្ដីថា ÷ ដែលប្រេះបែកច្រហខ្លាំង ។ សូមប្រឱតតាមលំនាំពាក្យ ច្រហេញច្រហាញ់ ។

ប្រឡូក-ប្រឡុំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាក់លាយបូកឡូកគ្នា គឺ ដាក់ប្រឡុំបូកឡូកគ្នា ។ បរិវារស័ព្ទ ប្រឡូក អាចគន្លាស់បានជាពាក្យ ប្រឡូកបូកឡុំ គឺ ប្រឡុំបូកឡូក ។

ប្រាស់-ប្រាល់.- ពាក្យនេះ មានន័យថា ÷ អន្ទះអន្ទែង, ស្ទុះឆាល់ចុះឆាល់ឡើង ។ មេមាន់ប្រាស់ប្រាល់រកពង ។ បរិវារស័ព្ទ ប្រាល់ អាចគន្លាស់បានជាពាក្យ ប្រាល់យ៉ាងរហ័ស គឺ ប្រាស់យ៉ាងរហាល់ ។

ប្រាស់-ប្រំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស៊ីដូចគេបញ្ចូលដោយបង្ខំ ។ ចុះប្រាស់ប្រំដល់ណាទៀត? ។ បរិវារស័ព្ទ ប្រំ អាចគន្លាស់បានជាពាក្យ ប្រំដូចគេញាត់បញ្ចូលដោយបង្ខាស់ គឺ ប្រាស់ដូចគេញាត់បញ្ចូលដោយបង្ខំ ។

ប្រេញ-ប្រុញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ច្រិមច្រុមតិញតុញ ញញើតញញើមដោយអាការមិនស៊ប់ ។ ដើរប្រេញប្រុញ ។ ល ។ បរិវារស័ព្ទ ប្រេញ អាចគន្លាស់បានជាពាក្យ

ច្រេញតិញ្ចតុញ គឺ ច្រុញតុញតិញ ពោលគឺ ច្រេញច្រុញញ-ញើតញញើម ។

**ចប្រែត-ចប្រាយ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សម្ដីស្រួយឥតទាក់, សម្ដីប្រែតៗ ។ បរិវារស័ព្ទ ចប្រាយ អាចគន្លាស់បានជាពាក្យ ចប្រាយដោយសប្បែត គឺ ចប្រែតដោយសប្បាយ ។ល។

* * *

# ឆ

**ឆើត_ឆាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អប្រពៃ, ថ្លៃថ្លា ។ ជនឆើតឆាយ គឺ ជនល្អប្រពៃដូចសេចក្ដីប្រាថ្នា ។ គេច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ឆាយ អាចគន្លាស់បានជាពាក្យ ឆាយអភិប្រើត គឺ ឆើតអភិប្រាយ ។ (អភិប្រាយ = សេចក្ដីប្រាថ្នា, បំណង, សេចក្ដីត្រូវការ) ។

**ឆែត_ឆត.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរឮដោយកណ្ដាស ឬផ្ដាសសាយ, តឹងច្រមុះ ។ ញើសសំបោរឆែតឆត ។ បរិវារស័ព្ទ ឆត អាចគន្លាស់បានជាពាក្យ ឆតដោយខ្សតខ្សែត គឺ ឆែតដោយខ្សែតខ្សត ពោលគឺ ដោយខ្សឹតខ្សត ។

ឆោម_ឆាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មានរូបស្រៀវស្រស់, ល្អប្រពៃ ។ សម្រាប់ប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ឆាយ អាចគន្លាស់បានជាពាក្យ ឆាយល្អល្បីទៅឆ្ងោម គឺ ឆោមល្អល្បីទៅឆ្ងាយ ។

ឆោម_ឆើត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានរូបរាងប្រសើរល្អដាច់គេ ។ សម្រាប់ប្រើក្នុងពាក្យកាព្យ ។ ស្រីឆោមឆើត ។ បរិវារស័ព្ទ ឆោម អាចគន្លាស់បានជាពាក្យ ឆោមល្អមានគេរោមចើត គឺ ឆើតល្អមានគេរោមចោម ពោលគឺ ល្អឆើតដាច់គេ មានអ្នកផងចោមរោមចង់បាន ។

ឆ្គាំ_ឆ្គង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មិនគប្បី, មិនសមរម្យ ។ សម្ដីឆ្គាំឆ្គង ។ បរិវារស័ព្ទ ឆ្គាំ អាចគន្លាស់បានជាពាក្យ ឆ្គាំមិនគប្បីតាមលំនង គឺ ឆ្គងមិនគប្បីតាមលំនាំ ពោលគឺ មិនគប្បីតាមទំនងច្បាប់គម្រា ។

ឆ្មើង_កន្ត្រើង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឆ្មើងហួសបែបភាព, ឆ្មើងធ្វើពើម្ដងៗ ។ល។ បរិវារស័ព្ទ កន្ត្រើង អាចគន្លាស់បានជាពាក្យ កន្ត្រើងខំដំកែត គឺ កន្ត្រែតខំតម្កើង ពោល

គឺ មានសំណាង មានបានជាមនុស្សមួយ ហើយភ្លេចកាលនៅកំសត់ជាមួយគ្នា កាលនៅកន្ទ្រែតនៅឡើយ ។

**ឆ្អើង_ឆ្អែ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឆ្អើងលេងឫកលេងខ្លួន ។ ឆ្អើងវាយតម្លៃខ្លួន ។ បរិវារស័ព្ទ ឆ្អៃ អាចគន្លាស់បានជាពាក្យ ឆ្អៃវាឫកឱ្យមានតម្លើង គឺ ឆ្អើងវាយឫកឱ្យមានតម្លៃ ។

**ឆ្លៀវ_ឆ្លាត ឬ ឆ្លៀវ_ឆ្លាស់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឆ្លាតវៃ, តែពាក្យនេះ គេច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ឆ្លៀវ អាចគន្លាស់បានជាពាក្យ ឆ្លៀវដូចបញ្ញាក្មេងនៅវ៉ាត គឺ ឆ្លាតដូចបញ្ញាក្មេងនៅវាវ ។

**ឆ្លេ_ឆ្លា**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលចេញអាការប្រញាប់ប្រញាល់ដោយស្ទុះស្ទា ។ បរិវារស័ព្ទ ឆ្លេ អាចគន្លាស់បានជាពាក្យ ឆ្លេដោយស្ទុះហា គឺ ឆ្លាដោយស្ទុះហេ ។

**ឆ្វាត់_ឆ្វែង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលខ្វាត់ខ្វែង ។ សត្វហើរឆ្វាត់ឆ្វែង ។ សូមមើលពាក្យខ្វាត់ខ្វែង ។ បរិវារស័ព្ទ ឆ្វែង អាចគន្លាស់បានជាពាក្យ ឆ្វែងដោយខ្វែងខ្វាត់ គឺ ឆ្វាត់ដោយខ្វាត់ខ្វែង ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ឆ្វៀលឆ្វាត់ វិញ ។

**ភ្លិន_ភ្លៅ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ហួត់ចត់, ពុំមែន ឆៅ ។ បរិវារស័ព្ទ ឆ្អៅ អាចគន្លាស់បានជាពាក្យ ឆ្អៅ ពុំមែន ឆិន គឺ ឆ្អិនពុំមែនឆៅ ពោលគឺ ឆ្អិនមែនទែន ។

**ភ្លឹង_ភ្លេង.-** មុននឹងវែកញែកពាក្យនេះ តាមលំនាំដូចខ្ញុំបានដោះស្រាយរួចពីមុនមកហើយ ខ្ញុំសូមអត្ថាធិប្បាយជូនជាសំណៅមួយដែលជាដើមកំណើតនៃពាក្យនេះ :

ជាបឋម ខ្ញុំសូមជូនអត្ថន័យពាក្យ **បាយ័ន** ដែលជាឈ្មោះប្រាសាទបុរាណមួយឋិតនៅចំកណ្តាលកំពែងនគរ គឺ ឈ្មោះដែលខ្មែរយើងហៅសព្វថ្ងៃនេះ ។

តាមវចនានុក្រមខ្មែរ ភាគ១ ទំព័រ៩៦៦ ដែលមានន័យស្រប តាមព្រះរាជបន្ទូលនៃសម្តេចព្រះសង្ឃរាជ ជួន-ណាត បាន សេចក្តីថា ÷

**បាយ័ន.** ន. (សំ.បា.បាយន ''ការផឹកឬចៅ'') ពាក្យនេះ ប្រហែលជាកាលពីដើមហៅថា **បាយ័ង្គ** = បល្ល័ង្ក, ព្រះទែន ។ (សំ.បយិង្ក ; បា.បល្ល័ង្ក) ក្លាយមកជាបញ្យាង្គ (ប័ញ្ញយង់) គឺ ប្រាសាទនេះ ជាទីតាំងបល្ល័ង្ក តម្កល់ព្រះពុទ្ធរូប ឬ

ទេវរូប ឬក៏ជាទីតម្កល់ព្រះទែន សម្រាប់ព្រះមហាក្សត្រិយ៍ ឬ បើពុំនោះ ជាទីតម្កល់ស្វេតច្ឆត្រ សម្រាប់រាជ្យទេដឹង? ពោល គឺ ជាទីតម្កល់គ្រឿងសក្ការបូជា ។

**ពត៌មានស្រាវជ្រាវ..** តាមឯកសារផ្សេងៗ ស្ដីអំពីប្រាសាទបាយ័ន ( បាយិង្គ) ដែលជាស្នាដៃស្រាវជ្រាវនៃអ្នកប្រាជ្ញបារាំង ផ្នែកសាលាបារាំងនៃចុងបូព៌ាប្រទេស **(E.F.E.O)** ដូចជាអាទិ ។

១. លោក សឺដេស (Cœdès) ក្នុងសៀវភៅ ''ដើម្បីយល់ច្បាស់នូវប្រាសាទអង្គរ'' (Pour Mieux Comprendre ANGKOR) ។

២. លោកប៉ារម៉ងជេ (Parmentier) និងលោកគ្លេស (Glaize) ក្នុងសៀវភៅពីរ មានចំណងជើងដូចគ្នា ''សេចក្ដីលំនាំដើម្បីស្គាល់ច្បាស់អង្គរ'' (Guide d'Angkor) ។

៣. លោកល្វីហ្វីណូ (Louis Finot) ក្នុងសៀវភៅ ''ដើម្បីកំណើតនៃអង្គរ '' (L'Origine d'Angkor) ។

៤. លោកហង់រីម៉ារសាល (Henri Marchal) ក្នុងសៀវភៅ ''សេចក្ដីលំនាំថ្មី ដើម្បីស្គាល់ច្បាស់អង្គរ'' (Nouveau Guide d'Angkor) ។

៥. លោកប័សសឺលីយេ (Boisselier) ក្នុងសៀវភៅ ''អាស៊ីផ្នែកអាគ្នេយ៍, ភាគទី ១, ប្រទេសកម្ពុជា'' (Asie de Sud-Est, Tome 1, Le Cambodge) ។

៦. លោកគ្រូលីយេ (B.P. Groslier) ក្នុងសៀវភៅ ''អង្គរ មនុស្ស និងថ្ម'' (Angkor, Homme et Pierres) ។ល។ ឃើញថា ប្រាសាទបាយ័ន (បាយ៉ង្គ) នេះ ជាវិមានមួយ ដែលអ្នកប្រាជ្ញបារាំងបានប្រដូចទៅវិមាន នៃប្រទេសគេសព្វថ្ងៃ ដែលមានឈ្មោះហៅថា ÷ ប៉ង់តេអុង (Panthéon) ពោលគឺ ជាវិមានមួយស្ថាបនាឡើងក្នុងរជ្ជកាល ព្រះបាទជ័យវរ្ម័នទី ៧ ដើម្បីទុកតម្កល់គ្រឿងសក្ការបូជាគ្រប់ប្រភេទ ព្រមទាំងតម្កល់ធាតុវរជនខ្មែរយើងទាំងអស់ ដែលបានបូជាជីវិតចំពោះមាតុប្រទេស ។

របៀបតម្កល់ធាតុនោះសោត មានជាលំដាប់តាមជាន់

ថ្នាក់ ស្របតាមកម្លាំងថ្មីដៃប្រយុទ្ធ នៃវរជននៅសម័យនោះ ពោលគឺ អ្នកបារាំង គេឃើញមាននៅសល់ស្លាមធ្មើរដែលធ្វើអំពីមាស, ប្រាក់, ស្ពាន់, ថ្ម ដែលសព្វថ្ងៃនេះបាត់បង់អស់ទៅហើយ ។

អ្នកប្រាជ្ញបារាំង គេបានសរសេរទុកជាឯកសារទៀតថា ÷ ធ្មើរមាសសម្រាប់តម្កល់កោដ្ឋមាស, ធ្មើប្រាក់សម្រាប់កោដ្ឋប្រាក់, ធ្មើរស្ពាន់និងថ្មសម្រាប់កោដ្ឋស្ពាន់និងថ្ម ។ សព្វថ្ងៃនេះ គេឃើញនៅសល់តែធ្មើរប៉ុណ្ណោះទេ ។

តាមអក្សរចារឹកជាចំណងជើងតាមធ្មើរនិមួយៗ គេឃើញជាអាទិពាក្យ ÷ ក្រុមតែងជគតរាជា (Kamrateng jagataràja) និងក្រុមតែងអញ (Kamrateng Anh) ។ (នេះជាអក្សរសំរ្កិត) ពាក្យទាំងនេះ តាមវចនានុក្រមខ្មែរ មានន័យថា ÷

**គម្តែង** = (គំម្តែង-ជើងៈដ.ឬ គំ-មៈដែង) (ក្លាយ ឃ្លាត មកពីពាក្យខ្មែរ ក្នុងសម័យបុរាណព្រេងនាយថា ក្រុមតាង >

ក្រុមតេង > ក្រុមតែង , កម្រតាញ) មានន័យថា ព្រះតេជ-ព្រះគុណ ; លោកជាអម្ចាស់ ។ លុះចំណេរកាលតៗមក ខ្មែរយើងប្រើពាក្យនេះ សំដៅសេចក្ដីថា លោកអ្នកមានបុណ្យច្រើនគួរជាទីគោរព គួរធ្វើសក្ការបូជា; លោកអ្នកមានស័ក្ដិយសខ្ពង់ខ្ពស់ ។ (សូមអានសៀវភៅលោក សឺដេស ដូចបានអធិប្បាយខាងលើ ចាប់ពីទំព័រ ៤៤ ទៅ) ។

ជគត - (ជៈគត់) ន (សំ.) សត្វលោក , មហាជន . . . ។ ពាក្យនេះ ប្រទះឃើញប្រើជាញឹកញយនៅសិលាចារឹក សម័យមហានគរ (នគរធំ, នគរវត្ត) ។

ដូច្នេះ បរិវារស័ព្ទ **ឆ្លែខ** អាចប្រឌិតបានជាវគ្គមួយគន្លាស់ថា ÷ ឆ្លែងជាគម្ពីង គឺ ឆ្លឹងជាគម្លែង ពោលគឺ ពាក្យឆ្លឹងឆ្លែងបានសេចក្ដីថា ÷ ឆ្លែងនិងឆ្លឹង ឬ ឆ្លឹងនិងអដ្ឋិ ។ គឺជាអដ្ឋិដែលយើងតម្កល់ទុកជាសក្ការបូជា ដើម្បីធ្វើបុណ្យរំលឹកគុណនិងឧទ្ទិសកុសល ។ បើឱ្យត្រូវតាមសម្លេងដើម យើងត្រូវនិយាយថាឆ្លឹងជាក្រុមតែង ។

ចំពោះពាក្យ បាយ័ន បើតាមយោបល់ខ្ញុំផ្ទាល់ យើងគួរ

ហៅនិងសរសេរជាពាក្យ បាយ័ង្គវិញទើបសមជាង ព្រោះអក្សរឡាតាំង Bayon ដែលអ្នកប្រាជ្ញបារាំងសរសេរចម្លងពីសិលាចារឹកខ្មែរយើង ដែលមានសម្លេងចំថា បាយ័ង្គ បើតាមសម្លេងបារាំងវិញ គឺសម្លេង Bayon បាយុង ពោលគឺ on = អុង ។

**ឆ្អែត_ឆ្អន់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឆ្អែតបរិបូណ៌គ្រប់គ្រាន់ ដរាបដល់ជិនឆ្អន់ លែងត្រូវការបរិភោគទៀត ។ លោកពូពិសារបាយឆ្អែតឆ្អន់ហើយឬ? ពោលគឺពិសារបាយឆ្អែតគ្រប់គ្រាន់ហើយឬ? ដូច្នេះ បរិវារស័ព្ទ ឆ្អន់ អាចដោះស្រាយបានជាពាក្យគន្លាស់មួយថា ÷ ឆ្អន់គ្រប់ក្រែត គឺ ឆ្អែតគ្រប់គ្រាន់ ។

**ឆ្អើស_ឆ្អើម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ច្បិចច្បើម, ដែលស្ទាក់ស្ទើ ។ បរិភោគ ឆ្អើសឆ្អើម ។ល។ បរិវារស័ព្ទ ឆ្អើស អាចគន្លាស់បានជាពាក្យ ឆ្អើសឆ្អើម១ គឺ ឆ្អើមឆ្អើស១ ពោលគឺ បរិភោគមិនចូល ដូចអ្នកជម្ងឺរោគ ហើមពោះឆ្អើស១ ។

# ជ

**ជំជុះ_ជំជាយ.-** រលាស់ដាក់ចោល រាត់រាយឥតសណ្ដាប់ធ្នាប់ ។ បរិវារស័ព្ទ ជជាយ អាចគន្លាស់បានជាពាក្យ ជជាយ រាត់រាយដោយរាយមុះ គឺ ជជុះរាត់រាយ ដោយរាយមាយ ។

**ជំង្អិក_ជំង្អុក.-** មិនរាបស្មើ, ដែលរូងខូងជារណ្ដៅ ។ ដីជង្អិកជង្អុក ។ល។ បរិវារស័ព្ទ ជង្អិក អាចគន្លាស់បានជាពាក្យ ជង្អិក ដោយរូងខូង ហាក់ដូចជារណ្ដៅគេជុក គឺ ជង្អុកដោយរូងខូងហាក់ដូចជារណ្ដៅគេជីក ពោលគឺ កន្ធិកកន្ធុក ។

**ជំញ្ជប់_ជំញ្ជឹង.-** រំពឹង, ត្រិះរិះរំពឹង ។ បរិវារស័ព្ទ ជញ្ជប់ អាចគន្លាស់បានជាពាក្យ ជញ្ជប់ពិចារណារកឱ្យសព្វគ្រឹង គឺ ជញ្ជឹងពិចារណារកឱ្យសព្វគ្រប់ ។

**ជន្ល_ជន្លេញ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជន្លញ។ ដោយប្រឡែងលេង, លូកល, លូកលាន់, នាយអាយ ដោយអាការប្រឡែងលេង ។ និយាយលូកលនាយអាយ ដោយពាក្យចម្លែចម្លន់, និយាយលេញលេង ។ បរិវារស័ព្ទ ជន្លេញ អាចគន្លាស់បានជាពាក្យ ជន្លេញដោយសម្តីលេងល គឺ ជន្លដោយសម្តីលលេង ។

**ជាតិ_ជៅ.**- តាមវចនានុក្រម បានសេចក្តីថា ÷ រសជាតិសំខាន់ ដែលមានប្រចាំក្នុងអាហារ ក្នុងគ្រឿងបរិភោគគ្រប់ប្រភេទ ឬក្នុងការតម្រេក ។ល។ សម្លនេះមានជាតិជៅណាស់ ។ បរិវារស័ព្ទ ជៅ នេះ អ្នកប្រាជ្ញបុរាណ ប្រហែលជាមានគំនិត ចង់ប្រដូចទៅនឹងរសជាតិដ៏សំខាន់ ពិសេសជាងគេក្នុងលោក ពោលគឺ រសជាតិឆ្ងាញ់មួយប្រភេទ ក្នុងការតម្រេក ដូច្នេះ បរិវារស័ព្ទ ជៅ នេះយើងអាចដោះស្រាយបានជាវគ្គមួយថា ÷ ជៅនៅកៀនភ្លាត គឺ ជាតិនៅកៀនភ្លៅ ពោលគឺ មានតែរសជាតិកន្លែងនេះហើយដែលមានឱជារសសំខាន់ជាងគេក្នុងលោក ។

**ជិន_ឆ្អន់**.-តាមវចនានុក្រម ពាក្យនេះមានន័យថា÷ ទើ្បយណាយជ្រេញ ចិត្ត, ធុញទ្រាន់ ។ បរិវារស័ព្ទ ឆ្អន់ អាចគន្លាស់បានជាពាក្យ ឆ្អន់ដោយធុញត្រើម គឺ ឆ្អើមដោយធុញទ្រាន់ ។ ក្នុងសមាស ពាក្យជិននិងឆ្អន់ សម្លេងបរិវារស័ព្ទ និងស័ព្ទដើមពុំដូចគ្នាទេ គឺ ពុំមានសម្លេងរត់ចុងជួន ស្របគ្នាដូចសមាសពាក្យធម្មតា ដែល ខ្ញុំបានវែកញែកជូនរួចមកហើយស្រាប់ ។ ជិនមានសម្លេងអក្សរ ជ រីឯឆ្អន់ មានសម្លេងអក្សរ ឆ ទេវិញ ។

**ជំទាវ_ជិតូក**.- តាមវចនានុក្រម ពាក្យជំទាវនេះ មានន័យដូចតទៅ នេះ ÷ បណ្តាស័ក្តិ សម្រាប់ស្ត្រីជាភរិយាសេនាបតី ដោយព្រះ ករុណាជាម្ចាស់ជីវិត ទ្រង់ប្រោសព្រះរាជទានតាំង ÷ លោកជំ-ទាវ (លោកស្រី) ។ បណ្តាស័ក្តិនេះ ទោះបីភរិយារបស់ មន្ត្រី ស័ក្តិ១០ហ៊ូពាន់ឯទៀតៗ ក្រៅពីសេនាបតីក៏ដោយ ស្រេចតែ ព្រះករុណាជាម្ចាស់ជីវិត, បើទ្រង់ព្រះមេត្តាប្រោស ព្រះរាជ ទានតាំងក៏បាន ។ ពាក្យនេះ កាលពីសម័យបុរាណ ប្រហែល ជាហៅថាំទាវ ឬចំទាវទេដឹង ? ព្រោះបានសង្កេតឃើញថា ÷

ប្រហែលជាក្លាយមកពីពាក្យសៀម សម័យបុរាណយូរអង្វែង ហើយថា ÷ ប្រះចាំទាវ (-ថាវ) ''ប្រចាំជើង'' ឬហ្សិងប្រះចាំទាវ ''ស្រីប្រចាំជើង'' គឺ ស្រីអ្នកនៅប្រចាំការ បម្រើជិតជើងនៃស្វាមី (ភរិយា) ជាពាក្យប្រែចេញមកអំពីសំ.បា.ថា ÷ បាទបរិចារិកា ?

ពាក្យ ជិតូក ដែលខ្មែរយើងប្រើជា បរិវារស័ព្ទ សម្រាប់ពាក្យ ជិទាវ នេះ គឺ ពាក្យរិះគន់មួយប្រភេទ គន្លាស់បានជាវគ្គតូចមួយថា ÷ ជិតូកដោយសារស្ពៅ គឺ ជិទាវដោយសារស្នូក ពោលគឺ បានឡើងបុណ្យស័ក្តិដោយសារស្នូក ពុំមែនដោយសារតំរេះវិជ្ជា ។ ពាក្យ ស្នូក នេះ ជាពាក្យអាសគ្រាម ដោយខ្ញុំពុំបាច់ធ្វើអត្ថាធិប្បាយជូន ។

**ជិទាស់_ជិទែង.**- សូមមើលពាក្យ ចំទាស់ចំទែង ។

**ជិទើត_ជិទើង.**- សូមមើលពាក្យ ចំទើតចំទើង ។

**ជិពាក់_ជិពិន.**- សូមមើលពាក្យ ចំពាក់ចំពិន ។

**ជិរិត_ជិរ៉ាញ់.**- តាមវចនានុក្រម ពាក្យនេះ បានសេចក្តីថា ÷ តឿនតឹងឱ្យបាន ឆាប់បង្ហំទារ ។ បរិវារស័ព្ទ ជិរ៉ាញ់ អាច គន្លាស់បាន

ជាពាក្យ ចំរាញ់តឹងទារឱ្យអស់ពីឃ្លិតគឺជិតតឹងទារឱ្យអស់ពីខ្លាញ់ ពោលគឺ ជិតចំរាញ់តឹងទារឱ្យខាងតែបាន ។

**ជំហាញ់_ជំហាញ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យះគន្លង បង់ជំទែង ។ អង្គុយជំហាញ់ ជំហាញ (សម្រាប់ប្រើជាវិសេសនៈ អង្គុយ) ។ បរិវារស័ព្ទ ជំហាញ អាចគន្លាស់បានជាពាក្យ ជំហាញយះគន្លងបង់ជំតាញ គឺ ជំហាញយះគន្លងបង់ជំទាញ ។

**ជ្រហិត_ជ្រហម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបះមុខបះក្រោយ ។ ច្រានគ្នាដួលជ្រហិតជ្រហម ។ បរិវារស័ព្ទ ជ្រហិត អាចគន្លាស់បានជាពាក្យ ជ្រហិតដួលដាំទម គឺ ជ្រហមដួលដាំតិត ពោលគឺ ដួលច្រងាប់ច្រងិល ។

**ជ្រាល_ជ្រៅ.-** ខ្មែរយើងនិយាយថា ÷ សម្តីជ្រាលជ្រៅ គឺ សម្តីជ្រៅណាស់ ហើយមានខ្លឹមសារផង ។ បរិវារស័ព្ទ ជ្រាល អាចគន្លាស់បានជាពាក្យ ជ្រាលពុំអាចជម្រៅ គឺ ជ្រៅពុំអាចជម្រាល ពោលគឺ សម្តីជ្រៅល្អ ជាដំបូងមានមួយ ពុំអាចជម្រាលចោល គឺពុំអាចបំភ្លេចចោលបានឡើយ ។

ជ្រិត_ជ្រីវ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជ្រួញគ្រជីវស្វិត ។ មនុស្សចាស់ជរា ច្រើនមានសាច់ជ្រិតជ្រីវ ។ បរិវារស័ព្ទ ជ្រិតស្វិតក្រពីវ គឺ ជ្រីវស្វិតក្រពិត ។

ជ្រីវ_ជ្រួញ.- រួញដោយផ្លត់ឬមានស្នាមផ្លត់ ។ សំពត់ជ្រីវជ្រួញ ។ បរិវារស័ព្ទ ជ្រីវ អាចគន្លាស់បានជាពាក្យ ជ្រីវជ្រួញ គឺ ជ្រួញក្រជីវ ពោលគឺ ជ្រួញខ្ទីខ្ទុក អ្នកខ្លះនិយាយពាក្យនេះថា ÷ ជ្រីវជ្រួញទៅវិញ ។

ជ្រុល_ជ្រួស.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជ្រលួសជ្រុលហួស ។ ដើរជ្រុលជ្រួស ។ បរិវារស័ព្ទ ជ្រួស អាចគន្លាស់បានជាពាក្យ ជ្រួសដើរហ៊ុល គឺ ជ្រុលដើរហួស ។

ជ្រៀត_ជ្រៃ.- ពាក្យនេះ មានន័យខុសគ្នាបន្តិចពីពាក្យ ជ្រៀតជ្រែក ព្រោះជ្រៀតជ្រែក ជាសមាសពាក្យមួយ មានពាក្យ ជ្រៀត ហើយនិងពាក្យជ្រែក ។ តាមវចនានុក្រម ពាក្យជ្រៀតជ្រៃវិញ មានន័យថា ÷ ជ្រៀតតាមកន្លែងដែលទេរ ។ បរិវារស័ព្ទ ជ្រៃ អាចគន្លាស់បានជាពាក្យ ជ្រៃតាមកន្លែងទៀត គឺ ជ្រៀតតាមកន្លែងទេរ ។

ជ្រោក_ជ្រាក.- តាមវចនានុក្រមពាក្យនេះមានន័យថា ÷ ស្គោកមិនហាប់ មិនណែន, ដែលជ្រោករយាក, ជ្រោកខ្លាំង ។ សាច់ជ្រោកជ្រាក ។ បរិវារស័ព្ទ ជ្រាក អាចគន្លាស់បានជាពាក្យ ជ្រាករយីករយោក គឺ ជ្រោករយីករយាក ។

ជ្រោម_ជ្រែង.- តាមវចនានុក្រម បានសេចក្តីថា ÷ ទំនុកបំរុងដោយជួយគាំពារ ។ ជួយជ្រោមជ្រែងគ្នាកុំឱ្យរលំ ។ បរិវារស័ព្ទ ជ្រោម អាចគន្លាស់បានជាពាក្យ ជ្រោមដោយចោមរែង គឺ ជ្រែងដោយចោមរោម ។

ជ្រៅ_ជ្រះ.- ដែលចេះដឹងច្រើន ហើយច្បាស់ប្រាកដផង ។ លោកនេះ ចេះធម៌ជ្រៅជ្រះណាស់ ។ល។ បរិវារស័ព្ទ ជ្រះ អាចគន្លាស់បានជាពាក្យ ជ្រះច្បូវ គឺ ជ្រៅច្បាស់ ពោលគឺ ចេះជ្រៅច្បាស់ប្រាកដ ។

ជ្រះ_ជ្រាំ.- បរិភោគដូចគេបង្ខំ ។ ពាក្យអសប្បុរសដែលគេស្រដីដោយកំហឹងទៅលើអ្នកតូចតាច ដូចជាកូនចៅឬខ្ញុំកំដរ ។ បរិវារស័ព្ទ ជ្រាំ អាចគន្លាស់បានជាពាក្យ ជ្រាំដូចគេបង្ខះ គឺជ្រះដូចគេបង្ខំ ។ គេច្រើននិយាយថា ច្រាស់ច្រំ ។

* * * *

# ឈ

**ឈូ_ឆរ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អ៊ូអរ ។ មានមនុស្សឈូឆរ, ដើរឈូឆរ ។ បរិវារស័ព្ទ ឆរ អាចគន្លាស់បានជាពាក្យ ឆរដោយអរអ៊ូ គឺ ឈូដោយអ៊ូអរ ឬ ឆរទៅស្រូ គឺ ឈូទៅស្រ ។

**ឈ្មុយ_ឈ្មប់.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ផ្ទៀងផ្ទាត់, ពិនិត្យពិច័យ ។ ធ្វើការឈ្មុយឈ្មប់, ជននេះឈ្មុយឈ្មប់ ហើយក្នុងកិច្ចការប្រកបការងារ ។ល។ បរិវារស័ព្ទ ឈ្មប់ អាចគន្លាស់បានជាពាក្យ ឈ្មប់នឹងការងារទល់ព្រលុយ គឺ ឈ្មុយនឹងការងារទល់ព្រលប់ ពោលគឺ សម្ដីនឹងការងារដោយពិនិត្យពិច័យ មិនថាពេលណា ជាពេលណា ។

ឈ្ងុះ_ឈ្ងាន.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឃ្លើន, ឈ្លានពាន, ឥតកោតញញើត ។ ក្មេងម្នាក់នេះឈ្ងុះឈ្ងាន ណាស់ ។ បរិវារស័ព្ទ ឈ្ងាន អាចគន្លាស់បានជាពាក្យ ឈ្ងាន ដោយឈ្លានពាន គឺ ឈ្ងុះដោយឈ្លានពាន ។

ឈ្មុស_ឈ្មុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឈ្មុស គាស់ត្បុលចូល, រុករុលចូល ។ល។ បរិវារស័ព្ទ ឈ្មុល អាចគន្លាស់បានជាពាក្យ ឈ្មុលដោយចូលត្បុស គឺ ឈ្មុស ដោយចូលត្បុល ។

ឈ្លក់_ឈ្លី ឬ ឈ្លី_ឈ្លក់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ ញក់ញី ឬ ញីញក់ទក់ទី ។ បរិវារស័ព្ទ ឈ្លក់ អាចគន្លាស់បាន ជាពាក្យ ឈ្លក់ដោយញក់ញី គឺ ឈ្លីដោយញីញក់ ។

ឈ្លេច_ឈ្លី.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សង្កត់សង្កិន ញាំញីឥតប្រណី ។ សួរចម្លើយឈ្លេចឈ្លី គឺ ជីកសួរសង្កេតឱ្យ ខ្ទេចខ្ទី ។ បរិវារស័ព្ទ ឈ្លី អាចគន្លាស់បានជាពាក្យ ឈ្លីជីក ឫសគល់ឱ្យខ្ទីខ្ទេច គឺ ឈ្លេចជីកឫសគល់ឱ្យខ្ទេចខ្ទី ។

❀ ❀ ❀ ❀ ❀

# ញ

**ញញើ_ញញ័រ**.- តាមវចនានុក្រម មានន័យថា ÷ ញ័រទទីទទ័រ ។ មនុស្សចាស់ដើរញញើញញ័រ ។ បរិវារស័ព្ទ ញញើ អាចគន្លាស់បានជាពាក្យ ញញើទទីទទ័រសព្វឥន្ទ្រ័រ គឺ ញញ័រទទីទទ័រសព្វឥន្ទ្រិយ ។

**ញញឹម_ញញែម**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សើចបិទមាត់មិនចេញសម្លេង ដោយដួងចិត្តសប្បាយរីករាយ ផ្អែមល្ហែម ។ បរិវារស័ព្ទ ញញែម អាចគន្លាស់បានជាពាក្យ ញញែមសប្បាយចិត្តដោយផ្អែមល្ហឹម គឺ ញញឹមសប្បាយចិត្តដោយផ្អែមល្ហែម ។

**ញញើត_ញញើម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ទាក់ស្ទើរ, រួញរា ។ ខ្លាចញញើតញញើម ។ បរិវារស័ព្ទ ញញើម អាចគន្លាស់បានជាពាក្យ ញញើមត្រូវវារចូលគើត។ គឺ ញញើតត្រូវវារចូលគើម។ ព្រោះមានពាក្យចាស់ថា ÷ បើខ្លាចឱ្យចូលជិត ពោលគឺ ចូលទៅជិតដោយគោរពយ៉ាងពិសេស តាមប្រពៃណីខ្មែរបុរាណ ។

**ញាប់_ញ័រ.-** ពាក្យនេះ មានន័យថា ÷ ព្រឺព្រួចដោយអបអរសាទរ ឬដោយភ័យស្លុតរន្ធត់ ។ ញាប់ញ័រដោយបានឮដំណឹងប្រកប ឬពុំប្រកប ។ បរិវារស័ព្ទ ញាប់ អាចគន្លាស់បានជាពាក្យ ញាប់ដោយបានដំណឹងប្រករ ឬ ពុំប្រករ ពោលគឺ ញ័រដោយបាន-ដំណឹងប្រកប ឬ ពុំប្រកប ឬ ញាប់ដោយសន្ធ័រ គឺ ញ័រដោយសន្ទប់ ។

**ញិញ_ញ៉ុញ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ច្រិមច្រុម, តិញតុញ ។ ដំណើរញិញញ៉ុញ ។ បរិវារស័ព្ទ ញិញ អាចគន្លាស់បានជាពាក្យ ញិញដោយពុំហ៊ានបញ្ចុញ គឺ ញ៉ុញដោយពុំហ៊ានបញ្ចេញ ពោលគឺ ពុំហ៊ានបញ្ចេញមុខដោយខ្លាច ញញើតញញើម ។

**ញី_ញក់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ញីហើយញីទៀត ឱ្យទាល់តែបានល្អិត, ឱ្យខ្ទេចខ្ទី, ធ្វើបាប, រុកគួនខ្លាំង ។ល។ បរិវារស័ព្ទ ញក់ អាចគន្លាស់បានជាពាក្យ ញក់ឱ្យទាល់តែទី គឺ ញីឱ្យទាល់តែទក់ ពោលគឺ ញីញក់ឱ្យទាល់តែបានទន់រត់ល្បត់ ។

**ញុះ_ញង់**.- តាមវចនានុក្រមពាក្យនេះ មានន័យថា ÷ និយាយចាក់ រុកនាំអុចអាលឱ្យកើតរឿងទាស់ទែងគ្នាឱ្យបែកគ្នា ។ បរិវារ-ស័ព្ទ ញង់ អាចគន្លាស់បានជាពាក្យ ញុងដើម្បីឱ្យបែកសាមគ្គី ក្នុះ គឺ ញុះដើម្បីឱ្យបែកសាមគ្គីក្នុង ពោលគឺ ញង់តាមផ្លូវក្នុង ។

**ញូង_ញាំង**.- សូរសម្លេងផូងផាំងដូចរថយន្តបុកគ្នា ។ បរិវារស័ព្ទ ញូង អាចគន្លាស់បានជាពាក្យ ញូងដូចស្នូរផាំងផូង គឺញាំង ដូចស្នូរផូងផាំង ។

**ញ៉ែច_ញ៉ោច**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរកូនក្មេង ឬកូនសត្វជាច្រើនយំ ឬស្រែក ។ បរិវារស័ព្ទ ញ៉ែច អាច គន្លាស់បានជាពាក្យ ញ៉ែចដូចសម្រែកកូនក្មេងស្រោច គឺ ញ៉ោច

ដូចសម្រែកកូនក្មេងស្រែក ។ អ្នកខ្លះនិយាយពួស្ទូរដូចជា ÷ ញ៉េកញ៉ាចវិញ ។

**ញ្រោច_ញ្រើ.-** តាមវចនានុក្រម បានសេចក្តីថា ÷ សង្កត់ឈ្លេចបំបែកឱ្យខ្ទេចខ្ទី ។ បរិវារស័ព្ទ ញ្រី អាចគន្លាស់បានជាពាក្យ ញ្រីឱ្យខ្ទីខ្ទេច ពោលគឺ ញ្រោចឱ្យបែកខ្ទេចជាល្អងធូលី ។

**ញ្រាំ_ញ្រើ.-** ពាក្យនេះ មានន័យថា ÷ សង្កត់សង្កិន, ឈ្លេចឈ្លី ។ល។ បរិវារស័ព្ទ ញ្រាំ អាចគន្លាស់បានជាពាក្យ ញ្រាំសង្កត់សង្កិនធ្វើបាបឱ្យជោកជី គឺ ញ្រីសង្កត់សង្កិនធ្វើបាបឱ្យជោកជាំ ពោលគឺ តាមសង្កត់សង្កិនព្យាបាទពុំមានហាក់ ។

❋ ❋

❋

# ដ

ដាច់_ដោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាច់ជាចម្រៀក, ជាកំណាត់តូចៗ ។ បរិវារស័ព្ទ ដោច អាចគន្លាស់បានជាពាក្យ ដោចល្អាច់ គឺ ដាច់ល្អោច ឬ ដាច់ហិនហោច ។

ដាប_ចុន.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលទ័លក្រទ្រព្យ ទ័លគំនិត, ទ័លដំណើរ, ទ័លផ្លូវ, ទ័លសេចក្ដី, ចាញ់គេ ។ល។ បរិវារស័ព្ទ ចុន អាចគន្លាស់បានជាពាក្យ ចុនគាប់ គឺ ជាប់កុនពោលគឺ ដាបចាញ់ដៃគេ ឬ ស៊ុនគំនិតដោយជាប់កុន ។

ដាប_ដុន.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលទន់ថយទន់ទាបជាងគេ, ដាបណាស់ ។ មនុស្សដាបដុន ឬ ដុនដាប ។

មន្ត្រីដាបដុន គឺ មន្ត្រីថយបុណ្យ ។ល។ បរិវារស័ព្ទ ដុន អាចគន្លាស់បានជាពាក្យ ដុនថយបាប គឺ ដាបថយបុណ្យ ។ យើងអាចដោះស្រាយពាក្យ នេះថា ÷ ដាបដោយថយទ្រព្យធន ។

**ដី_ធ្លី**.- តាមការស្រាវជ្រាវ ដែលខ្ញុំបានធ្វើឃើញថា ÷ ពាក្យដីធ្លីនេះបានសេចក្ដីថា ដីវាលពុំមានដីព្រៃ ឬ ដីលិចទឹក ។ ខ្មែរយើងបុរាណ ប្រើពាក្យ ដីធ្លីនេះ សំដៅទៅលើដីស្រែណា ដែលធ្វើស្រែចំការបានដោយស្រួល ។ ដូច្នេះ បរិវារស័ព្ទ ធ្លី អាចគន្លាស់បានជាវគ្គមួយថា ÷ ធ្លីនៃប្រថពា គឺ ធ្លានៃប្រថពី ពោលគឺ ធ្លាឬ ដីវាល ។

**ដុក_ដាន់**.- តាមវចនានុក្រម ពាក្យនេះ ក្លាយមកពីពាក្យសៀម ឌុដាន់មានន័យថា ÷ ដែលរឹងត្អឹងស្អីថា, ហាមប្រាមមិនស្ដាប់, រំអុកឱ្យរករឿងរកហេតុ, រុកគួន, ចាក់រុកដោយប្រកាន់ ។ បរិវារស័ព្ទដាន់ អាចគន្លាស់បានជាពាក្យ ដាន់រុកគួន ដោយចិត្តប្រកុក គឺដុករុកគួនដោយចិត្តប្រកាន់ ។

**ដួស_ដង**.- តាមវចនានុក្រម ÷ និយាយដួសដង គឺ និយាយបញ្ចៀសវាសវាង គៀសនាយគៀសអាយ ។ បរិវារស័ព្ទ ដង អាច

គន្លាស់បានជាពាក្យ ដងសម្ដីទៅរក ដោយបញ្ចិតបញ្ចួស គឺ ដួសសម្ដីទៅរកដោយសម្ដីបញ្ចិតបញ្ចៀង ។

**ដៀង_ដង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បញ្ចិតបញ្ចៀង មួយដងមួយយាម, ដួសនាយ ដួសអាយ មួយដង មួយកាល ។ល។ បរិវារស័ព្ទ ដង អាចគន្លាស់បានជាពាក្យ ដងដោយបញ្ចិតបញ្ចៀងមួយដៀង គឺ ដៀងដោយបញ្ចិតបញ្ចៀងមួយដង ។ អ្នកខ្លះនិយាយថា ÷ ដឿងដងទៅវិញ ។

**ដេរ_ដាស.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ពាសពេញ ត្រៀបត្រា ។ មនុស្សឈរដេរដាស ។ល។ បរិវារស័ព្ទ ដេរ អាចគន្លាស់បានជាពាក្យ ដេរច្រើន ញឹកស្ទាស គឺ ដាសច្រើន ញឹកស្ទេរ ។

**ដំណាក់_ដំណេក ឬ ដំណេក_ដំណាក់.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ទីសម្រាប់ស្នាក់, ទទួលដំណេក ។ បរិវារស័ព្ទ ដំណាក់ អាចគន្លាស់បានជាពាក្យ ដំណាក់នៅទីសម្រាប់ស្នេក គឺ ដំណេកនៅទីសម្រាប់ស្នាក់ ។

**ដំណែ_ដំណាល.-** តាមវចនានុក្រម ពាក្យនេះបានសេចក្ដីថា ÷

និយាយរំលឹករឿងដើម ។ បរិវារស័ព្ទ ដំណែ អាចគន្លាស់បាន ជាពាក្យ ដំណែរឿងដើមដោយហួរហាល គឺ ដំណាលរឿង ដើមដោយហួរហែ ។

ដំណែ_ដំណើង.- តាមវចនានុក្រម ពាក្យនេះបានសេចក្ដីថា ÷ ដែល ដឹងដោយហួរហែ ។ ពុំដែលបានដំណែដំណើងអ្វីសោះ បរិ-វារស័ព្ទ ដំណែ អាចគន្លាស់បានជាពាក្យ ដំណែដោយហួរហឹង គឺ ដំណើងដោយហួរហែ ។

ដំណែ_ដំណើរ.- ពាក្យនេះមានន័យថា ÷ ទំនង, លំនាំ, ហេតុ ការណ៍, សេចក្ដីហួរហែ ។ បរិវារស័ព្ទ ដំណែ អាចគន្លាស់ បានជាពាក្យ ដំណែដោយហួរហើរ គឺ ដំណើរដោយហួរ ហែ ។

ដំបែ_ដំបៅ.- ដំបែដំបៅកូនខ្ញុំពុំចេះជាសោះ ។ល។ បរិវារស័ព្ទ ដំ-បែ អាចគន្លាស់បានជាពាក្យ ដំបែស្ងៅ គឺ ដំបៅស្ងែ ពោល គឺ ដំបៅច្រើន ។

ដំបៅ_ដំបៀក.- ពាក្យនេះ មានន័យប្រហាក់ប្រហែលគ្នា នឹងពាក្យ ដំបែដំបៅដែរ ។ កូនអ្នកដូចជាពុំមានឃើញដំបៅដំបៀកអ្វី ។

បរិវារស័ព្ទ ដំបៀក អាចគន្លាស់បានជាពាក្យ ដំបៀករទ្បៅ គឺ ដំបៅរលាក ។

**ដំរ៉េ_ដំរង់.**- តាមវចនានុក្រម ពាក្យនេះ អាចសរសេរបានជាអក្សរ តម្រង់មានន័យថា ÷ ធ្វើឱ្យត្រង់ ។ល។ បរិវារស័ព្ទ ដំរែ អាច គន្លាស់បានជាពាក្យ ដំរែដូចទាញបន្ទាត់ខ្សង់ គឺ តម្រង់ដូច ទាញបន្ទាត់ខ្សែ ។ សូមមើលពាក្យ តម្រែតម្រង់ ។

**ដំអែ_ដំអក់.**-តាមវចនានុក្រមពាក្យនេះ មានន័យថា÷អែអង់, រេរងអែ មមែ ។ល។ បរិវារស័ព្ទ ដំអែ អាចគន្លាស់បានជាពាក្យ ដំអែ ដោយរេរង អែមម៉ក់ គឺ ដំអក់ដោយរេរងអែមមែ ។

* *
*

# ឋ

**ឋិត_ថេរ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឋិតនៅយូរ, អង្វែង ដែលជាប់បានយូរ ។ របស់ឋិតថេរ ។ បរិវារស័ព្ទ ថេរ អាចគន្លាស់បានជាពាក្យ ថេរបានយូរជាកាលកិត គឺ ឋិតបានយូរជាកេរកាល ។

* *
*

# ឌ

**ឌី_ដង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឌីដោយតតង អារ៉ង ។ និយាយដៀមដាម ។ និយាយបញ្ចៀសវាសវាងឱ្យខឹង ឱ្យឈឺចិត្ត ។ វាចេះតែឌីដងឱ្យខ្ញុំ ។ល។ បរិវារស័ព្ទ ដង អាចគន្លាស់បានជាពាក្យ ដងដោយតតងអាឬ គឺ ឌីដោយតតង អារ៉ង ។

* *
*

# ណោ

ណា_ណី.- គេច្រើនឃើញពាក្យនេះក្នុងវគ្គដូចជា ÷ យើងត្រូវតែវារឿងនេះឱ្យដល់ណាណី ។ល។ បរិវារស័ព្ទ ណី អាចគន្លាស់បានជាពាក្យ ណីឱ្យវាអស់អា គឺ ណាឱ្យវាអស់អី ពោលគឺ ទាល់តែបានសម្រេចដូចសេចក្ដីប្រាថ្នា ។ រឿងនេះកើតតាំងពីណាពីណីមក គឺ ណីតាំងពីកើតទឹកដា; ណាតាំងពីកើតទឹកដី ពោលគឺ តាំងពីយូរអង្វែងណាមកហើយ ។

ណែ_នាំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដឹកនាំ, ឱ្យទំនង, ពន្យល់ ។ ណែនាំឱ្យរៀនសូត្រ ។ បរិវារស័ព្ទ ណែ អាចគន្លាស់បានជាពាក្យ ណែពន្យល់ផ្លូវដូចជូនជួយហាំ គឺ នាំពន្យល់ផ្លូវដូចជូនជួយហែ ។

ណែន_ណាន់.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ចង្អៀត ។ ភ្ញៀវអង្គុយណែនណាន់ក្នុងរោង ។ល។ បរិវារស័ព្ទ ណាន់ អាចគន្លាស់បានជាពាក្យ ណាន់តែន គឺ ណែនតាន់ ។

❄ ❄

✺

# ត

**តម្កុំ_តម្កើង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លើក, សសើរឱ្យថ្កុំថ្កើង ។ តម្កុំតម្កើង កូនឱ្យទាល់តែឡើងចិត្ត ឡើងចាងច្រងេងច្រងាងខូចអស់ ។ បរិវារស័ព្ទ តម្កុំ អាចគន្លាស់បានជាពាក្យ តម្កុំឱ្យថើង គឺ តម្កើងឱ្យធំ ពោលគឺ តម្កើងឱ្យថ្កុំថ្កើង ។

**តម្រែ_តម្រង**.- សូមមើលពាក្យ ដំរែដំរង ។

**តម្រែ_តម្រូវ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យត្រូវ, កែតម្រូវ, ទុកដាក់ការងារ ។ បរិវារស័ព្ទ តម្រែ អាចគន្លាស់បានជាពាក្យ តម្រែ តាមការកែប្រូវ គឺ តម្រូវតាមការកែប្រែ ។

**តម្បាញ_តម្បែរ**.- ការត្បាញត្បែរ ។ សូមមើលពាក្យ ត្បាញត្បែរ ។

**តាណាត់ _ តាណែង.**- គ្មានសណ្ដាប់ធ្នាប់, គ្មានការថែរក្សា ។ អ្នកនេះ ដើរចោលកូនចៅ ទុកឱ្យតាណាត់តាណែងមួយថ្ងៃពីរហើយ ។ ពាក្យតាណាត់តាណែង នេះបើតាមយោបល់ខ្ញុំផ្ទាល់ប្រហែលជាក្លាយពីពាក្យ ទីណាត់ទីណែង ព្រោះបរិវារ-ស័ព្ទ ទីណែង បានសេចក្ដីថា ÷ ទីណែងខុសកន្លាត់ គឺ ទីណាត់ខុសកន្លែង ពោលគឺ បែកខ្ញែកគ្នា ខុសអំពីកន្លែងណាត់ គឺកន្លែងសន្មត ឬកន្លែងទុកដាក់ ។ល។

**តាក់_តែង.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រៀបចំ, សំអិតសំអាងឱ្យស្អាតបាតល្អ ។ តាក់តែងផ្ទះ, តាក់តែងខ្លួន ។ បរិវារស័ព្ទ តាក់ អាចគន្លាស់បានជាពាក្យ តាក់ឱ្យបានល្អថែង គឺ តែងឱ្យបានល្អជាក់ ។

**តាន់_តាប់.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខ្ទាន់ខ្ទាប់ ។ មនុស្សឈរតាន់តាប់ ។ បរិវារស័ព្ទ តាប់ អាចគន្លាស់បានជាពាក្យ តាប់ ដោយច្រើនយ៉ាងខ្ទាប់ខ្ទាន់ គឺតាន់ដោយច្រើនយ៉ាងខ្ទាន់ខ្ទាប់ ។

**តិច_តួច.**- សូមមើលពាក្យ បន្តិចបន្តួច ។

**តឹក_តាង.-** ភស្តុតាង, គ្រឿងអាង ។ បរិវារស័ព្ទ តឹក អាចគន្លាស់បានជាពាក្យ តឹកដែលល្អពនឡាង គឺ តាងដែលល្អពន្លឹក ពោលគឺ តាងល្អត្រឹមត្រូវបានការ ។

**តឹង_តែង.-** បង្ខំតឿន, តឹងរឹងយ៉ាងខ្លាំង ។ បរិវារស័ព្ទ តែង អាចគន្លាស់បានជាពាក្យ តែងឱ្យដូចខ្សែខ្លឹង គឺ តឹងឱ្យដូចខ្សែខ្លែង ពោលគឺ បង្ខំយ៉ាងតឹងរឹងឱ្យទាល់តែបានរត់ល្បត់ ។

**តូច_តាច.-** ពាក្យនេះ ខ្មែរយើងច្រើននិយាយថា ÷ ជននោះ គ្នាជាមនុស្សតូចតាច ។ល។ ពោលគឺ មនុស្សពុំមានបណ្តាស័ក្តិក្នុងមុខដំណែងនឹងគេ ក្នុងរដ្ឋការ ។ បរិវារស័ព្ទ តាច អាចគន្លាស់បានជាពាក្យ តាចមែនតែច្រើនកូច គឺ តូចមែនតែច្រើនកាចពោលគឺ មនុស្សតូចតាចប្រភេទនេះ ច្រើនតែកាចដោយមានចិត្តឆាប់ខឹង ។ ម្យ៉ាងវិញទៀត បរិវារស័ព្ទ តាច នេះយើងអាចគន្លាស់បានជាពាក្យមួយទៀតថា ÷ តាចគ្មានអំណូច គឺតូចគ្មានអំណាច ។

**តំណែ_តំណាល.-** សូមមើលពាក្យ ដំណែដំណាល ។

**តាំងយូ_តាំងយែង**.- ពាក្យតាំងយូនេះ ជាពាក្យចិន ដែលខ្មែរយើងយកមកប្រើ សម្រាប់ហៅឆត្រមួយប្រភេទពាសក្រដាសស្អិតឬសំពត់ជ្រលក់ជ័រ ។ល។ សមាសពាក្យ តាំងយូតាំងយែង ជាឃ្លាដើម នៃពាក្យបណ្ដៅ បុរាណខ្មែរយើងមួយ ពោលគឺ ÷ តាំងយូរតាំងយែង តាំងយូរដងវែង ប៉ងដោះមេទំបុត្រស្ដេច ។ ពាក្យបណ្ដៅនេះ មានន័យថា ÷ ឆាងនិងផ្លែល្ហុង ។ ដូច្នេះ បរិវារស័ព្ទ តាំងយែង អាចគន្លាស់បានជាពាក្យ តាំងយែងដងវូ គឺ តាំងយូរដងវែង ។

**ត្រង់_ត្រាច់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដើរតម្រង់ទៅ, ចរយាត្រាទៅ ។ ត្រាច់ត្រង់ទៅមក ។ បរិវារស័ព្ទ ត្រង់ អាចគន្លាស់បានជាពាក្យ ត្រង់យាត្រាតម្រាច់ គឺ ត្រាច់យាត្រាតម្រង់ ។ ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ ។

**ត្រង់_ត្រាប់**.- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ត្រង់ដើម្បីយកជាតម្រាប់, គឺធ្វើតាមគេ ។ បរិវារស័ព្ទ ត្រាប់ អាចគន្លាស់បានជាពាក្យ ត្រាប់ដើម្បីជាតម្រង់ គឺ ត្រង់ដើម្បីជាតម្រាប់ ។ ពាក្យនេះ ច្រើនប្រើក្នុងកាព្យ ។

**ត្រជាក់_ត្រជំ.**- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលប្រកប ដោយសេចក្ដីសុខ សេចក្ដីចម្រើន ។ បរិវារស័ព្ទ ត្រជំ អាច គន្លាស់បានជាពាក្យ ត្រជំដោយសុខខាក់ គឺ ត្រជាក់ដោយ សុខដុម ពោលគឺ សុខដុមរមនា ។

**ត្រឈឹង_ត្រឈៃ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ម្លប់ ជិតឈឹងសន្ធៃ ។ បរិវារស័ព្ទ ត្រឈឹង អាចគន្លាស់បានជា ពាក្យ ត្រឈឹងជិតឈៃ គឺ ត្រឈៃជិតឈឹង ។

**ត្រដាប_ត្រដួស.**- តាមវចនានុក្រម បានសេចក្ដីថា ÷ លំបាកដុនដាប, ស្ទើរស្លាប់ស្ទើររស់ ។ ខំប្រឹងរកស៊ី ដោយត្រដាបត្រដួស ។ បរិវារស័ព្ទ ត្រដួស អាចគន្លាស់បានជាពាក្យ ត្រដួសជ្រុលហាប គឺ ត្រដាបជ្រុលហួស ពោលគឺ ត្រដួសខំប្រឹងរកស៊ីស្ទើរស្លាប់ ស្ទើររ៉ាប គឺ ត្រដាបខំប្រឹងរកស៊ីស្ទើរស្លាប់ស្ទើររស់ ។

**ត្រដេរ_ត្រដរ ឬ ត្រដែរ_ត្រដរ.**- តាមវចនានុក្រម ពាក្យនេះ មាន ន័យថា ÷ ខំប្រឹង, ខំស្ទុះឡើងដោយកម្លាំងចិត្តគំនិត ។ ខំប្រឹង ត្រដែត្រដរ ។ បរិវារស័ព្ទ ត្រដែ អាចគន្លាស់បានជាពាក្យ ត្រដែនឹងគេដរ គឺ ត្រដរនឹងគេដែរ ។

ត្រដេប_ត្រដាប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឺដាប ហេប១, លិច១, អណ្តែត១ ។ ពាក្យត្រដេបត្រដាបនេះពុំខុស គ្នាប៉ុន្មាន នឹងពាក្យ ត្រដាបត្រដួសឡើយ ។ បរិវារស័ព្ទ ត្រដេប អាចគន្លាស់បានជាពាក្យ ត្រដេបហាប១ គឺ ត្រដាប ហេប ១ ។

ត្រដែត_ត្រដួង.- ពាក្យនេះ មានន័យថា ÷ ដែលរសាត់អណ្តែតខ្ពស់ ឡើង១ ហើយកាន់តែឆ្ងាយទៅ១ ។ អណ្តែតអណ្តូងចិត្ត ។ល។ បរិវារស័ព្ទ ត្រដួង អាចគន្លាស់បានជាពាក្យ ត្រដួង ខ្ពស់ឆ្ងាយឡើង១ ហាក់ដូចជាអណ្តែតបេះដែត គឺ ត្រដែត ខ្ពស់ឆ្ងាយឡើង១ហាក់ដូចជាអណ្តែតបេះដួង ។

ត្រម៉ែង_ត្រមោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឯក ឯងនៅក្នុងទីស្ងាត់ ។ ត្រមែងត្រមោចតែម្នាក់ឯង ។ បរិវារស័ព្ទ ត្រម៉ែង អាចគន្លាស់បានជាពាក្យ ត្រម៉ែងម្នាក់អោច គឺ ត្រមោច ម្នាក់ឯង ។

ត្រសុក_ត្រសុស .- អត្ថន័យ ក្នុងវចនានុក្រម គឺ : រុលមមុល , ចូល

ជ្រកទៅក្នុងទីសុខមមុល ។ បរិវារស័ព្ទ ត្រសុក អាចគន្លាស់បានជាពាក្យ ត្រសុករុលចូលក្នុងទីសុកមមុល គឺ ត្រសុលរុលចូលក្នុងទីសុខមមុក ។ អ្នកខ្លះនិយាយជាពាក្យ សសុកសសុលទៅវិញ ។

**ត្រឡប់_ត្រឡិន.-** ដូលត្រឡប់ត្រឡិន គឺ ច្រងាប់ច្រងិល រហូតដល់របូតសំពត់អាវ ។ បរិវារស័ព្ទ ត្រឡិន អាចគន្លាស់បានជាពាក្យត្រឡិនបាយបិណ្ឌជាបាយបប់ គឺ ត្រឡប់បាយបប់ជាបាយបិណ្ឌពោលគឺ ពាក្យត្រឡប់ត្រឡិននេះ និងវិញ្ញាតិ (expression) បាយបិណ្ឌជាបាយបាត្រមានន័យដូចគ្នា គឺ ភាន់ច្រឡំ ។

**ត្រឡុង_ត្រឡាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឺ ឧត្តម, ថ្លៃថ្លា, ឆើតឆាយ, សំខាន់, ចំណាប់ ។ល។ បរិវារស័ព្ទ ត្រឡាយ អាចគន្លាស់បានជាពាក្យ ត្រឡាយថ្លៃថ្លាឧត្តមឧត្តុង គឺ ត្រឡុងថ្លៃថ្លាឧត្តុងឧត្តម ។ អ្នកខ្លះនិយាយពាក្យនេះថា : ត្រឡុងត្រឡៃទៅវិញ ។

**ត្រអេក_ត្រអាល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឺរីករាយសប្បាយតាមតែតម្រេក ។ បរិវារស័ព្ទ ត្រអេក អាចគន្លាស់

បានជាពាក្យ គ្រអេកគ្រិកវាយដោយតម្រាល គឺ គ្រអាលរីក វាយដោយតម្រេក ។ ពាក្យនេះដូចគ្នានឹងពាក្យគ្រេកគ្រអាល ។

**គ្រាណា_គ្រើយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទីពំនាក់ទុកស្មើគ្រើយ ។ បរិវារស័ព្ទ គ្រាណ អាចគន្លាស់បានជាពាក្យ គ្រាណជាអវសោយ គឺ គ្រើយជាអវសាន ។

**គ្រុក_គ្រុយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គ្រុកៗ ស្រាប់តែលឿនរ៉ុយ ។ បរិវារស័ព្ទ គ្រុយ អាចគន្លាស់បានជាពាក្យ គ្រុយលឿនយ៉ាងរ៉ុក គឺ គ្រុកលឿនយ៉ាងរ៉ុយ ។

**គ្រូវ៉_រ៉ូវ៉.-** សូមរៀបចំកិច្ចការឱ្យបានត្រូវរ៉ូវគ្នា ដើម្បីឱ្យបានលទ្ធផលល្អ ។ល។ បរិវារស័ព្ទ រ៉ូវ៉ អាចដោះស្រាយបានជាឃ្លាគន្លាស់មួយថា ÷ រ៉ូវតម្រេ គឺ រេតម្រូវ ពោលគឺ រកហេតុផលកែតម្រូវ ដើម្បីឱ្យស្របមតិគ្នា ។

**គ្រូត_គ្រា.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា គ្រូតបន្ថែមគ្រូត ដោយបង្គាប់បញ្ជា ។ មេជាងបានគ្រូតគ្រាមើលការហើយ ។ បរិវារស័ព្ទ គ្រា អាចគន្លាស់បានជាពាក្យ គ្រាមើលពិនិត្យគូត គឺ គ្រូតមើលពិនិត្យការ ។

ត្រុស_ត្រុយ.- តាមវចនានុក្រម មានន័យថា ÷ ច្បោល, លំៗ, ជាតម្រុយ ។ និយាយត្រុសត្រុយ គឺ និយាយដោយសង្ខេបជាតម្រុយ ។ បរិវារស័ព្ទ ត្រុយ អាចគន្លាស់បានជាពាក្យ ត្រុយជាតម្រូស គឺ ត្រូសជាតម្រុយ ។

ត្រៀប_ត្រា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលដេរដាសពាសពេញកុះករ ដូចគេតម្រៀប ។ បរិវារស័ព្ទ ត្រា អាចគន្លាស់បានជាពាក្យ ត្រាដោយមានកៀប គឺ ត្រៀបដោយមានការ ពោលគឺ ទាល់តែមានបុណ្យ, ល្មោន ឬមានការអ្វីទើបមានមនុស្សច្រើនត្រៀបត្រាទៅបាន ។

ត្រេក_ត្រអាល.- សូមមើលពាក្យ ត្រអេកត្រអាល ។

ត្រាំ_ត្រែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជិអក់រង់នៅមានការហាក់ដូចជាក្របីត្រាំជិអក់នៅក្នុងត្រែង, ក្នុងខ្ទាច ។ នៅត្រាំត្រែង គឺ នៅយូរ ។ បរិវារស័ព្ទ ត្រែង អាចគន្លាស់បានជាពាក្យ ត្រែងនៅយូរអង្វាំ គឺ ត្រាំនៅយូរអង្វែង ។

ត្លួញ_ត្លែរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ត្លួញហើយត្លួញទៀត, ចែបចែប្រែ ។ បរិវារស័ព្ទ ត្លែរ អាចគន្លាស់បានជាពាក្យ ត្លែរ

ចែប៉ប្រួញ គឺ គួញចែប៉ប្រែ ។ ពាក្យ ចែប៉ប្រែឬពាក្យ ដែប៉ប្រែ ជាពាក្យខ្មែរបុរាណ បានសេចក្ដីថា ÷ ជ្រាំដែល ឬ ដដែល១ ។ សូមមើលវចនានុក្រម នូវពាក្យនេះ ។

ត្រមេល_ត្រមោល.- ទោល, តែឯង ។ល។ បរិវារស័ព្ទ ត្រមេល អាចគន្លាស់បានជាពាក្យ ត្រមេលដោយរលីងឆោល គឺ ត្រ-មោលដោយរលីងឆេល ពោលគឺ នៅតែឯកឯងហាក់ដូចជា នៅឆោល ឬអ្នកផងដើរចោល ។

ព្រេះ_ព្រុះ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលច្រេម ច្រុម អេះអុះពុំមានបានការអ្វី ។ ដើរត្រេះត្រុះ ។ល។ បរិវារ-ស័ព្ទ ត្រុះ អាចគន្លាស់បានជាពាក្យ ត្រុះដោយច្រេមច្រុមអុះ អេះ គឺ ត្រេះដោយច្រេមច្រុមអេះអុះ ពោលគឺ ត្រេះត្រុះអេះ មមេះ ។

* *

*

# ថ

ថម_ថយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យទាប ឱ្យថយចុះដុនដាប ។ ថមថយកម្លាំង ។ បរិវារស័ព្ទ ថម អាចគន្លាស់បានជាពាក្យ ថមអស់កម្លាំងរកពួនសម្ងំយ គឺ ថយ អស់កម្លាំងរកពួនសម្ងំ ។

ថ្កើង_ថ្កាន.- តាមវចនានុក្រម បានសេចក្តីថា ÷ ថ្កើងរុងរឿង, ថ្កើង មានកេរ្តិ៍ឈ្មោះ, ខ្ពស់ត្រដែត ។ លោកនេះឥឡូវបានថ្កើង ថ្កានណាស់ ។ ប្រទេសយើងបានថ្កើងថ្កានរុងរឿងជាងគេក្នុង សតវត្សរ៍ទី១២ ។ល។ តាមការសង្កេត ពាក្យថ្កើងថ្កាននេះ ឃើញប្រើតែក្នុងឃ្លាដូចជូនក្នុងឧទាហរណ៍ខាងលើនេះ ។ ដូច្នេះ បរិវារស័ព្ទ ថ្កាន អាចគន្លាស់បានជាពាក្យ ថ្កានរុងរឿងក្រៀម ក្រៀង គឺ ថ្កើងរុងរឿងក្រៀមក្សាន្ត ។

ថ្កុំ_ថ្កើង.- តាមវចនានុក្រម បានសេចក្ដីថា ÷ ឧត្ដុង្គឧត្ដម, ខ្ពង់ខ្ពស់, មានយសបរិពារ ។ល។ បរិវារស័ព្ទ ថ្កុំ អាចគន្លាស់បានជាពាក្យ ថ្កុំឧត្ដមឧត្ដើង គឺ ថ្កើងឧត្ដុង្គឧត្ដម ពោលគឺ ថ្កើងបានធ្វើធំ មានយសបរិពារ ។

ថ្ងៃ_ទ្បេង.- ក្នុងសមាសពាក្យនេះ បរិវារស័ព្ទ ឡេង ពុំមានសម្លេងស្របផ្ទួលតាមពាក្យ ថ្ងៃដែលជាស័ព្ទដើម ពោលគឺ ថ្ងៃមាន (ថ្ង) ឡេង មានសម្លេង (ឡ) ។ កូននេះកាលនៅថ្ងៃឡេងនៅឡើយ ពុំឃើញរៀនសូត្រអ្វី គិតតែដើរលេង; កាលនៅថ្ងៃឡេងនៅឡើយ ពុំគិតធ្វើដំណើរទេ ។ល។ ដូច្នេះ បរិ-វារស័ព្ទ ឡេង អាចគន្លាស់បានជាពាក្យ ឡេងឃើញពន្លឺស្វាងទេច គឺ លេចឃើញពន្លឺស្វាងទែង ពោលគឺ ថ្ងៃដែលមានពន្លឺស្វាងថែសនៅឡើយ ។

ថ្នាក់_ថ្នម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បីបាច់រក្សាមិនឱ្យមានហ្មង ។ល។ បរិវារស័ព្ទ ថ្នាក់ អាចគន្លាស់បានជាពាក្យ ថ្នាក់មិនឱ្យមានអម គឺ ថ្នមមិនឱ្យមានអាក់ ។

ថ្នាក់_ថ្នាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យទាំងពីរ បានសេច-

ក្តីថា ÷ សេចក្តីអាក់អន់ចិត្តដោយគ្រា ដោយកាល ហាក់ដូចជាមានថ្នាក់មានថ្នាំង ។ ឧទាហរណ៍.- កាលនៅរួមជាមួយគ្នារមែងនាំឱ្យមានថ្នាក់ថ្នាំងបន្តិចបន្តួចជាធម្មតា ។ បរិវារស័ព្ទ ថ្នាំង អាចគន្លាស់បានជាពាក្យ ថ្នាំងអាក់អន់ចិត្តហាក់ដូចជាមានរបាក់ គឺ ថ្នាក់អាក់អន់ចិត្តហាក់ដូចជាមានរបាំង ពោលគឺ ហាក់ដូចជាមានរនាំងបាំង ។ បើពាក្យថ្នាក់ ជាបរិវារស័ព្ទ វិញយើងអាចផ្សំបានជាវគ្គមួយថា ÷ ថ្នាក់ហាក់ដូចជាមានកន្លាំង គឺ ថ្នាំងហាក់ដូចជាមានកន្លាក់ ។

ថ្មិត_ថ្មម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ថ្នមអស់ពីចិត្ត ថ្នមមិនឱ្យលំបាកចិត្ត ។ បរិវារស័ព្ទ ថ្មិត អាចគន្លាស់បានជាពាក្យ ថ្មិតមិនឱ្យលំបាកចម គឺ ថ្នមមិនឱ្យលំបាកចិត្ត ។

ថ្នាំ_បង្កូវ.- គឺវត្ថុសម្រាប់ព្យាបាល ។ អាវ៉ាឯងទៅរកថ្នាំបង្កូវលោកគ្រូយើងបន្តិចមក ដើម្បីឱ្យប្អូនវាផឹក ព្រោះវាគ្រុនក្តៅ ។ បរិវារស័ព្ទ បង្កូវ អាចគន្លាស់បានជាពាក្យ បង្កូវអាស្រា គឺ បង្ការអាស្រូវ ។ អ្នកខ្លះនិយាយពាក្យនេះថា ថ្នាំដង្កូវ ខ្លះទៀតថា ថ្នាំសង្កូវ ។

ថ្មី_ថ្មោង.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ ÷ ថ្មី

និងថ្មោង ។ ថ្មីបានសេចក្ដីថា ÷ ប្រើប្រាស់ហើយតែពុំទាន់សៅហ្មង, មិនទាន់ខូចខាត ។ ថ្មោងបានសេចក្ដីថា ÷ ដំបូង, ចំពើបដែលថ្មោងហើយទើបបានថ្មី, ចំណីថ្មោង ។ ពាក្យថ្មីថ្មោងនេះខ្មែរយើងច្រើនប្រើក្នុងវគ្គថា ÷ អ្នកនេះទើបនឹងបានប្រពន្ធថ្មីថ្មោង ។ល។ អាស្រ័យហេតុនេះ បរិវារស័ព្ទ ថ្មី អាចគន្លាស់បានជាពាក្យ ថ្មី ដូចព្រហ្មចារ៉ោង គឺ ថ្មោងដូចព្រហ្មចារី ពោលគឺ ប្រពន្ធថ្មីថ្មោងបរិសុទ្ធពុំមែនជាស្រីមេម៉ាយ ឬ សវជ័យឡើយ (សៅផៃ) ។

ពាក្យសាវជ័យនេះ ជាព្រះនាមព្រះមហាក្សត្រ ប្រទេសជ្វា (Java), (Srivijaya) ដែលខ្មែរយើងយកមកប្រើជាឈ្មោះចំអក (Sobriquet) ដើម្បីដាក់ឈ្មោះស្រីខិលខូចពេស្យានិងដើម្បីជាអនុស្សាវរីយ៍រំលឹកដល់គ្រាថោកទាប (ទាសភាព) នៃប្រទេសខ្មែរយើងនៅសម័យហ្វូណនចិនឡា នៅឡើយ ព្រោះសម័យនោះយើងច្បាំងចាញ់ប្រទេសជ្វាហើយធ្លាក់ខ្លួនជាប្រទេសរណបគេ អស់រយៈវេលាជិតមួយសតវត្ស ។

នៅដំបូងដៃនៃវេលានោះ កងទ័ពព្រះមហាក្សត្រស្រីវិជ័យនេះ (សវជ័យ) បានប្រមូលចាប់បង្ខំស្រីខ្មែរពុំថាក្មេងពុំថាចាស់

យកទៅកំដរអារម្មណ៍បំភិតណ្ហារៀងខ្លួន ហើយយកទៅបង្ខាំងទុកឱ្យប្រព្រឹត្តពេស្យាកម្មសម្រាប់តម្រេកនៃកងទ័ពនោះ ។ សព្វថ្ងៃនេះ ពាក្យ "សវជ័យ" នេះ យើងសរសេរ "សៅជៃ" ទៅវិញ ។

អាស្រ័យហេតុនេះហើយ បានជាខ្មែរយើងហៅស្រីប្រភេទនេះ ជាស្រីសំផឹងសវជ័យ ។ ពាក្យនេះពុំសូវឃើញមានប្រើ ។ សូមអានសៀវភៅលោកសឺដេស (Cœdès) វឌ្ឍនធម៌ឥណ្ឌូនិយមនៃប្រទេសឥណ្ឌូចិន និងប្រទេសឥណ្ឌូនេស៊ី (Les États Hindouisés de L'Indochine et de L'Indonésie) ។

ថ្លា-ថ្លែង.- ពាក្យនេះច្រើនប្រើជាលំនាំដើម នៃពាក្យកាព្យឃ្លោង ឬចម្រៀង ។ នេះនឹងថ្លាថ្លែងពីម៉ាក់ថឹង នៅស្រុកតាកៀងរាជភារា ។ល។ បរិវារស័ព្ទ ថ្លា អាចគន្លាស់បានជាពាក្យ ថ្លាថែង គឺ ថ្លែងថា ។

តាមវចនានុក្រម ពាក្យ ភារា មានន័យថា ÷ រាជធានី, ក្រុង ; ប្រែក្លាយមកពីពាក្យពារា ដែលជាពាក្យហៅក្រុងពារាណសី សព្វថ្ងៃ បារាំងហៅក្រុងនេះថា បេណោរេស

(Bènérès) ។ ដោយសង្ខេប គឺសម្រាប់ប្រើសម្រួលក្នុងកាព្យ, លុះយូរៗមកក៏ក្លាយសេចក្ដីថា ក្រុង ។ (ច្រើនឃើញប្រើក្នុងពាក្យរឿងជាតក) ។

ថ្លៃ_ថ្លា.- ពាក្យនេះ មានន័យថា ÷ ថ្កើងថ្កាន, ថ្លៃវិសេសវិសាល ។ បរិវារស័ព្ទ ថ្លា អាចគន្លាស់បានជាពាក្យ ថ្លាថ្កើងថ្កាន ឥតឧបម៉ៃ គឺ ថ្លៃថ្កើងថ្កានឥតឧបមា ពោលគឺ ថ្លៃថ្លា ថ្កើងថ្កានអស្ចារ្យ ។

ថ្លោះ_ធ្លោយ.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ភ្លាត់ជ្រុលដោយធ្លោយគំនិត ។ ប្រយ័ត្នកុំឱ្យថ្លោះធ្លោយខូចខាតការ ។ បរិវារស័ព្ទ ធ្លោយ អាចគន្លាស់បានជាពាក្យ ធ្លោយដោយមានការបណ្ដែតបណ្ដោះ គឺ ថ្លោះដោយមានការបណ្ដែតបណ្ដោយ ។

ថ្វាត់_ថ្វាយ.- ពាក្យនេះ សម្រាប់ប្រើតែក្នុងពាក្យកាព្យ ។ លើកដៃប្រណម្យ ថ្វាត់ថ្វាយបង្គំ ចំពោះព្រះមហាក្សត្រ ។ល។ បរិវារស័ព្ទ ថ្វាត់ អាចគន្លាស់បានជាពាក្យ ថ្វាត់បង្គំព្រះមហាក្សាយ គឺ ថ្វាយបង្គំព្រះមហាក្សត្រ ។

# ទ

**ទទាក់_ទទាម.-** គឺទាក់ៗ ទើសៗ វឹមវាម ញ៉ីកញ៉ួយ ។ និយាយគ្នាឱ្យជ្រះស្រឡះ ទៅកុំឱ្យទទាក់ទទាម ទៅថ្ងៃក្រោយ ។ បរិវារស័ព្ទ ទទាម អាចគន្លាស់បានជាពាក្យ ទទាមវឹមវាក់ គឺ ទទាក់វឹមវាម ។

**ទទាស់_ទទែង.-** ដែលនាំឱ្យ ទាស់ទើសទែង, ដែលនាំឱ្យឈ្លោះប្រកែកគ្នា ។ បរិវារស័ព្ទ ទទែង អាចគន្លាស់បានជាពាក្យ ទទែងនាំឱ្យឈ្លោះគ្នាអ៊ាស់ គឺ ទទាស់នាំឱ្យឈ្លោះគ្នាឯង ។

**ទទី_ទទ័រ.-** គឺទទ័រខ្លាំង ។ លោកតាកុំខំប្រឹងដើរ ទទីទទ័រធ្វើអ្វី ។ បរិវារស័ព្ទ ទទី អាចគន្លាស់បានជាពាក្យ ទទីញ៉ូរអស់ឥន្ទ្រ័រ គឺ ទទ័រញ៉ូរអស់ឥន្ទ្រិយ ។

**ទទី_ទទារ.**- តាមវចនានុក្រម មានន័យថា ÷ ដែលញ័រ។ ដោយស្លុះ ម៉្មឹម្មា ។ ខ្ញុំខំស្លុះទទីទទារចូលមកដោយភ័យខ្លាចមានការអ្វី ។ល។ បរិវារស័ព្ទ ទទី អាចគន្លាស់បានជាពាក្យ ទទីភ័យ-ដោយស្លុះម្ល៉ឹម្មា គឺទទាភ័យដោយស្លុះម្មាម្ល៉ឹ ។

**ទទឹម_ទទើម.**- គឺ ភាវង់, ទើមចុះទើមឡើងច្រើនដង ។ ដើរទទឹម-ទទើម ។ បរិវារស័ព្ទ ទទឹម អាចគន្លាស់បានជាពាក្យ ទទឹម ដើរគគឹមគគើម គឺ ទទើមដើរគគើមគគឹម ។

**ទទីស_ទទាស.**- តាមវចនានុក្រម បានន័យថា ÷ ទាសទៅទាសមក ច្រើនដង, ឃឹសងាស ខុសផ្លូវ ខុសគន្លង ។ ដើរទទីសទទាស ពេញផ្លូវដោយស្រវឹងស្រា ។ បរិវារស័ព្ទ ទទីស អាចគន្លាស់ បានជាពាក្យ ទទីស ពេញផ្លូវដោយពីសពាស គឺ ទទាសពេញ ផ្លូវដោយពាសពីស ។

**ទទឹង_ទទែង.**- គឺខ្វាត់ខ្វែង នាំឱ្យទើសទែង ។ បរិវារស័ព្ទ ទទែង អាចគន្លាស់បានជាពាក្យ ទទែង ដូចគេខ្វាត់ខ្វឹង គឺ ទទឹងដូចគេ ខ្វាត់ខ្វែង ពោលគឺ ច្រងេងច្រងាងពាសពេញ ។

**ទទូច_ទទៃ.-** តាមវចនានុក្រម មានន័យថា ÷ ត្រូវការមិនលែង, គឺ ទទូចដែលព្រៃមិនលែង ។ បរិវារស័ព្ទ ទទៃ អាចគន្លាស់បាន ជាពាក្យ ទទៃដែលព្រួច គឺ ទទូចដែលព្រៃ ។ អ្នកខ្លះស្រដីថា ÷ ចៃប៉ប្រែវិញ ។

**ទទ្រេម_ទទ្រម ឬ ទទ្រែម_ទទ្រម.-** ដែលទ្រេមទ្រមខ្លាំង ដោយមានជម្ងឺឬធ្វើការជាទម្ងន់ច្រើន ។ បរិវារស័ព្ទ ទទ្រេម អាចគន្លាស់បានជាពាក្យ ទទ្រេមដោយគ្មានកម្លាំងអិម គឺ ទទ្រមដោយគ្មានកម្លាំងអេម ពោលគឺ ទ្រេមទ្រមខ្លាំង ។

**ទន្ទូរ_ទន្ទេញ.-** តាមវចនានុក្រម មានន័យថា ÷ គឺទន្ទេញរទូ ឬរអ៊ូរឿយៗ ខ្ជាន់ៗ ។ បរិវារស័ព្ទ ទន្ទូរ អាចគន្លាស់បានជាពាក្យ ទន្ទូរខ្ជាន់ៗ រអើញៗ គឺ ទន្ទេញខ្ជាន់ៗរអ៊ូៗ ។

**ទន្ទេង_ទន្ទាំ.-** តាមវចនានុក្រម ពាក្យនេះ មានន័យ ចំហទាំងពីរបានសេចក្តីថា ÷ ដែលមានដំណើរសមរម្យ ហឹកហ៊ាក់ដោយលំនាំរំពើន ។ រាំទន្ទេងទន្ទាំ ។ល។ សមាសពាក្យនេះ យើងយកពាក្យណាធ្វើ បរិវារស័ព្ទ បានទាំងអស់ហើយមានន័យប្រហាក់ប្រហែលគ្នាទៀត ។ ច្រើនប្រើក្នុងពាក្យកាព្យ

១- បរិវារស័ព្ទ ទន្ទាំ អាចគន្លាស់បានជាពាក្យ ទន្ទាំដោយមានដំណើររំពើនដូចគេរេង គឺ ទន្ទេងដោយមានដំណើររំពើនដូចគេរាំ ។

២- បរិវារស័ព្ទ ទន្ទេង អាចគន្លាស់បានជាពាក្យ ទន្ទេងដោយមានដំណើររំពើនបាក់ដូចតាមចង្វាក់ភ្លាំ គឺ ទន្ទាំដោយមានដំណើររំពើនបាក់ដូចតាមចង្វាក់ភ្លេង ។

**ទម្រែ_ទម្រង់**.- សូមមើលពាក្យ តម្រែតម្រង់, ដំរែដំរង់ ។

**ទម្លុះ_ទម្លាយ**.- គឺធ្វើឱ្យធ្លុះធ្លាយពីម្ខាងទៅម្ខាង ។ ពាក្យនេះ មានន័យចំហទាំងពីរ គឺ ទម្លុះនិងទម្លាយ ។ យើងយកពាក្យណាមួយមកធ្វើជា បរិវារស័ព្ទ បានទាំងអស់ ហើយគន្លាស់ទៅបានជាវគ្គមួយមានន័យដូចគ្នាទៀត ពោលគឺ ទម្លុះឱ្យធ្លាយ គឺទម្លាយឱ្យធ្លុះ ។

**ទាក់_ទង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានគន្លង, ឬទំនាក់ទំនងគ្នា, ទទួលគ្នា ។ បរិវារស័ព្ទ ទង អាចគន្លាស់បានជាពាក្យ ទងឱ្យត្រូវតាមទំនាក់ គឺ ទាក់ឱ្យត្រូវតាមទំនង ។

**ទាក់_ទាម.**- ពាក្យនេះ មានន័យ និងលំនាំប្រហាក់ប្រហែលគ្នា នឹងពាក្យ ទទាក់ទទាមដែរ គឺ ជាប់ជំពាក់គ្នាទៅវិញទៅមក ។ បរិវារស័ព្ទ ទាក់ អាចគន្លាស់បានជាពាក្យ ទាក់ដោយមានជំពាម គឺទាមដោយមានជំពាក់ ។

**ទាក់_ទិន.**- តាមវចនានុក្រម មានន័យថា ÷ ជំពាក់ឆ្វាក់នឹងគ្នា, ជំពាក់វាក់វិន ។ បរិវារស័ព្ទ ទិន អាចគន្លាស់បានជាពាក្យ ទិនឆ្វាក់គ្នា ដោយជាប់ក្លាក់ គឺ ទាក់ឆ្វាក់គ្នាដោយជាប់ក្លិន ។

**ទាញ_ទង់.**- គឺប្រអូសប្រទាញគ្នា, ដឹកនាំចិត្តគំនិតអ្នកដទៃឱ្យធ្វើតាម ។ ខ្ញុំចង់ទាញទង់វាដែរ តែគេមិនតាម ។ល។ បរិវារស័ព្ទ ទង់ អាចគន្លាស់បានជាពាក្យ ទង់ចិត្តគំនិតឱ្យចុះសម្រាញ គឺ ទាញចិត្តគំនិតឱ្យចុះសម្រុង ។

**ទាស់_ទែង.**- ឈ្លោះគ្នា ។ បរិវារស័ព្ទ ទែង អាចគន្លាស់បានជា-ពាក្យ ទែងឈ្លោះគ្នាអ៊ាស់ គឺ ទាស់ឈ្លោះគ្នាឯង ពោលគឺ ទែងដោយមានគំនិតខ្វាស់ គឺ ទាស់ដោយមានគំនិតខ្វែង ។

**ទី_ទាល់** ឬ **ទី_ទ័ល.**- តាមវចនានុក្រម មានន័យថា ÷ ទព្ទុំតុះ, ខ្វះខាត, មិនគ្រប់គ្រាន់ ។ ទីទ័លក្រ ។ បរិវារស័ព្ទ ទី អាច

គន្លាស់បានជាពាក្យ ទីពេញទ័ល គឺ ទ័លពេញទី ពោលគឺ ទី-ទ័លក្រណាស់ ។

**ទី_ទើរ.**- គឺរុញរា, អល់ឯក, ញញើតញញើម, ស្ទាក់ស្ទើរ ។ បរិវារស័ព្ទ ទី អាចគន្លាស់បានជាពាក្យ ទីដោយព្រែកចិត្តពីរ គឺ ទើរដោយព្រែកចិត្តពីរ ។

**ទីម_ទើម.**- សូមមើលពាក្យទទឹមទទើម ។

**ទុរន៍_ទុរា.**- ដែលគ្រាំគ្រាខ្លាំង, គ្រដាបគ្រដួសខ្លាំង ។ បរិវារស័ព្ទ ទុរា អាចគន្លាស់បានជាពាក្យ ទុរាដូចចាស់ជរុន គឺ ទុរន់ដូចចាស់ជរា ។

**ទូ_ទុក្ខ.**- ពាក្យនេះ មានន័យចំហទាំងពីរ គឺ ទូ និងទុក្ខ មានសេចក្តីថា ÷ ទុក្ខជាទម្ងន់ ហាក់ដូចជាមានទុក្ខដោយគ្រួសារស្លាប់ ។ ពាក្យ ទុក្ខ អស់លោកស្គាល់ស្រាប់ហើយ ។ ខ្ញុំសូមជូនអត្ថន័យ ពាក្យទូ តាមវចនានុក្រម : ទូ មានន័យថា ÷ ជាយោង គឺ សំពត់បន្ទះវែងសម្រាប់ទាញយោងពីសាកសព ឬពីអដ្ឋិធាតុមកដល់ដៃព្រះភិក្ខុសង្ឃ ចាប់កាន់សូត្រធម៌បង្សុកូល ; ហៅ-ថាទូ ឬ សំពត់ទូ ក៏បានដោយប្រើតាមទំនៀមប្រទេស ។ បរិ-

វារស័ព្ទ ទូ អាចគន្លាស់បានជាពាក្យ ទូប្រចាំពុំបានធុក គឺ ទុក្ខប្រចាំពុំបានធូរ ពោលគឺ មានទុក្ខទុំនៅជានិច្ច ពុំស្រាក់ស្រាន្តស្បើយរហ័ស ។

**ទូលំ_ទូលាយ.**- តាមវចនានុក្រម មានន័យថា ÷ គឺ ធំទូលាយ ឥតទើសទាល់ ។ បរិវារស័ព្ទ ទូលំ អាចគន្លាស់បានជាពាក្យ ទូលំធាយ គឺ ទូលាយធំ ។

**ទៀង_ទាត់.**- តាមវចនានុក្រម មានន័យថា ÷ ដែលពិតប្រាកដ, មិនប្រែប្រួល, មិនល្ហៀង ។ល។ បរិវារស័ព្ទ ទាត់ អាចគន្លាស់បានជាពាក្យ ទាត់ពិតប្រាកៀង គឺ ទៀងពិតប្រាកដ, ទៀងដូចសន្ទតឬទៀងដូចបន្ទាត់ ។

**ទំណែ_ទំនង.**- តាមវចនានុក្រម មានន័យថា ÷ ដើមទង, គន្លង, លំអាន ។ បរិវារស័ព្ទ ទំណែ អាចគន្លាស់បានជាពាក្យ ទំណែដោយហួរហ៊ង គឺ ទំនងដោយហួរហែ ។ អ្នកខ្លះនិយាយថា ÷ តំណែតំនងវិញ ។

**ទំនាក់_ទំនង.**- តាមវចនានុក្រម បានសេចក្តីថា ÷ ដើមទង, លំអាន, ន័យឬហេតុប្រាកដ ។ រឿងនេះមានទំនាក់ទំនងស្រួល

ណាស់ ។ បរិវារស័ព្ទ ទំនាក់ អាចគន្លាស់បានជាពាក្យ ទំ-នាក់ដីជាក់លង គឺ ទំនងដីជាក់លាក់ ។

ទំនឹម_ទំនៀម.- អត្ថន័យ តាមវចនានុក្រមគឺ ÷ ពាក្យដែលអ្នកប្រាជ្ញចងជាប្រស្នាប្រៀបផ្ទឹមទៅរកសេចក្ដីណាមួយ ដែលគេច្រើនឃើញនៅក្នុងពាក្យសុភាសិត ដូចជាពាក្យ ចិត្តជាទេវទត្តមាត់ជាទេវតា វគ្គមួយនេះហើយ ដែលហៅថា : ទំនឹមទំ-នៀម ។ បរិវារស័ព្ទ ទំនឹម អាចគន្លាស់បានជាពាក្យ ទំនឹមដែលជាពាក្យផ្ទៀម គឺ ទំនៀមដែលជាពាក្យផ្ទឹម ។

ទំយើច_ទំយើ.- គឺទម្រើស, ថ្នមជំទូយ, ពោលពាក្យ ជំទូយ ។ បរិ-វារស័ព្ទ ទំយើច អាចគន្លាស់បានជាពាក្យ ទំយើចដោយពាក្យបញ្ចើ គឺ ទំយើដោយពាក្យបញ្ចើច ពោលគឺ ទំយើចទំយើបញ្ចើចបញ្ចើ ។

ទ្រង់_ទ្រាយ.- សណ្ឋាន, រូបរាង, រាងរៅ, លំនាំ ។ ពាក្យនេះមានន័យចំហទាំងពីរ គឺ ទ្រង់និងទ្រាយដែលបានសេចក្ដីថា ÷ ស-ភាពរាងរៅ ប្រកបស្របគ្នាឬខុសគ្នាពីខាងមួយទៅខាងមួយពោលគឺ ពីខាងដើមរហូតដល់ចុងជាយ ។ បរិវារស័ព្ទ ទ្រាយអាចគន្លាស់បានជាពាក្យ ទ្រាយសណ្ឋានរាងរៅពីដើមដង់ជង់គឺ ទ្រង់សណ្ឋានរាងរៅពីដើមដល់ជាយ ។

ទ្រមឹង_ទ្រមើយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលធ្មឹងធើយដោយស្ងៀមឈឹងមិនស្តី, មិននិយាយធ្មឹងដោយព្រួយចិត្ត ឬដោយអស់កម្លាំងព្រោះនឿយហត់ខ្លាំង ។ បរិវារស័ព្ទ ទ្រមឹង អាចគន្លាស់បានជាពាក្យ ទ្រមឹងដោយស្ងៀមឈើយ គឺ ទ្រមើយដោយស្ងៀមឈឹង ។

ទ្រុប_ទ្រុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលស្តុកច្រើន, ញឹកណាស់ ។ល។ ស្មៅដុះទ្រុបទ្រុល ។ បរិវារស័ព្ទ ទ្រុប អាចគន្លាស់បានជាពាក្យ ទ្រុបដោយស៊ុបទ្រុល គឺ ទ្រុលដោយស៊ុបទ្រុប ។

* *

*

# ធ

**ធន_ធាន.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធន (ទ្រព្យសម្បត្តិ) + ធាន (ការទ្រទ្រង់) ។ ទ្រព្យរបស់ផ្សេងៗដែលគង់នៅ ។ គេមានធនធានច្រើន ។ល។ បរិវារស័ព្ទ ធាន អាចគន្លាស់បានជាពាក្យ ធានដែលជាសម្បត្តិអ្នកមុន គឺ ធនដែលជាសម្បត្តិអ្នកមាន ពោលគឺ សម្បត្តិដែលគង់វង់នៅឬកំពុងទ្រទ្រង់នៅ ។

**ធូរ_ធារ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ការទ្រទ្រង់, ទប់ទល់ ធន់ទ្រាំ ។ល។ បរិវារស័ព្ទ ធូរ អាចគន្លាស់បានជាពាក្យ ធូរទប់ទល់ឬធនទ្រាំបានយារ គឺ ធារទប់ទល់ឬធន់ទ្រាំបានយូរ ។

**ធូរ_ធា.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រាកស្បើយ, មានបានបន្តិចបន្តួច ។ ឈ្មួញកណ្តាលសព្វថ្ងៃគេបានធូរធាណាស់ ។ បរិវារស័ព្ទ ធា អាចគន្លាស់បានជាពាក្យ ធាមួយគ្រូ គឺ ធូរមួយគ្រា ។ យើងអាចគន្លាស់បានជាវគ្គមួយទៀតថា ÷ ធាទើបចិត្តសាធូរ គឺ ធូរទើបចិត្តសទ្ធា ។

**ធូរ_ធារ.**- ធូរធារនេះ ជាពាក្យយើងប្រើចម្ងាសព្វថ្ងៃ មានន័យចំហទាំងពីរ គឺ ជាសមាសពាក្យ មួយពុំមានបរិវារស័ព្ទ ។

**ធំ_ធេង.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធំទូលាយក្រៃពេក ។ សមុទ្រធំធេង, វិមានធំធេង ។ បរិវារស័ព្ទ ធេង អាចគន្លាស់បានជាពាក្យ ធេងវង់រុំ គឺ ធំវង្វេង ឬ ធេងល្វឹងល្ហុំ គឺ ធំល្វឹងល្វេង ។

**ធ្ងន់_ធ្ងរ.**- ការនេះធ្ងន់ធ្ងរណាស់ គឺ ការនេះមានទម្ងន់ហើយពិបាកផង ។ល។ បរិវារស័ព្ទ ធ្ងរ អាចគន្លាស់បានជាពាក្យ ធ្ងរដូចនៅក្រោមគំនន់ គឺ ធ្ងន់ដូចនៅក្រោមគំនរ ។

**ធ្មឹង_ធ្មើយ.**- តាមវចនានុក្រម បានសេចក្តីថា ÷ នៅស្ងៀមមិនស្ដីដោយធ្វើព្រងើយ ។ អង្គុយធ្មឹងធ្មើយ ។ បរិវារស័ព្ទ ធ្មើយ អាចគន្លាស់បានជាពាក្យ ធ្មើយធ្វើឈឹង គឺ ធ្មឹងធ្វើឈើយ ។

**ថ្អឹង_ថ្អាំង.-** ពាក្យនេះ មានន័យចំហទាំងពីរ គឺ ថ្អឹង និង ថ្អាំង មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យ ថ្អឹងថ្អើយដែរ ។ ក្នុងពាក្យថ្អឹងថ្អាំងនេះយើងអាចយកពាក្យណាមកធ្វើបរិវារស័ព្ទ ក៏បានទាំងអស់ ហើយមានន័យប្រហែលគ្នាទៀតផង ។

**ឆ្នាំខ.-** ថ្អាំង អាចគន្លាស់បានជាពាក្យ ថ្អាំងដោយស្រឡាំងគឹង គឺ ថ្អឹងដោយស្រឡាំងកាំង ។

**ឆ្នឹខ.-** ថ្អឹង អាចគន្លាស់បានជាពាក្យ ថ្អឹង ដូចបាត់ព្រលាំង គឺ ថ្អាំង ដូចបាត់ព្រលឹង ។

**ធ្លុះ_ធ្លាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រហែករបើកដែលមានប្រហោងរហូតទៅម្ខាង ។ ជញ្ជាំងធ្លុះធ្លុះធ្លាយ គឺ ធ្លុះ រហែកប្រហោង ។ល។ បរិវារស័ព្ទ ធ្លុះ អាចគន្លាស់បានជាពាក្យ ធ្លុះត្រាតែធ្លាយ គឺ ធ្លាយត្រាតែធ្លុះ ។

* *

*

# ន

**នឹក_នា.**- ផ្ចួចក្នុងចិត្ត, ចាប់ភ្លឹក, ដួចក្នុងចិត្ត ។ល។ បរិវារស័ព្ទ នា អាចគន្លាស់បានជាពាក្យ នារកត្អឹត្អឹក គឺ នឹករកត្អឹត្អា ។

**នឹង_នរ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ នឹងជំហរ ។ បរិវារស័ព្ទ នរ អាចគន្លាស់បានជាពាក្យ នរជំហឹង គឺ នឹងជំហរ ។

**នឹង_នួន.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ នឹងធឹងសមរម្យ មិនឆ្គង ។ កូនក្មេងនេះឫកនឹងធឹងល្អណាស់ ។ បរិវារស័ព្ទ នួន អាចគន្លាស់បានជាពាក្យ នួនដោយឫកល្អ សមសឹង គឺ នឹងដោយឫកល្អសមសួន ។

**នឿយ_ណាយ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធុញ-

ទ្រាន់, ទ្រាន់ចិត្តជ្រេញចិត្តរសាយចិត្ត ។ បរិវារស័ព្ទ ណាយ អាចគន្លាស់បានជាពាក្យ ណាយដោយចិត្តរសើយ គឺ ឡើយ ដោយចិត្តរសាយ ។

នែប_និត្យ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អែបជិត, ផ្ដេកផ្ដិត, កៀកឱប ។ល។ ខ្ញុំសូមជូនឧទាហរណ៍ ដែលខ្ញុំដកស្រង់ពីសាស្ត្រាកាកី ព្រះរាជនិពន្ធដោយព្រះបាទអង្គឌួង ។

«នែបនិត្យក្រសោប ជួញជិតអង្គឱប អង្អែលឥន្ទ្រីយ ថើបថៃកាយា ភក្ត្រាកាកី កួចកើតមេត្រី រាគរសតណ្ហា» ។

បរិវារស័ព្ទ និត្យ អាចគន្លាស់បានជាពាក្យ និត្យឱ្យជែប គឺ នែបឱ្យជិត ។

នំ_នែក.- តាមវចនានុក្រម បានសេចក្ដីថា ÷ ចំណីអាហារមានច្រើនមុខ ។ បរិវារស័ព្ទ នែក អាចគន្លាស់បានជាពាក្យ នែកច្រើនមុខប៉ុំៗ គឺ នំច្រើនមុខប្លែកៗ ។

# ប

**បង្កាច់_បង្កិន.-** ពោលពាក្យ មួលកាច់ឱ្យខុសពីដំណើរពិត ។ បង្កាច់បង្កិនគេឱ្យខូចឈ្មោះ គឺ និយាយកាច់កិនគេឱ្យខុសពីដំណើរពិតដើម្បីឱ្យខូចឈ្មោះ ។ បរិវារស័ព្ទ បង្កិន អាចគន្លាស់បានជាពាក្យ បង្កិនឱ្យខុសខូចឈ្មោះកិនកាច់ គឺ បង្កាច់ឱ្យខុសខូចឈ្មោះកាច់កិន ។

**បង្ខា_បង្ខាំង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខាំងទុកមិនឱ្យទៅណាបាន ។ បរិវារស័ព្ទ បង្ខា អាចគន្លាស់បានជាពាក្យ បង្ខាទុកមិនឱ្យទៅណាំង គឺ បង្ខាំងទុកមិនឱ្យទៅណា ។

**បង្ខិត_បង្ខំ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បង្ខំខ្លាំងហាក់ដូចជាឱ្យចេះតែខិតចូលទៅមុខនឹងថយក្រោយវិញ ពុំបាន ។

បរិវារស័ព្ទ បង្អិត អាចគន្លាស់បានជាពាក្យ បង្អិតយ៉ាងប្រកំ គឺ បង្ខំយ៉ាងប្រកិត ពោលគឺ បង្អិតបង្ខំខ្លាំង ដោយកៀកជាប់ មិនឱ្យដោះដៃ ។

**បង្អិក_បង្អឹន.-** ហ្វឹកហ្វឺនឱ្យថ្នឹក, ធ្វើឱ្យថ្នឹក ។ បរិវារស័ព្ទ បង្ហឹន អាចគន្លាស់បានជាពាក្យ បង្ហឹនឱ្យថ្នឹកដោយហ្វឹនហ្វឹក គឺ បង្ហឹកឱ្យថ្នឹកដោយហ្វឹកហ្វឺន ។

**បង្វេះ_បង្វៀង.-** តាមវចនានុក្រម បានសេចក្ដីថា÷ ធ្វើឱ្យវេះវៀងគេចមុខឬផ្លូវ ។ បរិវារស័ព្ទ បង្វេះ អាចគន្លាស់បានជាពាក្យ បង្វេះឱ្យជៀង គឺ បង្វៀងឱ្យជៀស ពោលគឺ បង្វេះបង្វៀងឱ្យខ្វែងផ្លូវគ្នា កុំឱ្យជួបប្រទះ ។

**បង្វេះ_បង្វែរ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ធ្វើឱ្យវេរ, ឱ្យបែរវេះចេញ ។ បរិវារស័ព្ទ បង្វេះ អាចគន្លាស់បានជាពាក្យ បង្វេះឱ្យចៃរ គឺ បង្វែរឱ្យចៀស ។

**បង្ហិន_បង្ហោច.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យវិនាស, ឱ្យហិនហោច ។ បរិវារស័ព្ទ បង្ហោច អាចគន្លាស់បានជាពាក្យ បង្ហោចឱ្យវិនាសហោចហិន គឺ បង្ហិនឱ្យវិនាសហិនហោច ។

បង្អាប់_បង្អោន.- ធ្វើឱ្យអាប់អោន ។ បង្អាប់បង្អោនកេរ្តិ៍ឈ្មោះ ។ល។ បរិវារស័ព្ទ បង្អាប់ អាចគន្លាស់បានជាពាក្យ បង្អាប់ឱ្យអន់ថយជាលំដោន គឺ បង្អោនឱ្យអន់ថយជាលំដាប់ ។

បង្អែ_បង្អង់.- គឺបង្អង់ដោយដំណើរយឺតយូររ៉ែរ៉ៃ ។ បរិវារស័ព្ទ បង្អែ អាចគន្លាស់បានជាពាក្យ បង្អែយឺតយូរ ដោយអែ-មម៉ង់ គឺ បង្អង់យឺតយូរដោយអែ-មម៉ែ ។

បញ្ចើច_បញ្ចោល.- តាមវចនានុក្រម បានសេចក្ដីថា ÷ និយាយលើកបញ្ចោរ ថាល្អ ថាខ្ពស់ជាដើម ដើម្បីផលប្រយោជន៍ផ្ទាល់ខ្លួន ។ បរិវារស័ព្ទ បញ្ចោល អាចគន្លាស់បានជាពាក្យ បញ្ចោលថាល្អត្រគើច គឺ បញ្ចើចថាល្អត្រកាល ពោលគឺ បញ្ចើចឱ្យសប្បាយចិត្តត្រេកត្រអាល ។

បញ្ចើច_បញ្ចើ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពោលពាក្យលើកសរសើរហួសហេតុ ហួសទំនង ដោយទំយើ ។ បរិ-វារស័ព្ទ បញ្ចើ អាចគន្លាស់បានជាពាក្យ បញ្ចើបញ្ចោរសរសើរដោយទំយើច គឺ បញ្ចើចបញ្ចោរសរសើរដោយទំយើ ។

បញ្ជួស_បញ្ជុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើ

ឱ្យជ្រលូស, ឱ្យហួសពីទីកន្លែងដែលកំណត់ ដែលកម្រិត ។ បរិវារស័ព្ទ បញ្រួស អាចគន្លាស់បានជាពាក្យ បញ្រួសឱ្យហ៊ុល គឺបញ្រួលឱ្យហួស ។

បណ្ដាច់_បណ្ដោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យដាច់ខូចហីនហោច ។ បរិវារស័ព្ទ បណ្ដោច អាចគន្លាស់បានជាពាក្យ បណ្ដោចឱ្យខូចហីនហាច់ គឺ បណ្ដាច់ឱ្យខូចហិនហោច ។

បណ្ដុះ_បណ្ដាល.- ធ្វើឱ្យដុះដាល ។ បរិវារស័ព្ទ បណ្ដាល អាចគន្លាស់បានជាពាក្យ បណ្ដាលឱ្យដាលដុះ គឺ បណ្ដុះឱ្យដុះដាល ។

បណ្ដែ_បណ្ដាំ.- សេចក្ដីដែលផ្ដាំដោយហួរហៃ ។ ចូរស្ដាប់បណ្ដែបណ្ដាំចាស់ទុំ ។ល។ បរិវារស័ព្ទ បណ្ដែ អាចគន្លាស់បានជាពាក្យ បណ្ដែដោយដំបូន្មានជាហួរហាំ គឺ បណ្ដាំដោយដំបូន្មានជាហួរហៃរ ។

បណ្ដែត_បណ្ដោយ.- គឺបណ្ដោយឱ្យធ្វើតាមទំនើងចិត្ត មិនមើលថែទាំ, មិនត្រួតត្រាហាក់ដូចជាគេបណ្ដោយឱ្យអណ្ដែតតាមតែបាន ។ បរិវារស័ព្ទ បណ្ដែត អាចគន្លាស់បានជាពាក្យ បណ្ដែត

តាមទំនើងចិត្ត ដោយមិនត្រូតត្រាមើលហោយ គឺ បណ្តោយតាមទំនើងចិត្តដោយមិនត្រូតត្រាមើលហេតុ ។

**បត់_បែន.**- ធ្វើឱ្យបត់បែនពត់ពេន, ដែលបត់ពត់ពេន, ដែលវៀចពេនព័ទ្ធជាល្បត់ ។ ផ្លូវបត់បែន ។ បរិវារស័ព្ទ បត់ អាចគន្លាស់បានជាពាក្យ បត់ឱ្យវៀចពេនព័ទ្ធ ជាល្បែន គឺ បែនឱ្យវៀចពេនព័ទ្ធជាល្បត់ ។

**បន់_ស្រន់.**- តាមវចនានុក្រម មានន័យថា ÷ ពោលពាក្យសច្ចាថាសូមជួយឱ្យបានសម្រេចដូចបំណងដែលផ្តង ហើយនិងមាន-តង្វាយ ឬរង្វាន់លាបំណន់វិញពុំខាន ។ បន់ស្រន់អ្នកតា, អា-រ័ក្សឬមេមត់ ។

ក្នុងពិធីបន់ស្រន់នេះ គេតែងសង្កេតឃើញ ជាកិច្ច ជូនតង្វាយជាបណ្តោះអាសន្ន មានចេក ស្រា ។ល។ មុនបានសម្រេចដូចគោលបំណង ។ ដូច្នេះ បរិវារស័ព្ទ ស្រន់ អាចដោះស្រាយ បានជាពាក្យ គន្លាស់មួយស្របតាមដំណើររឿងផងដូចជា : ស្រន់នេះហើយជាតង្វាយ បណ្តោះអាសារ ពោល-គឺ ស្រានេះហើយជាតង្វាយបណ្តោះអាសន្ន ។

តង្វាយផ្លែចេកទុំ ដែលខ្មោចអារ័ក្ស ឬ មេមត់ចូលស្កិតភ្ជាមហើយទាររកជាពាក្យ ÷ កន្ទន់បាក់កនោះ គឺជាពាក្យក្លាយមកពីពាក្យបាលីថា ÷ កទលិបក្ក គឺ កទលិ + បក្ក ។ កទលិ = ចេក ; បក្ក = ទុំ ។ ខ្លះទៀតហៅថាមហាត្រសោល ។

**បន្តិច_បន្តួច.-** ដែលតិចតួច ។ របស់បន្តិចបន្តួច ។ល។ ធនធានបន្តិចបន្តួច គឺ ធនធានស្តួចស្តើងតិចពេក សូម្បីតែចោរក៏មិនអើពើចង់លួចឡើយ ដូច្នេះ បរិវារស័ព្ទ បន្តួច នេះ អាចគន្លាស់បានជាពាក្យមួយថា : បន្តួចពេកចោរហួសលិច គឺ បន្តិចពេកចោរហួសលួច ។

**បន្ថោក_បន្ថោង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ចងព្យួរតែងតោង លំនាំតោក ។ បរិវារស័ព្ទ កន្ថោក អាចគន្លាស់បានជាពាក្យ បន្ថោកព្យួរស្តោង គឺ បន្ថោងព្យួរស្តោក ។

**បន្ទប់_បន្ទឹង.-** តាមវចនានុក្រម បានសេចក្តីថា ÷ ទីកន្លែងមានជញ្ជាំងបាំងបិទសម្រាប់ដេក ឬ សម្រាប់ធ្វើការ ។ល។ បរិវារស័ព្ទ បន្ទឹង អាចគន្លាស់បានជាពាក្យ បន្ទឹងស្អាតរលប់ គឺ បន្ទប់ស្អាតរលីង ពោលគឺ បន្ទប់ទទេស្អាតគ្មានអ្វីទាំងអស់ ។ អ្នកខ្លះនិយាយជាពាក្យ កន្ទប់កន្ទឹងវិញ ។

**បន្ទិច_បន្ទៀន.**- ធ្វើឱ្យលេចលៀន ។ គាត់មិនដែលបន្ទិចបន្ទៀន ប្រាក់កាសបន្តិចបន្តួចឱ្យទៅកូនក្មួយឡើយ ។ល។ បរិវារស័ព្ទ បន្ទៀន អាចគន្លាស់បានជាពាក្យ បន្ទៀនបន្តិចបន្តួចធ្វើជាអំណោយតិច គឺ បន្ទិចបន្តិចបន្តួចធ្វើជាអំណោយទាន ។

**បន្លែ_បន្លុក.**- តាមវចនានុក្រម បានសេចក្ដីថា ÷ គឺបន្លែគ្រប់មុខ សម្រាប់ស្លដណ្ដាំ ។ល។ បរិវារស័ព្ទ បន្លុក អាចគន្លាស់បាន ជាពាក្យ បន្លុកគ្រប់ម៉ែ គឺ បន្លែគ្រប់មុខ ។ល។

**បន្លែ_បន្លយ.**- តាមវចនានុក្រម បានសេចក្ដីថា ÷ បញ្ចេញសម្ដីឬក ហេតុជាតម្រុយដើម្បីកែប្រែ ។ បរិវារស័ព្ទ បន្លែ អាចគន្លាស់ បានជាពាក្យ បន្លែជាសញ្ញាឱ្យកុយ គឺ បន្លយជាសញ្ញាឱ្យកែ ។

**បន្លែ_បន្លំ.**- តាមវចនានុក្រម មានន័យថា ÷ គឺ លបលួចលាក់ឱ្យច្រឡំ ឬកុំឱ្យគេឃើញដើម្បីនឹងប្រព្រឹត្តអំពើផ្សេងៗ ។ បរិវារស័ព្ទ បន្លែ អាចគន្លាស់បានជាពាក្យ បន្លែលួចលាក់ដើម្បីកំ គឺ បន្លំលួច លាក់ដើម្បីកែ ។

**បបរ_បបៀក.**- តាមវចនានុក្រម មានន័យថា ÷ អាហាររាវចម្អិន ដោយអង្ករ ។ បបរគ្រឿងឬបបរស ។ល។ បរិវារស័ព្ទ បបៀក

អាចគន្លាស់បានជាពាក្យ បបៀកក្តៅរឡ គឺ បបរក្តៅរលាក ពោលគឺ បបរក្តៅៗ ។

**បបែ_បបួល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ហៅរក, ឱ្យទៅឬឱ្យមកជាមួយ ។ខ្ញុំបានបបែបបួលវាឱ្យមកដែរ តែវាពុំព្រម ។ល។ បរិវារស័ព្ទ បបែ អាចគន្លាស់បានជាពាក្យ បបែឱ្យព្រមតាមដួល គឺ បបួលឱ្យព្រមតាមដែរ ។

**បម្រើ_បម្រាស់.-** ទទួលភារៈតាមកិច្ចដែលគេប្រើប្រាស់ ។ បរិវារស័ព្ទ បម្រាស់ អាចគន្លាស់បានជាពាក្យ បម្រាស់តាមបញ្ជាគេប្រាស់ប្រើ គឺ បម្រើតាមបញ្ជាគេប្រើប្រាស់ ។

**បម្រែ_បម្រុង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ផ្គងគំនិតប្រុងរៀបចំទុកបម្រុង ។ បរិវារស័ព្ទ បម្រែ អាចគន្លាស់បានជាពាក្យ បម្រែរៀបចំទុក ដោយហូហុង គឺ បម្រុងរៀបចំទុកដោយហូរហែ ។

**បរ_បាញ់.-** នៅសម័យដើម ព្រាហ្មបរបាញ់ គឺជនប្រមាញ់ប្រកបមុខរបរប្រភេទនេះ ដើម្បីចិញ្ចឹមជីវិតនិងសាច់សត្វដែលបាញ់បានព្រមទាំងបំបែក ភាគខ្លះយកទៅដូរជា អំបិល ជាអង្ករ ។ល ។

ដូច្នេះ បរិវារស័ព្ទ បរ អាចគន្លាស់បានជាពាក្យ បរបានសាច់ដើម្បី ដូរអង្កាញ់ គឺ បាញ់បានសាច់ដើម្បីដូរអង្ករ ។

បាក់_បប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ចុះចាញ់រាបឥត ប៉ានខ្ទើក ព្រមទាំងមានរបបរាបសារៀបរយផង ។ បច្ចាមិត្រ បានចាញ់ដៃបាក់បកខ្ទបខ្ទាច ។ល។ បរិវារស័ព្ទ បប អាចគន្លាស់ បានជា បបចាញ់ដៃជារណាក់ គឺ បាក់ចាញ់ដៃជារណប ។

បាំង_បាំុ.- ពាក្យនេះខ្មែរយើងច្រើនប្រើនៅសម័យ អនានិគមព្រោះ កាលនៅជនជាតិបរទេស អឺរុបទាំងប៉ុន្មានសុទ្ធសឹងជាអ្នកធំ ៗ ទាំងអស់ ទោះបីជននេះជាជនដើរលេង ប៉ៅឡៅគ្មានមុខរបរ អ្វីក៏ដោយ ។ អាស្រ័យហេតុនេះហើយបានជាបរិវារស័ព្ទ បាំុ អាចគន្លាស់បានជាពាក្យ បាំុអ្នកធំង ១ គឺ បាំងអ្នកធំ ១ ឧទាហរណ៍ : កន្លែងដែលគេរៀបចំនេះ សំរាប់តែអស់លោក បាំងបាំុទេ ។ល។

បាវ_ព្រាវ.- ជនខ្សត់ខ្សោយដែលបម្រើយើង ។ សូមមើលប្រវត្តិជន បម្រើយើងតាមទម្លាប់ទំនៀមខ្មែរយើងនាសម័យបុរាណ ដែល ខ្ញុំបានអធិប្បាយនៅក្នុងពាក្យមនុស្សម្នា ។ អាស្រ័យហេតុនេះ

ខ្ញុំសូមគ្រាន់តែបន្ថែមសេចក្ដីបន្តិច ចំពោះបរិវារស័ព្ទ ព្រាវ ដែលមានន័យថា ÷ ដោយស្មាន, ទាំងប្រថុយឬបំពានទាំងប្រថុយដោយដឹងពុំប្រាកដ ។ល។

បាវព្រាវ បានសេចក្ដីថា ÷ មនុស្សគេដាក់ក្នុងបាវលក់ឱ្យយើងដែលបានទិញយកប្រើប្រាស់, ដោយព្រាវ ពោលគឺយើងគ្មានបានឃើញជាក់ស្ដែងនឹងភ្នែក ឬជ្រើសរើសតាមចេត្នា តើជននៅក្នុងបាវនោះមានសភាពដូចម្ដេច ។ ដូច្នេះពាក្យបាវព្រាវនេះ មានន័យចំហទាំងពីរ ហើយពុំឃើញមានបរិវារស័ព្ទគន្លាស់ផ្សំបានជាវគ្គអ្វីឡើយ ។ មូលហេតុទៅ : បាវព្រាវនេះ គឺ មនុស្សនៅក្នុងបាវដែលយើងបានទិញមកដោយព្រាវ ។

**បី_បម**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បីថ្នមដោយស្ងួនគ្រង ។ បីបមថ្នមព, ដោយថ្នាក់ថ្នម ។ បរិវារស័ព្ទ បម អាចគន្លាស់បានជាពាក្យ បបដោយថ្មី គឺ បីដោយថ្នម ។

**បី_បាច់**.- ថែរក្សាដោយយកចិត្តទុកដាក់ ។ ក្មេងនេះខ្ញុំបានបីបាច់ថែរក្សាតាំងពីតូចមក ។ បរិវារស័ព្ទ បាច់ អាចគន្លាស់បានជាពាក្យបាច់លៀងអី គឺ បីលៀងអាចម៍ ពោលគឺ ពុំមែនបីគក់ប្រចាច់

ឡើយ ព្រោះយើងច្រើនស្រដីពាក្យ បីបាច់នេះក្នុងវគ្គចិញ្ចឹមបីបាច់ថែរក្សាកូនចៅ ពុំមែនចិញ្ចឹមបីបាច់ថែរក្សាមនុស្សចាស់ឡើយ ។

**បៀត_បៀន.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ជ្រៀតបៀត, យាយី, ធ្វើទុក្ខធ្វើទោសអ្នកដទៃ ឱ្យបានសេចក្ដីក្ដៅក្រហាយ ។ កុំបៀតបៀនគេ ។ល។ បរិវារស័ព្ទ បៀន អាចគន្លាស់បានជាពាក្យ បៀនឱ្យនៅកៀត គឺ បៀតឱ្យនៅកៀន ពោលគឺ ÷ បៀតបៀនជ្រៀតបៀត ធ្វើឱ្យស្មើរតែរកដង្ហើមដក ពុំបានហាក់ដូចជានៅកៀនកន្លៀតតូច ។

**បំណែ_បំណាង.-** គឺសេចក្ដីប៉ងជារឿយៗ ។ ខ្ញុំពុំមានបំណែបំណាងអ្វីចង់ព្យាបាទគេទេ ។ បរិវារស័ព្ទ បំណែ អាចគន្លាស់បានជាពាក្យ បំណែប៉ុនប៉ងដោយហួហាង គឺ បំណាងប៉ុនប៉ងដោយហួរហែ ។

**បំណែ_បំណុល.-** តាមវចនានុក្រម បានសេចក្ដីថា ÷ បំណុលច្រើនជំពូកដោយបុលបណ្ដាក់រៀងៗមក ។ បរិវារស័ព្ទ បំណែ អាចគន្លាស់បានជាពាក្យ បំណែខ្ចីបណ្ដាក់ដោយហួហុល គឺ បំណុល ខ្ចីបណ្ដាក់ដោយហួរហែ ។

**បំបះ_បំបោរ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ នាំឱ្យបះបោរ ឱ្យផ្អើលជ្រួលជ្រើម ។ បរិវារស័ព្ទ បំបោរ អាចគន្លាស់បានជាពាក្យ បំបោរឱ្យកាន់ចិត្តជាចាស់ គឺបំបះឱ្យកាន់ចិត្តជាចោរ ពោលគឺ ទាល់តែអ្នកប្រកាន់ចិត្តជាចោរ ទើបប្រទូស្តរ៉ាយនឹងសេចក្តីសុខសាន្ត ។

**បំផះ_បំផាយ.**- គឺបំបោលឱ្យលឿនពេញកម្លាំង ។ បរិវារស័ព្ទ បំផះ អាចគន្លាស់បានជាពាក្យ បំផះឱ្យបោលលឿនឆាប់រហាយ គឺ បំផាយឱ្យបោលលឿនឆាប់រហ័ស ។

**បំផ្លិច_បំផ្លាញ.**- តាមវចនានុក្រម បានសេចក្តីថា ÷ គឺ បំផ្លាញឱ្យគេលិចលង់ ហិនហោច វិនាសអន្តរាយ ។ បរិវារស័ព្ទ បំផ្លិច អាចគន្លាស់បានជាពាក្យ បំផ្លិចឱ្យវិនាសហិនហោចខ្លាញ គឺ បំ-ផ្លាញឱ្យវិនាសហិនហោចខ្ទេច ។

**បំពារ_បំពាន.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពារពានលើ, រំលោភលើ ។ បំពារបំពានលើច្បាប់ ។ ល ។ បរិវារស័ព្ទ បំពាន អាចគន្លាស់បានជាពាក្យ បំពានរំលោភលើទាំងប្រណិ-ធារ គឺ បំពាររំលោភលើទាំងប្រណិធាន ពោលគឺ រំលោភលើ

សេចក្ដីស្បថសច្ចាដោយពុំមានសេចក្ដីកោតញញើត ។ ពាក្យប្រណិធាននេះ យើងបានប្រើក្លាយសព្ទថ្ងៃទៅជាពាក្យ ប្រាំធានទៅវិញ ។

**បំពើត_បំពើង.-** គឺ បំពើងខ្លួនឱ្យខ្ពស់ទាបចុះឡើង ។ បរិវារស័ព្ទ បំពើត អាចគន្លាស់បានជាពាក្យ បំពើតខ្លួនឱ្យយ៉ាងខ្មើង គឺ បំពើងខ្លួនឱ្យយ៉ាងខ្មើត ។

**បំពោក_បំពោរ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ធ្វើឱ្យពោរឡើង, ឱ្យមានពោរពាស ។ បំពោកបំពោរភោជនាហារ ។ល។ បរិវារស័ព្ទ បំពោក អាចគន្លាស់បានជាពាក្យ បំពោកឱ្យមានច្រើនគោកគោរ គឺ បំពោរឱ្យមានច្រើនគរគោក ។

**បំភិត_បំភ័យ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យគេភ័យខ្លាំង ។ បំភិតបំភ័យគេឱ្យខ្លាច, ឱ្យព្រួយចិត្ត បរិវារស័ព្ទ បំភិត អាចគន្លាស់បានជាពាក្យ បំភិតឱ្យគេព្រួយដៃ គឺ បំភ័យឱ្យគេព្រួយចិត្ត ។

**បំភ្លើត_បំភ្លើន.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលធ្វើឱ្យចូលចិត្តសប្បាយភ្លេចខ្លួន ហួសហេតុហួសផលដល់ទៅឡើងចាង

ក្រអឺតក្រអោង។ល។ បរិវារស័ព្ទ បំភ្លើត អាចគន្លាស់បានជា-ពាក្យ បំភ្លើត ឱ្យសប្បាយបានចិត្តក្រអឺន គឺ បំភ្លើនឱ្យសប្បាយបានចិត្តក្រអឺត ។

**បំភ្លេច_បំភ្លាំង.**- ដែលនាំឱ្យភ្លេចភ្លាំង ។ សូមមើលពាក្យ ភ្លេចភ្លាំង ។

**បះ_បើក.**- តាមវចនានុក្រម បានសេចក្ដីថា ÷ បះ បង្ហើបចុះបង្ហើប-ឡើង ពីម្ខាងទៅម្ខាង, កម្រើកងើបឡើងចុះ ។ បរិវារស័ព្ទ បើក អាចគន្លាស់បានជាពាក្យ បើក ដោយទម្ងន់មិនស្មើគ្នានាំឱ្យកម្រេះ គឺ បះ ដោយទម្ងន់មិនស្មើគ្នា នាំឱ្យកម្រើក ឬ នាំឱ្យប៉ះប៉ើក ។

**បះ_បោរ.**- សូមមើលពាក្យ បំបះបំបោរ ។

**ប៉ប៉ាច់_ប៉ប៉ោច.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល-ពោលប៉ាច់ៗប៉ោចៗមិនដាច់សួរ ។ និយាយប៉ប៉ាច់ប៉ប៉ោច ។ បរិវារស័ព្ទ ប៉ប៉ោច អាចគន្លាស់បានជាពាក្យ ប៉ប៉ោចច្រើនពេកដោយស្ដាប់ពុំដឹងខ្ចាច់ គឺ ប៉ប៉ាច់ច្រើនពេកដោយស្ដាប់ពុំដឹងខ្ចោច ពោលគឺ និយាយប៉ប៉ាច់ប៉ប៉ោចច្រើនពេកទៅ គ្មានអ្នកណាយកត្រចៀកស្ដាប់ ហាក់ដូចជានិយាយជាមួយខ្មោច ។

**ប៉ប៉ាច់_ប៉ពូ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប៉ប៉ាច់ រអ៊ូរទាំមិនសូវស្រាក់ ។ បរិវារស័ព្ទ ប៉ពូ អាចគន្លាស់បានជាពាក្យ ប៉ពូ មិនស្រាក់ដោយរអាច់ គឺ ប៉ប៉ាច់មិនស្រាក់ដោយ-រអ៊ូ ពោលគឺ និយាយប៉ប៉ាច់ប៉ពូបែកពពុះមាត់ ។

**ប៉ប៉ិច_ប៉ប៉ាច់.-** គឺ សើម ឬ ជ្រាយប៉ប៉ាច់ខ្លាំង ។ ភ្លៀងធ្លាក់នាំឱ្យប៉ប៉ិចប៉ប៉ាច់ដីអស់ ។ បរិវារស័ព្ទ ប៉ប៉ិច អាចគន្លាស់បានជា-ពាក្យ ប៉ប៉ិចភក់ជ្រាំកខ្វាច់ គឺ ប៉ប៉ាច់ភក់ជ្រាំកខ្វិច ។

**ប៉ប៉ិល_ប៉ប៉ូច.-** តាមវចនានុក្រម មានន័យថា ÷ ដែលខិលខូចក្រមិច-ក្រមើមណាស់ ។ ក្មេងប៉ប៉ិលប៉ប៉ូច ។ បរិវារស័ព្ទ ប៉ប៉ិល អាចគន្លាស់បានជាពាក្យ ប៉ប៉ិលក្រមិចក្រមើម ខិលខូច គឺ ប៉ប៉ូចក្រមិចក្រមើមខូចខិល ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ រប៉ិលរប៉ូចវិញ ។

**ប៉ប៉ុក_ប៉ប៉ាច.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលព-ពុលជាន់ដើរទៅរអិល ។ ដីភក់ប៉ប៉ុកប៉ប៉ាច់ ។ បរិវារស័ព្ទ ប៉ប៉ុក អាចគន្លាស់បានជាពាក្យ ប៉ប៉ុករអិលពពុលក្នុងផាច់ គឺ ប៉ប៉ាច់រអិលពពុលក្នុងភក់ ។

**ប៉ប៉ះ_ប៉ប៉ុន.**- តាមវចនានុក្រម បានសេចក្តីថា ÷ ប៉ះផ្សែផ្សំឱ្យតែកើតការ ។ បរិវារស័ព្ទ ប៉ប៉ុន អាចគន្លាស់បានជាពាក្យ ប៉ប៉ុនឱ្យកើតការដោយកែកះ គឺ ប៉ប៉ះឱ្យកើតការដោយកែកុន ។

**ប៉ប្លែច_ប៉ប្លូច.**- គឺប្លែចប្លូចក្រៃពេក ។ និយាយប៉ប្លែចប៉ប្លូចតាមតែរអិលមាត់ ។ បរិវារស័ព្ទ ប៉ប្លែច អាចគន្លាស់បានជាពាក្យ ប៉ប្លែចយ៉ាងរអិលមាត់ ស្រួលដូចបញ្ចុកចូច គឺ ប៉ប្លូចយ៉ាងរអិលមាត់ស្រួលដូចបញ្ចុកចេក ពោលគឺ ចេះតែនិយាយឱ្យតែរួចពីមាត់ ពុំមានគិតពិចារណារករាក់ជ្រៅ ឬ សមហេតុផល ប្រៀបធៀបដូចការបកចេកបរិភោគ ព្រោះការបកចេកបរិភោគនេះពុំមានកិច្ចអ្វីធ្វើឱ្យពិបាកឡើយ ។

**ប៉ប្លេះ_ប៉ប្លោះ.**- ដែលប្លេះប្លោះច្រើនពន់ពេក ។ ដែលឡេះឡោះក្រៃពេក ។ ឬកពាប៉ប្លេះប៉ប្លោះ ។ បរិវារស័ព្ទ ប៉ប្លោះ អាចគន្លាស់បានជាពាក្យ ប៉ប្លោះពន់ពេក ដោយឫកឡោះឡេះ គឺ ប៉ប្លេះពន់ពេក ដោយឫកឡេះឡោះ ។

**ប៉ផុត_ប៉ផើយ.**- រលីបរលាប ស្មើរខ្ទះ ស្មើរគ្រាន់ ។ ម្ហូបប៉ផុត-ប៉ផើយ ។ បរិវារស័ព្ទ ប៉ផើយ អាចគន្លាស់បានជាពាក្យ

ប៉ផើយរលីបរលាបចុងបង្កុត គឺ ប៉ផុតរលីបរលាបចុងបង្ហើយ ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ប្រផិតប្រផើយវិញ ។

**ប៉ផ្ទាក់_ប៉ផ្ញើក.-** គឺផ្ទាក់ផ្ញើក ឬ ង៉ាក់ងើករឿយ ៗ ។ ជិះរទេះរលាក់ប៉ផ្ទាក់ប៉ផ្ញើក ។ល។ បរិវារស័ព្ទ ប៉ផ្ញើក អាចគន្លាស់បានជាពាក្យ ប៉ផ្ញើករលាក់ង៉ើកង៉ាក់ គឺ ប៉ផ្ទាក់រលាក់ង៉ាក់ង៉ើក ។

**ប៉ផ្លិត_ប៉ផ្លក់.-** ស្លឹកស្លក់, ត្រដាបត្រដួស ។ បរិវារស័ព្ទ ប៉ផ្លក់ អាចគន្លាស់បានជាពាក្យ ប៉ផ្លក់ស្លក់ស្លឹត គឺ ប៉ផ្លិត ស្លឹតស្លក់ ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ប៉ផ្លើតប៉ផ្លក់ ។

**បរេ_បរោ.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលប្រព្រឹត្តឆ្វេងក្រៅច្បាប់ ។ ជនបរេបរោ គឺ ជនពុំបានការចោលបង់ម្បៀត ។ល។ បរិវារស័ព្ទ បរេ អាចគន្លាស់បានជាពាក្យ បរេដោយប្រព្រឹត្តខុសគោ គឺ បរោដោយប្រព្រឹត្តខុសគេ ។

**ប៉ុន_ប៉ង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មានបំណង គឺ ផ្តងបំណងទុក ។ ជននេះមានគំនិតប៉ុនប៉ងប្រព្រឹត្តអំពើអ្វីមួយ ។ បរិវារស័ព្ទ ប៉ុន អាចគន្លាស់បានជាពាក្យ ប៉ុនចិត្តគំនិតទុកជាម៉ង គឺ ប៉ងចិត្តគំនិតទុកជាមុន ពោលគឺ ផ្តងបំណងទុកមុនឱ្យស្រេច ។

**ប៉ះ_ប៉ុន.**- បិទផ្ចិត ។ សូមមើលពាក្យប៉ប៉ះប៉ប៉ុន ។

**ប្ដី_សី.**- តាមវចនានុក្រម បានសេចក្ដីថា ÷ ប្ដី ស្រី ឬ ប្ដី សេរី គឺ ប្ដី ស្រី សួស្ដីឬប្ដីរបស់ស្រី (?) ដូច្នេះ ឃើញថាន័យនេះនៅប្រហាក់ប្រហែលនៅឡើយព្រោះបុច្ឆនសញ្ញា (?) – នៅខាងចុងឃ្លា ។ តាមយោបល់ខ្ញុំវិញ ពាក្យ ប្ដីសីនេះជាពាក្យ សំណួរដែលខ្មែរយើងច្រើនពោលសួរចំពោះមិត្តភ័ក្តិ ឬសាច់សាលោហិតជាដើម ដូចតទៅនេះ ÷ តើកូនចៅមានប្ដីសីហើយឬនៅ ។ល។ បរិវារស័ព្ទ សី នេះពុំមានសម្លេងដូច បរិវារស័ព្ទ ក្នុងសមាសពាក្យដទៃទៀត ដែលច្រើនមានសម្លេងផ្ដួលរៀងតាមគ្នាដូចជាពាក្យ សម្លសម្លុក មាំមួន ។ល។ ពាក្យប្ដីសីនេះ មានសម្លេងប្ដីជាស័ព្ទដើម និងសីជាបរិវារស័ព្ទ ។ ដូច្នេះ បើយើងពិនិត្យនូវសំណួរដូចបានជូនជាឧទាហរណ៍ខាងលើនេះ យើងឃើញគោលដៅនៃសំណួរនោះ ថាចង់គាស់កកាយឱ្យដឹងឬសគល់សព្វគ្រប់ទាំងអស់ ចំពោះពតិមានក្នុងគ្រួសារ ។ អាស្រ័យហេតុដូចខាងលើនេះ យើងអាចសន្និដ្ឋានបានថា ÷ សីជាពាក្យ

គន្លាស់ថា ÷ សីជាថ្មា គឺ សាជាថ្មី ពោលគឺ អ្នកសួរចង់ដឹង ថា ÷ កូនស្រីនោះមានប្តីហើយ តើប្តីនោះនៅគង់វង្សរួម សុខទុក្ខជាមួយគ្នាសព្វថ្ងៃទេ ឬបែកបាក់គ្នាទៅហើយ ឬមានគូរស្រករថ្មីទៀត ឬយ៉ាងដូចម្តេច ។

ប្រកាក់_ប្រកប.- គឺ កាក់កប, គឺ បានកបដោយបានទទួលលទ្ធផលសមតាមបំណង ។ សូមមើលពាក្យកាក់កប ។

ប្រកែ_ប្រកាន់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ចាប់ដំណើររឿង, ចាប់ហេតុចាប់ថ្នាក់ ដើម្បីចោទប្រកាន់ ។ បរិវារស័ព្ទ ប្រកែ អាចគន្លាស់បានជាពាក្យ ប្រកែចាប់ថ្នាក់ចោទប្រកាន់ជាប់ដូចបំណងខ្សាន់ គឺ ប្រកាន់ចាប់ថ្នាក់ចោទប្រកាន់ជាប់ដូចចំណងខ្សែ ។

ប្រចុប_ប្រចែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយផ្សំផ្សំលើកជើង ដោយបញ្ចេញស្នៀតគ្រប់វិធី, ជួយចាត់ចែងកិច្ចការគ្រាន់តែហោះហោះ ហោះហ៏ ផ្សំផ្សំ ដោយប្រើមធ្យោបាយប្រចុបឱ្យគេចាប់ចិត្ត ។ បរិវារស័ព្ទ ប្រចែង អាចគន្លាស់

បានជាពាក្យ ប្រថែងដើម្បីឱ្យឃើញថា មានចិត្តឈឺឆ្អាល ដូច-គេអុប គឺ ប្រចុបដើម្បីឱ្យឃើញថាមានចិត្តឈឺឆ្អាលដូចគេឯង ។

ប្រថៃ_ប្រច័ណ្ឌ.- តាមវចនានុក្រម បានសេចក្តីថា ÷ ច្រណែនអន្ទះអន្ទែងព្រោះកាមរោគ ។ បរិវារស័ព្ទ ប្រថៃ អាចគន្លាស់បានជាពាក្យ ប្រថៃព្រោះកាមរោគនៅជាប់ស្អាន់ គឺ ប្រច័ណ្ឌព្រោះកាមរោគនៅជាប់ស្នេហ៍ ។

ប្រជុំល_ប្រជ្ជុំស.- សូមមើលពាក្យ ជ្រុលជ្រូស ។

ប្រញាប់_ប្រញាល់.- ពាក្យនេះ មានអត្ថន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ ប្រញឹកប្រញាប់ ហើយនិងពាក្យ ប្រញិបប្រញាប់ដែរ ។ បរិវារស័ព្ទ ប្រញាល់ អាចគន្លាស់បានជាពាក្យប្រញាល់ដោយមានការជាឱរ៉ាប់ គឺ ប្រញាប់ ដោយមានការជាឱរ៉ាល ពោលគឺ ប្រញាប់ដោយមានការចម្បាប ។

ប្រញិប_ប្រញាប់.- ពាក្យនេះ មានន័យ ប្រហាក់ប្រហែលនឹងពាក្យប្រញឹកប្រញាប់ គឺ ប្រញាប់ជាបន្ទាន់ ដោយដុតដៃដុតជើងយ៉ាងរួសរាន់បំផុត ។ បរិវារស័ព្ទ ប្រញិប អាចគន្លាស់បានជា

ពាក្យ ប្រញិបជាបន្ទាន់ឱ្យព្រិបប្រាប់ គឺ ប្រញាប់ជាបន្ទាន់ឱ្យ-ប្រាប់ព្រិប ។

**ប្រញឹក_ប្រញាប់.-** គឺបង្ខំឱ្យប្រញាប់ ឱ្យឆាប់ ។ បរិវារស័ព្ទ ប្រញឹក អាចគន្លាស់បានជាពាក្យ ប្រញឹកដោយមានការមមាញាប់ គឺ ប្រញាប់ដោយមានការមមាញឹក ។

**ប្រដាប់_ប្រដា.-** គឺ គ្រឿងប្រដាប់ផ្សេងៗ ច្រើនមុខ ច្រើនយ៉ាង សម្រាប់ប្រើប្រាស់ ។ល។ ពាក្យ ប្រដា នេះជាពាក្យអារ៉ាប់ Barda à បារដា ដែល បារាំងខ្ចីមកប្រើមានន័យដូចពាក្យខ្មែរ ប្រដាប់ដែរ ហើយច្រើនប្រើជាគ្រាមភាសា នៃក្រុមទាហាន (Argot militaire) ។ ពាក្យ បារដា នេះទៀត ខ្មែរយើងបាន ខ្ចីពីបារាំង (បារដា Barda) មកប្រើក្លាយបន្តិច ដោយកាល នោះ ទាហានខ្មែរ និងទាហានបារាំង បានរស់នៅជាមួយគ្នាជិត មួយសតវត្ស ។ ពាក្យ បារដា ដែលយើងហៅក្លាយជា ប្រដា វិញ នោះមានន័យថា ÷ គ្រឿង ឬ ប្រដាប់ផ្សេងៗ ច្រើនយ៉ាង គ្រប់មុខ ។ បើតាមពាក្យទាហានមួយ បារដា គឺគ្រឿងមួយ កុមភ្លេ (complet) ឬ មួយប្រដាប់មានរបស់ផ្សេងៗច្រើនមុខ

ច្រើនយ៉ាងទាំងអស់សម្រាប់ទាហានមួយរូប១ ។ ពោលគឺ មួយ បារដា គឺ មួយប្រដាប់ ឬ មួយកុមភ្លៃ ។ ដូច្នេះ បរិវារស័ព្ទ ប្រដា អាចគន្លាស់បានជាពាក្យ ប្រដា ច្រើនគ្រឿងគ្រប់ចំនួន ប្រើកាប់ គឺ ប្រដាប់ច្រើនគ្រឿងគ្រប់ចំនួនប្រើការ ។

ប្រដៃ_ប្រដៅ.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ គឺស្តីប្រដៅឱ្យដឹងខុសដឹងត្រូវ ក្នុងវេលាដែលបុគ្គលបានប្រព្រឹត្តខុសរួចហើយ ។ ប្រដៃប្រដៅ កូនចៅឱ្យមានសុជីវធម៌ ។ល។ បរិវារស័ព្ទ ប្រដៃ អាចគន្លាស់បានជាពាក្យ ប្រដៃស្តីឱ្យដឹងខុស ដឹងត្រូវ ដោយហូហៅ គឺ ប្រដៅស្តីឱ្យដឹងខុស ដឹងត្រូវ ដោយហូរហែ ។

ប្រណិត_ប្រណម្យ.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ផ្គង់កាយគោរព, លើកដៃប្រណម្យដោយផ្ចិតផ្គង់, ផ្ចិតផ្គង់អស់ពីចិត្ត ។ បរិវារស័ព្ទ ប្រណិត អាចគន្លាស់បានជាពាក្យ ប្រណិតផ្គង់កាយគោរពដោយអស់ពីចំ គឺ ប្រណម្យកាយគោរពដោយអស់ពីចិត្ត ។

ប្រតេក_ប្រតោក.- ដែលប្រឡាក់ ឬ ដាមប្រតាក ឬ ស្រកាកច្រើនពេក ។ បរិវារស័ព្ទ ប្រតេក អាចគន្លាស់បានជាពាក្យ ប្រតេក

ជាប់ប្រឡាក់ច្រើនប៉ាក គឺ ប្រតាកជាប់ប្រឡាក់ច្រើនពេក ។

ប្រតែង_ប្រតោង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឺ ប្រតោងចាប់ដោយប្រវេប្រវា, ព្យួរជារំយោល រណែង រណោង ។ ប្រតែងប្រតោង ខ្វាត់ខ្វែង ។ បរិវារស័ព្ទ ប្រតែង អាចគន្លាស់បានជាពាក្យ ប្រតែងជារំយោល រណែងរណោង គឺ ប្រតោងជារំយោលរណោងរណែង ឬ ប្រតែងចាប់ស្រវា-ស្រតោង គឺ ប្រតោងចាប់ស្រវាស្រទែង ពោលគឺ ប្រតោងចាប់ស្រវាស្រទាញ ។

ប្រចុំច_ប្រចិ.- តាមវចនានុក្រម បានសេចក្ដីថា ÷ ប្រចិភ្លាម ៗ យ៉ាងមមាញឹក ឬ បង្ខំខ្លាំង ។ បរិវារស័ព្ទ ប្រចិ អាចគន្លាស់បានជាពាក្យ ប្រចិដោយបង្ខុច គឺ ប្រចុចដោយបង្ខំ ។

ប្រចុំយ_ប្រចាន.- តាមវចនានុក្រម មានសេចក្ដីថា ÷ ប្រចុយខ្លួនដោយគំនិតថា ÷ តាមតែដូចម្ដេចក៏ដោយ ។ ដូច្នេះ បរិវារ-ស័ព្ទ ប្រចាន អាចគន្លាស់បានជាពាក្យ ប្រចានឱ្យតែបុយ គឺ ប្រចុយឱ្យតែបាន ។

ប្រទាញ_ប្រទង់.- ដែលទាញទង់គ្នាទៅវិញទៅមករឿយៗ ។ ប្រ-

ទាញប្រទង់គ្នាទាល់តែខូចខាតអស់ ។ល។ បរិវារស័ព្ទ ប្រទង់ អាចគន្លាស់បានជាពាក្យ ប្រទង់ឱ្យខូចខុសជ្រាញ គឺ ប្រទាញ ឱ្យខូចខុសជ្រុង ពោលគឺ ប្រទាញប្រទងគ្នាឱ្យបានសៅហ្មង ឬកើតរឿងកើតហេតុ ដែលជាការខុសលំនាំ ខុសច្បាប់ ខុស ជ្រុង ។ល។

**ប្រផុត-ប្រផើយ.-** តាមវចនានុក្រម បានសេចក្តីថា ÷ ចាប់ផុត១ ខ្ទះតែបន្តិចទៀតនឹងដល់ ។ សូមមើលពាក្យ ប៉ផុតប៉ផើយ ។

**ប្រមែ-ប្រមាណ.-** ការរាប់, ស្ទង់, ត្មេរ, ស្មាន, ចំនួន ។ល។ ការ ហ្នឹងវាមានតម្លៃប្រមែប្រមាណណាទៅ? បរិវារស័ព្ទ ប្រមែ អាចគន្លាស់បានជាពាក្យ ប្រមែមានតម្លៃប៉ុន្មានណាទៅដាន គឺ ប្រមាណមានតម្លៃប៉ុន្មានណាទៅដែរ ។

**ប្រមែ-ប្រមូល.-** តាមវចនានុក្រម បានសេចក្តីថា ÷ ធ្វើឱ្យមូលផ្តុំ, ឱ្យ រួបរួមគ្នាមិនឱ្យរាត់រាយឬខ្ចាត់ខ្ចាយ ។ បរិវារស័ព្ទ ប្រមែ អាច គន្លាស់បានជាពាក្យ ប្រមែផ្តុំមិនឱ្យរាត់រាយស្ងួល គឺ ប្រមូលផ្តុំ មិនឱ្យរាត់រាយស្មែ ។

ប្រមែ_ប្រមុម.- តាមវចនានុក្រម បានសេចក្ដីថា ÷ គឺ ប្រមុមប៉ះប៉ុនផ្សែផ្សំឱ្យតែកើត ។ បរិវារស័ព្ទ ប្រមែ អាចគន្លាស់បានជាពាក្យ ប្រមែផ្សែផ្សំឱ្យកើតការជាស្រេចដោយពុំមានកុំ គឺប្រមុមផ្សែផ្សំឱ្យកើតជាការស្រេច ដោយពុំមានកែ ពោលគឺសម្រេចឱ្យបានការ ដោយពុំមានកែប្រែទៀត ។

ប្រយ័ត្ន_ប្រយែង.- តាមវចនានុក្រម បានសេចក្ដីថា ÷ ប្រយ័ត្នដោយយកចិត្តទុកដាក់និងដោយប្រឹងប្រែង ។ បរិវារស័ព្ទ ប្រ-យែង អាចគន្លាស់បានជាពាក្យ ប្រយែងយកចិត្តទុកដាក់ដោយប្រឹងប្រាត់ គឺ ប្រយ័ត្នយកចិត្តទុកដាក់ដោយប្រឹងប្រែង ។

ប្រវេ_ប្រវា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លូកដៃឈោងចាប់ដោយប្រវាទាំងត្រដរ ។ ក្មេងលង់ទឹកខំប្រវេប្រវាតោងទូក ។ បរិវារស័ព្ទ ប្រវេ អាចគន្លាស់បានជាពាក្យ ប្រវេឈោងរកតោងចាប់ឯងកា គឺ ប្រវាឈោងរកតោងចាប់ឯងគេ ។

ប្រសេក_ប្រសាច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបែកខ្ញែក ច្របូកច្របល់គ្នាដូចគេបាចសាច ។ ក្មេងរត់

លេងប្រសេកប្រសាច ។ បរិវារស័ព្ទ ប្រសេក អាចគន្លាស់បានជាពាក្យ ប្រសេកច្រើនប៉ាច គឺ ប្រសាចច្រើនពេក ។ អ្នកខ្លះបានប្រើពាក្យនេះថា ÷ ប្រសេចប្រសាចទៅវិញ ។ ខ្លះទៀតថា÷ វសេចវសាច ។

**ប្រហាក់_ប្រហែល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពុំសូវច្បាស់ ប្រហែលដោយស្រពេចស្រពិល ។ បរិវារស័ព្ទ ប្រហាក់ អាចគន្លាស់បានជាពាក្យ ប្រហាក់ដោយមិនដែល គឺ ប្រហែលដោយមិនជាក់ ។

**ប្រហោត_ប្រហាត.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ភ្លាវលាយជូរ, ភ្លាវបាត់រសជាតិកំណើត ។ មាត់ប្រហោតប្រហាត, សម្លប្រហោតប្រហាត ។ល។ បរិវារស័ព្ទ ប្រហោត អាចគន្លាស់បានជាពាក្យ ប្រហោតភ្លាវលាយជូរស្លាត គឺ ប្រហាតភ្លាវលាយជូរស្លេត ។

**ប្រហែង_ប្រហោង.-** តាមវចនានុក្រម បានសេចក្ដីថា ÷ រន្ធ ឬ រូងប្រហោង រហែករហោកតូចធំជាច្រើន ។ ជញ្ជាំងផ្ទះ ប្រហែងប្រហោងច្រើន ។ បរិវារស័ព្ទ ប្រហែង អាចគន្លាស់បានជា

ពាក្យ ប្រហែងរហែករហោកច្រើនកន្លោង គឺ ប្រហោងរហែក រហោកច្រើនកន្លែង ។

**ប្រឡាក់_ប្រឡូស.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ប្រឡាក់សៅហ្មងច្រើន, ប្រឡាក់សៅហ្មងជាមួយគ្នា ។ បរិវារស័ព្ទ ប្រឡូស អាចគន្លាស់បានជាពាក្យ ប្រឡូសសៅហ្មងរួមគ្នា ដោយមានកំហាក់ គឺ ប្រឡាក់សៅហ្មងរួមគ្នាដោយមានកំហុស ឬ ប្រឡូសសាម៉ាក់ ៗ គឺ ប្រឡាក់សាម៉ូស ៗ ។

**ប្រឡូក_ប្រឡាក់.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ប្រឡាក់សៅហ្មងជាមួយ ។ គឺល្អលាយនឹងអាក្រក់ ។ល។ បរិវារស័ព្ទ ប្រឡូក អាចគន្លាស់បានជាពាក្យ ប្រឡូកសៅហ្មងបូកឡាក់ គឺ ប្រឡាក់សៅហ្មងបូកឡូក ។

**ប្រាកង_ប្រជា.-** គឺមែនទែនពិតណាស់ ។ សម្ដីប្រាកដប្រជា ។ បើតាមយោបល់ខ្ញុំផ្ទាល់ ពាក្យប្រាកដប្រជានេះ ជាពាក្យមួយ ដែលយើងយកមកនិយាយរត់មាត់ ដោយកាលនៅក្មេងនៅឡើយ បានទន្ទេញចាំមាត់ នូវសាស្ត្រាកំណាព្យច្បាប់ស្រី ព្រោះនៅសម័យដើម នៅគ្រប់កន្លែង លោកគ្រូអាចារ្យរមែងបង្ហាត់

បង្រៀនកូនខ្មែរយើងគ្រប់រូប ឱ្យទន្ទេញចាំមាត់ ដើម្បីទុកជាតម្រាដំបូន្មានទៅអនាគត ។ ប្រាកដប្រជា នេះជាឃ្លាលំនាំដើម នៃសាស្ត្រាច្បាប់ស្រីដូចជាអាទិ នេះបទប្រាកដចងជាភូជង់លីលាចងជាច្បាប់ស្រី ។ល។ សាស្ត្រាច្បាប់ស្រីនេះជាសាស្ត្រាមួយ វិសេសវិសាលណាស់ ក្នុងសម័យបុរាណ ដែលជាក្បួនតម្រាទូន្មានបុត្រីៗ ក្នុងកិច្ចសូត្យរៀន ផ្ចង់គំនិតមារយាទឱ្យបានសមសួនតាមគន្លងធម៌ ។ល។ ដោយកូនខ្មែរយើងច្រើនរូប បានហាត់រៀនទន្ទេញចាំមាត់សឹងគ្រប់គ្នា នូវសាស្ត្រាច្បាប់ស្រីនេះ រហូតមកទល់សម័យអណានិគមបារាំងទៀត វគ្គ ''នេះបទប្រាកដចងជា'' បានក្លាយជាឃ្លាសង្ខេបក្នុងភាសាសាមញ្ញធម្មតា ថាជាពាក្យ ប្រាកដប្រជាតែប៉ុណ្ណោះ ដោយយកពាក្យ ប្រជាមកធ្វើជា បរិវារស័ព្ទ ហៃហមរត់មាត់គ្មានលំអៀងជាពាក្យគន្លាស់អ្វីឡើយ ។

**ប្រាជ្ញ-ព្រោក ឬ ព្រោក-ប្រាជ្ញ**.- សូមមើលពាក្យ ព្រោកប្រាជ្ញ ។

**ប្រាប់-ប្រុង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រាប់ដោយផ្តាំផ្ញើ នឹងអ្នកដទៃឱ្យផ្សាយដំណឹងតៗគ្នាទៅ ។ បរិវារស័ព្ទ

ប្រង អាចគន្លាស់បានជាពាក្យ ប្រង ដោយផ្ដាំផ្ញើនឹងអ្នកដទៃទៅផាប់ គឺ ប្រាប់ដោយផ្ដាំផ្ញើនឹងអ្នកដទៃទៅផង ។

**ប្រាប់_ប្រាម.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រាប់ឱ្យស្គាល់ឱវាទ ។ បរិវារស័ព្ទ ប្រាម អាចគន្លាស់បានជាពាក្យ ប្រាមដោយបានហាប់ គឺ ប្រាប់ដោយបានហាម ពោលគឺ ប្រាប់បញ្ជាក់ជាបំរាម ។

**ប្រាប់_ប្រាយ.**- ប្រាប់ដំណើររឿយៗ ដោយសម្រួលសេចក្ដី ។ បរិវារស័ព្ទ ប្រាយ អាចគន្លាស់បានជាពាក្យ ប្រាយ ដំណឹងរឿងដោយធ្វើបរិយ៉ាប់ គឺ ប្រាប់ដំណឹងរឿងដោយធ្វើបរិយាយ ពោលគឺ ដោយធ្វើអត្ថាធិប្បាយ ។

**ប្រាយ_ព្រោក.**- សូមមើលពាក្យ ព្រោកប្រាយ ។

**ប្រិត_ប្រៀង.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រិតដោយរឹតត្បិតឱ្យប្រព្រឹត្តហ្មត់ចត់ ទៀងទាត់តាមគតិធម៌និងគតិច្បាប់ ។ គ្រូអាចារ្យប្រិតប្រៀងសិស្ស ឱ្យកាន់សុចរិតប្រព្រឹត្តល្អ ។ ល ។ បរិវារស័ព្ទ ប្រៀង អាចគន្លាស់បានជាពាក្យ ប្រៀងរឹតត្បិតពុំឱ្យមានលំអិត គឺ ប្រិតរឹតត្បិតពុំឱ្យមានលំអៀង ។

**ប្រិត_ប្រៀន**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បញ្ជូត្តិឱ្យខំរៀនមានកម្រិតមានកំណត់ ។ គ្រូបាធ្យាយប្រិតប្រៀនសិស្សឱ្យខំប្រឹងរៀនសូធ្យ ។ល។ បរិវារស័ព្ទ ប្រៀន អាចគន្លាស់បានជាពាក្យ ប្រៀនតាមកំណត់ឱ្យខិតខំរិត គឺ ប្រិតតាមកំណត់ឱ្យខំរៀន ។

**ប្រិត_ប្រៀប**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាក់កម្រិតយ៉ាងតឹងរ៉ឹងដើម្បីឱ្យមានរបៀបឬរឹតត្បិតឱ្យមានរបៀប ។ បរិ-វារស័ព្ទ ប្រៀប អាចគន្លាស់បានជាពាក្យ ប្រៀបយ៉ាងតឹងរ៉ឹងឱ្យមានរបិត គឺ ប្រិតយ៉ាងតឹងរ៉ឹងឱ្យមានរបៀប ។

**ប្រឹង_ប្រែង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខំពេញកម្លាំង, ខំឱ្យរឹងជំហរ, ខំព្យាយាម ។ល។ ខំប្រឹងប្រែងរៀនសូធ្យ ។ល។ បរិវារស័ព្ទ ប្រែង អាចគន្លាស់បានជាពាក្យ ប្រែងរៀនសូធ្យ ដោយកោតក្រឹង គឺ ប្រឹងរៀនសូធ្យដោយកោត-ក្រែង ពោលគឺ ប្រែងរៀនសូធ្យ ដើម្បីឈ្នះគេអឹង គឺ ប្រឹងរៀនសូធ្យដើម្បីឈ្នះគេឯង ។

**ប្រុង_ប្រៀប**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រុងទុកជា

មុនតាមរបៀបកិច្ចការ ។ បរិវារស័ព្ទ ប្រៀប អាចគន្លាស់បាន ជាពាក្យប្រៀបទុកជាមុនតាមរបុង គឺប្រុងទុកជាមុនតាមរបៀប ។

ប្រុង_ប្រែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រុងប្រយ័ត្ន ទុកជាមុន ។ បរិវារស័ព្ទ ប្រែង អាចគន្លាស់បានជាពាក្យ ប្រែង រៀបចំទុកជាមុនដោយប្រយ័ត្នប្រយុង គឺ ប្រុងរៀបចំទុកជាមុន ដោយប្រយ័ត្នប្រយែង ។

ប្រើ_ប្រាស់.- បង្គាប់ឱ្យធ្វើតាម, ប្រើទាំងសព្វទាំងគ្រប់ ប្រើតាមតែ ប្រទះ ។ បរិវារស័ព្ទ ប្រាស់ អាចគន្លាស់បានជាពាក្យ ប្រាស់ តាមតែប្រតើ គឺ ប្រើតាមតែប្រទះ ។

ប្រេវ_ប្រាវ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរព្ទប្រាវៗ តិចៗ ខ្លាំង ១ មួយភ្លែត ឬកំហឹងមួយនេវ មួយឆាវ ។ល។ ខឹងប្រេវប្រាវ ។ បរិវារស័ព្ទ ប្រេវ អាចគន្លាស់បានជាពាក្យ ប្រេវដោយកំហឹងមួយឆាវ គឺ ប្រាវដោយកំហឹងមួយនេវ ។

ប្រែ_ប្រួល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ត្រឡប់ ឬ ផ្លាស់ប្តូរ ។ល។ សម្តីប្រែប្រួល, ប្រទេសប្រែប្រួល ។ បរិវារ-ស័ព្ទ ប្រួល អាចគន្លាស់បានជាពាក្យ ប្រួលព្រោះមានការមិន

ស្រែ គឺ ប្រែព្រោះមានការមិនស្រួល ។

**ប្លេង_ប្លោង**.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលអណ្ដែតឃ្លេងឃ្លោង ប៉េលប៉ោល ។ បរិវារស័ព្ទ ប្លេង អាចគន្លាស់បានជាពាក្យ ប្លេងអណ្ដែតឃ្លេងឃ្លោង គឺ ប្លោងអណ្ដែតឃ្លោងឃ្លេង ។

**ប្លេច_ប្លូច**.- សូមមើលពាក្យ ប៉ប្លេចប៉ប្លូច ។

* * *

# ផ

**ផាត់_ផាយ.-** លើកចោលចេញ, បក់បង្ហើរបង្ហួស ។ ខ្យល់ផាត់ផាយពពក, ខ្យល់ផាត់ផាយទឹកភ្លៀង ។ល។ បរិវារស័ព្ទ ផាយ អាចគន្លាស់បានជាពាក្យ ផាយខ្ចាយខ្ចាត់ គឺ ផាត់ខ្ចាត់ខ្ចាយ ឬផាត់ទៅឆ្ងាយ ។

**ផ្ចូរ_ផង់.-** ត្រចង់ប្រផ្ចូរ, បំព្រង ។ល។ មុខផ្ចូរផង់ ។ បរិវារស័ព្ទ ផង់ អាចគន្លាស់បានជាពាក្យ ផង់ដោយត្រចូរ គឺ ផ្ចូរដោយត្រចង់ ។

**ផ្ដត់_ផ្ដង់.-** គឺទំនុកបំរុងមិនឱ្យខ្វះខាត ។ បរិវារស័ព្ទ ផ្ដត់ អាចគន្លាស់បានជាពាក្យ ផ្ដត់ទុកមិនឱ្យផុតរលង់ គឺ ផ្ដង់ទុកមិនឱ្យផុតរលត់ ពោលគឺ ទំនុកបំរុងឱ្យមានសម្ភារៈ សព្វគ្រប់ទាំងអស់ពុំឱ្យដាច់ ។

ផ្ដាប់_ផ្គុន.- តាមវចនានុក្រម មានន័យថា ÷ ខំសម្ដែងសេចក្ដីគោរព ដោយយកចិត្តទុកដាក់មិនឱ្យសៅហ្មង ដើម្បីកើតគុណប្រយោជន៍ដល់ខ្លួន ។ បរិវារស័ព្ទ ផ្គុន អាចគន្លាស់បានជាពាក្យ ផ្គុនដើម្បីកើតគាប់ គឺ ផ្ដាប់ដើម្បីកើតគុណ ។

ផ្ងាក់_ផ្ងើក.- ដែលបះចុះបះឡើង ងង៉ាកងង៉ើក, ប៉ាកប៉ើក ។ បរិវារស័ព្ទ ផ្ងើក អាចគន្លាស់បានជាពាក្យ ផ្ងើកដោយបះង៉ើកង៉ាក គឺ ផ្ងាក់ដោយបះង៉ាកង៉ើក ។

ផ្ដាញ់_ផ្ដាល.- តាមវចនានុក្រម មានន័យថា ÷ ធ្វើឱ្យចាញ់ ឱ្យរាង ចាលលែងហ៊ានតទៅទៀត ឬ ផ្ដន្ទាបង្អាប់បង្អោនឱ្យមានអៀនអន់រាងចាល ។

ផ្ចិត_ផ្ចង់.- ធ្វើដោយផ្ចង់អស់ពីចិត្ត អស់ពីចំណង់ ។ បរិវារស័ព្ទ ផ្ចិត អាចគន្លាស់បានជាពាក្យ ផ្ចិតឱ្យអស់ពីចង់ គឺ ផ្ចង់ឱ្យអស់ពីចិត្ត ។

ផ្ដុង_ផ្ដើម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទំនុកបំរុងឱ្យឃើញចុងឃើញដើម គឺ ទំនុកបំរុង ដោយសព្វគ្រប់ឱ្យដុះដាលចម្រើន ។ បរិវារស័ព្ទ ផ្ដុង អាចគន្លាស់បានជាពាក្យ ផ្ដុងឱ្យដុះ-

ដាល ចម្រើនឃើញចុងឃើញដើម គឺ ផ្ដើមឱ្យដុះដាលចម្រើនឱ្យឃើញដើមឃើញចុង ។

**ផ្ដួច_ផ្ដើម.-** ពាក្យនេះ មានន័យចំហាទាំងពីរ ។ តាមវចនានុក្រម ផ្ដួច ផ្ដើម មានន័យថា ÷ ដួចនាំធ្វើមុនគេ, ដួចឡើងដើមដំបូងបង្អស់ ។ បរិវារស័ព្ទ ផ្ដើម អាចគន្លាស់បានជាពាក្យ ផ្ដើមគំនិតនាំធ្វើមុនគេជាដួច គឺ ផ្ដួចគំនិតនាំធ្វើមុនគេជាដើម ។

**ផ្ដៀង_ផ្ដង.-** និយាយបញ្ចិតបញ្ចៀងនាយអាយ, និយាយដៀមដាម-ដួសដង ដៀងទៅរក និយាយផ្ដៀងផ្ដង ។ បរិវារស័ព្ទ ផ្ដង អាចគន្លាស់បានជាពាក្យ ផ្ដង ដៀមដាមដោយសំម្ដីដួសដៀង គឺ ផ្ដៀងដៀមដាមដោយសំម្ដីដួសដង ។

**ផ្ដេក_ផ្ដិត.-** តាមវចនានុក្រម បានសេចក្ដីថា ÷ ជាប់ចិត្តជិតនៅមិនងាក មិនបែរ ។ ស្រឡាញ់ផ្ដេកផ្ដិត ។ បរិវារស័ព្ទ ផ្ដិត អាចគន្លាស់បានជាពាក្យ ផ្ដិតស្រឡាញ់ដោយជាប់ចេក គឺ ផ្ដេក-ស្រឡាញ់ដោយជាប់ចិត្ត ។

**ផ្ដេក_ផ្ដួល.-** ពាក្យនេះមានន័យចំហាទាំងពីរ ។ តាមវចនានុក្រម ផ្ដេក ផ្ដួល មានន័យថា ÷ ផ្ដេកចិត្តផ្ដួលខ្លួន ដោយស្រឡាញ់រាប់អាន

លើសលប់ ។ បរិវារស័ព្ទ ផ្តេក អាចគន្លាស់បានជាពាក្យ ផ្តេក ចិត្តស្រឡាញ់ ដោយតម្រូល គឺ ផ្តួលចិត្តស្រឡាញ់ ដោយតម្រេក ។

**ផ្តេស_ផ្តាស**.- ដែលខ្ជីខ្ជា, ឥតសណ្តាប់ធ្នាប់, ខុសផ្លូវខុសគន្លង ។ សំម្តីផ្តេសផ្តាស, ធ្វើផ្តេសផ្តាស ។ បរិវារស័ព្ទ ផ្តេស អាចគន្លាស់បានជាពាក្យ ផ្តេសដោយចចេស ពោលគឺ មិនព្រមប្រព្រឹត្តតាមគន្លងចាស់តម្រា ចេះតែប្រព្រឹត្តដោយចចេស ។

**ផ្តញ់_ផ្តាល់**.- ធ្វើឱ្យទញ់, ពោលពាក្យបន្តុចបង្អាក់ ឬ សង្កត់សង្កិនឱ្យទញ់, ឱ្យទាល់ផ្លូវ ទាល់សេចក្តី ។ បរិវារស័ព្ទ ផ្តាល់ អាចគន្លាស់បានជាពាក្យ ផ្តាល់ឱ្យទញ់ គឺ ផ្តញ់ឱ្យទាល់ ។

**ផ្តប់_ផ្តល់**.- តាមវចនានុក្រម បានសេចក្តីថា ÷ ទប់ទល់ឱ្យនៅនឹង, ឱ្យរឹងប៉ឹង ។ បរិវារស័ព្ទ ផ្តល់ អាចគន្លាស់បានជាពាក្យ ផ្តល់ឱ្យរឹងប៉ឹង ទល់ទប់ គឺ ផ្តប់ឱ្យរឹងប៉ឹងទប់ទល់ ។

**ផ្តុក_ផ្តាក់**.- តាមវចនានុក្រម បានសេចក្តីថា ÷ ដាក់បន្ទុក ។ ផ្តុកផ្តាក់កូនចៅឱ្យរៀនសូត្រ ។ល។ បរិវារស័ព្ទ ផ្តុក អាចគន្លាស់

បានជាពាក្យ ផ្ទុកកូនចៅឱ្យរៀនសូត្រពេញបន្ទាក់ គឺ ផ្ដាក់កូនចៅឱ្យរៀនសូត្រពេញបន្ទុក ។

**ផ្ទៀង_ផ្ទាត់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យទៀងទាត់ គឺ ពិនិត្យប្រៀបធៀបធ្វើឱ្យទៀង, ឱ្យត្រឹមត្រូវតាមលំនាំតាមគំនូរឬច្បាប់ ។ បរិវារស័ព្ទ ផ្ទាត់ អាចគន្លាស់បានជាពាក្យ ផ្ទាត់ឱ្យត្រឹមត្រូវបានល្អប្រកៀង គឺ ផ្ទៀងឱ្យត្រឹមត្រូវបានល្អប្រាកដ ។

**ផ្ទះ_សំបែង.-** ពាក្យនេះ គេច្រើនប្រើជាសំណួរដូចជា ÷ ផ្ទះសំបែងឯងនៅឯណា ឬ តើឯងមានផ្ទះសំបែងហើយឬនៅ ។ ពាក្យផ្ទះសំបែងនេះ បានសេចក្ដីថា ÷ លំនៅស្ថាន ឬ ក្រុមគ្រួសារញាតិសន្ដាន ពោលគឺ : ប្រពន្ធកូនផ្ទាល់ខ្លួនឯង ដែលសម្បត្តិទ្រព្យខ្លួនឯងពិតប្រាកដ ក្រៅអំពីកេរ្ដិ៍មរតក ។ បរិវារស័ព្ទ សំបែង នេះ អាចគន្លាស់បានជាពាក្យ សំបែងរបស់អាត់ គឺ សម្បត្តិរបស់ឯង ពោលគឺ ផ្ទះដែលជាសម្បត្តិរបស់ឯងនោះ តើមានឬនៅ ។ល។ ពាក្យសំបែងអាត់នេះ ខ្ញុំបានឮអ្នកស្រុកតាកែវប្រើជាទម្លាប់មួយនៅសព្វថ្ងៃនេះ ។

ផ្សារ_ផ្សៀ.- តាមវចនានុក្រម ពាក្យផ្សារនេះ ក្លាយមកពីពាក្យអារ៉ាប់ បាសារនៃប្រទេសពែរ្សសព្វថ្ងៃ ដូរឈ្មោះជាប្រទេស អ៊ីរ៉ង់ វិញ (បាសារ Bazar) ដែលបារាំងបានខ្ចីពាក្យនេះ ទៅប្រើដូចយើងដែរ ។ នៅសម័យបុរាណយើងប្រើពាក្យ អាប័ណ តែយើងបោះបង់ទៅហើយ យកពាក្យផ្សារនេះ មកប្រើរត់មាត់ដល់សព្វថ្ងៃនេះ ។ ម្យ៉ាងវិញទៀត តាមប្រពៃណីប្រជាពលរដ្ឋខ្មែរយើង តាំងពីសម័យព្រេងនាយមក យើងច្រើនសន្មតដោយគ្នាឯងហៅថាប្រជុំជន ឬ ដាក់ឈ្មោះទីកន្លែងណាមួយដូចជាយើងឱ្យឈ្មោះផ្សារនោះទៀតជាការងាយបំផុត ពោលគឺអ្នកស្រុកច្រើនប្រឌិតឈ្មោះ ដើម្បីសន្មតហៅទីកន្លែងផ្សារនេះ ដែលខ្លួននិយមទៅមករកស៊ីលក់ដូរ ឬ ទិញអីវ៉ាន់ផ្សេង ៗ ដែលជាការចាំបាច់ក្នុងមួយថ្ងៃ ។

សព្វថ្ងៃនេះទៀត យើងបានប្រឌិតឱ្យឈ្មោះក្រៅផ្លូវការ ទៅផ្សារតូចតាច តាមកៀនកោះ ឬ ជនបទដោយយល់ទៅតាមការចំណាំរៀងខ្លួន ដូចជាពាក្យផ្សារដើមគរ, ផ្សារអូរឫស្សី, ផ្សារស៊ីឡូប ដែលហៅក្លាយតាមចិនពីពាក្យខ្មែរស្លឹក, ផ្សារថ្កល់ទទឹង, ផ្សារស្ពោរ ។ល។

ប្រហែលជានៅក្នុងចំណុចផ្សារស្ពានេះហើយ បានជាបរិវារស័ព្ទ ផ្សា យើងមានលំអៀង គន្លាស់ជាពាក្យ មួយយោងស្របទៅតាមថា ÷ ផ្សាស្ពារ គឺ ផ្សារស្ពារ ព្រោះនៅសម័យដើម ប្រទេសខ្មែរយើងសម្បូរណ៍ទៅដោយបឹងបួរ ថ្លុកត្រពាំងដែលមានដើមស្ពារដុះជាច្រើនផង ។

**ផ្សែ្យ_ផ្សឹ្យ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រគំឱ្យប្រកបជាមួយគ្នា, ប្រមូលសន្សែសន្សំ ។ ផ្សែ្យផ្សំថ្នាំឱសថ ។ល។ បរិវារស័ព្ទ ផ្សែ្យ អាចគន្លាស់បានជាពាក្យ ផ្សែ្យ ប្រគំឱ្យត្រូវគ្នាដើម្បីកំ គឺ ផ្សំប្រគំឱ្យត្រូវគ្នាដើម្បីកែ ពោលគឺ ផ្សែ្យផ្សំប្រមូលវត្ថុធាតុ ឬ គ្រឿងប្រដាប់ផ្សេងៗ ដើម្បីជួសជុល, កែកុន ឬព្យាបាលជម្ងឺ ។ល។

**ផ្សះ_ផ្សា.-** តាមវចនានុក្រម មានន័យថា ÷ ធ្វើឱ្យជានឹងគ្នាវិញ គឺនិយាយសង្រួបសង្រួមអ្នកដែលឈ្លោះទាស់ទែងគ្នា ឱ្យជាលើកលែងប្រកាន់គ្នាទៅវិញទៅមក ។ បរិវារស័ព្ទ ផ្សា អាចគន្លាស់បានជាពាក្យ ផ្សាសម្រួលចិត្តគ្នាឱ្យអស់គំនិតអានាចៈ គឺ ផ្សះសម្រួលចិត្តគ្នាឱ្យអស់គំនិតអានាចារ ។

ផ្ទៀង_ផ្ទង.- តាមវចនានុក្រម បានសេចក្ដីថា ÷ ផ្ទៀងដាក់បែរឆ្វេង ស្ដាំវេចុះវេឡើងដោយលំនាំយឺត ។ បរិវារស័ព្ទ ផ្ទង អាច គន្លាស់បានជាពាក្យ ផ្ទងបែរស្ដាំមួយជៀង ឆ្វេងមួយជៀង គឺ ផ្ទៀងបែរស្ដាំមួយដង ឆ្វេងមួយដង ។

*

* *

# ៣

**ពង្រាត់_ពង្រាស.-** ធ្វើឱ្យបែកគ្នា ឱ្យព្រាត់ប្រាស់ ។ បរិវារស័ព្ទ ពង្រាស អាចគន្លាស់បានជាពាក្យ ពង្រាសឱ្យបែកគ្នាប្រាស់ព្រាត់ គឺ ពង្រាត់ឱ្យបែកគ្នាព្រាត់ប្រាស់ ។

**ពង្វក់_ពង្វី.-** ធ្វើឱ្យវិលវល់ចិត្តគំនិត ។ នាំឱ្យវក់វី ។ បរិវារស័ព្ទ ពង្វី អាចគន្លាស់បានជាពាក្យ ពង្វីចិត្តគំនិតឱ្យវីវក់ គឺ ពង្វក់ចិត្តគំនិតឱ្យវក់វី ។

**ពពាក់_ពពន្ធ.-** គឺ ពាក់ព័ន្ធលើគ្នា ។ បរិវារស័ព្ទ ពពាក់ អាចគន្លាស់បានជាពាក្យ ពពាក់តម្រួតលើគ្នាបាក់ដូចជាធាក់ជាន់ គឺ ព័ន្ធតម្រួតលើគ្នាបាក់ដូចជាជាន់ធាក់ ។

**ពពាក់_ពពូន.-** គឺ ប្រមូលគ្នា ឬ ភ្ជុំគ្នាជុំជិត ពូនចុះពូនឡើង ។ រត់ពពាក់ពពូន ។ បរិវារស័ព្ទ ពពាក់ អាចគន្លាស់បានជាពាក្យ ពពាក់តម្រួតលើគ្នាហាក់ដូចជាជាន់ពូន គឺ ពពូនតម្រួតលើគ្នាហាក់ដូចជាជាន់ពាក់ ។

**ពពាក់_ពពើម.-** គឺ ពើម ១ វឹមវាម ព្រោះងងឹតមើលមិនច្បាស់ ឬ ព្រោះទីកន្លែងដែលពុំស្គាល់ ។ នាំគ្នាដើរពពាក់ពពើមដួលតិតដួលតូង ។ បរិវារស័ព្ទ ពពាក់ អាចគន្លាស់បានជាពាក្យ ពពាក់ វឹមវាមដោយមិនដើម គឺ ពពើមវឹមវាមដោយមិនជាក់ ។

**ពពី_ពពើ.-** ពឹមពើមវឹមវាមហាក់ដូចជាធ្វើពើ ។ ដើរពពីពពើមិនដឹងអី ។ បរិវារស័ព្ទ ពពី អាចគន្លាស់បានជាពាក្យ ពពីពភ្លីពភ្លើហាក់ដូចជាស្មារតីរក់រើ គឺ ពពើពភ្លីពភ្លើហាក់ដូចជាស្មារតីរក់រី ។

**ពពឹម_ពពើម.-** ពាក្យនេះ មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យ ពពាក់ពពើមដែរ ។ បរិវារស័ព្ទ ពពឹម អាចគន្លាស់បានជាពាក្យ ពពឹមដោយវឹមវើម គឺ ពពើមដោយវើមវឹម ។ អ្នកខ្លះច្រើននិយាយពាក្យនេះថា ÷ ពពាមពពើមវិញ ។ បើដូច្នេះ បរិវារស័ព្ទ ពពាម អាចដោះស្រាយទៅជាពាក្យ ពពាមទឹមទើម គឺ ពពើមទឹមទាម ។

**ពព្រាក់_ពព្រើត.**- ញូញ័រ ។ ក្មេងពព្រាក់ពព្រើត ។ បរិវារស័ព្ទ ពព្រាក់ អាចគន្លាស់បានជាពាក្យ ពព្រាក់ញូញ័រញូញើត គឺ ពព្រើតញូញ័រញូញាក់ ។

**ពព្លិក_ពព្លាក់.**- ដែលមានសម្បុរខ្ទន់ៗ ខ័ណ្ឌៗ ពព្លាក់ខ្លាំង ។ ដែល ពព្លាក់ក្រវើមក្រវាម ។ សម្បុរពព្លិកពព្លាក់ ។ បរិវារស័ព្ទ ពព្លិក អាចគន្លាស់បានជាពាក្យ ពព្លិក ពពាលក្រវើមក្រវាម ខ្មៅកខ្វាក់ គឺពព្លាក់ពពាលក្រវើមក្រវាមខ្មៅកខ្វិក ។

**ពភ្លាក់_ពភ្លើ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរលាក់ រលើដោយភាន់ស្មារតី, ដោយវង្វេង ។ មនុស្សពភ្លាក់ពភ្លើ ។ បរិវារស័ព្ទ ពភ្លាក់ អាចគន្លាស់បានជាពាក្យ ពភ្លាក់ដោយស្មារតី រលាក់រលើ គឺ ពភ្លើដោយស្មារតីរលើរលាក់ ។

**ពភ្លាក់_ពភ្លើក.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល-មានដំណើរភ្លើកៗរលាក់រលើហាក់ដូចភាន់ច្រឡំទិស ។ ដើរ ពភ្លាក់ពភ្លើ ។ បរិវារស័ព្ទ ពភ្លាក់ អាចគន្លាស់បានជាពាក្យ ពភ្លាក់ ដោយមានដំណើររលាក់រលើក គឺ ពភ្លើកដោយមាន-ដំណើររលើករលាក់ ។

ពត្លិក_ពត្លក់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានសម្បុរកខ្វាក់ស្រដៀងនឹងពណ៌ភក់ ។ ស្បៀកពាក់ខោអាវពត្លិកពត្លក់ ។ បរិវារស័ព្ទ ពត្លិក អាចគន្លាស់បានជាពាក្យ ពត្លិកកខ្វក់ ដោយគគ្រិកគគ្រក់ គឺ ពត្លក់កខ្វក់ដោយគគ្រក់គគ្រិក ។

ពភ្លី_ពភ្លើ.- ដែលភ្លីភ្លើក្រៃពេក ។ សូមមើលពាក្យ ភ្លីភ្លើ ឬ ងីងើ ។

ពាក្យ_ពេចន៍.- តាមវចនានុក្រម ពាក្យនេះ មានអត្ថន័យចំហទាំងពីរ ហើយបានសេចក្តីថា ÷ ពាក្យសម្តីផ្សេងៗ, ពាក្យសម្តីថ្វីមាត់ ។ អ្នកចេះពាក្យពេចន៍ គឺ អ្នកចេះពាក្យសម្តីជ្រៅជ្រះ ប្រកបដោយមានវិជ្ជា និងសញ្ញាប័ត្រជាន់ខ្ពស់ផ្នែកភាសា ។ល។ បរិវារស័ព្ទ ពេចន៍ ដោះស្រាយបានជាពាក្យ ''ពេចន៍ដោយមានន័យគិតមិនលាក គឺពាក្យដែលមានន័យគេចមិនលេច '' ពោលគឺ ពាក្យពេចន៍ថ្លៃថ្នូរ មានអត្ថន័យជ្រៅពេកហួសនិស្ស័យ ជនសាមញ្ញ ។

ពិបាក_ពិបិន.- សូមមើលពាក្យ លំបាកលំបិន ។

ពិបេក_ពិបាក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ផលកម្ម, សេចក្តីទុក្ខ , ធ្វើបានដោយកម្រ ។ ល ។ ធ្វើដំណើរពិបេកពិបាក

ព្រោះផ្លូវអាក្រក់ ។ល។ បរិវារស័ព្ទ ពិបេក អាចគន្លាស់បានជាពាក្យ ពិបេកប៉ាក គឺ ពិបាកពេក ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ប៉ាបេកប៉ាបាកវិញ ។

**ពឹម_ពើម.-** បើតាមផ្លូវការវិញ គេច្រើនឃើញប្រើពាក្យ លំបេកលំបាក សូមមើលពាក្យ ពពឹមពពើម ។

**ពឹស_ពាស.-** គេឃើញមានមនុស្សដើរតែពឹសតែពាស គឺគេឃើញមនុស្សដើរពាសពេញ ដោយពុំដឹងទៅណា មកណាប្រាកដ ។ល។ បរិវារស័ព្ទ ពឹស អាចគន្លាស់បានជាពាក្យ ពឹសគ្រប់ទិសទាស គឺ ពាសគ្រប់ទិសទី ។

**ពុះ_ពារ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដោះស្រាយ, រំរេក, ជ្រែក, ជ្រោមជ្រែង, ជួយយកអាសារ ។ល។ បរិវារស័ព្ទ ពារ អាចគន្លាស់បានជាពាក្យ ពារដើម្បីជួយអ្នកអវិជ្ជា ។ ពាក្យនេះបើយើងគន្លាស់លេងឱ្យតែបានដូចជាពាក្យ ពារទ្វះ គឺ ពុះទ្វារទៅវិញ យើងបានអត្ថន័យសមាស ពាក្យនេះ មួយបែបផ្សេងទៅ ដែលមានគោលដៅចាកឆ្ងាយពីអត្ថន័យពិតប្រាកដនៃពាក្យដើមពុះពារ ។

ពូជ_ពង្ស.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បាន សេចក្ដីថា ÷ តំណ, ជាតិកំណើត ឬ វង្សត្រកូលរបស់ពួកមនុស្ស ឬ សត្វ ។ បរិវារស័ព្ទ ពង្ស អាចគន្លាស់បានជាពាក្យ ពង្សខាង ប្រពន្ធដូច គឺ ពូជខាងប្រពន្ធចុង ។ ចំពោះរឿងនេះ ខ្មែរយើង នៅសម័យបុរាណគេច្រើនរើសពូជពង្សឱ្យបានល្អ ។ ដូច្នេះ បុត្រខាងប្រពន្ធចុងក្តី ក៏ជាពូជខាងបិតាជាមួយគ្នានិងបុត្រខាង ប្រពន្ធដើមបង្អស់ ឬ ទីពីរនិងទីបីដែរ ។ល។

ពេប_ជ្រាយ.- សមាសពាក្យនេះ មានពាក្យ ពេប បានសេចក្តី ថា ÷ ពេបមាត់និងពាក្យជ្រាយ ។ ពាក្យ ពេបជ្រាយ នេះ បាន សេចក្តីថា ÷ វ៉ះគន់មើលងាយ ។ បរិវារស័ព្ទ ជ្រាយ អាចគន្លាស់ បានជាពាក្យ ជ្រាយមើលងុល គឺ ជ្រុលមើលងាយ ពោលគឺ វ៉ះគន់មើលងាយជាខ្លាំង ។

ពោរ_ពាស.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលជន់ជោរឡើង ដែលឡើងកំពង់ ។ល។ ទឹកទន្លេឡើងពោរពាស គឺ ទឹកទន្លេ ឡើងពោរពេញ ។ ម្ហូបចំណីមានពោរពាស ។ បរិវារស័ព្ទ ពោរ អាចគន្លាស់បានជាពាក្យ ពោរពេញដោយសំបៀស គឺ ពាសពេញដោយសម្បូណ៌ ។

**ពោះ_ពង់**.- មានផ្ទៃពោះ, មានគភ៌ ។ បរិវារស័ព្ទ ពង់ អាចគន្លាស់បានជាពាក្យ ពង់មូលផ្លោះ គឺ ពោះមូលផ្លុង ពោលគឺ អ្នកមានគភ៌ដែលពោះច្រើនមានសភាពមូលថ្លុំ ។

**ពោះវៀន_ពោះតាំង**.- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ពោះវៀនតូចធំទាំងអស់ក្នុងពោះ សត្វក្នុងលោក ។ ដូលច្រើនត្រឡប់លេចពោះវៀន ពោះតាំងអស់ ពោលគឺ ÷ លេចកើ្តខ្លាស់អាចិកំបាំងទាំងអស់ ។ ដូច្នេះ បរិវារស័ព្ទ ពោះតាំងអាចគន្លាស់បានជាពាក្យ ពោះតាំងដែលជាអាថិកំបៀន គឺ ពោះវៀនដែលជាអាថិកំបាំង ។

**ព្រយិត_ព្រយោង**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រ-តោងយិតទាញចុះមិនលែង, ទាញយិតអូសយោងដោយពេញកម្លាំង ។ បរិវារស័ព្ទ ព្រយោង អាចគន្លាស់បានជាពាក្យព្រយោងតោងទាញយិត គឺ ព្រយិតតោងទាញយោង ។

**ព្រលឹង_ព្រលះ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដំ-ណើរជីវិត ។ល។ ខ្ញុំភ័យរកព្រលឹងព្រលះមួយគ្មានទេ ។ ក្មេងនេះមានព្រលឹងព្រលះល្អណាស់ គឺក្មេងនេះធាត់មានសាច់

ឈាមល្អណាស់ ។ បរិវារស័ព្ទ ព្រលះ អាចគន្លាស់បានជា-ពាក្យ ព្រលះធាត់ល្អដោយសុខភាពជាស្រឡឹង គឺ ព្រលឹងធាត់ល្អដោយសុខភាពជាស្រឡះ ម្យ៉ាងវិញទៀត បរិវារស័ព្ទ ព្រលះ អាចគន្លាស់បានជាពាក្យ ព្រលះបាត់ពីផ្ទឹង គឺ ព្រលឹងបាត់ពីផ្ទះ ពោលគឺ អ្នកមានអាសន្នភ័យ ច្រើនពោលស្រដីថា ÷ ភ័យខ្លាំងបាត់ព្រលឹងពីផ្ទះអស់ហើយ ។

ព្រឹក_ព្រាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ វេលាព្រះអាទិត្យទើបរះព្រាង ៗ ។ ពាក្យនេះ ច្រើនឃើញប្រើក្នុងពាក្យកាព្យ ក្នុងចំណុចអធិប្បាយទេសភាព ដូចជា ព្រឹងព្រាងស្វាងជ្រះព្រះសុរិយា ។ បរិវារស័ព្ទ ព្រាង អាចគន្លាស់បានជាពាក្យព្រាងគ្មានភ្លឹក គឺ ព្រឹកគ្មានភ្លៀង ពោលគឺ ព្រឹកព្រលឹមដោយមេឃស្វាងស្រឡះ គ្មានពពកបន្តិចបន្តួចសោះ ។ រឿងនេះបើមេឃមានភ្លៀងវិញ ព្រះសុរិយាពុំអាចស្វាងជ្រះទៅបានឡើយ ។

ព្រោក_ប្រាថ្ង.- ពាក្យនេះ គេច្រើនដាក់ងារជនណាដែលមានវោហារច្រើនដូចពាក្យ គតិលោកថា ÷ អ្នកបានសម្ដីច្រើន ផ្ទៃផ្អែត

ដូច្នេះ បរិវារស័ព្ទ ព្រោក អាចគន្ទាស់បានជាពាក្យ ព្រោកដើម្បីបរិផាច គឺ ប្រាជ្ញដើម្បីបរិភោគ ឬព្រោកច្រើនសម្បូណ៌អាហារបរិផាច គឺ ប្រាជ្ញច្រើនសម្បូណ៌អាហារបរិភោគ ។

**ព្រោក_ប្រាយ.-** ពាក្យនេះ មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យព្រោកប្រាជ្ញ ។ បរិវារស័ព្ទ ប្រាយ អាចគន្ទាស់បានជាពាក្យប្រាយដើម្បីបូក គឺ ព្រោកដើម្បីបាយ ឬ ប្រាយកាលណាមិនខ្វះទេបូក គឺ ព្រោកកាលណាមិនខ្វះទេបាយ ។

**ភ្លើត_ភ្លើន.-** សូមមើលពាក្យ ភ្លើតភ្លើន ។

*

* *

# ភ

**ភប់_ភាន់ ឬ ភប់_ភ័ន្ត.-** តាមវចនានុក្រម បានសេចក្តីថា ÷ ជួប ប្រទះ, ប្រព្រឹត្តល្មើសដោយភាន់ច្រឡំ ។ បរិវារស័ព្ទ ភាន់ អាចគន្លាស់បានជាពាក្យ ភាន់ដោយប្រព្រឹត្តច្រឡប់ គឺ ភប់ ដោយប្រព្រឹត្តច្រឡំ ។

**ភាំង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គាំង ឬលង់ស្មារតី, ស្រឡាំងកាំង ។ ពាក្យភាំងនេះមាន បរិវារស័ព្ទ ដល់ទៅបួន-យ៉ាងហើយមានន័យល្បៀងគ្នាបន្តិច ដោយយោងទៅតាមន័យ បរិវារស័ព្ទទាំងនោះ ដូច្នេះពាក្យ ភាំងដែលមាន បរិវារស័ព្ទ ដូចខាងក្រោមនេះ អាចបកស្រាយបានដូចតទៅនេះ ÷

១._ភាន់_ភាំង.- ភាន់ដោយស្មារតីភាំង គឺ ភាំងដោយស្មារតីភាន់ពោលគឺ ដោយភាន់ច្រឡំ ។

២._ភីង_ភាំង.- ភីងដូចបាត់ព្រលាំង គឺ ភាំងដូចបាត់ព្រលឹង ។

៣._ភីន_ភាំង.- ភីនដូចលង់ក្នុងសុបាំង គឺ ភាំងដូចលង់ក្នុងសុបិន, ភាំងជីវិន ។

៤._ភិត_ភាំង.-ភិតទាំងចិត្តទាំងគំនាំង គឺ ភាំងទាំងចិត្តទាំងគំនិត ។

ភិព_ភ័យ.- សេចក្ដីខ្លាចណាស់ ។ បរិវារស័ព្ទ ភិត អាចគន្លាស់បានជាពាក្យ ភិតតក់ស្លុតអស់ពីជ័យ គឺ ភ័យតក់ស្លុតអស់ពីចិត្ត ។

កុំ_ភឿន.- ពាក្យនេះ មានន័យចំហទាំងពីរ គឺពាក្យ កុំជាពាក្យសៀមសុទ្ធមានន័យថា ÷ ខ្ញុំ និងពាក្យ ខ្មែរ-សៀម ផ្នែកខាងជើងនៃភ្នំដងរែក ភឿន ប្រែមកថា ក្លើ ឬមិត្តសម្លាញ់ ។ ដូច្នេះ ពាក្យកុំភឿន បានសេចក្ដីថា ÷ ភឿនខ្ញុំ ឬសម្លាញ់ខ្ញុំ ។ បរិវារស័ព្ទកុំ អាចគន្លាស់បានជាពាក្យ កុំរបស់ខ្សឿន គឺ ភឿនរបស់ខ្ញុំ ។ សព្វថ្ងៃនេះ អ្នកខ្លះបានប្រើពាក្យ ពួកម៉ាកជិនួស ពាក្យមិត្តសម្លាញ់ ឬ ក្លើវិញ ។ ពាក្យពួកម៉ាកនេះជាពាក្យខ្មែរ បារាំង គឺ

ពួកនិងម៉ាក (Marque) បានសេចក្ដីថា÷ ម៉ាកមួយពួកឬក្រុម ។

ភូមិ_អាករ.- ពាក្យនេះ ពុំមាន បរិវារស័ព្ទទេ គឺ ជាសមាសពាក្យមួយ មានន័យចំហាទាំងពីរ ពោលគឺ ភូមិដែលជាប់អាករ ដែលខ្មែរយើងហៅក្លាយសព្វថ្ងៃទៅជាភូមិម្ករ ។

ភ្ជុំ_ភ្ជរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គឺភ្ជុំគ្នាធ្វើបុណ្យនៅទីវត្តអារាមក្នុងថ្ងៃភ្ជុំបិណ្ឌ ។ បរិវារស័ព្ទ ភ្ជរ អាចគន្លាស់បានជាពាក្យ ភ្ជរគ្នាឱ្យបានច្រើនជាស្ថាពុំ គឺ ភ្ជុំគ្នាឱ្យបានច្រើនជាស្ថាពរ ។

ភ្លាត់_ភ្លាំង.- តាមវចនានុក្រម បានសេចក្ដីថា ÷ ជ្រុលជ្រលួស, ភាត់ដោយភ្លេចភ្លាំង ។ បរិវារស័ព្ទ ភ្លាំង អាចគន្លាស់បានជាពាក្យ ភ្លាំងគំនិតដោយភ្លេចភ្លាត់ គឺ ភ្លាត់គំនិតដោយភ្លេចភ្លាំង ។

ភ្លី_ភ្លើ.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមានស្មារតីភ្លេច ១, ល្ងីល្ងើ ។ មនុស្សភ្លីភ្លើ, សម្ដីភ្លីភ្លើ ។ល។ បរិវារស័ព្ទ ភ្លី អាចគន្លាស់បានជាពាក្យ ភ្លីដោយស្មារតី ល្ងេល្ងីវក់វើ គឺ ភ្លើដោយស្មារតីល្ងេល្ងីវក់វី ។

ភ្លើត_ភ្លើន.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលរីករាយសប្បាយ

ភ្លេចខ្លួន, ដែលបានចិត្តព្រហើនគឃ្លើនឡើងចាងក្រអើតក្រអោង ។ សប្បាយហួសពេក ។ បរិវារស័ព្ទ ភ្លើ អាចគន្លាស់បានជាពាក្យ ភ្លើតសប្បាយភ្លេចខ្លួនដោយភាន់ចិត្តក្រអើន គឺ ភ្លើនសប្បាយភ្លេចខ្លួនដោយភាន់ចិត្តក្រអើត ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ភ្លើតភ្លើនវិញ ។

ភ្លេង_ភ្លាត់.- គឺតន្ត្រី ។ បរិវារស័ព្ទ ភ្លាត់ អាចគន្លាស់បានជាពាក្យ ភ្លាត់ធ្វើនឹងមេង គឺ ភ្លេងធ្វើនឹងមាត់ ពោលគឺ ចម្រៀងព្រោះការប្រគំតន្ត្រីទាំងអស់សុទ្ធសឹងមានចម្រៀងកំដរផង ។

ភ្លេច_ភ្លាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ភ្លេចដោយភ្លាំងស្មារតី ។ បរិវារស័ព្ទ ភ្លាំង អាចគន្លាស់បានជាពាក្យ ភ្លាំងពុំបានរវិច គឺ ភ្លេចដោយពុំបានរវាំង ពោលគឺ ការអ្វីនិមួយៗបើយើងសម្ដីរវាំងជានិច្ច មុខជាវិញ្ញាណយើងពុំបានភ្លេចភ្លាំងបានឡើយ ។ម្យ៉ាងទៀត បរិវារស័ព្ទ នេះអាចគន្លាស់បានជាពាក្យ ភ្លាំងមមីងមមិច គឺ ភ្លេចមមីងមមាំង ។

✣

✣ ✣

# ម

**មនុស្ស-ម្នា.-** (អានថា ម្នះម្នា) តាមវចនានុក្រម ពាក្យនេះ មាន-ន័យថា ÷ មនុស្សសាមញ្ញ, មនុស្សរយ, មនុស្សអ្នកធ្វើការបំរើ ។ ផ្ទះលោក ទេព អរជុន (អរជូន) មានមនុស្សម្នាបំរើច្រើនណាស់ ។ល។ បរិវារស័ព្ទ ម្នា អាចគន្លាស់បានជាពាក្យ ម្នាចាំការពុះ គឺ មនុស្សចាំការពារ ឬម្នាជាបរិពុះ គឺ មនុស្សជាបរិពារ ។

ក្នុងប្រភេទមនុស្សអ្នកបំរើនេះ ខ្ញុំសូមឆ្លៀតឱកាស ជូននូវពត៌មាន ដោយសង្ខេប ស្ដីអំពីជនប្រភេទនេះ ដែលខ្ញុំបានស្រាវជ្រាវតាមឯកសារផ្សេងៗ ដូចជាអាទិ ÷

ប្រទេសកម្ពុជានៅសម័យដើម និពន្ធដោយលោក គួស្ដារ

សាណូ (Gustave-Janneau dans le Cambodge d'Aufrefois) ទស្សនាវដ្តី ឥណ្ឌូចិន ឆ្នាំ ១៩១៤ និង សៀវភៅមួយនិពន្ធដោយលោក អង់ត្វានកាបាតុង (Antonie Cabaton) ស្តីអំពីទាសភាពនានានៃប្រទេសកម្ពុជាយើងក្នុងសម័យបុរាណ (La Vie Domestique au Cambodge) ទស្សនាវដ្ដីឥណ្ឌូចិន ភាគ ៧ ឆ្នាំ ១៩១០ ទំព័រ ១០៣ ទៅ ១១៤ ។

ដើមឡើយទាសភាពនៅសាធារណរដ្ឋខ្មែរយើង ក្នុងសម័យបុរាណ មានច្រើនបែបច្រើនយ៉ាងណាស់គឺ ÷

**ខ្ញុំ.–** (ខ្ញុំគេ) គឺជនកំដឹងទ្រព្យគេ, គឺជនដែលទ័លក្រហើយ ទៅខ្ចីទ្រព្យគេមករកស៊ីចិញ្ចឹមជីវិត រកសងគេមិនបានយកខ្លួនទៅនៅបម្រើគេ ឬមាតាបិតាជំពាក់ទ្រព្យគេឱ្យកូនទៅនៅបម្រើគេ, កូននោះក៏ឈ្មោះថា ខ្ញុំគេដែរ ។

ពាក្យគួរសម ហៅជាបាលីភាសាថា ទាសា, ទាសី (ខ្ញុំប្រុស, ខ្ញុំស្រី) ។

ពាក្យថា ខ្ញុំបាទ ឬខ្ញុំព្រះបាទធ្វើនេះ (votre serciteur a fait ceci) គឺ ជាពាក្យ ដាក់ខ្លួនប្រដូចខ្លួនឯងឱ្យស្មើនឹងខ្ញុំ

គេ ។ ខ្លះទៀតប្រើពាក្យ ខ្ញុំប្រុស ឬខ្ញុំស្រីធ្វើនេះជំនួសពាក្យ ខ្ញុំព្រះបាទធ្វើនេះវិញ ព្រោះដើមឡើយខ្មែរយើងប្រើពាក្យ អញ ដែលឥឡូវយើង ប្រើពាក្យ ខ្ញុំដោយពុំមានន័យសម្ដែងឱ្យចំ (sous-entendu) ថា ÷ ខ្ញុំគេឱ្យអស់សេចក្ដី ។

**ខ្ញុំបំរើ.-** គឺជាជនស៊ីឈ្នួលបំរើដោយបើកប្រាក់ជាមុន ឬឱ្យគ្រួសារមកបំរើជំនួសដើម្បីកាត់ទឹកលុយដែលជំពាក់នោះ ។

**ខ្ញុំកំដរ.-** ចំពោះជនប្រភេទនេះ គ្មានអត្ថន័យអ្វីដែលជាអាថិកំបាំងពិបាកដោះស្រាយឡើយ គឺជនកំដរ បំរើ ឬ ជនជំនួយ (aide-serviteur) ។

**បាវ_ព្រាវ.-** បាវព្រាវនេះ ដែលបារាំងហៅថា ÷ អេសក្លាវ (esclave) គឺជាជនបម្រើមួយប្រភេទ ដែលយើងបានជាវ (ទិញ) ដោយព្រាវយកមកប្រើ ពោលគឺ យើងទិញដោយពុំបានជ្រើសរើសយ៉ាងសម្ងិតសម្ងាងឡើយ ព្រោះជនបំរើប្រភេទនេះ សុទ្ធសឹងជាជនពុំមានសុខភាពល្អបរិបូណ៌ ឬមានពិការជើងដៃ ដែលឈ្មួញបានចាប់ដាក់ក្នុងបាវ យកមកលក់នៅប្រជុំជននិមួយៗ ។ ដើម្បីកុំឱ្យអ្នកទិញអាចស្គាល់សភាពច្បាស់

នៃជនក្នុងបាវនោះ ។ អ្នកដែលគេចាប់មកលក់ឱ្យធ្វើជាបាវព្រាវច្រើនតែពួក គួយ ស្ទៀង, រដែ, ខា ។ល។ ដែលឋិតនៅក្នុងទីរួមខេត្តក្រចេះ, ស្ទឹងត្រែង, កំពង់ស្វាយ ដែលសព្វថ្ងៃយើងហៅថា÷ ខេត្តកំពង់ធំវិញ ។

ចំពោះខ្មែរលើសព្វថ្ងៃដែលយើងហៅថា ÷ ភ្នង ។ បើតាមលោក អៀវកើស ក្នុងសៀវភៅភាសាខ្មែរភាគទី ២ ទំព័រ ២៨៨ មានសេចក្ដីដូចតទៅនេះ÷

ពាក្យ ភ្នង គឺជាពាក្យគន្លាស់កាត់នៃពាក្យ "ភ្នាក់ងារ+ គង=ភ្នងងារគាក់លោក" បានពន្យល់ទៀតថា÷ ពួកកុលសម្ពន្ធនេះជាអ្នកព្រៃកមួយពួក ដែលទទួលខ្លួនធ្វើជាភ្នាក់ងារ ធ្វើគងថ្វាយព្រះមហាក្សត្រិយ៍ខ្មែរសម័យបូរាណ ជាសួយសារអាករ ។ គងធំៗ មានតែភ្នងទើបចេះធ្វើ ។ ធ្វើដោយសំរិទ្ធ ។ សំរិទ្ធជា-លោហធាតុកើតអំពីការរំលាយបញ្ចូលគ្នា នូវលោហធាតុច្រើនយ៉ាង ។ កាលសិតបានជាគងហើយ គេយកទៅលត់ឱ្យរីង ។ សំរិទ្ធសាចរឹង ហើយស្រួយផង ។ កាលណាលត់មិនត្រូវទៅជាស្រួយហួស ដល់យកមកវាយនឹងញញួរដើម្បីឱ្យបានជាគង

និងប្រែះបែកជាមិនខាន ។ ហេតុនេះ ការលត់សិរិទ្ធិជាការសំ-ខាន់បំផុតក្នុងការធ្វើគង ។ ដើម្បីនឹងលត់ឱ្យបានល្អ ត្រូវស្គាល់កំដៅភ្លើងដែលប្រើសម្រាប់លត់ ។ នាយចៅហ្វាយពួកក្នុងជាអ្នកមានវិជ្ជាខាងលត់សិរិទ្ធិ ធ្វើគងបានលាក់វិជ្ជានេះ ទុកសម្រាប់ខ្លួន ។ ឪពុកខ្ញុំគាត់យល់ថា ÷ ព្រោះហេតុនេះហើយបានជាចៅហ្វាយក្នុងមានងារជាស្តេចទឹក, ស្តេចភ្លើង, គឺទឹក-និងភ្លើងដែលប្រើសម្រាប់លត់សិរិទ្ធិ ។

**ពួកឈ្លើយ.-** ពួកឈ្លើយដែលយើងយកមកឱ្យបំរើយើង គឺជាជនអ្នកស្រុកភូមិ នៃប្រទេសឯទៀត ដែលយើងច្បាំងឈ្នះហើយកៀរយកមកទាំងគ្រួ ដើម្បីផ្ទុកឱ្យនៅទីកន្លែងណាមួយដែលគ្មានអ្នកស្រុកនៅ ឬក៏ឱ្យនៅជាមួយនឹងអ្នកស្រុក ដើម្បីបំរើអ្នក-ទាំងនោះ ក្នុងការធ្វើស្រែចំការ ។ល។

**ពួកពល.-** គឺជាពួកទាហានខ្លាំង នៅវេលាដែលយើងច្បាំងឈ្នះហើយ ចាប់បានយកមកធ្វើទណ្ឌកម្ម ឱ្យនៅបំរើអ្នកស្រុក ឬរដ្ឋការតពូជអស់មួយជីវិត ។

ចំពោះពួកពលនេះ សូមអានសៀវភៅលោក ម៉ូរ៉ា (Moura) ទើបអស់សេចក្ដី ។

**ម៉ប_ម៉ាយ.**- តាមអក្ខរាវិរុទ្ធត្រឹមត្រូវ ពាក្យនេះ គេសរសេរដូច្នេះ ហ្មប-ហ្មាយ ។ សូមមើលពាក្យ ហ្មបហ្មាយ នេះ ។

**មមិង_មមាំង.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិងមាំង ងេងងាង ស្ទាក់ស្ទើរ ស្មារតីមិនជាក់លាក់ ។ មនុស្ស-មមិងមមាំង ។ល។ បរិវារស័ព្ទ មមិង អាចគន្លាស់បានជា-ពាក្យ មមិងដោយស្មារតីភិងភាំង គឺ មមាំងដោយស្មារតីភាំងភិង ពោលគឺ មមិងមមាំង ស្ទាក់ស្ទើរ ស្មារតីភិនភាំង ។

**មមី_មមើ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិនទាន់-ដឹងខ្លួនច្បាស់ប្រាកដ ដូចជាមមើ, ដែលធ្ងន់ភ្នែកពព្រឹមនៅឡើយ ។ មមីមមើភ្ញាក់ពីដេក ។ល។ បរិវារស័ព្ទ មមី អាច-គន្លាស់បានជាពាក្យ មមីដោយនៅក្នុងសភាពភើ គឺ មមើដោយនៅក្នុងសភាពភី ពោលគឺ ពុំទាន់ដឹងខ្លួនប្រាកដនៅក្នុងសភាពងុយដេកនៅឡើយ ។

មមើ_មមាយ.- តាមវចនានុក្រម បានសេចក្ដីថា ÷ បញ្ចេញវាចា ឬនិយាយក្នុងវេលាកំពុងដេកលក់ដោយយល់សប្ដិឃើញ ។ ដេកមមើមមាយ, និយាយមមើមមាយ ។ បរិវារស័ព្ទ មមាយ អាចគន្លាស់បានជាពាក្យ មមាយនិយើ គឺ មមើនិយាយ ឬ មមាយ-ភាយមើ គឺ មមើភាយមមាយ ។

មាយី_មាយា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដំណើរលាក់ពុត, មាយាហួសពេក ឬច្រើនបែបច្រើនប្រភេទ។ ក្មេងមាយីមាយា ។ល។ បរិវារស័ព្ទ មាយី អាចគន្លាស់បានជាពាក្យ មាយីគ្រប់វិធា គឺ មាយាគ្រប់វិធី ឬ មាយីពុតត្បុតដាក់ស្រីញា គឺ មាយាពុតត្បុតដាក់ស្រីញី ពោលគឺ បញ្ចេញកិច្ចកលឱ្យស្រីកំណាន់ផ្ទម ។ ច្រើននិយាយក្លាយថា ÷ មយីមយា, ម្យី-ម្យា, ម៉្យីម៉្យ ឬ ម៉ែ្យម៉្យ, ម៉ែ្ម៉ម ។ល។

ម៉ឹង_ម៉ាត់.- ពាក្យនេះមានន័យថា ÷ មាំទាំ មធ្យ៉ត, ហ្មត់ចត់, ទៀងទាត់ ។ ធ្វើការម៉ឹងម៉ាត់ គឺធ្វើការហ្មត់ចត់, មានយុត្តិធម៌ តឹង-រ៉ឹងត្រឹមត្រូវពិតប្រាកដ ពុំមានការបន្លំ ។ល។ ដូច្នេះ បរិវារ-ស័ព្ទ ម៉ាត់ អាចគន្លាស់បានជាពាក្យ ម៉ាត់ដោយដាច់ណឹង គឺម៉ឹងដោយដាច់ណាត់ ។

ម៉ូត_ម៉ាយ.- ពាក្យនេះ ខ្មែរយើងខ្ចីពាក្យ បារាំងម៉ូត (mode) យកមកប្រើដោយថែម បរិវារស័ព្ទ ម៉ាយ បញ្ចូលតាមទម្លាប់ធ្វើជាសមាសពាក្យ មួយមានន័យថា ÷ របៀប, បែប, ទំនើប, វិធី ។ល។ ខ្ញុំចាស់ហើយស្ទើរតែពាក់ពុំមាន ម៉ូតម៉ាយទេ ។ បរិវារស័ព្ទ ម៉ាយ អាចគន្លាស់បានជាពាក្យ ម៉ាយតាមគេនាយអូត គឺម៉ូតតាមគេនាយអាយ ។

មួ_ម៉ៅ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ក្តាញ់, ខឹងក្តៅក្តួលក្នុងចិត្តដោយស្រើបរង្វេងស្មារតី ។ បរិវារស័ព្ទ ម៉ៅ អាចគន្លាស់បានជាពាក្យ ម៉ៅដោយក្តាញ់ចិត្តខ្ញួ គឺ មួដោយក្តាញ់ចិត្តខ្មៅ ។

មួ_ហ្មង ឬ មោះ_ហ្មង .- ពាក្យនេះ មានន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ មួម៉ៅ គឺ ខឹងក្តាញ់ល្អក់ចិត្ត ។ បរិវារស័ព្ទ ហ្មង អាចគន្លាស់បានជាពាក្យ ហ្មងដោយចិត្តសៅមួ គឺ មួដោយចិត្តសៅហ្មង ឬ ហ្មងដោយគេធ្វើខុសបំណូ គឺ មួដោយគេធ្វើខុសបំណង ។

មៀង_មើល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ងាក ឬបែរមើលដោយចំហៀងភ្នែក, ក្រឡេកមើល ឬ គយគន់ដោយ

កន្ទុយភ្នែក ។ ដើរបណ្ដើរមៀងមើលបណ្ដើរ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ មៀង អាចគន្លាស់បានជាពាក្យ មៀងដោយចំហើល គឺ មើលដោយចំហៀង ពោលគឺ មើលដោយកន្ទុយភ្នែក ។

**មាំ_មួន.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខ្ជាប់ខ្ជួនរឹងប៉ឹង ។ បរិវារស័ព្ទ មួន អាចគន្លាស់បានជាពាក្យ មួនដោយខ្ជាប់ខ្ជាំ គឺ មាំដោយខ្ជាប់ខ្ជួន ។

**មោះ_មុត.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលក្លាហាន, អង់អាចដែលមានចិត្តមុត, ឥតញញើត ។ ចិត្តមោះមុត, មនុស្សមោះមុត ។ បរិវារស័ព្ទ មុត អាចគន្លាស់បានជាពាក្យ មុតដោយចិត្តអង់អាចដូចអាវោះ គឺ មោះដោយចិត្តអង់អាចដូចអាវុធ ។

**មោះ_មៃ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ការទាស់ហេតុ ទាស់ដំណើរ, សេចក្ដីខុសឆ្គង ឬ ហ្មងឆ្គង ។ ដំណើរមោះមៃ នៃគណៈបក្សនយោបាយ គឺ ការប្រេះឆា នៃគណៈបក្ស

នយោបាយ ។ បរិវារស័ព្ទ មៃ អាចគន្លាស់បានជាពាក្យ មៃដោយខុសក្ដីប្រពោះ គឺ មោះដោយខុសក្ដីប្រពៃ ពោលគឺ ខុសសេចក្ដីល្អរៀបរយ ។

មោះ_ហ្មង.- ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យមោះមៃ ។ បរិវារស័ព្ទ ហ្មង អាចគន្លាស់បានជាពាក្យ ហ្មងដោយចិត្តសៅមោះ គឺ មោះដោយចិត្តសៅហ្មង ។

ម្ដេច_ម្ដា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ម្ដេចក៏ដោយ, ម្ដេចក៏បាន, ម្ដេចក្ដី ឬ យ៉ាងណា ។ ម្ដេចម្ដាទៅជម្ងឺលោកតានោះ ។ បរិវារស័ព្ទ ម្ដា អាចគន្លាស់បានជាពាក្យ ម្ដាទៅម៉េច គឺ ម្ដេចទៅម៉ា (វគ្គនេះជាគ្រាមភាសា ដែលខ្មែរយើងតាមជនបទច្រើននិយាយសព្វថ្ងៃ) ។ តាមពាក្យអ្នកក្រុងទៅវិញ យើងច្រើននិយាយថា ÷ ម្ដាទៅយ៉ាងណិច គឺ ម្ដេចទៅយ៉ាងណា ។

ម្ហូប_ម្ហា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ម្ហូបផ្សេង ៗ នេះខ្លះ នោះខ្លះ ឬ ម្ហូបច្រើនមុខ ។ បរិវារស័ព្ទ ម្ហា អាចគន្លាស់បានជាពាក្យ ម្ហាភោជនាហូប គឺ ម្ហូបភោជនាហារ ឬ ម្ហាក្រយាហូប គឺ ម្ហូបក្រយាហារ ។

ម្ហេប_ម្ហប ឬ ម្ហែប_ម្ហប.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បានសេចក្ដីថា ÷ ដែលធ្វើមាត់ទុលហើបៗ ដោយហាត់ហបៗ ព្រោះខ្លាច ឬស្លន់ខ្លាំង ។ និយាយម្ហេបម្ហប ។ បរិវារ-ស័ព្ទ ម្ហេប អាចគន្លាស់បានជាពាក្យ ម្ហេបដោយមានសភាពហេប ៗ ហប ៗ គឺ ម្ហបដោយមានសភាពហប ៗ ហេប ៗ ។

*

* *

# យ

**យង់_យល់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ក្រឡេក ទៅយល់, យល់ជាក់, ឃើញច្បាស់ ។ល។ ច្រើនប្រើក្នុង ពាក្យកាព្យ ស្តេចទតយង់យល់បក្សី ចោមចឹកចំណី ។ល។ បរិវារស័ព្ទ យង់ អាចគន្លាស់បានជាពាក្យ យង់ឃើញច្បាស់ ជ្រោដល់ខ្ចល គឺ យល់ឃើញច្បាស់ជ្រៅដល់ក្នុង ។

**យាង_យាវ**.- តាមវចនានុក្រម ពាក្យនេះ មានន័យ ចំហទាំងពីរ គឺ យាង = ឈានដើរ; យាវ = វែង ។ ច្រើនប្រើក្នុងពាក្យកាព្យ សម្រាប់រាជស័ព្ទ ។ បរិវារស័ព្ទ យាវ អាចគន្លាស់បានជាពាក្យ យាវដោយមានព្រះរាជបរិពារ បាវព្រាង គឺ យាងដោយមាន

ព្រះរាជបរិពារ បាវព្រាវ ពោលគឺ ស្តេចយាងដោយមានពល-
រេហ៍សេនាហែហម ។

**យាង_យាស.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដើរដោយ
មានលំនាំ, ដើរដោយលំនាំល្វាសល្វន់ ។ ច្រើនប្រើក្នុងពាក្យ
កាព្យ សម្រាប់រាជស័ព្ទ ។ បរិវារស័ព្ទ យាស អាចគន្លាស់បាន-
ជាពាក្យ យាសប្រស្រ័យនឹងប្រជារាង គឺ យាងប្រស្រ័យនឹងប្រ-
ជារាស្ត្រ ពោលគឺ នៅពេលកំពុងប្រស្រ័យជាមួយប្រជារាស្ត្រ
ដូចជាប្រជាសវនការជាដើម ព្រះរាជដំណើរព្រះមហាក្សត្រ
ទ្រង់មានសភាពល្វាសល្វន់ គឺ ទន់ភ្លន់ ។

**យ៉ាប់_ឆា.-** ពាក្យនេះខ្មែរបុរាណប្រើថា ÷ ហ្យាប់ជា, តែសព្វថ្ងៃ
យើងនិយាយផ្តលតាមសម្លេងសៀមវិញ ។ ពាក្យនេះ ពុំមាន
បរិវារស័ព្ទទេ ហើយបានសេចក្តីថា ÷ មិនសុភាពរាបសា, ថោក
ទាប, លំបាកណាស់ ។ល។ ដូចពាក្យទាំងឡាយ ខ្មែរបុរាណ
យើងសរសេរទ្វាំហ្វាយ, ពាក្យខ្លះទៀត ខ្មែរយើងសរសេរ
(ខ្លា) ហើយអានថា ខាល ។

**យ៉ាប់_យ៉ឺន.**- តាមវចនានុក្រម ពាក្យនេះ យើងខ្ចីសៀមមកប្រើ បាន សេចក្ដីថា ÷ ដែលខូចវិនាស, ដែលលំបាកខ្លាំង ។ ធ្វើការ យ៉ាប់យ៉ឺន ។ល។ បរិវារស័ព្ទ យ៉ឺន អាចគន្លាស់បានជា-ពាក្យ យ៉ឺនដោយត្រដាបត្រដួសពុំមានចំរ៉ាប់ គឺ យ៉ាប់ដោយ ត្រដាបត្រដួស ពុំមានចម្រើន ។

**យឹត_យោង.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ ស្រោចស្រង់, សង្គ្រោះឱ្យបានរួចពីការក្រ, ឱ្យបានរួចពីសេចក្ដី ក្រីក្រលំបាក ។ អ្នកប្រាជ្ញជួយយឹតយោងអ្នកខ្លៅ, អ្នកមាន គួរយឹតយោងអ្នកក្រ, អ្នកល្អគួរយឹតយោងអ្នកអាក្រក់ ។ បរិ-វារស័ព្ទ យោង អាចគន្លាស់បានជាពាក្យ យោងដោយប្រតឹត គឺ យឹតដោយប្រតោង ។

**យឺត_យ៉ាវ.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ យឺត = យូរ ; យ៉ាវ = វែង ។ បានសេចក្ដីថា ÷ ដែលច្រអូស មិនរហ័សរហួន ។ ដំណើរយឺតយ៉ាវ គឺដំណើរដំអៀក, ដំអែ-ដំអក់ ។ បរិវារស័ព្ទ យ៉ាវ អាចគន្លាស់បានជាពាក្យ យ៉ាវ ទាល់តែស្រែកហ៊ូ គឺ យូរទាល់តែស្រែកហៅ ពោលគឺ យឺត យ៉ាវទាល់តែស្រែកឡើន ។

យឺត_យូរ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ យូរ ព្រោះយឺត, មិនរហ័ស ។ល។ បរិវារស័ព្ទ យឺត អាចគន្លាស់បានជាពាក្យ យឺតម្លូៗ គឺ យូរម្លឺតៗ ពោលគឺ យឺតយូរដោយសភាពប៉ផ្ចិតប៉ផ្ចក់ ។

យឺន_យូរ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ យឺន = ឈរ; យូរ = ធន់ ។ បានសេចក្តីថា ÷ ស្ថិតនៅបានយូរ, ស្ថិតស្ថេរ, យូរច្រើន ។ អាយុយឺនយូរ ។ល។ បរិវារស័ព្ទ យឺន អាចគន្លាស់បានជាពាក្យ យឺនដោយស្ថិតស្ថេរនៅបានយូរ គឺ យូរដោយស្ថិតស្ថេរនៅបានយឺន ។

យុរ_យារ ឬ យុល_យារ .- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទន់ជាបស្តុបចុះ, សំយាកជាបចុះ ។ ដែលយូរយារ រយីករយាក, ចាស់ជរាសាច់ស្បែកឡើងយុលយារ ឬ យុរយារ ។ល។ បរិវារស័ព្ទ យារ អាចគន្លាស់បានជាពាក្យ យាររយាកដោយជរុល ឬជរុហ៍ គឺ យុល ឬយុររយាកដោយជរា ។

យូរ_យារ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យូរអង្វែង, យូរជ្រុល , យូរហួសកំណត់ ។ រឿងយូរយារណាស់ហើយ

ៗល។ បរិវារស័ព្ទ យារ អាចគន្លាស់បានជាពាក្យ យារហួស ច្រើនវេល្ងរ គឺ យូរហួសច្រើនវេលា ពោលគឺ យូរណាស់ហួស ច្រើនកាល ។

យូរ_យាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យូរណាស់ មកហើយ ឬទៅហើយ ។ បរិវារស័ព្ទ យាំង អាចគន្លាស់បាន ជាពាក្យ យាំងពេកទៅរកកល់ភ្លេចភ្លូរ គឺ យូរពេកទៅរកកល់ ភ្លេចភ្លាំង ។

យួន_ព្រួន.- តាមការដំណាលនៃអស់លោកតាចាស់ ៗ ខ្លះ ពាក្យ យួន ព្រួននេះ ខ្មែរយើងបាននិយមប្រើ ហៅជនជាតិយួនចាប់តាំង ពីសម័យ ឧត្តមសេនីយយួនឈ្មោះ ទ្រឿង មិញ យ៉ាង ដែល ត្រួតត្រាផ្តាច់ការប្រទេសយើង ។ កាលនោះដោយនៅទ្រាំរង ទុក្ខ វេទនាតទៅទៀតពុំបាន ក៏នាំគ្នាភ្ញាក់រលឹកតស៊ូ ដេញវាយ កាប់សម្លាប់ទ័ពយួនឱ្យថយចេញពីស្រុក ។ នៅពេលនោះមាន ទាហានយួនភាគខ្លះ បាននាំគ្នាភៀសខ្លួន លោតចុះទៅក្នុងទឹក ស្ទឹង និងទន្លេ ដោយយកស្រកីដូងទូលលើក្បាល បន្លំបណ្តែត

ទឹករត់ឱ្យផុតពីកណ្ដាប់ដៃខ្មែរ ។ ត្រង់នេះហើយដែលខ្មែរយើងហៅពួកយួនថា ÷ អាស្រុកីយឿ ពោលគឺ ÷ អាស្រុកីដូង ព្រោះពាក្យ យឿ ជាពាក្យយួនប្រែមកថា ÷ ផ្លែដូង ។

នៅវេលានោះទៀត មានយួនមួយភាគទៀត ដែលរកស្រុកីដូងពុំបានដូចចិត្តបានរត់ចុះទឹកទៅពួនក្នុងគុម្ពត្រកួន ។ ត្រង់នេះហើយ ដែលខ្មែរយើងដាក់ឈ្មោះថា ÷ យួនព្រួន ព្រោះបរិវារស័ព្ទ ព្រួន នេះជាពាក្យគន្លាស់ថា ÷ ព្រួនក្នុងគុម្ពត្រកួច គឺប្រួចក្នុងគុម្ពត្រកួន ។

សព្វថ្ងៃនេះ ខ្មែរយើងភាគខ្លះ បានហៅជនជាតិយួនថា ÷ អាត្រកួនឆា ឬត្រកួនស្ងោរ ។ នេះពិតជាពាក្យក្លាយពីចំណុចដើម ដូចខ្ញុំបានធ្វើអត្ថាធិប្បាយជូនខាងលើ ។ ដូចជាឈ្មោះព្រែកពាម ប្រទេសនោះទៀត ដែលខ្មែរយើងឱ្យឈ្មោះក្នុងសម័យកំពប់តែអុងនោះ បានក្លាយពីភាសាខ្មែរទៅសម្ដីយួនថា : ព្រែកពាមប្រតេ រហូតមកដល់ព្រែកយិនតេ ឬ វិនតេ ដូចសព្វថ្ងៃទៅវិញ (Canal de Vintte) ។

យឿង_យ៉ាង.- គឺបញ្ចេញអាការឌឺ យឿងទឹកមុខដាក់ ។ បរិវារស័ព្ទ យ៉ាង អាចគន្លាស់បានជាពាក្យ យ៉ាងដោយអាការឌឺឡើងជឿង គឺ យឿងដោយអាការឌឺឡើងចាង ពោលគឺ ឌឺដោយខ្លាំងដៃ ។

យោក_យោក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យោក យោលផ្អេកចុះផ្អេកឡើង ឬយោកយោលទៅមុខទៅក្រោយ ។ ដំណើរយោកយោក ។ល។ បរិវារស័ព្ទ យោក អាចគន្លាស់បានជាពាក្យ យោកយោលចុះឡើងរាងផ្អក គឺ យោកយោលចុះឡើងរាងផ្អេក ។

យោក_យល់.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ យល់ដោយសេចក្ដីលម្អៀង, យល់មុខ ។ បរិវារស័ព្ទ យល់ អាចគន្លាស់បានជាពាក្យ យល់ដោយលម្អៀងចិត្តរវើក គឺ យោកដោយលម្អៀងចិត្តរវល់ ។

យោល_យោក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យោក ចុះយោកឡើង លឿនទៅលឿនមក, យោកខ្ចោល ៗ ឡើង ។

រលកទឹកយោលយោកបោកខ្លាំងស្មើរលិចទូក ។ល។ បរិវារ-ស័ព្ទ យោល អាចគន្លាស់បានជាពាក្យ យោលដោយរលកទឹកបោកខ្លាំងខ្លោក គឺ យោកដោយរលកទឹកបោកខ្លាំងខ្លោល ។

**យំ_យែក.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យំរៀបរាប់ ។ យាយនេះគាត់យំយែកដល់ណាទៀត ។ល។ បរិវារស័ព្ទ យែក អាចគន្លាស់បានជាពាក្យ យែកស្រុម គឺ យំស្រែក ។

* *

*

# រ

**រកាក់_រកុប**.- ដែលរដាក់រដុប. ខ្ពស់ទាបៗ ។ ផ្ទុយរកាក់រកុប ។ បរិវារស័ព្ទ រកាក់ អាចគន្លាស់បានជាពាក្យ រកាក់ ដោយមានរឡុប គឺ រកុបដោយមានរលាក់ ។

**រកិប_រកុប**.- ដែលរដិបរដុប ខ្ពស់ទាបច្រើន ។ ផ្ទុយរកិបរកុប ។ បរិវារស័ព្ទ រកិប អាចគន្លាស់បានជាពាក្យ រកិប ដោយមានរដិបរដុប គឺ រកុបដោយមានរដុបរដិប ។

**រកេត_រកូត**.- ដែលរាយគ្នារង្វើលៗ មើលទៅឃើញខ្ពស់ខ្លះទាបខ្លះ ។ល។ កូនឈើដុះរកេតរកូតពេញវាល ។ល។ បរិវារស័ព្ទ រកេត អាចគន្លាស់បានជាពាក្យ រកេត រាយគ្នាដោយកំប៉េតកំប៉ូត គឺ រកូតរាយគ្នាដោយកំប៉ូតកំប៉េត ។

**កាំ_កូស.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មានមោះ មៃសៅហ្មងនឹងគ្នាមិនស្ងវស្រោក; ដែលចេះតែប្រដាក់ប្រទុក, រើរុស, រអាក់រអួល មិនជាប្រក្រតី ។ ចេះតែរកាំរកូសនឹងគ្នា ។ល។ បរិវារស័ព្ទ រកូស អាចគន្លាស់បានជាពាក្យ រកូសសៅហ្មងនឹងគ្នា ដោយមានរឿងខាំ គឺ រកាំសៅហ្មងនឹងគ្នា ដោយមានរឿងខុស ពោលគឺ ចេះតែមានរឿងពុំត្រូវចិត្តគ្នា ។

**ខិក_ខក់.**- តាមវចនានុក្រម, ពាក្យនេះ មានន័យថា ÷ ដែលរលុង ឬរង្គោះរង្គើករង៉ក់ ។ រលុងរខិករខក់ ។ បរិវារស័ព្ទ រខក់ អាចគន្លាស់បានជាពាក្យ រខក់ដោយរលុងកខ្លិក គឺ រខិកដោយរលុងកខ្លក់ ។

**ខិញ_ខុញ.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្ដីថា ÷ មានស្នាមដោយអន្លើ១មិនរាប, មិនរលីង ។ ស្នាមមុខដែលឈូសរខិញរខុញ ។ បរិវារស័ព្ទ រខិញ អាចគន្លាស់បានជាពាក្យ រខិញ ដោយមានស្នាមរខុញ គឺ រខុញ ដោយមានស្នាមរខិញ ។

**ខេក_ខោក.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល

រខាករឃើករយាកក្រៃពេក ។ ជញ្ជាំងស្លឹករខេករខាក ។ល។ បរិវារស័ព្ទ រខេក អាចគន្លាស់បានជាពាក្យ រខេកក្រៃបាក គឺ រខាកក្រៃពេក ។

**រខែក_រខោក.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរខោកក្រៃពេក ។ បររទេះគោរខែករខោក ។ ល។ បរិវារ-ស័ព្ទ រខែក អាចគន្លាស់បានជាពាក្យ រខែកដោយឮសូរចង់បោក គឺ រខោក ដោយឮសូរចង់បែក ។

**រគិប_រគុប.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរដិបរដុប ។ ខ្ពស់ទាប ៗ ។ ផ្លូវរគិបរគុប គឺ ផ្លូវរដិបរដុប ។ បរិវារស័ព្ទ រគិប អាចគន្លាស់បានជាពាក្យ រគិបដោយរដិបរដុប គឺ រគុបដោយរដុបរដិប ។

**រគិម_រគាម.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិនរាបស្មើ, តំរៀបគ្នាមិនស្មើ, ដែលលេចថ្កោល ៗ ឡើង ។ ឆ្អឹងជំនីរគិមរគាម ។ល។ បរិវារស័ព្ទ រគិម អាចគន្លាស់បានជាពាក្យ រគិមដោយលេចថ្កោល ៗ គគ្រិមគគ្រាម គឺ រគាមដោយលេចថ្កោល ៗ ដោយគគ្រាមគគ្រិម ។

រតើម_រតើម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រតើមពេញពាស ។ ក្ដាមវាររតើមរតើម ។ល។ បរិវារស័ព្ទ រតើម អាចគន្លាស់បានជាពាក្យ រតើមដោយគគ្រឹមគគ្រើម គឺ រតើមដោយគគ្រើមគគ្រឹម ។

រគោក_រគោល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរងិបរងុបថ្ពោល១ ច្រើន ឬ គគោក ។ សត្វក្ដាន់រគោករគោល ។ បរិវារស័ព្ទ រគោក អាចគន្លាស់បានជាពាក្យ រគោកច្រើនគគោល គឺ រគោលច្រើនគគោក ។

រឆាក់_រឆើ.- សូមមើលពាក្យ ល្ហាក់ល្ហើ ។

រឆាក់_រឆើក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលង៉ាក់ងើកចុះឡើង ។ សូមមើលពាក្យ ង៉ាក់ងើក ។

រង៉ាប់_រងួ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមួរម៉ៅ, គួរចុះគួរឡើង ។ ខឹងរង៉ាប់រងួ ។ បរិវារស័ព្ទ រងួ អាចគន្លាស់បានជាពាក្យ រងួរដោយខឹងម៉ាប់ គឺ រង៉ាប់ដោយខឹងមួ ។

រង៉ាប់_រងើ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលងេងដោង ឬ ងេងើរកកល់ក្អួតចង្អោរហាក់ដូចជាពុលថ្នាំជាដើម ។

បរិវារស័ព្ទ រង៉ាប់ អាចគន្លាស់បានជាពាក្យ រង៉ាប់ផេងផោងវិល ក្រលើ គឺ រងើផេងផោងវិលក្រឡាប់ ។

**រង៉ិក_រង៉ក់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលទន់ល្វៃ ពត់ពែន ។ ទៀនត្រូវក្តៅទន់រង៉ឹករងក់ ។ បរិវារស័ព្ទ រង៉ក់ អាចគន្លាស់បានជាពាក្យ រង៉ក់ទន់ល្វៃវៀចរ៉ឹក គឺ រង៉ឹកទន់ល្វៃ វៀចវៃក់ ។

**រងី_រងើ.-** សូមមើលពាក្យ ល្ងីល្ងើ ។

**រងឹត_រងល់.-** សូមមើលពាក្យ ងងឹតងងល់ ។

**រងេ_រងើ.-** សូមមើលពាក្យ ល្ងេល្ងើ ។

**រង៉ែ_រង៉ូវ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលពោល-ពាក្យ រទូរទាំ ត្អូញត្អែរ ឥតស្រាក. រង៉ែរង៉ូវក្រៃពេក ។ បរិវារ-ស័ព្ទ រង៉ែ អាចគន្លាស់បានជាពាក្យ រង៉ែ ដោយពោលពាក្យ រទូរទាំ ត្អូញត្អូរ គឺ រង៉ូវ ដោយពោលពាក្យ រទូរទាំ ត្អូញត្អែរ ។

**រងោក_រងល់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល មើលទៅឃើញច្រើនត្រៀបពាសពេញ ។ មនុស្សអង្គុយស្តាប់ ទេសនា រងោករងល់ ។ បរិវារស័ព្ទ រងល់ អាចគន្លាស់បាន

ជាពាក្យ រងល់ច្រើនត្រៀបពាសពេញច្រឡំបូក គឺ រងោកច្រើនត្រៀបពាសពេញច្រឡំបល់ ។

**រងោក_រង្គយ.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលមើលទៅឃើញត្រៀបច្រើនរយ ។ បរិវារស័ព្ទ រង្គយ អាចគន្លាស់បានជាពាក្យ រង្គយត្រៀបច្រើនរោក គឺ រងោកត្រៀបច្រើនរយ ។

**រងោក_រង្គំរ៉.-** ពាក្យនេះមានអត្ថន័យប្រហាក់ប្រហែលគ្នា នឹងពាក្យរងោករង្គយ ។ មនុស្សឈររងោករង្គំរ៉ស្តាប់ប្រកួតចម្រៀង ។ បរិវារស័ព្ទ រង្គំរ៉ អាចគន្លាស់បានជាពាក្យ រង្គំរ៉ច្រើនត្រៀបពេញភ្លោក គឺ រងោកច្រើនត្រៀបពេញផ្លូវ ។

**រង្គិក_រង្គើក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិនមាំ, រញ្ជួយ, ដែលធ្វើអោយកម្រើក ។ បរិវារស័ព្ទ រង្គិក អាចគន្លាស់បានជាពាក្យ រង្គិក រញ្ជួយគគ្រឹក គឺ រង្គិក រញ្ជួយគគ្រើក ។

**រំពែក_រពោក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលឈ្លោះប្រកែកគ្នារអែករអោក, ដែលទាស់ទែងបាក់បែកគ្នា ។ អ្នកលេងបៀរឈ្លោះប្រកែករំពែករពោក ។ បរិវារស័ព្ទ រំពែក

អាចគន្លាស់បានជាពាក្យ រចែក ដោយឈ្មោះប្រកោក គឺ រចោក ដោយឈ្មោះប្រកែក ។

**រចេក_រចូច.-** ពាក្យនេះមានន័យប្រហាក់ប្រហែលគ្នានឹងពាក្យ រឆេត រឆូត ។ អាស្រ័យហេតុនេះ សូមមើលពាក្យ រឆេតរឆូត ។

**រឆេត_រឆូត.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានស្នាមឆូតក្រវេមក្រវាមពាសពេញ ។ ក្មេងធ្វើអោយស្នាមរឆេតរឆូត ។ បរិវារស័ព្ទ រឆូត អាចគន្លាស់បានជាពាក្យ រឆូតដោយស្នាមក្រវេមក្រវាមឆេត គឺរឆេតដោយស្នាមក្រវេមក្រវាមឆូត ។

**រញ៉ិង_រញ៉ាំង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលខឹងខ្លាំង, ត្រកោះបោះបោក, រនឹងរនាំងក្រែពេក ។ បរិវារស័ព្ទ រញ៉ាំង អាចគន្លាស់បានជាពាក្យ រញ៉ាំងដោយខឹងខ្ញិង គឺ រញ៉ិងដោយខឹងខ្លាំង ។

**រញ៉ិម_រញ៉ាំ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលសាំញ៉ាំក្រែពេក, ដែលរញ៉ាំរសេមរសាម ឬ រញ៉ាំក្រវេមក្រវាម ។ បរិវារស័ព្ទ រញ៉ិម អាចគន្លាស់បានជាពាក្យ រញ៉ិមដោយក្រវេមក្រវាម សាំញ៉ាំ គឺ រញ៉ាំដោយក្រវេមក្រវាមសាំញ៉ាំ ។

**រញ្ញី_រញ្ញ័រ.-** សូមមើលពាក្យ ញញ្ញីញញ្ញ័រ ។

**រញ្ញឹក_រញ្ញុឹ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរញ្ញុឹយ៉ាងញ្ញឹក, ដែលចេញអាការដណ្ដើមគ្នាយ៉ាងញ្ញឹកញ្ញាប់ ។ ដណ្ដើមលុយទានរញ្ញឹករញ្ញុឹ ។ បរិវារស័ព្ទ រញ្ញុឹ អាចគន្លាស់បានជាពាក្យ រញ្ញុឹដោយដណ្ដើមគ្នាយ៉ាងប្រញ្ញឹក គឺ រញ្ញឹកដោយដណ្ដើមគ្នាយ៉ាងប្រញ្ញុឹ ។

**រញ្ញ៉ោច_រញ្ញ៉ាច.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរញ្ញ៉ោចញ្ញ៉ាចរឿយៗដោយច្រើនគ្នា ។ បរិវារស័ព្ទ រញ្ញ៉ាចអាចគន្លាស់បានជាពាក្យ រញ្ញ៉ាចដោយសូរសម្លេងចាចចេច គឺ រញ្ញ៉ាចដោយសូរសំលេងចេចចាច ។ អ្នកខ្លះនិយាយថា ÷ រញ្ញ៉ោក រញ្ញ៉ាចវិញ ។ ពាក្យរញ្ញ៉ោចរញ្ញ៉ាចនេះមានន័យចំហទាំងពីរ ។

**រញ្ញ៉ែ_រញ្ញ៉ូវ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរអែរអូវពេកក្រៃ, ដែលរង៉ែរង៉ូវ, ដែលទន្ទូរទន្ទេញរឿយៗ ។ សម្ដីរញ្ញ៉ែរញ្ញ៉ូវ ។ បរិវារស័ព្ទ រញ្ញ៉ូវ អាចគន្លាស់បានជាពាក្យ រញ្ញ៉ូវដោយរអូវរអែ គឺ រញ្ញ៉ែដោយរអែរអូវ ឬ រញ្ញ៉ូវពេកកែ គឺ រញ្ញៃពេកកូវ ។

រញ្ញាំ_រញ៉ូវ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទន្ទេញ ទន្ទូររឿយ ៗ ដោយសន្សំរករឿងរកហេតុ ពីនេះមាននោះមិនស្ងូវស្រាក ។ មនុស្សរញ្ញាំរញ៉ូវ គឺ មនុស្សស្ងួញសាញខឹងច្រើន ។ បរិវារស័ព្ទ រញ៉ូវ អាចគន្លាស់បានជាពាក្យ រញ៉ូវដោយទន្ទេញទន្ទូររអែរអាំ គឺ រញ្ញាំដោយទន្ទេញទន្ទូររអែរអូរ ឬរញ៉ូវពេកកាំ គឺ រញ្ញាំពេកកូវ ។

រដោក់_រដុប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរកាក់រកុបខ្ពស់ទាបច្រើន ។ ដីរដាក់រដុប ។ សូមមើលពាក្យរកាក់រកុប ។

រដោច់_រដោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាច់ដោចឃ្លាតពីគ្នា ។ សូមមើលពាក្យ ដាច់ដោច ។

រដិប_រដុប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រកិបរកុបខ្ពស់ទាបច្រើន ។ ដីរដិបរដុប ។ សូមមើលពាក្យ រកិបរកុប ។

រណោប_រណាប ឬ រណែប_រណាប.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ រណាបរណិបអែបអប ។ ផ្ដាប់ផ្ដន់រណោប-

រណេប ។ បរិវារស័ព្ទ រណែប អាចគន្លាស់បានជាពាក្យ រណែប រាយអែបអប គឺ រណេបរាយអបអែប ។

**រណេប_រណឹប.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឃ្មើប ចុះឃ្មើបឡើង, ដែលឱន ១ ក្រាប ១ ដោយសេចក្ដីគោរព ឬ ផ្គាប់ផ្គុន ។ អង្គុយគាល់រណេបរណឹប, ផ្គាប់ផ្គុន រណេប-រណឹប ។ល។ បរិវារស័ព្ទ រណេប អាចគន្លាស់បានជាពាក្យ រណេបដោយផ្គាប់ផ្គុននិតនឹប គឺ រណឹបដោយផ្គាប់ផ្គុននិត្យនែប ។

**រណែង_រណោង.-** គឺរណោងច្រើន ។ សូមមើលពាក្យ រតែង រតោង ឬប្រតែងប្រតោង ។

**រតាត់_រតាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រាត់រាយ ចេញពីគ្នា, រាត់រាយពាសពេញ, បាចសាច, រាយប៉ាយ ។ បរិវារស័ព្ទ រតាត់ អាចគន្លាស់បានជាពាក្យ រតាត់ ដោយរាត់រាយរប៉ាតរប៉ាយ គឺ រតាយដោយរាត់រាយរប៉ាយរប៉ាត ។

**រតិប_រតុប.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រអាក់រអួល ខ្ពស់ទាប១ដូចគេដាក់បន្ទុក, ចង្អៀតចង្អល់, លំបែកលំបាក ។ ដំណើររតិបរតុប ។ បរវារស័ព្ទ រតិប អាចគន្លាស់បានជាពាក្យ

រតិបដោយរអាក់រអួល រកិបរកុប គឺ រតុបដោយរអាក់រអួល រកុបរកិប ។ អ្នកខ្លះនិយាយថា : តតិបតតុបវិញ ។

**រពេក_រពាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល សាកគ្រាកពេក, កន្ត្រាក់ពេក ។ សំពត់យាររពេករពាក ។ បរិវារស័ព្ទ រពេក អាចគន្លាស់បានជាពាក្យ រពេកដោយយារ សាកគ្រាកប៉ាក គឺ រដាកដោយយារសាកគ្រាកពេក ។ អ្នកខ្លះ និយាយពាក្យនេះថា : តពេកតពាកវិញ ។

**រពេយ_រពាយ ឬ រំពៃយ_រពាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលវែងអន្លាយពេកក្រៃ ។ ជាយសំពត់វែង រំពៃយរពាយ ។ បរិវារស័ព្ទ រំពៃយ អាចគន្លាស់បានជាពាក្យ រំពៃយដោយវែងអន្លាយពេកក្រាយ គឺ រពាយដោយវែងអន្លាយ ពេកក្រៃ ។

**រំពែក_រពោក.-** ពាក្យនេះ មានន័យថា ÷ ដែលរពោកយាររយោក ខើចខ្លះយារខ្លះ, ចង្កោមស្វាយព្យួររំពែករពោក ។ បរិវារស័ព្ទ រំពែក អាចគន្លាស់បានជាពាក្យ រំពែកដោយយាររយោកស្ពោក គ្រប់ម៉ោក គឺ រពោកដោយយាររយោកស្ពោកគ្រប់មែក ។

រកែង_រពោង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលព្យួរ ដូចគេចងបន្តោងជិត ១ គ្នា ។ ព្យួររកែងរពោង ។ បរិវារស័ព្ទ រកែង អាចគន្លាស់បានជាពាក្យ រកែងជារំយោល រណែង រណោង គឺ រពោងជារំយោល រណោងរណែង ។

រទើស_រទាស់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល-ទាស់ចុះទាស់ឡើង. ដែលទទើសទទាស់ ។ សូមមើលពាក្យ ទទើសទទាស់ ។

រទូ_រទាំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលពោលរទូៗ ច្រំដែលៗ ។ និយាយរទូរទាំ គឺ និយាយរអ៊ូរទាំ ។ សម្ដីរទូ-រទាំ ។ បរិវារស័ព្ទ រទាំ អាចគន្លាស់បានជាពាក្យ រទាំដោយ-រអ៊ូ ចជ្រូ គឺ រទូដោយរអ៊ូ ចច្រំ ពោលគឺ ដោយរអ៊ូច្រំដែលៗ ។

រនិង_រនាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលខ្លាំង. រឹងប៉ឹង. រឹងរូសច្រងេងច្រងាង ។ ក្មេងរនិងរនាំង. ចិត្តរនិង-រនាំង ។ បរិវារស័ព្ទ រនាំង អាចគន្លាស់បានជាពាក្យ រនាំង ដោយច្រងេងច្រងាងរឹងរូសខ្លិង គឺ រនិងដោយច្រងេងច្រងាង-រឹងរូសខ្លាំង ។

របស់_របរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អម្រស់អម្រ. អម្រស់ដែលរកបានដោយកម្លាំងកាយ. វត្ថុ ឬ ទ្រព្យដែលជារបស់លក់ដូរ ។ ពាក្យរបស់របរ និងអម្រស់អម្រ មានន័យដូចគ្នាទាំងពីរ ។ ពាក្យអម្រស់អម្រនេះ ជាពាក្យដែលមហាច្រើនប្រើក្នុងពិធីរៀបចំអាពាហ៍ពិពាហ៍ ។ បរិវារស័ព្ទ របរ អាចគន្លាស់បានជាពាក្យ របរដែលជាអម្រស់ គឺ របស់ដែលជាអម្រ ។

រញ៉ាត់_រញ៉ោយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរតាតរតាយ. រាត់រាយ ។ ជ្រុះរប៉ាតរប៉ាយ ។ល។ បរិវារស័ព្ទ រប៉ាយ អាចគន្លាស់បានជាពាក្យ រប៉ាយដោយរាត់រាយ រតាយរតាត គឺ រប៉ាតដោយជ្រុះរាត់រាយ រតាតរតាយ ។

របុិច_របុិ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលតិចតួចរាយរងហើយងាយរកបាន ។ ការរបុិចរបុិ. របស់របររបុិចរបុិ បរិវារស័ព្ទ របុិ អាចគន្លាស់បានជាពាក្យ របុិតិចតួចដែលបាត់មិនអុិច គឺ របុិតិចតួចដែលបាត់មិនអី ។

របិញ_របុញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានពុត. មានកិច្ចកល់ខិលខូចរខិញរខុញ ។ គំនិតរបិញរបុញ.

មនុស្សរបិញរបុញ ។ បរិវារស័ព្ទ របិញ អាចគន្លាស់បានជាពាក្យ របិញដោយមានពុតខិលខូចរខិញរខុញ គឺ របុញដោយមានពុតខិលខូចរខុញរខិញ ។

**របិុល_របុ៉ច.–** ជនរបិុលរបុ៉ច គឺ ជនខិលខូច ។ បរិវារស័ព្ទ របិុល អាចគន្លាស់បានជាពាក្យ របិុលខូច គឺ របុ៉ចខិល ។ សូមមើលពាក្យ ប៊ប៉ុលប៉ប៉ុច ។

**របឹង_របាញ.–** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរឹងមិនងាយខ្លាច, មិនងាយស្តាប់, មិនងាយជឿ, គឺ របឹងខ្លាំង, របឹងក្រាញ, របឹងមិនងាយចាញ់ ។ មនុស្សរបឹងរបាញ, ចិត្តរបឹងរបាញ ។ល។ បរិវារស័ព្ទ របាញ អាចគន្លាស់បានជាពាក្យ របាញដោយមានចិត្តរឹងមិនងាយចឹង គឺ របឹងដោយមានចិត្តរឹងមិនងាយចាញ់ ។

**របួត_របាញ.–** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរបួតរាត់រាយ ឬ រយីករយាក ។ បរិវារស័ព្ទ របាញ អាចគន្លាស់បានជាពាក្យ របាញជ្រុះដោយរអិលដូចលាបខ្លួត គឺ របួតជ្រុះដោយរអិលដូចលាបខ្លាញ់ ។

រពើក_រពាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរបើកខ្លាំង ។ ឈ្លោះរករឿងគ្នារបើករបាញ គឺ ឈ្លោះរករឿងគ្នាលើកបើកកកាយ សកេរ្តិ៍សគល់អស់មិនសល់ ។ សើរើរបើករបាញ គឺ សើរើទាល់តែឃើញដំណើរហេតុពិត ពុំមានចន្លោះអ្វីនៅសល់ ។ បរិវារស័ព្ទ របាញ អាចគន្លាស់បានជាពាក្យ របាញហើបកកាយសើរើអស់គ្មានអ្វីនៅសើក គឺ របើកហើបកកាយសើរើអស់គ្មានអ្វីនៅសាញ ។

រពេត_រពូត.- គឺរលូត, ឃ្លាតចេញដូចគេចាប់បូត ។ បរិវារស័ព្ទ របេត អាចគន្លាស់បានជាពាក្យ របេតក្រហតថ្លូត គឺ របូតក្រហតថ្លេត ។

រពេះ_រពោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ របេះដូចគេចាប់បោច, របោចរបូតចេញ ។ បរិវារស័ព្ទ របោច អាចគន្លាស់បានជាពាក្យ របោច ដូចគេចាប់បេះ គឺ របេះដូចគេចាប់បោច ។

រពោះ_រពោយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលហោច, របោយណាស់, ដែលយូរ ។ ឃើញមួយៗ ។ ឆ្នាំ

នេះ ស្វាយផ្លែរបោះរបោយ ។ល។ បរិវារស័ព្ទ របោះ អាចគន្លាស់បានជាពាក្យ របោះ ដោយថយឱ្យ គឺ របោយដោយថយអស់ ។

របេះ_របើក.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហរទាំងពីរ បានសេចក្ដីថា ÷ ដែលមិនស័ប់ចេះតែបះចុះបះឡើង ។ សូមមើលពាក្យ បះបើក ។

របេះ_របោរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបះបោរក្រៃពេក, ដែលចេះតែបះបោរញឹកញាប់ ។ ស្រុករបះរបោរ ។ សូមមើលពាក្យ បះបោរ ។

រផាត់_រផុយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បាត់ខ្ចាត់ខ្ចាយអស់ដូចគេផាត់ចោល ។ មិនចេះថែទាំទ្រព្យរបស់បណ្ដោយឱ្យរផាត់រផុយអស់រលីង ។ បរិវារស័ព្ទ រផាត់ អាចគន្លាស់បានជាពាក្យ រផាត់ដោយបាត់ខ្ចុយ គឺ រផុយដោយបាត់ខ្ចាត់ ។

រពុក_រពាក់.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បានសេចក្ដីថា ÷ ដែលជ្រុះព្រួសរខុកៗខ្លាក់ៗរឿយៗ ។ ផ្លែអំពិលជ្រុះរពុករពាក់ ។ បរិវារស័ព្ទ រពាក់ អាចគន្លាស់បានជា

ពាក្យ រពាក់ដោយជ្រុសខ្ទុក១ គឺ រពុកដោយជ្រុះខ្ទាក់១ ។

**រពុក_រពុយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលចេះតែជ្រុះបន្ត១គ្នា ។ ស្លឹកឈើជ្រុះរពុករពុយ ។ បរិវារស័ព្ទ រពុក អាចគន្លាស់បានជាពាក្យ រពុកដោយជ្រុះខ្ទុយ គឺ រពុយដោយជ្រុះខ្ទុក១ ។

**រពើត_រពើង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានលំនាំពើង ហើយចំទើតចំទយ របះរបើក ។ ដើររពើតរពើង, ដំណើររពើតរពើង ។ បរិវារស័ព្ទ រពើង អាចគន្លាស់បានជាពាក្យ រពើងដោយលំនាំដើរទើងចុងជើត គឺ រពើតដោយលំនាំ-ដើរទើងចុងជើង ។

**រយ៉ុ_រយ៉ៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរគាយដូចគេច្រៀកភាត់វាយ, ដែលរយ៉ៃក្រៃពេក ។ សំពត់រហែករយ៉ុរយ៉ៃ ។ បរិវារស័ព្ទ រយ៉ុ អាចគន្លាស់បានជាពាក្យ រយ៉ុផុយឆាប់រហែកដោយពុំមែនដូចថ្ងៃ គឺ រយ៉ៃផុយឆាប់រហែកដោយពុំមែនដូចថ្មី ។

**រយើក_រយោក ឬ រយេក_រយាក.-** តាមវចនានុក្រម ពាក្យនេះមាន-

ន័យថា ÷ ដែលគ្រាំគ្រា ជ្រោកជ្រាក, រខាក, ដែលរយាកក្រៃពេក ។ ផ្ទះចាស់រយីករយាក ។ បរិវារស័ព្ទ រយេក អាចគន្លាស់បានជាពាក្យ រយេកដោយរហែកជ្រាក រខាកពាក គឺ រយាក-ដោយរហែកជ្រាករខាកពេក ។

រយីក_រយោក ឬ រយេក_រយោក.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលតែកតោកយោកទៅយោកមករឿយៗ ។ រទេះអីវ៉ាន់រយីករយោក ។ បរិវារស័ព្ទ រយេក អាចគន្លាស់បានជាពាក្យ រយេកដោយរតែករតោត ពោកគឺ រយោកដោយរតែករតោតពេក ។

រយឹង_រយោង ឬ រយេង_រយោង.- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ដែលរយោងខ្លីខ្លះវែងខ្លះ លាយឡំគ្នា, ដែល-សំយុងចុះរណោងរណោង ។ ព្យួរសាច់ក្រករយេងរយោង ។ បរិវារស័ព្ទ រយេង អាចគន្លាស់បានជាពាក្យ រយេងដោយព្យួរ-សំយុងចុះរណោងរនោង គឺ រយោងដោយព្យួរសំយុងចុះរណោងរណោង ។

រយេះ_រយាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បែក

រហែកយែកចេញដូចគេចាប់រះ ។ សំពត់រយះរយាយ ។ បរិវារស័ព្ទ រយាយ អាចគន្លាស់បានជាពាក្យ រយាយធ្លះ គឺ រយះធ្លាយ ។

រលាក_រលោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រលាត់. របក. ខ្លោចស្បែកដោយត្រូវចំហាយក្ដៅ ឬ ដោយត្រដុស. កកិត ។ ភ្លើងរលាករលោចសាច់អស់ ។ បរិវារស័ព្ទ រលោច អាចគន្លាស់បានជាពាក្យ រលោចឃ្លាក គឺ រលាកខ្លោច ។

រលាក់_រលើ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរលើដោយភាន់ស្មារតី. ភាន់ផ្លូវ. ពភ្លាក់ពភ្លើ ។ សូមមើលពាក្យ ពភ្លាក់ពភ្លើ ។

រលាត_រលោច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រលាត់ស្បែកខ្លោច. រលាត់រវាមឬច្រើនអន្លើ ។ បរិវារស័ព្ទ រលោចអាចគន្លាស់បានជាពាក្យ រលោចស្បែកឃ្លាត់ គឺ រលាត់ស្បែកខ្លោច ។

រលី_រលើ.- ពាក្យនេះ មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យ ភ្លីភ្លើ. ពភ្លីពភ្លើ. ល្ងីល្ងើ. រងីរងើ ។ ល ។ សូមមើលពាក្យទាំងនេះ ។

រលិប_រលោប ឬ រលិបរលោប.- តាមវចនានុក្រម ពាក្យនេះ មាន

ន័យថា ÷ ដែលនៅសល់បន្តិចបន្តួចរលាប១ ។ សម្លនៅសល់រលិបរលាបនៅបាតឆ្នាំង ។ បរិវារស័ព្ទ រលិប អាចគន្លាស់បានជាពាក្យ រលិបដោយនៅសល់មិនបានមួយជាប គឺ រលាបនៅសល់មិនបានមួយជិប ពោលគឺ មិនបានភ្លក់មួយម៉ាត់ផង ។

**រលើម_រលាម.-** សូមមើលពាក្យ លលឹមលលាម ។

**រលុប_រលាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រលុបមិនអស់នៅរលាប១ គឺ នៅសល់បន្តិចបន្តួច ។ បរិវារស័ព្ទ រលាក អាចគន្លាស់បានជាពាក្យ រលាកនៅសល់ពព្រុប១ គឺ រលុបនៅសល់ពព្រាក១ ។ អ្នកខ្លះនិយាយ ពាក្យនេះថា ÷ រលុបរលាយវិញ ។

**រលុប_រលាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រលុបលាយច្រឡំចូលគ្នា. រលុបវិនាសបាត់សូន្យ ។ អ្នកខ្លះសរសេរពាក្យលុបជារលប់តាមសូរសម្លេងវិញ ។ បរិវារស័ព្ទ រលុប អាចគន្លាស់បានជាពាក្យ រលុបចូលច្រឡំគ្នាដោយរលាយ គឺ រលាយចូលច្រឡំគ្នាដោយរលុប ។

**រលុះ_រលាញ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលលុះ មិនរុញរា, ដែលហ៊ានរុករានចេញចូលទៅមកសុសសព្វ ។ មនុស្សរលុះរលាញ ។ បរិវារស័ព្ទ រលាញ អាចគន្លាស់បានជាពាក្យ រលាញដោយមានការជំនុះ គឺ រលុះដោយមានការជំនាញ ពោលគឺ ដោយជាអ្នកជំនាញមានការហ៊ឹកហ៊ឺនពិសោធន៍ច្រើន ។

**រលុះ_រលាយ ឬ រលាយ_រលុះ.**- តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ធ្លុះធ្លាយជារន្ធ, ជាប្រហោង, ជារូង ជាប្រឡាយ បរិវារស័ព្ទ រលាយ អាចគន្លាស់បានជាពាក្យ រលាយជាប្រហោងដោយធ្លាយធ្លុះ គឺ រលុះជាប្រហោងដោយធ្លុះធ្លាយ ។

**រលុះ_រលួយ ឬ រលួយ_រលុះ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរលួយហូរខ្ទុះ ។ ដំបៅរលុះរលួយគឺ ដំបៅរលួយហូរខ្ទុះ ។ បរិវារស័ព្ទ រលុះ អាចគន្លាស់បានជាពាក្យ រលុះចេញខ្ទុយ គឺ រលួយចេញខ្ទុះ ឬ រលុះជ្រួយ គឺ រលួយជ្រុះ ។

**រលៀ_រលា.**- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ដែលស្រដៀងគ្នា, ប្រដុំប្រសងគ្នា, ស្ទើរតែនឹងដូច ឬ នឹងប៉ុនគ្នា ។ រូប

រាងឱ្យរលឿរលាគ្នា ។ បរិវារស័ព្ទ រលា អាចគន្លាស់បានជាពាក្យ រលាស្រដៀងគ្នើ គឺ រលឿស្រដៀងគ្នា ។

**រលេ_រលាំ.-** តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ដែលហៃលឬអណ្ដែតរេទន្ទាំ ។ រលេឃឹកងាករំពើន ។ សត្វពស់ហែលទឹករលេរលាំ ។ល។ បរិវារស័ព្ទ រលាំ អាចគន្លាស់បានជាពាក្យ រលាំ ដោយហែលទឹករេទន្ទេ គឺ រលេដោយហែលទឹករេទន្ទាំ ។

**រលោក_រលាំ.-** តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ដែលជ្រាយពពុលខ្លាំងដោយបៀមទឹក. ដែលរលោកជោកជាំនៅយូរ ។ បរិវារស័ព្ទ រលាំ អាចគន្លាស់បានជាពាក្យ រលាំជ្រាយពពុលខ្លាំងដោយជាំជោក គឺ រលោកជ្រាយពពុលខ្លាំងដោយជោកជាំ ។

**រវិច_រវាម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អើតរលិបរលប្ចូរវាមជិតខាង ។ កុំមករវិចរវាមជិតគេកំពុងធ្វើការ ។ បរិ-វារស័ព្ទ រវិច អាចគន្លាស់បានជាពាក្យ រវិច នាំឱ្យប៉ះទង្គាម គឺ រវាមនាំឱ្យប៉ះទង្គិច ពោលគឺ រវាមរំខានពេក ។ អ្នកខ្លះ

និយាយថា : រិករវាមវិញ ។

រិល_រវល់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជាប់ជំពាក់ដោយកិច្ចធុរៈអ្វីមួយ ។ កុំរិលរវល់រឿងគេ គឺ ខ្ជិលរវល់រឿងគេ។ បរិវារស័ព្ទ រវល់ អាចគន្លាស់បានជាពាក្យ រិលដោយខ្វល់ គឺ រវល់ដោយខ្ជិល ។

រិច_រើក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលកម្រើកឬវាររញ្ជាវ ។ ដង្កូវវាររិចរើក ។ បរិវារស័ព្ទ រិច អាចគន្លាស់បានជាពាក្យ រិចកខ្ញើក គឺ រើកកខ្ចិច ។ អ្នកខ្លះនិយាយពាក្យនេះថា : រិករើកវិញ ។

រីម_រវាម.- ល្វឹមល្វាម ទទើសទទាស់ ។ រឹមវាម ។ ក្មេងរត់លេងរីមរវាម ។ បរិវារស័ព្ទ រីម អាចគន្លាស់បានជាពាក្យ រីមទើសទាសរីមវាម គឺ រវាមទើសទាស់វាមរីម ។

រើ_រវាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយផ្តេសផ្តាស ព្រោះឃើញនេះឃើញនោះ ដោយក្លាំងស្លុងស្មារតីក្នុងវេលាដែលកំពុងមានជម្ងឺធ្ងន់ ។ បរិវារស័ព្ទ រវាយ អាចគន្លាស់

បានជាពាក្យ រវាយនិយាយផ្ដេសផ្ដាសរាយមេី គឺ រវេីនិយាយ ផ្ដេសផ្ដាសរាយមាយ ។

**រវៀស_រវៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រុតរះ, រូស-រាន់, ប្រញាប់ប្រញាល់, ម្នីម្នា ។ បរិវារស័ព្ទ រវៃ អាចគន្លាស់បានជាពាក្យ រវៃដោយរូតរះជេីងដៀស គឺ រវៀសដោយរូតរះជេីងដៃ ។

**រវេស_រវាំ.-** តាមវចនានុក្រម បានសេចក្ដីថា ÷ មេីលថែទាំរក្សា, គយគន់មេីលដោយមិនធ្វេស, ប្រុងប្រយ័ត្ន ។ បរិវារស័ព្ទ រវេស អាចគន្លាស់បានជាពាក្យ រវេសដោយប្រុងប្រយ័ត្នមិនធ្វាំ គឺ រវាំដោយប្រុងប្រយ័ត្នមិនធ្វេស ។

**រវះ_រវាម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សង្វាតខាងតែស៊ី ។ កុំរវះរវាមពេក ។ បរិវារស័ព្ទ រវះ អាចគន្លាស់បានជាពាក្យ រវះឱ្យតែពេញក្រពាម គឺ រវាមឱ្យតែពេញក្រពះ ។

**រសាប់_រសល់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបណ្ដាលឱ្យស្មៀបរមាស់ស្អុះស្អាប់, ក្រវល់ក្រវាយមិនសុខមិនសាប់ ។ ចេះតែរសាប់រសល់ដេកមិនលក់ ។ បរិវារស័ព្ទ

រសាប់ អាចគន្លាស់បានជាពាក្យ រសាប់ដោយក្រវាយក្រវល់ស្អុះស្អល់ គឺ រសល់ដោយក្រវាយក្រវល់ស្អុះស្អាប់ ។

រសាប់_រសាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រសាប់រសល់ខ្វល់រសាយគំនិត. រសាយព្យាយាម ។ រសាប់រសាយចិត្តគិតការអ្វីពុំលេច ។ បរិវាររស័ព្ទ រសាប់ អាចគន្លាស់បានជាពាក្យ រសាប់ ដោយចិត្តគំនិតរលារលែងខ្វាយ គឺ រសាយដោយចិត្តគំនិតរលាលែងខ្វាប់ ពោលគឺ អស់មានសេចក្ដីខ្វាប់ពោលគឺ អស់មានសេចក្ដីខ្វាប់ខ្វួនព្យាយាម ។

រសុក_រសុល.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលចូលឈូឆរបន្តគ្នាដូចគេចាប់ត្រសុក. ចាប់ត្បុលសុលចូល ។ សូមមើលពាក្យ ត្រសុកត្រសុល ។

រសេច_រសាច.- សូមមើលពាក្យ ប្រសេចប្រសាច ។

រហេ_រហាច.- សូមមើលពាក្យ ល្ហល្ហាច ។

រហេ_រហេវ.- សូមមើលពាក្យ ល្ហល្ហេវ ។

រហ័ស_រហាល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រហ័សដោយប្រជុំជើងច្រាស់ច្រាល់ ដោយចង់ប្រញាប់ហួសពេក ។

បរិវារស័ព្ទ របោល អាចគន្លាស់បានជាពាក្យ របោលដោយប្រជុំជើងប្រញាប់ប្រញាស គឺ របាសដោយប្រជុំជើងប្រញាប់ប្រញាល់ ។

របាស_របួន.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិនយឺត. មិនលំអៀក ។ ក្មេងរបាសរបួន ។ បរិវារស័ព្ទ របួន អាចគន្លាស់បានជាពាក្យ របួនដោយមានការប្រថាស់ គឺ របាសដោយមានការប្រថ្មន ។

របាស_របែង.- ដែលប្រញាប់ញាប់ដៃញាប់ជើង ។ បរិវារស័ព្ទ របែង អាចគន្លាស់បានជាពាក្យ របែងដោយសេចក្ដីខ្លាចកោតក្រាស់ គឺ របាសដោយសេចក្ដីខ្លាចកោតក្រែង ។

របាស_របែ.- ពាក្យនេះ មានអត្ថន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ របាសរបែង ។ បរិវារស័ព្ទ របែ អាចគន្លាស់បានជាពាក្យ របែដោយប្រញាប់ញាប់ជើងដាស់ គឺ របាសដោយប្រញាប់ញាប់ជើងដៃ ។

**រហាក់_រហៀង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រពិចស្រពិល, រហិចរហៀង, ដែលពួររហៀង ១ ពុំប្រាកដ ។ បរិវារស័ព្ទ រហាក់ អាចគន្លាស់បានជាពាក្យ រហាក់ដោយពួមិនជៀង គឺ រហៀងដោយពួមិនជាក់ ។

**រហិច_រហៀង.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលពួរហៀង ១ បន្តិចបន្តួចពុំប្រាកដ ។ បរិវារស័ព្ទ រហិច អាចគន្លាស់បានជាពាក្យ រហិចដោយពួពុំប្រាកដបន្ទៀង គឺ រហៀងដោយពួពុំប្រាដកបន្តិច ។

**រហិត_រហៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អស់កម្លាំងរសេះរសោះជើងដៃធេងធោង ។ បរិវារស័ព្ទ រហៃ អាចគន្លាស់បានជាពាក្យ *រហៃដោយអស់កម្លាំងរសេះរសោះជើងដិត* គឺ រហិតដោយអស់កម្លាំងរសេះរសោះជើងដៃ ។

**រហើរ_រហោយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលច្រាស់ច្រាល់ដោយកម្លាំងកាមគុណ, ដែលមានសេចក្ដីស្រឡាញ់ប្រតិព័ទ្ធ រើរុះរវើរវាយ ហើរពីអ្នកនេះទៅរកអ្នកនោះ ហើយពីអ្នកនោះទៅអ្នកដទៃទៀត ដោយពុំចេះបាននៅយូរ ។

(ច្រើននិយាយចំពោះតែស្រី ឬចិត្តរបស់ស្រី ) ។ ស្រីរហើរ រហាយ ។ បរិវារស័ព្ទ រហាយ អាចគន្លាស់បានជាពាក្យ រហាយច្រាស់ច្រាល់រកសហើរ គឺ រហើរច្រាស់ច្រាល់រក សហាយ ។

រហោង_រហាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែល រាយមាយអស់ទីពំនាក់ ពឹងផ្អែកជ្រកអាស្រ័យ ឬ ព្រោះខ្ជិល ធុញទ្រាន់ ។ ចិត្តរហោងរហាង ។ បរិវារស័ព្ទ រហោង អាច គន្លាស់បានជាពាក្យ រហោងដោយអស់ទីពំនាក់ ទៅជាចង់ខូច ចិត្តដើរតែឡាង គឺ រហាងដោយអស់ទីពំនាក់ ទៅជាចង់ខូច ចិត្តដើរតែលេង ។

រហោញ_រហាង.- ដែលឥតមានម្លប់នៅជិត. ដែលមានចំហាយកម្ដៅ ថ្ងៃច្បាស់បណ្ដាលឱ្យចាំង ឬ ឱ្យក្ដៅមិនស្រួល ។ ផ្ទះរហោញ-រហាង ។ បរិវារស័ព្ទ រហោញ អាចគន្លាស់បានជាពាក្យ រហោញដោយក្ដៅហាង គឺ រហាងដោយក្ដៅហោញ ។

រហោត_រហូត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលឥត សណ្ដាប់ធ្នាប់. ឥតកំណត់ទី ឬ កំណត់ពេលវេលា ។ ដើរចេញ-

ចូលរហេតរហូត ។ បរិវារស័ព្ទ រហេត អាចគន្លាស់បានជាពាក្យ រហេតដោយប្រហោងធ្លូត គឺ រហូតដោយប្រហោងធ្លេត ។

**រហេម_រហាម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ វេទនា. លំបាកតោកយ៉ាក ។ បរិវារស័ព្ទ រហេម អាចគន្លាស់បានជាពាក្យ រហេមដោយចាកសេចក្ដីសុខក្សាម គឺ រហាមដោយចាកសេចក្ដីសុខក្សេម ពោលគឺ ចាកសេចក្ដីសុខក្សេមក្សាន្ត ឬ សុខសម្រាន្ត. សុខស្រួល ។

**រហេវ_រហាវ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលឆេវឆាវ. ដែលខឹងដោយរហ័ស. ដែលឆាប់ខឹងឆួវឆេវទប់មិនទាន់ ។ ចិត្តរហេវរហាវ ។ បរិវារស័ព្ទ រហាវ អាចគន្លាស់បានជាពាក្យ រហាវដោយចិត្តខឹងឆាវឆេវ គឺ រហេវដោយចិត្តខឹងឆេវឆាវ ។

**រហែក_រហុយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាច. រយេះ. ដែលរហែកផង ធ្លុះផង ។ សំពត់ដាចរហែករហុយ ។ បរិវារស័ព្ទ រហុយ អាចគន្លាស់បានជាពាក្យ រហុយដាចស្នែក គឺរហែកដាចស្នុយ ឬ រហុយព្រោះផែក គឺ រហែកព្រោះផុយ ។

**រហែក_រហោក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាច, រយះ, ដែលរហែកធ្លុះធ្លាយពាស ។ ជញ្ជាំងស្លឹករហែករហោក ; សំពត់រយះរហែករហោកដោយទាក់នឹងបន្លា ។ បរិវារស័ព្ទ រហោក អាចគន្លាស់បានជាពាក្យ រហោកខ្ញែក គឺ រហែកខ្ញោក ។

**រឡេក_រឡោក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលហៀវ ឬស្រក់សស្រិកសស្រាកកខ្វក់គួរខ្ពើម ។ អ្នកខ្លះនិយាយពាក្យនេះថា : រឡេករឡោកវិញ ។ សូមមើលពាក្យ សស្រេកសស្រាក ។

**រឡូង_រឡាង.-** សូមមើលពាក្យ ឡូងឡាង ។

**រឡេម_រឡើម.-** សូមមើលពាក្យ ឡេមឡើម ។

**រឡែ_រឡ.-** សូមមើលពាក្យ ឡែឡ ។

**រឡែ_រឡប់.-** សូមមើលពាក្យ ឡែឡប់ ។

**រអាក_រអាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រុសរាយ ក្អាកក្អាយដោយសេចក្ដីរាក់ទាក់ស្មោះសរ ។ និយាយ

រអាក់រអាយ ។ បរិវារស័ព្ទ រអាយ អាចគន្លាស់បានជាពាក្យ រអាយ ដោយសម្ដីក្លាយក្លាក គឺ រអាកដោយសម្ដីក្លាកក្លាយ ។

**រអាក់_រអួល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលអាក់ៗអួលទើសៗទាក់ៗ ។ និយាយរអាក់រអួល, ធ្វើការរអាក់រអួល ។ បរិវារស័ព្ទ រអួល អាចគន្លាស់បានជាពាក្យ រអួលដោយមានដំណើរមិនស្រាក់ គឺ រអាក់ដោយមានដំណើរមិនស្រួល ។

**រអាក់_រអើ ឬ រអាក់_រអើក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រងាប់រងើ, រងាក់រងើក ។ បរិវារស័ព្ទ រអើក អាចគន្លាស់បានជាពាក្យ រអើកដោយរងាប់រងើបះបាក់ គឺ រអាក់រងាប់រងើបះបើក ។

**រអា_រអូម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលកាចសាហាវ លេចឮឈ្មោះ ឮអំណាច ឬឮសម្ដី សាយសុសគួរឱ្យខ្លាចរអាមរអូម ។ បរិវារស័ព្ទ រអូម អាចគន្លាស់បានជាពាក្យ រអូមកាចសាហាវល្បីឃោរឃៅដូចយក្សដុះចង្កា គឺ

រអាកាចសាហាវល្បីឃោរឃៅដូចយក្សដុះចង្កូម ពោលគឺ រអារ
រអូមកាចសាហាវល្បីជាអនាចារ ។

**រអី_រអ៊ូ**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា : ស្ងួរព្ទអ៊ីអ៊ូ ១តិច
ខ្លាំង ១ ។ លាន់មាត់រអ៊ីរអ៊ូ ។ បរិវារស័ព្ទ រអី អាចគន្លាស់
បានជាពាក្យ រអីលាន់ឮដោយមានគ្នាខ្សឹបខ្សាវមិនតិចពីពួរ គឺ
រអ៊ូលាន់ឮដោយមានគ្នាខ្សឹបខ្សាវមិនតិចពីពីរ ។

**រអេច_រអួច**.- សូមមើលពាក្យ ចេកចួច ។

**រអែ_រអូវ**.- សូមមើលពាក្យ រញ៉ែរញ៉ូវ ។

**រា_រង់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រាចុះរាឡើង, រង់
ចាំ, បង្អែបង្អង់ចាំ ។ រារង់ចាំដំណើរ ។ បរិវារស័ព្ទ រា អាច
គន្លាស់បានជាពាក្យ រាចាំវេលង់ គឺ រង់ចាំវេលា ។

**រា_រែក**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា : ដែលរាចុះរាឡើង
ស្មើភាគដូចគេរែក គឺ ស្ទាក់ស្ទើរ, អល់អែក, មិនដាច់ស្រេច
ទៅខាងណា ។ ចិត្តរារែក ; ដំណើររារែក ។ បរិវារស័ព្ទ
រែក អាចគន្លាស់បានជាពាក្យ រែកដោយចិត្តអល់អ៊ា គឺ រា

ដោយចិត្តអល់អែក ឬរែកដោយមានចិត្តកន្ទ្រា គឺ រាដោយមាន
ចិត្តកន្ទ្រែក ។

ភា_រាំង ឬ រាំង_ភា.- តាមវចនានុក្រម ពាក្យនេះ មានន័យចំពោះទាំង
ពីរ បានសេចក្ដីថា ÷ ខាខាំង. ហាមឃាត់. ការពារ ។ល។
បរិវារស័ព្ទ រាំង អាចគន្លាស់បានជាពាក្យ រាំងដោយខាឃា គឺ
រាដោយខាខាំង ឬរាដោយការពាំង គឺ រាំងដោយការពារ ។

រាង_រៅ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រូបរាងរូប
ស្បាត ។ មានរាងរៅសមរម្យ ។ បរិវារស័ព្ទ រៅ អាចគន្លាស់
បានជាពាក្យ រៅ សមតាមការអ្នកផងតម្រេង គឺ រាងសមតាម
ការអ្នកផងតម្រូវ ។

រាត់_រាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រាយមាយ
រាយរតាត់រតាយ. ខ្ចាត់ខ្ចាយពីសពាស ។ ឧទាហរណ៍ៈ.

១.- ដាក់អីវ៉ាន់ចោលរាត់រាយ ។

បរិវារស័ព្ទ រាត់ អាចគន្លាស់បានជាពាក្យ រាត់ខ្ចាត់ខ្ចាយ ដោយ
គ្មានបែបប៉ាយ គឺ រាយខ្ចាត់ខ្ចាយ ដោយគ្មានបែបបទ ពោល
គឺ ពុំមានសណ្ដាប់ធ្នាប់ ។

២.- ស្រីភត់ភាយ ។

បរិវារស័ព្ទ ភត់ អាចគន្លាស់បានជាពាក្យ ភត់នាយអាយដោយពុំមានទីពំនាក់ប្រាកាយ គឺ ភាយនាយអាយ ដោយពុំមានទីពំនាក់ពិតប្រាកដ ។

៣.- ធ្វើការភត់ភាយ ។

បរិវារស័ព្ទ ភត់ អាចគន្លាស់បានជាពាក្យ ភត់ដោយធ្វើការខ្ជីខ្ជាពុំហ្មត់ជាយ គឺ ភាយដោយធ្វើការខ្ជីខ្ជាពុំហ្មត់ចត់ ។

**រាស្ត្រ-ប្រជាស.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រជារាស្ត្រធំតូចក្នុងអាណាចក្រនិមួយៗ ។ បរិវារស័ព្ទ ប្រជាស អាចគន្លាស់បានជាពាក្យ ប្រជាសនុរា គឺ ប្រជានុរាស្ត្រ ។

**រីក-រាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រស់ស្រាយសប្បាយចិត្តស្រើបស្រួលចិត្ត ។ បរិវារស័ព្ទ រាយ អាចគន្លាស់បានជាពាក្យ រាយចិត្តសប្បាយដោយញញឹមពព្រីក គឺ រីកចិត្តសប្បាយដោយញញឹមពព្រាយ ។

**រឹង-រៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្គមរឹង, ភ្ញុំរៃរ៉ប៉ផ្អិតប៉ផ្អក់ ។ របេងរឹងរៃ, ស្គមរឹងរៃ ។ បរិវារស័ព្ទ រៃ អាច

គន្លាស់បានជាពាក្យ រៃស្គមស្គួតហួតពេកគ្រីង គឺ រីងស្គមស្គួតហួតពេកក្រៃ ។

**រឹង_ស្រស់.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រឹងគគ្រីសគគ្រួស រឹងមិនព្រមចុះរុះ, មិនព្រមទន់តាម ។ ក្មេងរឹងរូស ។ រូស អាចគន្លាស់បានជាពាក្យ រូសគគ្រីសគគ្រឹង គឺរឹងគគ្រីសគគ្រួស ។

**រឹត_រួត.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យតឹង, រឹតព័ទ្ធរួតរូប ។ ចងរឹតរួត ។ បរិវារស័ព្ទ រួត អាចគន្លាស់បានជាពាក្យ រួតចំណងព័ទ្ធច្រើនត្រឹត គឺរឹតចំណងព័ទ្ធច្រើនត្រួត ។

**រុក_រាន.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រុកទន្ទ្រានចូលរានយកទី ។ ដើររុករាន គឺ ទន្ទ្រានចូលឥតក្រែង ។ បរិវារស័ព្ទ រាន អាចគន្លាស់បានជាពាក្យ រានចូលដោយទន្ទ្រុក គឺ រុក-ចូលដោយទន្ទ្រាន ។

**រុក_រុល.**- តាមវចនានុក្រម ពាក្យនេះ មានន័យ ចំហទាំងពីរ គឺ រុកត្បុលជម្រុលចូល, រុករុលចូលទៅមុខ ។ បរិវារស័ព្ទ រុក អាចគន្លាស់បានជាពាក្យ រុកដោយត្បុលជម្រុលចូលទៅមុល គឺ រុលដោយត្បុលជម្រុលចួលទៅមុខ ។

រុញ_រា.- តាមវចនានុក្រម បានសេចក្ដីថា ÷ ស្ទាក់ស្ទើរ, មិនដាច់ស្រេច ទុញទើស ។ ពាក្យនេះ មានន័យ ប្រហាក់ប្រហែលគ្នានឹង ពាក្យរារែក ។ ចូលទៅក្នុងឱ្យផុតទៅកុំរុញរានៅធ្វើអ្វី ។ បរិវារស័ព្ទ រុញ អាចគន្លាស់បានជាពាក្យ រុញដោយចិត្តទើសទា គឺ រាដោយចិត្តទើសទុញ ។

រុត_រះ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រួតរូត, រវៀសរវៃ ; ម្ទីម្ទា ។ ដើររូតរះបន្តិចព្រោះមេឃជិតភ្លៀង ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ រះ អាចគន្លាស់បានជាពាក្យ រះដោយម្ទីម្ទាឆាប់ដល់ផ្ទុត គឺ រូតដោយម្ទីម្ទាឆាប់ដល់ផ្ទះ ពោល គឺ ពាក្យផ្ទះនេះ បានសេចក្ដីថា ÷ គោលបំណង, ត្រើយ ។ល។

រែះ_រេ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្ដីថា ÷ គិតគ្នេរគ្នាន់ រៃលកដោយវេគំនិត រិះរកឱ្យបានងាយឱ្យបានស្រួល ។ បរិវារស័ព្ទ រេ អាចគន្លាស់បានជាពាក្យ រេរកឱ្យបានស្រួលដោយគ្នាន់គ្និះ គឺ រិះរកឱ្យបានស្រួលដោយគ្នាន់គ្នេរ ។

រុច_រាល់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា : ស្រេចបាច់,

ចប់ចុងចប់ដើម, ចប់សព្វគ្រប់ ។ បរិវារស័ព្ទ រាល់ អាចគន្លាស់បានជាពាក្យ រាល់អស់សព្វគ្រប់លែងខ្វះ គឺ រួចអស់សព្វគ្រប់លែងខ្វល់ ពោលគឺ រួចផុតកង្វល់ ។

រុប_រួម.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្ដីថា ÷ ប្រមូលរួបរួមគ្នា, មូលជាដុំងមួយនឹងគ្នា ។ រួបរួមសេចក្ដី, រួបរួមកម្លាំងគ្នា ។ បរិវារស័ព្ទ រួប អាចគន្លាស់បានជាពាក្យ រួបដោយប្រមូលគំនិតគ្នាអោយជួម គឺ រួមដោយប្រមូលគំនិតគ្នាឱ្យជួប ពោលគឺ រួបរួមប្រមូលមតិគ្នាជាដុំងមួយ ។

រុស_រ៉ា.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្ដីថា ÷ រុស = ឆាប់របាល, រ៉ា = អេះ, ប្ដុំះ, ចុះ, ណា ។ រុស រ៉ា បានសេចក្ដីថា : ឆាប់ណា, របាសណាឬអេះ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ រ៉ា អាចគន្លាស់បានជាពាក្យ រ៉ាដោយឆាប់ណួស គឺ រួសដោយឆាប់ណា ។

រុស_រាន់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបន្ទាន់យ៉ាងប្រញាប់, ដែលប្រញាប់ឱ្យទាន់, ឆាប់ភ្លាម ។ ដំណើររួសរាន់ ។ បរិវារស័ព្ទ រាន់ អាចគន្លាស់បានជាពាក្យ រាន់យ៉ាងប្រញាប់ឱ្យទួស គឺ រួសយ៉ាងប្រញាប់ឱ្យទាន់ ។

រុស-រាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរគឺ រស មាត់ដោយមានការរាក់ទាក់ ។ និយាយរួសរាយ ។ បរិវារស័ព្ទ រាយ អាចគន្លាស់បានជាពាក្យ រាយ មាត់យ៉ាងពព្រួស គឺ រួស មាត់យ៉ាងពព្រាយ ។

រៀ-រី.- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ អង្គាសប្រាក់ កាសយកតាមស្ម័គ្រចិត្តរបស់អ្នកចូល ។ រៀរ៉ៃ ជាពាក្យ សៀម ដែលខ្មែរយើងយកមកប្រើ ដោយឃើញនៅសល់ប្រើច្រើនជាង គេនៅក្នុងខេត្តបាត់ដំបង ។ បរិវារស័ព្ទ រៃ អាចគន្លាស់បានជា ពាក្យ រៃអង្គាស់ប្រាក់កាសដើម្បីចតុបច្ចៀ គឺ រៀអង្គាសប្រាក់ កាសដើម្បីចតុបច្ច័យ ។

រៀប-រយ.-ដែលមានរបៀបល្អ. មានសណ្ដាប់ធ្នាប់ ។ កូនសិស្ស ឈររៀបរយ ។ បរិវារស័ព្ទ រយ អាចគន្លាស់បានជាពាក្យ រយដោយចុះរបៀបដូចមុខដូចក្រៀប គឺ រៀបដោយចុះរបៀប ដូចមុខដូចក្រោយ ។

រេ-រក.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរបានសេចក្ដី ថា ÷ រកដោយរេគំនិត. ដោយលៃលក ។ បរិវារស័ព្ទ រក អាច

គន្លាស់បានជាពាក្យ រកដោយមានគំនិតលៃលេ គឺ រេដោយមានគំនិតលៃលក ។

**រេ_រង់.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្តីថា ÷ រេចុះឡើងដោយរង់ចាំ ។ បរិវារស័ព្ទ រង់ អាចគន្លាស់បានជាពាក្យ រង់ចាំមើលទ្រាយទ្រេ គឺ រេចាំមើលទ្រាយទ្រង់ ពោលគឺ ចាំមើលទ្រង់ទ្រាយ. ចាំមើលដំណើរដើមទងនៃស្ថានការណ៍ ។

**រេ_រា.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្តីថា ÷ រាចុះរាឡើង បង្អែបង្អង់ចាំពេលវេលេ គឺ រេបង្អែបង្អង់ចាំពេលវេលា ។

**រោយ_រៀវ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលហោចនៅសល់តិចតួចស្តើងស្តួចណាស់ រកកល់នឹងអស់ឬគ្មានទៅហើយ ។ ដែលកាន់តែតិចចុះឬតួចចុះដោយលំដាប់ ។ របស់រោយរៀវ ។ បរិវារស័ព្ទ រៀវ អាចគន្លាស់បានជាពាក្យ រៀវហោចតួចស្តួចស្តួយ គឺ រោយហោចតួចស្តួចស្មៀវ ។

**រោល_រាល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រសាប់-រសល់, ក្រវល់ក្រវាយ, ក្រហល់ក្រហាយ ។ បរិវារស័ព្ទ រាល អាចគន្លាស់បានជាពាក្យ រាលពាសរោល គឺ រោលពាសរាល ។

**រំកាច់_រំកោច.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ តូចតាច, ល្អិតល្អោច, កម្មេចកម្ទី, ថោកថយ, បន្តិចបន្តួច, បន្ទាប់បន្ទុំ, រាយរង ។ល។ មនុស្សរំកាច់រំកោច, រឿង ឬ ការរំកាច់ រំកោច ។ល។ បរិវារស័ព្ទ រំកោច អាចគន្លាស់បានជាពាក្យ រំកោចរាយរងល្អិចល្អាច់ គឺ រំកាច់រាយរងល្អិចល្អោច ។

**រំជី_រំជា.-** តាមវចនានុក្រម ពាក្យរំជានេះ មានន័យថា ÷ និយាយជិ-ណាលរំជែ បំភ្លើស ជន្ល បង្កាច់ ផ្សែផ្សំហេតុ, ទំនងឱ្យបាន-កើតជារឿងមួយសើចលេងសប្បាយ អំពីរឿងជនណាមួយនាក់ ហើយនៅចំពោះមុខសាមីខ្លួនទៀតផង ។ និយាយរំជីរំជា-លេងខ្ចីខ្ចាតាមតែរួចពីមាត់ ។ រំជីរំជាឱ្យគ្នា ។ បរិវារស័ព្ទ រំជី អាចគន្លាស់បានជាពាក្យ រំជីសើចលេងតាមតែរួចពីមាត់ដោយ ខ្ចីខ្ចា គឺ រំជាសើចលេងតាមតែរួចពីមាត់ដោយខ្ចាខ្ចី ។

**រំណើប_រំជួល.-** តាមវចនានុក្រម បានសេចក្ដីថា ÷ កក្រើកជ្រួលច្របល់ខ្លាំងសព្វទីកន្លែង ។ ប្រទេសរំជើបរំជួល ។ល។ បរិវារស័ព្ទ រំជួល អាចគន្លាស់បានជាពាក្យ រំជួលជ្រួលកក្រើកខ្លាំងដោយមានការមិនស្រើប គឺ រំជើបជ្រួលកក្រើកខ្លាំងដោយមានការមិនស្រួល ។

**រំជិ_រំជែង.-** កក្រើករំពើកបោកបាចខ្លាំង ឬ យោកយោលខ្ទាល ១ បោកបាចខ្លាំង (ប្រើចំពោះតែរលកធំ ១ ហើយក្នុងពាក្យកាព្យផងទៀត) ។ រលកធំ១រំជិរំជែងបោកបែកផ្កាគ្រែងគគ្រែងគគ្រាំ ។ បរិវារស័ព្ទ រំជែង អាចគន្លាស់បានជាពាក្យ រំជែងគគ្រែងគគ្រាំបោកបែកផ្កាទ្រំ គឺ រំជិគគ្រែងគគ្រាំបោកបែកផ្កាគ្រែង ។

**រំដេក_រំដាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលយោកខ្លាំង, ដែលរំដាកក្រែពេក ។ យាយចាស់សាច់យាររំដេករំដាក ។ បរិវារស័ព្ទ រំដេក អាចគន្លាស់បានជាពាក្យ រំដេកដោយរំយារកក្រែប៉ាក គឺ រំដាកដោយរំយារកក្រែពេក ។

**រំពឹង_រំពៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបាន

សេចក្ដីថា ÷ គិតជញ្ជឹង, ទ្រឹងគិត ។ រំពឹងរំពៃមើលផ្លូវក្រែង មានលាភមុននឹងចេញដំណើរ ។ បរិវារស័ព្ទ រំពឹង អាចគន្លាស់បានជាពាក្យ រំពឹងគិតជញ្ជៃ គឺ រំពៃគិតជញ្ជឹង ។

**រយីក_រយាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលចាស់រយាកជ្រោកជ្រាក, រំដាកចាស់រយាក សូមមើលពាក្យ រយីករយាក ។

**រអែ_រអុក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រអុកដែពព្រៃ រអុកត្នូញត្អែរជ្រាំដែល ។ បរិវារស័ព្ទ រអែ អាចគន្លាស់បានជាពាក្យ រអែដែពព្រៃត្នូញត្អុក គឺ រអុកដែពព្រៃត្នូញត្អែរ ។

**រអែ_រអួយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើពុតចំទួយខ្លួនពេក, រអួយពេក ។ ក្មេងរអែរអួយ ។ បរិវារស័ព្ទ រអែ អាចគន្លាស់បានជាពាក្យ រអែធ្វើពុតចំទួយខ្លួនដោយត្នូញត្អួយ គឺ រអួយធ្វើពុតចំទួយខ្លួនដោយត្នូញត្អែរ ។

**រាំ_រែក.-** ពាក្យនេះ ខ្មែរយើងច្រើនស្រដីចំពោះតែរបាំតាមវាលស្រែ ឬនៅកណ្ដាលទីធ្លា ពុំមែនសំដៅទៅលើក្រុមល្ខោនសិល្បៈ ឬក៏

ល្ងាចបាសាក់ យើងសព្វថ្ងៃក៏ទេដែរ គឺ ចំពោះតែរបាំមួយប្រភេទដូចជារាំវង់, រាំថូន, រាំយីកេ ។ល។ អ្នកដែលពោលសំដីរាំរែកនេះទៀត ច្រើនមាតាបិតា ស្តីប្រដៅទៅកូនចៅជាពាក្យ ÷ ឯងមិនគិតរៀនសូត្រទេ គិតតែដើររាំរែកឬភរិយាប្រច័ណ្ឌប្តីបានពោលថា ÷ មិនគិតទៅវត្តអាំឱ្យហើយទេ គិតរកតែផ្លូវទៅរាំរែក ។ល។ បរិវារស័ព្ទ រែកនេះមានអត្ថន័យឆ្ងាយណាស់ បើយើងយកមកគន្លាស់វិញ យើងបានវត្តមួយថា ÷ រែកក្នុងរោងក្បែរមាត់ព្រាំ គឺ រាំក្នុងរោងក្បែរមាត់ព្រែក ពោលគឺ ÷ កាលណារាំរួចហើយ គេច្រើនសង្កេតឃើញអ្នកទាំងនោះបណ្តើរគ្នាមួយគូ ៗ ទៅបន្តអារម្មណ៍ ដូចជារកចំណីអាហារស្រស់ស្រួបនៅក្នុងរោងឬផ្ទះផែ ដើម្បីចំអែតឱ្យមានកម្លាំងកាយមុននឹងត្រលប់ទៅផ្ទះវិញ ។

* *
*

# ល

**លន្លង់_លន្លោច.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឆ្ងាយសន្ធឹមគួរនឹកសង្វេគស្រងោចចិត្ត ឬ គួរស្រងេះស្រងោច ។ លន្លង់គួរឱ្យលន្លោចចិត្ត ។ បរិវារស័ព្ទ លន្លោច អាចគន្លាស់បានជាពាក្យ លន្លោចគួរនឹកសង្វេគយ៉ាងស្រងេះស្រងង់ ្ គឺ លន្លង់គួរនឹកសង្វេគយ៉ាងស្រងេះស្រងោច ។ អ្នកខ្លះប្រើពាក្យនេះថា : អន្លង់អន្លោចវិញ ។

**លម្អិត_លម្អន់.**- តាមវចនានុក្រម ពាក្យនេះ មានន័យ ចំហាទាំងពីរបានសេចក្តីថា : ធ្វើឱ្យល្អិតល្អន់, ធ្វើឱ្យល្អិតប៉ន់, ឱ្យល្អិតខ្ទេចខ្ទី ។ បរិវារស័ព្ទ លម្អន់ អាចគន្លាស់បានជាពាក្យ លម្អន់ឱ្យខ្ទេចខ្ទីឱ្យល្អន់ល្អិត គឺ លម្អិតឱ្យខ្ទេចខ្ទីឱ្យល្អិតល្អន់ ។

**លលោក់_លលាប.-** តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ល្អរុងរឿងដោយអំណាច ; ដែលគឃ្លើនអង់អាចឥតក្រែង ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ សព្វថ្ងៃនេះខ្មែរយើងយកពាក្យនេះ មកប្រើក្លាយខុសសម្រាប់និយាយជំនួសពាក្យ ពព្រាក់ពព្រើត ឬពាក្យលលីមលលាម ។ បរិវារស័ព្ទ លលោក់ អាចគន្លាស់-បានជាពាក្យ លលោក់ដោយគឃ្លើនអង់អាចពុំអន់អ៊ា គឺ លលាមដោយគឃ្លើនអង់អាចពុំអន់អាក់ ។ អ្នកខ្លះប្រើពាក្យ នេះ ក្លាយជារលាមក៏មាន ។ ល ។

**លលីម_លលាម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លលាមក្រែពេក, ពភ្លឹមពភ្លាម ។ បរិវារស័ព្ទ លលីម អាច គន្លាស់បានជាពាក្យ លលីមដោយឫកពភ្លឹមពភ្លាម គឺ លលាម ដោយឫកពភ្លាមពភ្លឹម ពោលគឺ លលាមពព្រាត់ពព្រើតដូចស្វា ។

**លន់_លក់ ឬ លក់_លន់.-** តាមវចនានុក្រម ពាក្យនេះ មានន័យ ថា ÷ លក់ជ្រុលដំណោក, លក់ហួសប្រមាណ, លក់ជ្រៅមិន-ងាយភ្ញាក់ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ លន់ អាចគន្លាស់បានជាពាក្យ លន់ដោយជ្រុលដំណោកស៊ក់ គឺ លក់ ដោយជ្រុលដំណោកស៊ុន ។

លា_លាកឬលាក_លា.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ ពាក្យខ្មែរលានិងពាក្យ សៀមលាក (ឡាក) ពាក្យលាគឺ ÷ បែកគ្នា, លាដើម្បីចេញចាកគ្នា ។ លាកគឺ ÷ ទាញអូស, ងាកបែរថយ, ឃ្លាតចាកទី ។ ពាក្យកាព្យខាងក្រោមនេះ ខ្ញុំដកស្រង់ពីវចនានុក្រម ទំព័រ ១០៩៨÷

បើបានជាលាលាក ចូរកុំងាកបែរមើលក្រោយ ទោះរស់ស្លាប់ក៏ដោយ ត្រូវកុំឱ្យលំបាកទៀត ។

ពាក្យកាព្យដ៏ខ្លីនេះជាអត្ថាធិប្បាយនៃអត្ថន័យ នៃពាក្យលាលាក ។ ដូច្នេះ បរិវារស័ព្ទ លាក អាចគន្លាស់បានជាពាក្យលាកដោយបែកគ្នាដើម្បីចេញជា គឺ លាដោយបែកគ្នាដើម្បីចេញចាក ។

លាក់_លៀប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លាក់ក្បិតក្បៀត ទុកសំចៃ ឬលាក់ទុកនៅកៀនកោះ ។ បរិវារស័ព្ទ លៀប អាចគន្លាស់បានជាពាក្យ លៀបទុកក្នុងដង្កាក់ គឺ លាក់ទុកក្នុងដង្កៀប ពោលគឺ លាក់ទុកសំចៃដោយក្បិតក្បៀត ហាក់ដូចជាជាប់នៅក្នុងដង្កៀប ។

លាក់_លៀម.-តាមវចនានុក្រម ពាក្យនេះ មានន័យប្រហាក់ប្រហែលគ្នានឹងពាក្យ លាក់លៀប ។ បរិវារស័ព្ទ លៀម អាចគន្លាស់បានជាពាក្យ លៀមទុកនៅស្ងៀក់ គឺ លាក់ទុកនៅស្ងៀម ។

លាយ_លក្ខណ៍.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្នាមលក្ខណ៍នៅបាតដៃបាតជើង ។ បរិវារស័ព្ទ លក្ខណ៍ អាចគន្លាស់បានជាពាក្យ លក្ខណ៍ដែលជាក់លាយ គឺលាយដែលជាក់លាក់ ពោលគឺ លាយលក្ខណ៍ដ៏ពិតប្រាកដច្បាស់ ។

លាយ_ឡំ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលលាយបន្លំគ្នា ឬលាយច្រឡូកច្រឡំគ្នា ។ ដាក់ខោអាវលាយឡំគ្នា. អង្គុយលាយឡំគ្នា ។ បរិវារស័ព្ទ ឡំ អាចគន្លាស់បានជាពាក្យឡំគ្នាដោយច្រឡូកច្រឡាយ គឺ លាយគ្នាដោយច្រឡូកច្រឡំ ។

លិច_លង់.- តាមវចនានុក្រម ពាក្យនេះ មានន័យ ចំហទាំងពីរ គឺ វិនាសអន្តរាយអស់ ដូចលិចលង់ក្នុងទឹក. គឺ វិនាសអន្តរាយផុងលង់រើខ្លួនពុំរួច ។ សមាសពាក្យនេះ យើងយកពាក្យណាមកធ្វើជាបរិវារស័ព្ទបានទាំងអស់ ហើយមានន័យប្រហាក់ប្រហែលគ្នាផងទៀត ។

១.បរិវារស័ព្ទ លិច អាចគន្លាស់បានជាពាក្យ លិចដោយវិនាសអន្តរាយខ្ទង់ គឺ លង់ដោយវិនាសអន្តរាយខ្ទេច ។

២.បរិវារស័ព្ទ លង់ អាចគន្លាស់បានជាពាក្យ លង់ដោយវិនាសអន្តរាយអស់គ្មានគិច គឺ លិចដោយវិនាសអន្តរាយអស់គ្មានគង់ ។

ល្អក_លាន់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អកបិច ឬល្អកចីបបន្ថិចបន្តួច, ល្អកនាយល្អកអាយ, ល្អកកេះក្បៀវ ។ ម្ហូបនេះនៅថ្លោងឥតទាន់មានល្អកលាន់ទេ ។ ល ។ បរិវារស័ព្ទ លាន់ អាចគន្លាស់បានជាពាក្យ លាក់ចីបបន្តិចដើម្បីសមរូក គឺ ល្អកចីបបន្តិចដើម្បីសម្រន់ ។

ល្អត_លាស់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អតបែកមែកសន្លឹក ។ កូនឈើដុះល្អតលាស់, តម្រេះវិជ្ជាល្អតលាស់ ។ល ។ បរិវារស័ព្ទ លាស់ អាចគន្លាស់បានជាពាក្យ លាស់ចម្រើនគ្រប់ផ្លូវទាំងអ៊ូត គឺ ល្អតចម្រើនគ្រប់ផ្លូវទាំងអស់ ពោលគឺល្អតលាស់គ្រប់វិស័យទាំងអស់ ។

ល្អង_លោម.-តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរ គឺ÷

ពោលពាក្យ ទន់ផ្អែមល្ហែមសម្រួលចិត្តអ្នកដទៃឱ្យធូរ ឱ្យស្រួល ។ល។ ល្បងលួងឱ្យស្រួលចិត្ត ។ បរិវារស័ព្ទ លួង អាចគន្លាស់បានជាពាក្យ លួងឱ្យស្រួលចិត្តសម្ដីល្បួម គឺ លោមឱ្យស្រួល-ចិត្តដោយសម្ដីល្បួង ។

**លើស-លន់**.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ច្រើនហួសពេក ។ អំណោយទាំងនេះ ច្រើនលើសលន់ឥតឧបមា ។ បរិវារស័ព្ទ លន់ អាចគន្លាស់បានជាពាក្យ លន់ច្រើនហួសពេកដល់ទៅជាសឹស គឺ លើសច្រើនហួសពេកដល់ទៅជាស៊ុន ។

**ល្បៀង-លោម**.-តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ÷ រៀបពិធីបូជាលោមអង្វរអារក្ស ។ បរិវារស័ព្ទ ល្បៀង អាចគន្លាស់បានជាពាក្យ ល្បៀងដោយមានភ្លេងនិងជំរោម គឺ លោមដោយមានភ្លេងនិងចម្រៀង ។

តាមលោក អៀវកើស ក្នុងសៀវភៅភាសាខ្មែរ ភាគទី២ ទំព័រ ២៧៣ ពាក្យល្បៀងមួយម៉ាត់នេះមានសេចក្ដី អត្ថាធិប្បាយមួយបែបទៀត ដោយខ្ញុំដកស្រង់ទាំងស្រុង ជូនដូចខាងក្រោមនេះ ។

ក្នុងវចនានុក្រមខ្មែរ លោកថាពាក្យ លៀងជាពាក្យសៀម តាមយោបល់ឪពុកខ្ញុំ ពាក្យនេះជាពាក្យខ្មែរ សៀមខ្ចីយកទៅប្រើ ។ ហេតុផលដែលគាត់អាងមានដូចតទៅនេះ ។ ពាក្យលៀងជាពាក្យ គន្លាស់កាត់ ÷ លៀង + ច្រៀង > លៀង (+ច្រៀង) ។ ដើមដំបូងប្រើសម្រាប់អារក្ស ÷ លៀងអារក្ស លៀងអារក្ស គឺ បញ្ចោន់អារក្សឱ្យលេងសប្បាយ មានភ្លេង មានចម្រៀងឱ្យស្ដាប់ ដើម្បីកុំឱ្យវាធ្វើអ្នកជម្ងឺឱ្យឈឺតទៅទៀត ។ រូបអារក្សកាលខ្មោចចូលមកសណ្ឋិត ហើយក៏ផឹកស្រាហើយរាំ ក្រោយតមកការប្រជុំគ្នាស៊ីបាយផឹកស្រា . លេងភ្លេង. ច្រៀង តាមធម្មតា គ្មានបញ្ចោន់អារក្សក៏ហៅថាលៀងដែរ ។ តមកទៀតការឱ្យអាហារ មិត្រសំឡាញ់ច្រើនគ្នាបរិភោគ ទោះមាន ផឹកស្រា. លេងភ្លេង. ច្រៀងរាំ ក៏ដោយ ឬ គ្មានក៏ដោយគង់តែ ហៅថាលៀង ។ សៀមខ្ចីពាក្យខ្មែរនេះ ទៅប្រើសម្រាប់សំដែងសេចក្ដីថា ឱ្យអាហារដល់មិត្រសំឡាញ់ បរិភោគដូចខាង លើនេះផង ថាឱ្យអាហារបរិភោគជានិច្ច គឺ ចិញ្ចឹមផង ។ មិនតែប៉ុណ្ណោះ ស៊ីសេចក្ដីថា ថែទាំរក្សាទៀតផងក៏បាន ។

ល្វែង_លេះ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លែងគ្នាជ្រះស្រឡះ ឬលែងគ្នាដាច់ស្រឡះមិនត្រូវការតទៅទៀត ។ លែងលះប្ដីប្រពន្ធ។ បរិវារស័ព្ទ លះ អាចគន្លាស់បានជាពាក្យ លះគ្នាដាច់ជ្រះស្រឡែង គឺលែងគ្នាដាច់ជ្រះស្រឡះ ឬ លះគ្នាដោយដាច់សង្វែង គឺ លែងគ្នាដោយដាច់សង្វាស ។

លៃ_លក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ត្រៀវគ្នាន់ឱ្យល្មមដល់ការ. ស្ទង់មើលតាមប្រមាណ ។ កុំអាលធ្វើចាំគេលៃលកមើលសិន ។ ល។ បរិវារស័ព្ទ លក អាចគន្លាស់បានជាពាក្យ លក ដោយត្រៀវគ្នាន់រៃ គឺលៃដោយត្រៀវគ្នាន់រក ។

លោភ_លន់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លោភហួស. ចង់បានច្រើន ឬ ចង់បានហួសពេក ។ល។ បរិវារ-ស័ព្ទ លន់ អាចគន្លាស់បានជាពាក្យ លន់ហួសពេកទាល់តែស្ពោភ គឺ លោភហួសពេកទាល់តែស្អុន ។

លំបាក_លំបិន.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពិបាកពិបិន. លំបាកគ្រដេបគ្រដួស ។ ធ្វើបានដោយលំបាកលំបិន ។

បរិវារស័ព្ទ លំបិន អាចគន្លាស់បានជាពាក្យ លំបិនពីដើមទីទៅសាក គឺ លំបាកពីដើមទីទៅសិន ។

**លំបេក-លំបាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ លំបាកក្រៃពេក, លំបាកត្រដេបត្រដាប ។ សូមមើលពាក្យ ពិបេកពិបាក ។

**លំអិត-លំអន់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យ-ល្អិតល្អន់ខ្ចេចខ្ចី ។ សូមមើលពាក្យ ល្អិតល្អន់ ។

**លំអិត-លំអួន.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្ដីថា ÷ ដែលរាប់រកដោយទន់ភ្លន់, ថ្នាក់ថ្នម ។ ប្រើសម្ដីល្អិតល្អរកគ្នា ។ បងប្អូនគេល្អៗណាស់ សុទ្ធសឹងលំអិត-លំអួនរកគ្នាគេជានិច្ច ។ បរិវារស័ព្ទ លំអិត អាចគន្លាស់បានជាពាក្យ លំអួនរាប់រកគ្នាដោយថ្នាក់ថ្នមជិតស្និទ្ធ គឺ លំអួនរាប់រកគ្នាដោយថ្នាក់ថ្នមជិតស្និទ្ធ ។

**លំអុត-លំអួន.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ ÷ លំទោន, ឱនទន់ទាប ឬ បង្អោនបន្ទន់ចិត្តទៅរកផ្លូវល្អ ។

(ច្រើននិយាយចំពោះតែកាយវិចា) ។ បរិវារស័ព្ទ លំអូន អាចគន្លាស់បានជាពាក្យ លំអូនកាយវិចាចិត្តឱនទន់ទាបដោយ-លំអុត គឺ លំអុតកាយវិចាចិត្តឱនទន់ទាបដោយលំទោន ។

**លំអិត_លំឱន.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ ធ្វើឱ្យឱន, បង្អោនបន្ទន់ចុះ ។ (ច្រើនប្រើចំពោះតែកាយវិចា-ចិត្ត) ។ បរិវារស័ព្ទ លំឱន អាចគន្លាស់បានជាពាក្យ លំឱន-កាយវិចាចិត្តដោយបង្អុត គឺ លំអុតកាយវិចាចិត្តដោយបង្អោន ។

**លះ_លាក.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លះឃ្លាតលែងងាកបែរទៅរក ។ លះលាកកិច្ចការលែងនឹកនា ។ល។ បរិវារស័ព្ទ លាក អាចគន្លាស់បានជាពាក្យ លាកឃ្លាតបែរចេញលែងងះ គឺ លះឃ្លាតបែរ ចេញលែងងាក ។

**ល្ហាយ_ល្ហុង.-** ដែលមានលំនាំដំណើរ គាយទន់ភ្លន់ព្រៀងព្រៀងគគាត (ច្រើនប្រើចំពោះលំនាំដំណើរនៃដំរី ) ។ ដំរីដើរល្ហាយល្ហុង ។ល។ បរិវារស័ព្ទ ល្ហុង អាចគន្លាស់បានជាពាក្យ ល្ហុងដោយដំណើរគាយមានលើកក្បាលជង្ហាយ គឺ ល្ហាយដោយមានដំណើរគាយមានលើកក្បាលជង្ហង់ ។

ល្ងាក់_ល្ងើ.-តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបាន សេចក្ដីថា ÷ ដែលរងាក់រងើរពុំដឹងអ្វីទាំងអស់ ។ ដើរល្ងាក់ល្ងើ ។ល។ បរិវារស័ព្ទ ល្ងាក់ អាចគន្លាស់បានជាពាក្យ ល្ងាក់ ដោយមិនដឹងការជើ គឺ ល្ងើដោយមិនដឹងការជាក់ ពោលគឺ ដោយពត្លីពត្លើ ។

ល្ងាក់_ល្ងើក.- ដែលង៉ាក់ងើក ។ សូមមើលពាក្យ ង៉ាក់ងើក ។

ល្ងាប់_ល្ងើ.- សូមមើលពាក្យ រង៉ាប់រងើ ។

ល្ងឹត_ល្ងល់.- សូមមើលពាក្យ ងងឹតងងល់ ។

ល្ងី_ល្ងើ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរង៉េរងើ. ដែលទញ់ទាល់ វិលវល់ស្មារតី មមឹងមមាំង ។ បរិវារស័ព្ទ ល្ងី អាចគន្លាស់បានជាពាក្យ ល្ងីមមឹងមមាំង ពុំមានពីរ គឺ ល្ងើមមឹង មមាំងពុំមានពីរ ពោលគឺ ល្ងីល្ងើខ្លាំង ។ បើតាមទម្លាប់ខ្មែរ យើងនិយាយវិញយើងច្រើនពោលថា ÷ ល្ងីមិនដឹងទិសប្រថពី គឺ ល្ងើមិនដឹងទិសប្រថពី ពោលគឺ ល្ងីល្ងើមិនដឹងទិសតំបន់អ្វី ទាំងអស់ ។

ល្វេ_ល្វង់.-ល្ងង់ល្ងេល្ងើ ពុំយល់ការខុសត្រូវ ។ បរិវារស័ព្ទ ល្វេ អាចគន្លាស់បានជាពាក្យ ល្វេ ព្រោះគ្មានដំរេះអ្វីនឹងគង់ គឺ ល្ងង់ព្រោះគ្មានដំរេះអ្វីនឹងគេ ។

ល្វេ_ល្វើ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា រងេររងើ, ដែលងេងើ, ដែលទញ់ទាល់, វិលវល់ស្មារតីមមីងមមាំង ។ និយាយល្វេល្វើ ។ល។ បរិវារស័ព្ទ ល្វេ អាចគន្លាស់បានជាពាក្យ ល្វេមមីងមមាំងមិនដូចអស់ទាំងគេ គឺ ល្វើមមីងមមាំងមិនដូចអស់ទាំងគេ ពោលគឺ មិនដូចគេឯងផងទាំងពួង ។ អ្នកខ្លះនិយាយថា: រងើរងើ ឬ ល្វីល្វើក៏មានតាមទម្លាប់ប្រើ ។

ល្បិច_ល្បង.-តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរមានសេចក្តីថា ÷ ស្នៀតសម្រាប់ល្បងគេច, ល្បិចសម្រាប់ល្បងមើលឱ្យដឹងមុន ។ បរិវារស័ព្ទ ល្បិច អាចគន្លាស់បានជាពាក្យល្បិច មើលឱ្យដឹងមុនដើម្បីកង គឺ ល្បងមើលឱ្យដឹងមុនដើម្បីគេច ។

ល្បិច_ល្បើក.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរមានសេចក្តីថា÷ ល្បើកដែលគេប្រឌិតដោយប្រើល្បិច ។ បរិ-

វារស័ព្ទ ល្បិច អាចគន្លាស់បានជាពាក្យ ល្បិចដែលគេប្រឌិត ដោយល្បើក គឺ ល្បើកដែលគេប្រឌិតលើកដោយល្បិច ។

**ល្បិច_ល្បឿន.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ មានន័យថា ÷ ល្បឿនដោយប្រើល្បិច ។ បរិវារស័ព្ទ ល្បិច អាចគន្លាស់បានជាពាក្យ ល្បិច ដោយប្រើល្បឿន គឺ ល្បឿនដោយប្រើល្បិច ។

**ល្បិច_ល្បែង.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បានសេចក្ដីថា ÷ ល្បែងដែលគេលេងដោយប្រើល្បិច ។ បរិ-វារស័ព្ទ ល្បិច អាចគន្លាស់បានជាពាក្យ ល្បិច ដែលគេលេងដោយប្រើល្បែង គឺ ល្បែងដែលគេលេងដោយប្រើល្បិច ។

**ល្បី_ល្បា.-** លេចឮកេរ្តិ៍ឈ្មោះល្អឬអាក្រក់ ។ បរិវារស័ព្ទ ល្បា អាចគន្លាស់បានជាពាក្យ ល្បាដោយឮឈ្មោះគេនិយាយថា គឺ ល្បីដោយឮឈ្មោះគេនិយាយថា ។ ពាក្យល្បីល្បានេះ មានន័យមួយបែបទៀតគឺ ÷ ល្បីឈ្មោះក្រៃពេក ពោលគឺ បរិវារស័ព្ទ ល្បា អាចបកស្រាយបានជាវគ្គមួយថា ÷ ល្បាឈ្មោះណាស់ណា គឺ ល្បីឈ្មោះណាស់ណា ពោលគឺ ល្បីឈ្មោះអស្ចារ្យ ។

(សម្រាប់និយាយចំពោះ តែការល្បីឈ្មោះក្នុងវង្សត្រកូលឬបក្សពួកគ្នាឯង) ។

**ល្បី_ល្បាញ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លេចឮទៅទូវកេរ្តិ៍ឈ្មោះល្អឬអាក្រក់, ល្បីឮសុសសាយ ។ បរិវារស័ព្ទ ល្បាញ អាចគន្លាស់បានជាពាក្យ ល្បាញឮសាយសុសដោយគ្មានសី គឺ ល្បីឮសាយសុសដោយគ្មានសាញ ពោលគឺ ល្បីល្បាញខ្ទរខ្ទារពាសពេញ ។

**ល្បើក_ល្បាញ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្បើកដោយគាស់កកាយឱ្យរីកចេញសាញ ។ ខ្ញុំរករឿងហេតុឱ្យទាល់តែឃើញល្បើកល្បាញ ។ បរិវារស័ព្ទ ល្បាញ អាចគន្លាស់បានជាពាក្យ ល្បាញ ដោយគាស់កកាយឱ្យចេញរីកស្ញើក គឺ ល្បើកដោយគាស់កកាយឱ្យចេញរីកស្វាញ ពោលគឺ ឱ្យល្បើកចេញរឿងហេតុផលច្បាស់ក្រឡាញ ។

**ល្បើក_ល្បាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្បើកដោយគាស់កកាយសើរើ ។ បរិវារស័ព្ទ ល្បាយ អាចគន្លាស់បានជាពាក្យ ល្បាយដោយសើរើគាស់កកើក គឺ ល្បើកដោយ

សើរើគាស់កកាយ ពោលគឺ ល្បើកចេញខ្ទាត់ខ្ទាយអស់ ។

ល្បើក_ល្បាយ.-តាមវចនានុក្រម បានសេចក្ដីថា ÷ ពាក្យរាយរៀលដែលលើកលេងសម្រាប់សូត្រសើចសប្បាយ ។ ល្បើកល្បាយជជក់ ។ បរិវារស័ព្ទ ល្បាយ អាចគន្លាស់បានជាពាក្យល្បាយសម្រាប់សូត្រដើម្បីសើចលេងសបើក គឺ ល្បើកសម្រាប់សូត្រដើម្បីសើចលេងសប្បាយ ។

ល្បោះ_ល្បោយ.- សូមមើលពាក្យ របោះរបោយ ។

ល្មម_ល្មៃ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អតល្មៃ, ទន់ភ្លន់សមរម្យប្រពៃ ។ រូបឆោមល្មមល្មៃ គឺ រូបឆោមល្អប្រពៃ ។ ច្រើនប្រើក្នុងពាក្យកាព្យ។ បរិវារស័ព្ទ ល្មៃ អាចគន្លាស់បានជាពាក្យ ល្មៃទន់ភ្លន់ល្អប្រពម គឺ ល្មមទន់ល្អប្រពៃ ។

ល្មាក_ល្មម.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គួរដល់ការដោយបង្គួរមិនលើសមិនខ្វះ ។ តម្រេះវិជ្ជាក្មេងនេះ មានល្មាក-ល្មមទេ គឺតម្រេះវិជ្ជាគ្នាមិនច្រើនប៉ុន្មានទេ ។ល។ បរិវារស័ព្ទ ល្មាក អាចគន្លាស់បានជាពាក្យ ល្មាកបង្គួរដោយស្មើរស្មម គឺ ល្មមបង្គួរដោយស្មើរស្មាក់ ។

ល្ហេញ_ល្ហើ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្ងីល្ងើ, ស្ទើរឆ្កួតស្ទើរជា ។ មនុស្សល្ហេញល្ហើ ។ បរិវារស័ព្ទ ល្ហើ អាចគន្លាស់បានជាពាក្យ ល្ហើដោយឆ្កួតល្ងីល្ហេញ គឺ ល្ហេញដោយឆ្កួតល្ងីល្ងើ ។

ល្វត_ល្វៃ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទន់ភ្លន់ល្វាសល្វន់ពេកក្រៃ ។ ដំណើរល្វតល្វៃ ។ បរិវារស័ព្ទ ល្វៃ អាច-គន្លាស់បានជាពាក្យ ល្វៃដោយទន់ភ្លន់ល្វាសល្វន់ពេកក្រោត គឺ ល្វតដោយទន់ភ្លន់ល្វាសល្វន់ពេកក្រៃ ។

ល្វាស_ល្វន់.- តាមវចនានុក្រម ពាក្យនេះ មានន័យប្រហាក់ប្រ-ហែលនឹងពាក្យល្វតល្វៃ ។ ទន់ភ្លន់ល្វត ។ ល្ហោនរាំចាក់ក្បាច់ល្វាសល្វន់ ។ល។ បរិវារស័ព្ទ ល្វន់ អាចគន្លាស់បានជាពាក្យ ល្វន់ល្វតដោយទន់ភ្លាស គឺ ល្វាសល្វតដោយទន់ភ្លន់ ។

ល្វឹម_ល្វាម.- សូមមើលពាក្យ រឹមរវាម ។

ល្វឹង_ល្វើយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្ហល្ហេវ-ក្រៃពេក, ធំធេង ។ វាលធំល្វឹងល្វើយ ។ បរិវារស័ព្ទ ល្វើយ

អាចគន្លាស់បានជាពាក្យ លើយល្ហល្ហេវស្រឡះល្ហឹង គឺ ល្ហឹង ល្ហល្ហេវស្រឡះល្ហើយ ។

**ល្ហេង_ល្ហើយ.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមានសូរលាន់ឮរងំ ឬដែលផ្សាយក្លិនក្រអូបល្ហើយៗ គួរឱ្យស្រណោះ. គួរឱ្យចាប់ចិត្ត ។ សូរភ្លេងល្ហេងល្ហើយ. ផ្កាក្នុងព្រៃក្រអូបល្ហេងល្ហើយ ។ល។ ប្រើច្រើនក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ល្ហេង អាចគន្លាស់បានជាពាក្យ ល្ហេងលាន់ឮរងំដោយសូរភ្លើយ គឺ ល្ហើយលាន់ឮរងំដោយសូរភ្លេង ។

**ល្ហេត_ល្ហួត.**-តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បានសេចក្តីថា ÷ ដែលទន់ភ្លន់ទ្រេតទ្រោត ។ ដំណើរល្ហេតល្ហួត ។ បរិវារស័ព្ទ ល្ហេត អាចគន្លាស់បានជាពាក្យ ល្ហេតដូចគេចងគ្រួត គឺ ល្ហួតដូចគេចងទ្រេត ។

**ល្វែត_ល្ហាត់.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបានសេចក្តីថា ÷ ដែលទន់ឬធូរខ្លាំង ។ ធូរស្លែតស្លត. ដំណើរល្វែតល្ហត់ ។ល។ បរិវារស័ព្ទ ល្ហត់ អាចគន្លាស់បានជាពាក្យ ល្ហត់ស្លែត គឺ ល្វែតស្លត ។

**ល្ហ_ល្ហាច.**– តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្ហមើលទៅឃើញរាចល្ហាច ។ ទឹកឡើងចូលវាល្ហល្ហាច ។ បរិវារស័ព្ទ ល្ហាច អាចគន្លាស់បានជាពាក្យ ល្ហាចពាសពេញបាចស គឺ ល្ហពាសពេញបាចសាច ។

**ល្ហ_ល្ហេវ.**– តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្ហធ្លុងធ្លេវ, ល្ហស្រឡះស្លេវ ។ ផ្ទះធំល្ហល្ហេវ ។ល។ បរិវារស័ព្ទ ល្ហេវ អាចគន្លាស់បានជាពាក្យ ល្ហេវស្រឡះធ្លួ គឺ ល្ហស្រឡះធ្លេវ ។

**ល្ហាច_ល្ហឹម.**– តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដោយសាចរាយល្ហឹមលន្លឹម, ដែលទឹកឡើងពាសពេញលេចព្រៃលេចវាល ។ ទឹកឡើងល្ហាចល្ហឹម ។ បរិវារស័ព្ទ ល្ហឹម អាចគន្លាស់បានជាពាក្យ ល្ហឹមពាសពេញដោយទឹកឡើងលេចលន្លាច គឺ ល្ហាចពាសពេញដោយទឹកឡើងលេចលន្លឹម ។ ពាក្យលន្លឹម គឺ ឆ្ងាយឬខ្ពស់មើលទៅឃើញលឹមៗ ។

**ល្ហាក_ល្ហើយ.**– ខ្យល់បក់មិនល្ហាកល្ហើយ គឺ ខ្យល់បក់តិចពេក ។ មិនបាត់ក្ដៅស្អុះ ។ បរិវារស័ព្ទ ល្ហាក អាចគន្លាស់បានជាពាក្យ

ល្អាកនៅតែបែកញើសស្រើយ គឺ ល្មើយនៅតែបែកញើសសស្រាក ពោលគឺ ពុំសូវល្ហើយប៉ុន្មានឡើយ ។

ល្អាក-ល្អៀង.- សូមមើលពាក្យ រហាក់រហៀង ។

ល្អិច-ល្អៀង.- សូមមើលពាក្យ រហិររហៀង ។

ល្អិត-ល្អៃ.- សូមមើលពាក្យ រហិតរហៃ ។

ល្អែ-ល្អើយ.- សូមមើលពាក្យ រហែរហើយ ។

ល្អែក-ល្អុយ.- សូមមើលពាក្យ រហែករហុយ ។

ល្អែក-ល្អោក.- សូមមើលពាក្យ រហែករហោក ។

ល្អ-ល្អាច់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្អាតបាត, សមរម្យ ។ រូបរាងល្អល្អាច់, ធ្វើការល្អល្អាច់ ។ បរិវារស័ព្ទ ល្អាច់ អាចគន្លាស់បានជាពាក្យ ល្អាច់ដ គឺ ល្អដាច់ ពោលគឺ ល្អដាច់គេឯង, ល្អវិសេសក្រៃ ។

ល្អ-ល្អះ ឬ ល្អះ-ល្អ-.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អ ស្រស់ស្រលូតស្រឡះ, ស្រស់ល្អឥតឆ្គង ។ រូបឆោមល្អល្អះ ។ល។ បរិវារស័ព្ទ ល្អះ អាចគន្លាស់បានជាពាក្យ ល្អះស្រស់ស្រលូតស្រឡ គឺល្អស្រស់ស្រលូតស្រឡះ ។

**ល្អាក់_ល្អួល**.- សូមមើលពាក្យ រអាក់រអួល ។

**ល្អា_ល្អួម**.- សូមមើលពាក្យ រអារអួម ។

**ល្អិត_ល្អ**.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អហ្មត់ហ្មង. ល្អប្រពៃ ។ រូបឆោមល្អិតល្អ ។ល។ បរិវារស័ព្ទ ល្អិត អាចគន្លាស់បានជាពាក្យ ល្អិត ហ្មត់ហ្មងពេញច គឺ ល្អហ្មត់ហ្មងពេញចិត្ត ។

**ល្អិត_ល្អន់**.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អិតប៉ន់. ល្អិតខ្ទេចខ្ទីក្រៃពេក ។ ពិនិត្យការឱ្យល្អិតល្អន់ ។ បរិវារស័ព្ទ ល្អន់ អាចគន្លាស់បានជាពាក្យ ល្អន់ប៉ុត គឺ ល្អិតប៉ន់ ពោលគឺ ល្អិតខ្ទេចខ្ទីមិនសល់ ។ ( ពាក្យប៉ន់គឺ ÷ ខ្ទេចល្អិតមិនសល់អ្វី ) ។

**ល្អិត_ល្អោច**.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អិតខ្ទេចខ្ទីរំកាច់រំកោច ។ បរិវារស័ព្ទ ល្អោច អាចគន្លាស់បានជាពាក្យ ល្អោចខ្ទេចខ្ទីរំកាច់រំកិត គឺ ល្អិតខ្ទេចខ្ទីរំកាច់រំកោច ពោលគឺ ល្អិតខ្ទេចខ្ទីដូចស្រមោច ។

**ល្អិត_ល្អោញ**.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ មានសេចក្តីថា ÷ ល្អិតតិចតួចពេកដោយហោច. ស្តួចស្តើង.

ដែរស្មើរតែនឹងគ្នា ។ ចំណីល្អិតល្អោញ ។ល។ បរិវារស័ព្ទ ល្អិត អាចគន្លាស់បានជាពាក្យ ល្អិតស្តួចស្តើងពេក នាំឱ្យស្មើរក្នុងចោញ គឺ ល្អោញ ស្តួចស្តើងពេកនាំឱ្យស្មើរក្នុងចិត្ត ។

**ល្ហុក_ល្ហិន.-** តាមវចនានុក្រម សមាសពាក្យ ល្ហុកហើយនឹងល្ហិននេះ មានន័យដូចគ្នា ពោលគឺ ត្រជាក់ស្រួល ។ សម្ដីល្ហុកល្ហិន គឺ សម្ដីត្រជាក់ទន់ផ្អែមសុភាព, សាច់ត្រជាក់ល្ហុកល្ហិន គឺ សាច់ ធាត់ទ្រលុកត្រជាក់ស្រួល ។ល។ គេអាចនិយាយថា ÷ ត្រជាក់ល្ហុក ឬ ត្រជាក់ល្ហិនបានដូចគ្នា ។ បរិវារស័ព្ទ ល្ហុក អាច គន្លាស់បានជាពាក្យ ល្ហុកដោយត្រជាក់ស្រួលល្ហិន គឺ ល្ហិន ដោយត្រជាក់ស្រួលល្ហុក ពោលគឺ ត្រជាក់ល្ហុកៗ គឺ ត្រជាក់ ណាស់ ។

**ល្អៀច_ល្អែ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ល្អៀចក្រៃពេក ។ ដីភក់ល្អៀចល្អែ ។ (ប្រើតាមទម្លាប់និយាយដោយស្រុក) ។ បរិវារស័ព្ទ ល្អែ អាចគន្លាស់បានជាពាក្យ ល្អែ ដោយជ្រាយរអិលវក់វៀច គឺ ល្អៀចដោយជ្រាយរអិលវក់វៃ ។

**ឮ_លាន់ ឬ លាន់_ឮ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷

ដែលគ្រាន់តែលាន់ឮកងរំពង ប៉ុន្តែពុំប្រាកដថាជាសូរស័ព្ទអ្វី ឬ រឿងហេតុអ្វីឡើយ ។ ច្រើនប្រើជាពាក្យលាយក្នុងកាព្យ ដូចតទៅនេះ ÷

« មានការណ៍ឮលាន់ តើមានអាសន្ន អ្វីប្លែកយ៉ាងណា គួរសួរបញ្ជាក់ ឱ្យអ្នករាល់គ្នា បានដឹងច្បាស់ថា ជារឿងហេតុអ្វី ? » ។ (វចនានុក្រមទំព័រ ១១៤៧) ។

បរិវារស័ព្ទ លាន់ អាចគន្លាស់បានជាពាក្យ លាន់សូររំពងហាក់ដូចជាមានអាសី គឺ ឮសូររំពងហាក់ដូចជាមានអាសន្ន ។

* *

*

# វ

**វក់_វី.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា÷វិលចុះវិលឡើងដដែលៗ ដូចគេវី ។ ដើរវក់វី គឺ ដើរច្រើនសាច្រើនត្រឡប់ ។ បរិវារស័ព្ទ វី អាចគន្លាស់បានជាពាក្យ វីវិលវល់ចុះឡើងខ្ចីខ្ចក់ គឺ វក់វិលវល់ចុះឡើងខ្ចក់ខ្ចី ។

**វង់_វៀន.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ វងបង្វៀង វងឱ្យមានសណ្ឋានក្រវៀន ។ បរិវារស័ព្ទ វៀន អាចគន្លាស់បានជាពាក្យ វៀនបង្វង គឺ វងបង្វៀន ។

**វង្វេង_វង្វាន់.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ភ្លេចឬភាន់ស្មារតីឬគំនិត ។ល។ ចាស់វង្វេងវង្វាន់ ។ បរិវារស័ព្ទ

លលោក់_លលោប.- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ល្អរុងរឿងដោយអំណាច ; ដែលគឃ្លើនអង់អាចឥតក្រែង ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ សព្វថ្ងៃនេះខ្មែរយើងយកពាក្យនេះមកប្រើក្លាយខុសសម្រាប់និយាយជំនួសពាក្យ ពព្រាក់ពព្រើត ឬពាក្យលលីមលលាម ។ បរិវារស័ព្ទ លលាក់ អាចគន្លាស់-បានជាពាក្យ លលាក់ដោយគឃ្លើនអង់អាចពុំអន់អ៊ា គឺ លលាមដោយគឃ្លើនអង់អាចពុំអន់អាក់ ។ អ្នកខ្លះប្រើពាក្យនេះ ក្លាយជាលលាមក៏មាន ។ ល ។

លលីម_លលាម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លលាមក្រែពេក, ពភ្លឹមពភ្លាម ។ បរិវារស័ព្ទ លលីម អាចគន្លាស់បានជាពាក្យ លលីមដោយឫកពភ្លឹមពភ្លាម គឺ លលាមដោយឫកពភ្លាមពភ្លឹម ពោលគឺ លលាមពព្រាត់ពព្រើតដូចស្វា ។

លន់_លក់ ឬ លក់_លន់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ លក់ជ្រុលដំណេក, លក់ហួសប្រមាណ, លក់ជ្រៅមិន-ងាយភ្ញាក់ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ លន់ អាចគន្លាស់បានជាពាក្យ លន់ដោយជ្រុលដំណេកស៊ក់ គឺ លក់ដោយជ្រុលដំណេកស៊ុន ។

វង្វាន់ អាចគន្លាស់បានជាពាក្យ វង្វាន់ច្រឡំដោយស្មារតីភេង គឺ វង្វេងច្រឡំដោយស្មារតីភាន់ ។ អ្នកខ្លះប្រើពាក្យនេះថា ÷ អង្វេងអង្វាន់វិញ ។

**វត្ត-វ៉ា**.–ទីកន្លែងព្រះសង្ឃគង់ ។ល។ អ្នកស្រុកភុំគ្នានៅវត្តវ៉ាដើម្បីធ្វើបុណ្យ ។ល។ បរិវារស័ព្ទ វ៉ានេះ បើតាមយោបល់ខ្ញុំផ្ទាល់ឃើញថាខ្មែរយើងចង់និយាយចំពោះតែវត្តណា កសាងឡើងត្រឹមត្រូវ ប្រកបតាមលក្ខណៈព្រះពុទ្ធសាសនា ដោយមានពិធីបុណ្យបញ្ចុះសីមា ។ ដូច្នេះ បរិវារស័ព្ទ វ៉ា អាចគន្លាស់បានជាពាក្យមួយថា ÷ វ៉ាដែលបានបញ្ចុះសីមាត់ គឺ វត្តដែលបានបញ្ចុះសីមា ពោលគឺ វត្តសម្មាចារ គឺ វត្តដែលព្រះសង្ឃកាន់សីលទានត្រឹមត្រូវ ។

**វរ-វីក** ឬ **វីក-វរ**.–តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទាស់ការច្របូកច្របល់, ធ្វើឱ្យទាស់ការ ។ល។ វរវីកទទឹកស្ងួត ។ល។ បរិវារស័ព្ទ វីក អាចគន្លាស់បានជាពាក្យ វីកព្រោះភ័ន្តចា-រំ គឺ វរព្រោះភ័ន្តចារិក ពោលគឺ ធ្វើឱ្យច្រឡំបល់គោលដៅ ។

វាក់_វាម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ចាំស្រពេច ស្រពិលវាក់វាមគំនិតឬស្មារតី ។ល។ បរិវារស័ព្ទ វាម អាច គន្លាស់បានជាពាក្យ វាមស្មារតីរឹម វាក់ស្មារតីរឹមវាម ។

វាង_វៃ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឈ្លាសវៃដោយ រហ័ស. ស្ទាត់ជំនាញ. ប៉ិនប្រាកដ ។ល។ ប្រាជ្ញាវាងវៃ ។ល។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ វាង អាចគន្លាស់បាន-ជាពាក្យ វាងដោយជំនាញយ៉ាងរហ័សពុំមានលំអៃ គឺ វៃដោយ ជំនាញយ៉ាងរហ័សពុំមានលំអៀង ។

វាស_វាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយខ្ចី-ដង. និយាយបញ្ឆិតបញ្ឆៀងពង្វាងនាយអាយ ។ល។ និយាយ វាសវាង. បញ្ចៀសវាសវាង ។ បរិវារស័ព្ទ វាង អាចគន្លាស់-បានជាពាក្យ វាងដោយសម្ដីបញ្ឆិតបញ្ចៀស គឺ វាសដោយ សម្ដីបញ្ឆិតបញ្ឆៀង ។

វិសេស-វិសាល.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទូលាយ ប្លែក. ប្រសើរប្លែក. ល្អប្លែក ។ល។ ព្រះពុទ្ធរូបបុរាណនេះ ល្អវិសេសវិសាលណាស់ ។ល។ បរិវារស័ព្ទ វិសាល អាច

អាចគន្លាស់បានជាពាក្យ វិសាលល្អប្រសើរត្រកេស គឺ វិសេស
ល្អប្រសើរត្រកាល ។

វ៉ក_វ៉ាក.- គឺ ឮសម្លេងកោកកាក ។ និយាយវ៉ូកវ៉ាក ។ល។ បរិវារ-
ស័ព្ទ វ៉ាក អាចគន្លាស់បានជាពាក្យ វ៉ាកដោយសម្លេងខ្លាំង
កាកកូក គឺ វ៉ូកដោយសម្លេងខ្លាំងកោកកាក ។

វ៉ង_វ៉ាង.- សូរសម្ដីនិយាយខ្លាំងពេញទ្រពងមាត់ ដោយក្អេងក្អាង ។
និយាយវ៉ូងវ៉ាង ។ បរិវារស័ព្ទ វ៉ាង អាចគន្លាស់បានជាពាក្យ
វ៉ាងដោយសម្លេងខ្លាំងក្អេងក្អូង គឺ វ៉ូងដោយសម្លេងខ្លាំងក្អេង-
ក្អាង ។ ពាក្យនេះ អ្នកនិយាយថាៈ វឹងវ៉ាងវិញ ។

វ៉ប_វ៉ាក់.- សូរសម្លេងជាល្បែងក្មេងបិទពួន ឬសម្រាប់ធ្វើឱ្យភ្ញាក់ដើម្បី
ជាការប្រឡែងលេង ។ល។ វ៉ូមវ៉ាក់អី! ។ បរិវារស័ព្ទ វ៉ាក់
អាចគន្លាស់បានជាពាក្យ វ៉ាក់ជាសម្រែកដើម្បីធ្វើឱ្យភ្ញូម គឺ វ៉ូម
ជាសម្រែកដើម្បីធ្វើឱ្យភ្ញាក់ ។ អ្នកខ្លះនិយាយពាក្យនេះថា ÷
វ៉ូមវ៉ះវិញ ។

វ៉ស_វ៉ាស.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរឮដោយ
ស្រែកយ៉ាងពេញសម្លេង បាក់ដូចជាស្រែកបង្អើលដោយមាន

គ្នាច្រើន ។ ពួស្រែកវ៉ូសវ៉ាស ។ បរិវារស័ព្ទ វ៉ូស អាចគន្លាស់បានជាពាក្យ វ៉ូស ដោយសម្រែកខ្លាំងដូចសម្លេងអាក្រាស គឺ វ៉ាសដោយសម្រែកខ្លាំងដូចសម្លេងអាក្រោស ។

**វៀច_វេរ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ វៀចវាកបែរ. វៀចបែរវេរ ។ ចិត្តវៀចវេរ ។ ល ។ បរិវារស័ព្ទ វេរ អាចគន្លាស់បានជាពាក្យ វេរដោយបែរវៀច គឺ វៀចដោយបែរវេរ ។

**វេះ_វៀន.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គេចពួនក្រវៀន ។ បរិវារស័ព្ទ វៀន អាចគន្លាស់បានជាពាក្យ វៀនគេចពួនក្រវេះ គឺ វេះគេចពួនក្រវៀន ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ វៀះវៀនវិញ ។

ពាក្យវេះវៀននេះ ខ្មែរយើងច្រើនប្រើចំពោះកូនចៅវេះគេចពួនលេងពុំទៅរៀនសាលា ។ ដូច្នេះបរិវារស័ព្ទ វៀននេះ អាចដោះស្រាយជាពាក្យ គន្លាស់ថា ÷ វៀនគេចពួនលេងពុំទៅសាលាសូត្រវេះ គឺ វេះគេចពួនលេងពុំទៅសាលាសូត្រវៀន ។

✲ ✲

✲

# ៦៥

**ស័ក្ដ-សមឬសម-ស័ក្ដិ.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សមល្មមដល់ការ. សមដោយអំណាច. អំណាចដ៏សមរម្យឬអំណាចស្មើគ្នា ។ បរិវារស័ព្ទ សម អាចគន្លាស់បានជាពាក្យ សមដោយអំណាចដ៏សមរ៉ាក់ គឺ ស័ក្ដិដោយអំណាចដ៏សមរម្យ ។

**ស័ក្ដិ-សិទ្ធិ.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ÷ ស័ក្ដិហើយនិងសិទ្ធិ ។ ពាក្យនេះ មានន័យថា: ការសម្រេចដោយអំណាច. ធ្វើឱ្យឃើញជាក់ស្ដែង. ឱ្យឃើញប្រាកដ ។ល។ មន្តស័ក្ដិសិទ្ធិ. វត្ថុស័ក្ដិសិទ្ធិ ។ល។ បរិវារស័ព្ទ សិទ្ធិ ពូកែឆុតឆាប់ដូចនិម៉ាក់ គឺ សិក្ដិពូកែឆុតឆាប់ដូចនិមិត្ត ។

**ស៊ក_សៀត.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយអុចអាលញុះញង់, និយាយដាក់ផ្លែ, ដៀមដាមដោយស្មៀត ។ល។ សម្ដីស៊កសៀត ។ល។ បរិវារស័ព្ទ សៀត អាចគន្លាស់បានជាពាក្យ សៀតសម្ដីផ្លែផ្កាក្នុងស្ក៏ក គឺ ស៊កសម្ដីផ្លែផ្កាក្នុងស្មៀត ។

**សង_ស៊ក.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើអាក្រក់តបទៅវិញ, បំផ្លាញតបទៅវិញ, ចងពៀរតប ។ល។ បរិវារស័ព្ទ ស៊ក អាចគន្លាស់បានជាពាក្យ ស៊កតបវិញដោយអំពើអាក្រក់ពន់ឡង គឺ សងតបវិញដោយអំពើអាក្រក់ពន្លឹក ។

**សង្កត់_សង្កិន.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សង្កត់ដូចជាកិនឱ្យល្អិតខ្ទេចខ្ទី, បង្រ្កបលើ, បៀតបៀនយកប្រយោជន៍ ។ល។ ជនចិត្តអាក្រក់ ច្រើនសង្កត់សង្កិនលើអ្នកខ្សត់ខ្សោយ ដើម្បីបំផ្លាញ ធ្វើបាបឱ្យវិសនាសហីនហោច ។ល។ បរិវារស័ព្ទ សង្កិន អាចគន្លាស់បានជាពាក្យ សង្កិនធ្វើបាបឱ្យវិនាសហត់ គឺ សង្កត់ធ្វើបាបឱ្យវិនាសហីន ។

**សង្កើ_សង្កាញ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រៀវស្រាញ់រកកល់គ្រូន ។ បរិវារស័ព្ទ សង្កាញ់ អាចគន្លាស់បានជាពាក្យ សង្កាញ់រកកល់ស្រៀវស្រើ គឺ សង្កើរកកល់ស្រៀវស្រាញ់ ។

**សង្កេព_សង្កិន.-** តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ គឺ សង្កេតហើយនិងសង្កិនដែលបានសេចក្តីថា ÷ សង្កេតឈ្លេចឈ្លីឱ្យឃើញការពិត ។ សង្កេតសង្កិនឱ្យទាល់តែឆ្លើយត្រង់តាមផលហេតុ ។ បរិវារស័ព្ទ សង្កេត អាចគន្លាស់បានជាពាក្យ សង្កេតឈ្លេចឈ្លីឱ្យឃើញផលហិន គឺ សង្កិនឈ្លេចឈ្លីឱ្យឃើញផលហេតុ ។

**សង្រេង_សង្រៃ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ កើតទុក្ខដល់រីងខ្លួន ។ មនុស្សសង្រេងសង្រៃ គឺ មនុស្សកើតទុក្ខពេកក្រៃ ឬសង្រេងដល់រីងរៃ ។ល។ បរិវារស័ព្ទ សង្រៃ អាចគន្លាស់បានជាពាក្យ សង្រៃដោយកើតទុក្ខរីងរេង គឺ សង្រេងដោយកើតទុក្ខរីងរៃ ។

សញ្ជប់_សញ្ជើង.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ បានសេចក្ដីថា ÷ សញ្ជប់ទ្រឹងទ្រមឹងទ្រមើយ, ទ្រឹងជញ្ជើងគិតដោយអាការក្រៀមក្រំ ។ អង្គុយសញ្ជប់សញ្ជើងធ្មឹងម្នាក់ឯង ។ បរិវារស័ព្ទ សញ្ជើង អាចគន្លាស់បានជាពាក្យ សញ្ជើងដោយអង្គុយគិតម្នាក់ឯងធ្មប់ គឺ សញ្ជប់ដោយអង្គុយគិតម្នាក់ឯងធ្មឹង ។

សន្ធឹក_សន្ធាប់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ច្រើនហួសប្រមាណ, ច្រើនក្រៃ, ហ៊ឹកហាក់ខ្លាំង, ដែលរុងរឿងខ្លាំង។ គេធ្វើបុណ្យសន្ធឹកសន្ធាប់ណាស់ ។ បរិវារស័ព្ទ សន្ធឹក អាចគន្លាស់បានជាពាក្យ សន្ធឹកដោយហ៊ឹកហាក់ខ្លាំងយ៉ាងគគ្រាប់ គឺ សន្ធាប់ហ៊ឹកហាក់ខ្លាំងយ៉ាងគគ្រឹក ពោលគឺ យ៉ាងអឹកអធឹក ។

សន្ធឹក_សន្ធៃ.- ពាក្យនេះ មានន័យថា ÷ ដែលច្រើនពេកក្រៃ ។ ម្ហូបម្ហាសន្ធឹកសន្ធៃ ។ បរិវារស័ព្ទ សន្ធៃ អាចគន្លាស់បានជាពាក្យ សន្ធៃពេកគ្រឹក គឺ សន្ធឹកពេកក្រៃ ។

សន្ធឹង_សន្ធៃ.-ដែលព្រួយចិត្តខ្លាំងដេកកើតទុក្ខក្រៀមក្រំ ។ កើតទុក្ខសន្ធឹងសន្ធៃ ។ បរិវារស័ព្ទ សន្ធៃ អាចគន្លាស់បានជាពាក្យ

សន្ទៃដេកកើតទុក្ខព្រួយចិត្តពេកគ្រឹង គឺ សន្ទឹងដេកកើតទុក្ខពេកក្រៃ ។

សន្ទប់_សន្ទិន.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សន្ទប់ ឈឹងមិនដឹងខ្លួន មិនកម្រើកដៃជើង ។ យប់មិញខ្ញុំដេកលក់ដូចជាសន្ទប់សន្ទិន, ដូចជាមិនដឹងខ្លួន ។ល។ បរិវារស័ព្ទ សន្ទិន អាចគន្លាស់បានជាពាក្យ សន្ទិនលក់សូន្យគ្មានសុបប់ គឺ សន្ទប់លក់សូន្យគ្មានសុបិន, ពោលគឺ ÷ បើសន្ទប់មានសុបិន គឺ សន្ទប់នៅមានវិញ្ញាណនៅឡើយ ដូចជាសន្ទប់ពុំមែនលក់សូន្យឈឹង ។

សន្សៃ_សន្សំ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប្រមែប្រមូលពីតិចឱ្យបានច្រើន ។ រំផ្សំផ្សំឥតរើសមុខ ។ បរិវារស័ព្ទ សន្សៃ អាចគន្លាស់បានជាពាក្យ សន្សៃឱ្យបានច្រើនដោយប្រមូលប្រមឹម គឺ សន្សំឱ្យបានច្រើនដោយប្រមូលប្រមែ ។

សម_សួន.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សមតាមភាគតាមបែប, តាមខ្នាតឬតាមភាព ។ល។ តុបតែងរៀបចំខ្លួនប្រាណឱ្យសមសួន ឬដាក់ឬកពាឱ្យសមសួន ។ បរិវារស័ព្ទ

សួន អាចគន្លាស់បានជាពាក្យ សួននឹងខ្លំ គឺ សមនឹងខ្លួន ពោលគឺ ដាក់ឬកពាឱ្យសមតាមវណ្ណៈខ្លួន កុំឱ្យមានការហួសប្រមាណ ។

សម្ដី_សម្ដម.- ដែលស្ដមដោយអត់អ៊ីបរិភោគ ។ បរិវារស័ព្ទ សម្ដី អាចគន្លាស់បានជាពាក្យ សម្ដីដោយអត់អ៊ីស៊ម គឺ សម្ដម ដោយអត់អ៊ីស៊ី ។

សម្ដោក_សម្ដាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ៖ ដែលស្ដោកស្ដាំងខ្លាំង ។ បរិវារស័ព្ទ សម្ដាំង អាចគន្លាស់បានជាពាក្យ សម្ដាំងក្រៀមកន្ទោក គឺ សម្ដោកក្រៀមកន្ទាំង ។

សម្ដាំង_សម្ដម.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ៖ ដែលស្ដាំងស្ដមខ្លាំង ។ បរិវារស័ព្ទ សម្ដាំង អាចគន្លាស់បានជាពាក្យ សម្ដាំងឃ្លុម គឺ សម្ដមខ្លាំង ។

សំបុក_សម្បត្តិ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ៖ សម្បត្តិដែលទុកក្នុងទីកំបាំង ។ បរិវារស័ព្ទ សំបុក អាចគន្លាស់បានជាពាក្យ សំបុកដែលមានដាក់គាត់ គឺ សម្បត្តិដែលមានដាក់ទុក ។

សំបុក_សម្បូណ៌.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ច្រើន ពាសពេញ, បរិបូរណ៌ក្រៃពេក ។ បរិវារស័ព្ទ សម្បូរណ៌ អាចគន្លាស់បានជាពាក្យ សម្បូរណ៌ច្រើនពាសពេញបរិបុក គឺ សំបុក ច្រើនពាសពេញបរិបូរណ៌ ។

សម្រាក_សម្រន់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលធ្វើឱ្យស្រាក់ស្រន់ ។ បរិវារស័ព្ទ សម្រន់ អាចគន្លាស់បានជាពាក្យ សម្រាន្តដើម្បីឱ្យស្រន់ស្រាក គឺ សម្រាកដើម្បីឱ្យស្រាក់ស្រន់ ។

សម្រាក_សម្រាន្ត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលធ្វើឱ្យស្រាកស្រាន្ត ។ បរិវារស័ព្ទ សម្រាន្ត អាចគន្លាស់-បានជាពាក្យ សម្រាន្តដើម្បីឱ្យស្រាន្តស្រាក គឺ សម្រាកដើម្បីឱ្យស្រាកស្រាន្ត ។

សម្រាក_សម្រាល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលធ្វើឱ្យស្រាកស្រាល ។ បរិវារស័ព្ទ សម្រាល អាចគន្លាស់បានជាពាក្យ សម្រាលដើម្បីឱ្យស្រាលស្រាក គឺ សម្រាកដើម្បីឱ្យស្រាកស្រាល ។

សម្រិត_សម្រាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ផ្ចិត ផ្ចង់ឱ្យស្អាត, ឱ្យបរិសុទ្ធ, ឱ្យល្អ ។ល។ បរិវារស័ព្ទ សម្រិត អាចគន្លាស់បានជាពាក្យ សម្រិតផ្ចិតផ្ចង់ឱ្យល្អអស់ពីចាំង គឺ សម្រាំងផ្ចិតផ្ចង់ឱ្យល្អអស់ពីចិត្ត ។

សម្រុក_សម្រុញ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សម្រុក ចូលដើម្បីឱ្យសុញ ឱ្យទាល់, ចាប់រុញឱ្យស្រុញ ។ បរិវារស័ព្ទ សម្រុញ អាចគន្លាស់បានជាពាក្យ សម្រុញដោយចាប់រុញឱ្យ-ស្រុក គឺ សម្រុក ដោយចាប់រុញឱ្យស្រុញ ។

សម្រុក_សម្រុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រុក រុលចូលពេញទំហឹង ។ សម្រុកសម្រុលចូល ។ បរិវារស័ព្ទ សម្រុល អាចគន្លាស់បានជាពាក្យ សម្រុលពេញទំហឹងចុក គឺ សម្រុកពេញទំហឹងចូល ។

សម្រុះ_សម្រួល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និ-យាយសម្រួលឱ្យស្រុះចិត្តគំនិតគ្នា ។ និយាយដឹកនាំឱ្យស្រុះស្រួលនឹងគ្នា ។ល។ បរិវារស័ព្ទ សម្រុះ អាចគន្លាស់បានជាពាក្យ សម្រុះដឹកនាំដើម្បីឱ្យស្រុះស្រួល គឺ សម្រួលដឹកនាំដើម្បីឱ្យស្រួលស្រុះ ។

សម្រែ_សម្រេប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ កែឱ្យបានស្រួលឡើង ។ សម្រែសម្រួលការវិវាទ ។ បរិវារស័ព្ទ សម្រែ អាចគន្លាស់បានជាពាក្យ សម្រែការឱ្យបានល្អដោយកែប្រួល គឺ សម្រួលការឱ្យបានល្អដោយកែប្រែ ។

សម្លូ_សម្លុក.- ម្ហូបដែលកើតពីស្លូ. ម្ហូបដែលស្លស្លុក ។ បរិវារស័ព្ទ សម្លុក អាចគន្លាស់បានជាពាក្យ សម្លុកដែលបង់ប្រហា គឺ សម្លដែលបង់ប្រហុក ពោលគឺ អស់លោកអ្នកប្រាជ្ញបុរាណមានគំនិតមួយចង់រំលែក មុខសម្លឱ្យច្បាស់ចេញពីគ្នា អំពីសម្លប្រភេទឯទៀត ។

សម្លក់_សម្លេកឬសម្លេក_សម្លក់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បើកភ្នែកធំៗ សម្លឹងត្រង់ទៅរកដោយធ្វើមុខមាំ ឬធ្វើមុខស្មើ ។ បរិវារស័ព្ទ សម្លេក អាចគន្លាស់បានជាពាក្យ សម្លេកមុខមាំដោយបើកផ្លក់ គឺ សម្លក់មុខមាំដោយបើកភ្នែក ។

សម្អិត_សម្អាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្អិតស្អាងដោយប្រពៃ ។ បរិវារស័ព្ទ សម្អិត អាចគន្លាស់បានជា

ពាក្យ សម្ងិតស្អិតស្អាងដោយប្រពៃអស់ពីចាង គឺ សម្អាងស្អិតស្អាងដោយប្រពៃអស់ពីចិត្ត ។

**សម្ងិត_សម្អាត.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើឱ្យស្អាតហ្មត់ហ្មង, សម្អាតដោយប្រពៃ ។ បរិវារស័ព្ទ សម្ងិត អាចគន្លាស់បានជាពាក្យ សម្ងិតឱ្យស្អាងហ្មត់ហ្មងអស់ពីចាត គឺ សម្អាតឱ្យស្អាតហ្មត់ហ្មងអស់ពីចិត្ត ។

**ស៊ិយ_សៀវ.-** គឺឃ្លានលាភ, មិនសមបំណង, មោឃ ។ល។ ថ្ងៃនេះស៊ិយសៀវណាស់ ។ល។ បរិវារស័ព្ទ សៀវ អាចគន្លាស់បានជាពាក្យ សៀវឃ្លាងលាភដូចគេគ្រយ គឺ ស៊ិយឃ្លាងលាភដូចគេក្រៀវ ពោលគឺ ដូចគេកាត់, គេផ្ដាប់ឱ្យឃ្លាតឃ្លៀង ។

**សស្រុក_សស្រុល.-** ពាក្យនេះ មានន័យ ប្រហាក់ប្រហែលគ្នានឹង-ពាក្យ ត្រស្រុកត្រស្រុល ។ សូមមើលពាក្យត្រស្រុកត្រស្រុលនេះ ។

**សរសៃ_សសួង.-** ខ្ញុំឈឺចុកចាប់គ្រប់សរសៃសសួងទាំងអស់ ។ បរិ-វារស័ព្ទ សសួងនេះ អាចគន្លាស់បានជាពាក្យមួយថា: សសួងដែលជាប់ជាមែកធាងពីបេះដៃ គឺសរសៃដែលជាមែងធាងពី-

បេះដូង ។ គ្រាមភាសាខ្មែរយើងច្រើននិយាយថា ÷ ត្រសែ-ត្រសូង ឬ តាសែតាសូង ។

សស្រែក_សស្រាក.- ដែលស្រែកសស្រាកពាសពីស ។ ញើស-ស្រកសស្រែកសស្រាក ។ល។ បរិវារស័ព្ទ សស្រែក អាចគន្លាស់បានជាពាក្យ សស្រែកហូរពីសពាសច្រើនប៉ាក គឺសស្រាកហូរពីសពាសច្រើនពេក ។ អ្នកខ្លះនិយាយជាពាក្យ សស្រិកសស្រាក ឬ សស្រឹកសស្រាកវិញ ។

សស្រែាក_សស្រាញ.- តាមវចនានុក្រម ពាក្យនេះ បានសេចក្តីថា ÷ ដែលសស្រែាកសស្រាំដោយសេចក្តីរីករាយ ។ ពួកក្មេងរត់លេងសស្រែាកសស្រាញ គឺ ក្មេងរត់លេងពេញទំហឹង-ស្រែាកព្រមគ្នា ។ល។ បរិវារស័ព្ទ សស្រែាក អាចគន្លាស់បានជាពាក្យ សស្រែាកសប្បាយខ្លាំងដោយព្រមគ្នាស្រាញ គឺសស្រាញសប្បាយខ្លាំងដោយព្រមគ្នាស្រែាក ។

សស្រែាក_សស្រាំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ព្រមគ្នាមិនដាច់សូរ, ស្រែាកចុះស្រែាកឡើង ។ នាំគ្នាសស្រែាកចុះសស្រាំឡើង, ទះដៃសស្រែាកសស្រាំ ។ល។ បរិវារស័ព្ទ

សស្រោក អាចគន្លាស់បានជាពាក្យ សស្រោកដោយស្នូរ-សម្លេងស្រាំៗ គឺ សស្រាំដោយស្នូរសម្លេងស្រោកៗ ។

សស្លើត_សស្លក់.- ស្លើតស្លក់រឡេមរឡាម ។ ភ័យសស្លើតសស្លក់ ។ល។ បរិវារស័ព្ទ សស្លក់ អាចគន្លាស់បានជាពាក្យ សស្លក់-ដោយភ័យរឡេមរឡាមផ្លក់ផ្លើត គឺ សស្លើតដោយភ័យរឡេម-រឡាមផ្លើតផ្លក់ ពោលគឺភ័យខ្លាំងដោយញ័ររន្ធត់មានដង្ហើម-ប៉ផ្តើតប៉ផ្លក់ជាដើម ។ ពាក្យនេះ អ្នកខ្លះនិយាយសស្លើត-សស្លក់វិញ ។

សហាយ_ស្មន់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សហាយដែលខូចកាចនឹងគ្នា ដល់បែកការត្រូវបង់ប្រាក់ពិន័យមុខស្មន់ ។ ពាក្យនេះមានន័យចំហទាំងពីរគឺ ÷ សហាយនឹងស្មន់ ។ សមាសពាក្យនេះពុំមានសម្លេងស្របគ្នាដូចសមាសពាក្យឯទៀត ពោលគឺសម្លេង (ស) និង (ស្ម) ។ ដូច្នេះបរិវារស័ព្ទ ស្មន់ អាចគន្លាស់បានជាក្រោមភាសាមួយវគ្គថា ÷ ស្មន់បណ្តោះអាសាក់ គឺស្ម័គ្របណ្តោះអាសន្ន ពោលគឺ សហាយគ្នាក្នុងការលួចលាក់

ក្នុងផ្លូវឯងមិតខ្វាក់ស្មើគ្នា ឬដោយមានអ្នកដទៃជួយលាក់បំបាំងផងនៅឡើយ ។

សា_សង.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលឆ្លើយឆ្លងសាត្រឡប់តបវិញ ។ សម្តីសាសង ។ បរិវាស័ព្ទ សង អាចគន្លាស់បានជាពាក្យ សង ដែលឆ្លើយឆ្លា គឺ សាដែលឆ្លើយឆ្លង។

សា_ស័ព្ទ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយបូរបាច, និយាយរៀបរាប់ប្រាប់តាំងពីដើមដល់ខាងចុង ។ សា-សព្ទឱ្យអស់អាថិសេចក្តី ។ល។ បរិវារស័ព្ទ ស័ព្ទ អាចគន្លាស់បានជាពាក្យ ស័ព្ទរៀបរាប់ប្រា គឺ សារៀបរាប់ប្រាប់ ពោលគឺ រៀបរាប់បូរបាចគ្រប់ស័ព្ទ ។

សារ_ស័ព្ទ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពាក្យពិត, ពាក្យមានប្រយោជន៍, មានតម្លៃ ។ល។ ពាក្យនេះមានន័យចំ-ហាទាំងពីរគឺពាក្យ សារហើយនិងស័ព្ទ ។ បរិវារស័ព្ទ សារ អាចគន្លាស់បានជាពាក្យ សារដោយពាក្យពិតមានតម្លៃអស់ចាប់ គឺ ស័ព្ទដោយពាក្យពិតមានតម្លៃអស្ចារ្យ ។

សារ_សូន្យ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហាទាំងពីរ គឺ

ពាក្យសារនិងសូន្យហើយមានន័យថា ÷ ដែលសូន្យចាកតម្លៃ. ដំណើរសូន្យចាកប្រយោជន៏ ឬសូន្យចាកតម្លៃ. ការខូចប្រយោជន៏ ឬអស់តម្លៃ ។ល។ បរិវារស័ព្ទ សារ អាចគន្លាស់បានជាពាក្យ សារចាកប្រយោជន៍ពុំបានកូន គឺ សូន្យចាកប្រយោជន៍ពុំបានការ ។

សាក_សួរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សួរសង្កេតរកដំណើរដើមទងឱ្យជាក់សេចក្ដី ។ បរិវារស័ព្ទ សាក អាចគន្លាស់បានជាពាក្យ សាកឈ្លេចឈ្លីឫសគល់ដើម្បីឃើញចំណុចពិបួរ គឺ សួរឈ្លេចឈ្លីឫសគល់ដើម្បីឃើញចំណុចពិបាកពោលគឺ ឃើញមូលហេតុដើមដែលជាអាថិកំបាំងនៅឡើយ ។

សាយ_សុសឬសុស_សាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពាសពេញសាយសព្វអន្លើ. លេចឮសព្វអន្លើ ។ ឮសាយសុស ។ល។ បរិវារស័ព្ទ សុស អាចគន្លាស់បានជាពាក្យ សុសពាសពេញដូចគេផ្សាយអាក្រាយ គឺ សាយពាសពេញដូចគេផ្សាយអាក្រោស ។

សុខ_សាន្ត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ សុខស្ងប់ ។ ស្រុកទេសសុខសាន្តត្រាណ ។ល។ បរិវារស័ព្ទ សាន្ត អាចគន្លាស់បានជាពាក្យ សាន្តស្ងប់ក្សេមក្សេក គឺ សុខស្ងប់ក្សេមក្សាន្ត ។

សុទ្ធ_សាធ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ គ្រប់ព្រមសព្វគ្រប់គ្មានលាយ ។ ដូចគ្នាសុទ្ធសាធ គឺ ដូចគ្នាចាប់ច្រឡំ។ បរិវារស័ព្ទ សាធ អាចគន្លាស់បានជាពាក្យ សាធដោយសព្វគ្រប់ល្អស្អុត គឺ សុទ្ធដោយសព្វគ្រប់ល្អស្អាត ។

សុភំ_សុភាព.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សុភាពល្អស្រួលបួល. សុភាពល្អសមរម្យ ។ ជនសុភំសុភាព ។ល។ បរិវារស័ព្ទ សុភំ អាចគន្លាស់បានជាពាក្យ សុភំល្អសមរាប គឺ សុភាពល្អសមរម្យ ។

សុស_សៀ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សព្វដាសពាសពេញសព្វអន្លើ ។ ពួសុសសព្វ ។ល។ បរិវារស័ព្ទ សព្វ អាចគន្លាស់បានជាពាក្យ សព្វពាសពេញគ្រប់សុស គឺ សុស

ពាសពេញគ្រប់សព្វ ពោលគឺ ឮពាសពេញសព្វអន្លើសព្វទិសទី ។

សុស_សាច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សព្វសាច. មិនសល់សាច ។ ស្ដីប្រដៅសុសសាចហើយនៅតែមិនបានការទៀត ។ បរិវារស័ព្ទ សាច អាចគន្លាស់បានជាពាក្យ សាចសព្វសុស គឺ សុសសព្វសាច ។

សុស_សាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សាយសព្វអន្លើរលេចឮសព្វអន្លើ ។ ឮសុសសាយ ។ល។ បរិវារស័ព្ទ សាយ អាចគន្លាស់បានជាពាក្យ សាយឮខ្ចរខ្ចុស គឺ សុសឮខ្ចរខ្ចាយ ។

សួញ_សាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលសាំញ៉ាំរាំរែក. ដែលមិនងាយនឹងដាច់ស្រេច. ដែលស្អួញក្រៃពេក ។ បរិវារស័ព្ទ សួញ អាចគន្លាស់បានជាពាក្យ សួញដោយសាំ-ញ៉ាំស្អាញ គឺ សាញដោយសាំញ៉ាំស្អួញ ។

សូន្យ_ស័ញ្ញ ឬស័ញ្ញ_សូន្យ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូន្យឈឹង. សូន្យឥតឮសូរស័ព្ទ ។ បរិវាស័ព្ទ ស័ព្ទ អាច

គន្លាស់បានជាពាក្យ ស័ព្ទដោយឥតព្ទស្នូរសូន្យ គឺ សូន្យដោយឥតព្ទស្នូរស័ព្ទ ។

ស្ងួន្យ_ស៊ុង.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូន្យគ្មានពន្លឺតិចតួច ។ ងងឹតសូន្យសុង ។ល។ បរិវារស័ព្ទ សុង អាចគន្លាស់បានជាពាក្យ សុងដោយងងឹតយ៉ូន គឺ សូន្យដោយងងឹតយុង ពោលគឺ ងងឹតសូន្យយុងចាក់ភ្នែកមិនយល់ ។

ស្ងួន្យ_ស្រោះឬស្រោះ_ស្ងួន្យ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឃែតទទេ, ឥតអំពើ, ឥតប្រយោជន៍ ។ ជនសូន្យសោះ គឺ ជនចោលម្សៀត ។ល។ បរិវារស័ព្ទ សោះ អាច-គន្លាស់បានជាពាក្យ សោះឥតប្រយោជន៍ស្នួន គឺ សូន្យឥត-ប្រយោជន៍ស្នោះ ។

ស្នួន_ស័ក្តិ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សមស័ក្តិ, សមល្មមតាមភាគ តាមបែប តាមបណ្តាស័ក្តិ ។ បរិវារស័ព្ទ ស័ក្តិ អាចគន្លាស់បានជាពាក្យ ស័ក្តិសមល្មមតាមឋានន្តរស្នួន គឺ ស្នួនសមល្មមតាមឋានន្តរស័ក្តិ ។

សែស_សន់.- ជនសេសសន់ គឺ ជនសេសសល់ ។ បរិវារស័ព្ទ សន់

អាចគន្លាស់បានជាពាក្យ សន់ដោយសារវាអេស គឺ សេស ដោយសារវាអន់ ពោលគឺ វត្ថុអ្វីក៏ដោយបើពុំមានសភាពអន់ ឬ ខ្សោយទេ វត្ថុនោះពុំនៅសេសសល់ឡើយ ។

សែន_ព្រេន.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដាក់ភោជ-នាហារសម្បូងសម្រ៉ុងចំពោះទៅមតកបុគ្គល ឬដាក់ក្រយាបូជា ពោលពាក្យអំពាវនាវចំពោះខ្មោចបិសាច ។ ពាក្យសែនព្រេននេះ ខ្មែរយើងច្រើនប្រើតែក្នុងចំណុចពិធីសម្បូងសម្រ៉ុង អំពាវ-នាវដល់ខ្មោចមេបាចាស់ទុំ នៅវេលារៀបចំសែនសម្រួលបរិយាកាសក្នុងគ្រួសារដោយកូនចៅ បានប្រព្រឹត្តអំពើអាថិកំបាំង ខូចជានិងគ្នា ។ល។ (សហាយស្មន់)។ ដូច្នេះពាក្យសែនព្រេននេះ បើយើងបន្លាយអត្ថន័យឱ្យវែង តទៅទៀតយើងឃើញមានរឿងមួយថា : មានជនម្នាក់បានប្រព្រឹត្តជាអ្នកព្រានចិត្ត បានផុងខ្លួនជាប់កុន នឹងកូនស្រីគេទើបមានពិធីរៀបចំសែនព្រេន ដើម្បីសម្រួលការ កុំឱ្យមានការសៅហ្មងដល់ខ្លួនឡើយ ។ល។ ដូច្នេះបរិវារស័ព្ទ ព្រេន អាចគន្លាស់បានជាពាក្យ ព្រេនចិត្តទាល់តែបានស៊ាន គឺ ព្រានចិត្តទាល់តែបានសែន ។

សោះ_សា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ងោះស្អាន ស្រឡះ, ដាច់ស្រេច ។ ជាខ្លួនសោះសា គឺ ជាខ្លួនស្រឡះ ។ល។ បរិវារស័ព្ទ សា អាចគន្លាស់បានជាពាក្យ សាដោយស្រឡះអស់កោះ គឺ សោះដោយស្រឡះអស់ការ ។

សំកុក_សំកុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ញប់ស្ញុល ។ គឺ អង្គុយស្ញប់ក្រញុលមិនហ៊ានមើលមុខ ។ បរិវារស័ព្ទ សំកុល អាចគន្លាស់បានជាពាក្យ សំកុលស្ញប់ក្រញុក គឺ សំកុកស្ញប់ក្រញុល ។

សំកោក_សំកាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ ហើយគេច្រើនប្រើតែក្នុងសម័យបុរាណទេ ដោយមានអត្ថន័យថា ÷ ការឈប់ទ្រឹងនឹងនៅមួយស្របក់ ។ អ្នកចេះសំកោកសំកាំង គឺ អ្នកចេះរបៀនអាគមធ្វើឱ្យឈប់សំកាំងទ្រឹងនៅមួយកន្លែងបាន ។ល។ បរិវារស័ព្ទ សំកាំង អាចគន្លាស់បានជាពាក្យ សំកាំងឈប់ទ្រឹងមួយកន្លែងហាក់ដូចជាផោក គឺ សំកោកឈប់មួយកន្លែងហាក់ដូចជាភាំង ។

**សំគឹង_សំគម ឬ សំគីម_សំគម.-** តាមវចនានុក្រម ពាក្យនេះមានន័យថា ÷ ស្គមកំព្រីង, សំគមឃើញតែឆ្អឹង ។ បរិវារស័ព្ទ សំគឹង អាចគន្លាស់បានជាពាក្យ សំគឹងឃើញតែឈ្អម គឺ សំ-គមឃើញតែឆ្អឹង ។ អ្នកខ្លះនិយាយពាក្យនេះថា÷ សម្ដែមសម្ដម ឬសង្កឹមសង្គមវិញ ។

**សំចៃ_សំច័យ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សន្សំទុកខ្លះបំរុងការ, សំច័យទុកដោយលាក់លៀម ។ បរិវារស័ព្ទ សំចៃ អាចគន្លាស់បានជាពាក្យ សំចៃលាក់លៀមទុកដោយហួរហៃ គឺ សំច័យលាក់លៀមទុកដោយហួរហៃ ។ សព្វថ្ងៃនេះគេច្រើនសរសេរ សំចៃសំចៃជាង ។

**សម្ដី_សំដៅ.-** (សម្ដីសំដៅ) តាមវចនានុក្រម បានសេចក្ដីថា ÷ ពាក្យដែលនិយាយ ឬភាសាដែលនិយាយ ។ល។ បរិវារស័ព្ទ សំដៅ ដែលខ្មែរយើងប្រើភ្ជាប់នឹងពាក្យ «សម្ដី» នេះពុំមានការអ្វីក្រៅអំពីបំណងធំ នៃអស់លោកអ្នកប្រាជ្ញបុរាណ ចង់ដៅបង្ហាញអត្ថន័យយ៉ាងច្បាស់នៃពាក្យ «សម្ដី» មួយម៉ាត់នេះតើមានសណ្ឋានយ៉ាងដូចម្ដេច ពោលគឺ សម្ដីកោងកាច, សម្ដី

ព្រហើន, ត្រគោះ, ទន់ភ្លន់ ។ល។ ដូច្នេះ បរិវារស័ព្ទ សំ-ដៅនេះ គឺជាពាក្យ គន្លាស់ថា÷ សំដៅប្រដី គឺ សម្ដីប្រដៅ ។

**សំណើច_សំណាល.-** តាមវចនានុក្រម បានសេចក្ដី ÷ អំពើឬដំ-ណើរដែលដំណាលសើចលេង ។ អស់សំណើចសំណាល គឺ សើចលេងខ្លាំង ។ល។ បរិវារស័ព្ទ សំណាល អាចគន្លាស់បានជាពាក្យ សំណាលអំពីរឿងក្ដើកើច គឺ សំណើចអំពីរឿងក្ដើកាល ពោលគឺ រឿងដើម ។ល។

**សំពិច_សំពាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បង្ខិចដែលវេចស្ពាយ ។ វេចសំពិចសំពាយ ។ល។ បរិវារស័ព្ទ សំ-ពិច អាចគន្លាស់បានជាពាក្យ សំពិចដែលជាបង្វាយ គឺ សំ-ពាយដែលជាបង្ខិច ។

**សំពិះ_សំពីក.-** (សម្ពិះសម្ពីក) តាមវចនានុក្រម ពាក្យនេះ មាន ន័យថា ÷ ដែលស្ពឹក, ច្រអូស, យឺតពេក ។ល។ ជនសំពិះ សំពីក គឺ ជនខ្ជិលច្រអូស គ្មានតម្រេះអ្វី, ធ្វើអ្វីពុំបានការដូចអ្នកផងទាំងពួងឡើយ ។ បរិវារស័ព្ទ សំពិះ អាចគន្លាស់បានជាពាក្យ សំពិះអស់ជីវិក គឺ សំពីកអស់ជីវិះ ពោលគឺ មនុសកែពុំឡើង ឬជាមនុស្សអស់ផ្លូវតាមពាក្យសាមញ្ញនិយម ។

សំពីង_សំពោង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សំពោងក្រៃពេក ។ សំពាយសំពីងសំពោង ។ បរិវារស័ព្ទ សំពីង អាចគន្លាស់បានជាពាក្យ សំពីងធំដូចពោះប៉ោង គឺ សំពោងដូចពោះប៉ឹង ។ អ្នកខ្លះនិយាយពាក្យនេះថា : សំពិងសំពោងវិញ ។

សំពះ_សំពិន.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សំពះអង្វរគេ ។ សំពះជ្ពោម១រឿយ ។ ខ្ញុំមិនទៅសំពះសំពិនវាធ្វើអ្វីទេ ។ល។ បរិវារស័ព្ទ សំពិន អាចគន្លាស់បានជាពាក្យ សំពិននឹកគុណព្រះអិះ គឺ សំពះនឹកគុណព្រះឥន្ទ្រ ពោលគឺ សំពះអង្វរគេហាក់ដូចជាសំពះលោកធំ ។

ស្កប់_ស្កល់.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរហើយ មានន័យថា ÷ គ្រប់គ្រាន់. ឆ្អែត. អស់ចិត្ត. ពេញបំណង. អស់ងងុយ. បរិបូរណ៍ ។ល។ បរិវារស័ព្ទ ស្កល់ អាចគន្លាស់បានជាពាក្យ ស្កល់គ្រប់គ្រាន់អស់ខ្វប់ គឺ ស្កប់គ្រប់គ្រាន់អស់ខ្វល់ ។

ស្កាញ_ស្កាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ ហើយមានន័យថា ÷ ដែលមានឫស. សរសៃ. រោមរឹងច្រាញ

ស្ងួញស្ងាញ ។ រោមភ្លៀកស្ងួញស្ងាញ ។ល។ បរិវារស័ព្ទ ស្ងាញ អាចគន្លាស់បានជាពាក្យ ស្ងាញញឹកស្ងាញស្ងួញ គឺ ស្ងួញញឹកស្ងួញស្ងាញ ពោលគឺ ស្ងួញស្ងាញជិតកណ្ដាញ់ ។

ស្ដុះ_ស្ដាយ.- (ស្ដុសស្ដាយ) តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សច្បាស់, សក្បួសឬសសុទ្ធ ។ ផ្ការីកស្ដុសស្ដាយ គឺ ផ្ការីកមានសម្បុរសល្អត្រសាយត្រសុំ ។ល។ បរិវារស័ព្ទ ស្ដាយ អាចគន្លាស់បានជាពាក្យ ស្ដាយដោយសម្បុរសរីកល្អពព្រុះ គឺ ស្ដុះដោយសម្បុរសរីកល្អពព្រាយ ។

ស្ដាំង_ស្ដក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ដកក្រៀម ក្រទាំង ។ បរិវារស័ព្ទ ស្ដាំង អាចគន្លាស់បានជាពាក្យ ស្ដាំង ក្រៀមក្រតក គឺ ស្ដកក្រៀមក្រទាំង ។

ស្ដាំង_ស្ដម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ដមក្រ-ទាំង, ស្ដមកំព្រយកំព្រឹង ។ល។ បរិវារស័ព្ទ ស្ដាំង អាចគន្លាស់បានជាពាក្យ ស្ដាំងរីងក្រទម គឺ ស្ដមរីងក្រទាំង ។

ស្ដោក_ស្ដាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ដោក-ក្រៀមក្រទាំង, ស្ដោកសោះកក្រោះ ។ បរិវារស័ព្ទ ស្ដាំង អាច

គន្លាស់បានជាពាក្យ ស្កាំងក្រៀមក្រទោក គឺ ស្តោកក្រៀមក្រទាំង ។

ស្ងប់_ស្ងាត់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ ស្ងាត់មិនមានសូរស័ព្ទ, ស្ងាត់បាត់ ។ បរិវារស័ព្ទ ស្ងាត់ អាចគន្លាស់បានជាពាក្យ ស្ងាត់បប់ គឺ ស្ងប់បាត់ ។

ស្ងប់_ស្ងួត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សញ្ជប់សញ្ជឹង, ទ្រមឹងទ្រមើយ, ក្រៀមក្រំ ។ល។ បរិវារស័ព្ទ ស្ងួត អាចគន្លាស់បានជាពាក្យ ស្ងួតសញ្ជប់សញ្ជឹងក្រៀមក្រំចិត្តចង់ឆ្អប់ គឺ ស្ងប់សញ្ជប់សញ្ជឹងក្រៀមក្រំចិត្តចង់ឆ្អួត ។

ស្ងប់_ស្ងៀម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រគត់ស្រគំ, នឹងធឹង, រៀបរយ, មិនសូវស្ដីនិយាយ ។ បរិវារស័ព្ទ ស្ងៀម អាចគន្លាស់បានជាពាក្យ ស្ងៀមស្រគត់ស្រគំដោយអឹមអប់ គឺ ស្ងប់ស្រគត់ស្រគំដោយអឹមអៀម ។

ស្ងប់_ស្ងុល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ងប់ក្រញុល, ស្ងប់សំកុកសំកុលមិនហ៊ានងើបមុខ ។ បរិវារស័ព្ទ ស្ងុល អាចគន្លាស់បានជាពាក្យ ស្ងុលក្រញប់ គឺ ស្ងប់ក្រញុល ។

ស្ងប់_ស្ងែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ងប់ខ្លាច-
ក្រែងក្នុងចិត្ត ។ បរិវារស័ព្ទ ស្ងែង អាចគន្លាស់បានជាពាក្យ
ស្ងែងក្នុងចិត្តដោយខ្លាក្រប់ គឺ ស្ងប់ក្នុងចិត្តដោយខ្លាចក្រែង ។

ស្ញុក_ស្ញូវ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ខ្ញីវខ្ញូវ, ខ្ញុក-
ខ្ញូវ, ក្រញុកក្រញូវ ។ ក្រដាស់ស្ញុកស្ញូវ ។ល។ បរិវារស័ព្ទ
ស្ញុក អាចគន្លាស់បានជាពាក្យ ស្ញុកដោយឆ្នូលញីក្រញុកក្រញូវ
គឺ ស្ញូវដោយឆ្នូលញីក្រញូវក្រញុក ។

ស្ញែ_ស្ញុក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលញីកស្ញែក
ដេរដាស ។ ចៃក្បាលស្ញែស្ញុក ។ល។ បរិវារស័ព្ទ ស្ញុក អាច
គន្លាស់បានជាពាក្យ ស្ញុកច្រើនឧកមម៉ែ គឺ ស្ញែឧកមម៉ុក ។

ស្តុក_ស្តម្ភ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រំងជំហរ, មាំ-
មួន, មានសម្បត្តិច្រើន ។ល។ មនុស្សស្តុកស្តម្ភ, មានសម្បត្តិ
ស្តុកស្តម្ភ ។ល។ បរិវារស័ព្ទ ស្តម្ភ អាចគន្លាស់បានជាពាក្យ
ស្តម្ភដោយប្រសើរឧត្តុក គឺ ស្តុកដោយប្រសើរឧត្តម ។

ស្តួច_ស្តើង.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្តើងណាស់
ស្តើងតិចពេក ។ ដំរេះវិជ្ជាស្តួចស្តើង, ម្ហូបចំណីស្តួចស្តើង

។ល។ បរិវារស័ព្ទ ស្លួច អាចគន្លាស់បានជាពាក្យ ស្លួចដោយមានបន្តិចបន្តើង គឺ ស្តើងដោយមានបន្តិចបន្តួច ។

ស្តែង_ស្តាប់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ជាក់ច្បាស់, ជាក់ស្បាន់, ដែលគួរស្ញែង ។ល។ ពាក្យនេះច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្តែង អាចគន្លាស់បានជាពាក្យ ស្តែងឮយ៉ាងច្បាស់តាប់ គឺ ស្តាប់ឮយ៉ាងច្បាស់ទែង ពោលគឺ ស្តាប់បានច្បាស់មែនទែនមិនអាចភ្លេច ។

ស្តែង_ស្តេច.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ តួព្រះអង្គខ្លួនឯង, តួព្រះមហាក្សត្រខ្លួនឯង ។ ពាក្យនេះច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្តែង អាចគន្លាស់បានជាពាក្យ ស្តែងជាតួព្រះអង្គអេច គឺ ស្តេចជាតួព្រះអង្គឯង ។

ស្នាក់_ស្មើរ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទើសទាក់, ស្មើរដំណើរ, រារែក ។ បរិវារស័ព្ទ ស្មើរ អាចគន្លាស់បានជាពាក្យ ស្មើររារែកមួយអន្ទាក់ គឺ ស្នាក់រារែកមួយអន្ទើ ។

ស្នាត់_ស្នាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ទាត់ជំនាញ, ស្ទាត់ណាស់ ។ បរិវារស័ព្ទ ស្នាញ អាចគន្លាស់បានជាពាក្យ ស្នាញជំនាត់ គឺ ស្នាត់ជំនាញ ។

**ស្មុះ_ស្មា.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្មុះឆ្លាចុះឆ្លាឡើង, ចច្រេសចច្រាស ។ បរិវារស័ព្ទ ស្មា អាចគន្លាស់បានជាពាក្យ ស្មាឆ្លាចុះឆ្លាឡើងដោយម្មាម្មុះ គឺ ស្មុះឆ្លាចុះឆ្លាឡើងដោយម្មីម្មា ។

**ស្និទ្ធ_ស្នាល.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលជាទីរាប់អានពេញចិត្ត, ស្និទ្ធជិតដិតនឹងគ្នា ។ មិត្តស្និទ្ធស្នាល ។ល។ បរិវារស័ព្ទ ស្នាល អាចគន្លាស់បានជាពាក្យ ស្នាលជាឪរិត គឺ ស្និទ្ធិជាឪរ៉ាល ពោលគឺ រាប់អានគ្នាដ៏ជិតស្និទ្ធធម្មតា ។

**ស្នេហ៍_ស្នង.**- ពាក្យនេះ បានសេចក្ដីថា ÷ សេចក្ដីស្រឡាញ់ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្នង អាចគន្លាស់បានជាពាក្យ ស្នងនៃមាសបែ គឺ ស្នេហ៍នៃមាសបង ។

**ស្នេហ៍_ស្និទ្ធ.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្នេហាស៊ប់ចិត្ត, ស្រឡាញ់ស្និទ្ធល្អិតល្អួតជាប់ចិត្តនឹកជានិច្ច ។ល។ បរិវារស័ព្ទ ស្និទ្ធ អាចគន្លាស់បានជាពាក្យ ស្និទ្ធដោយស្រឡាញ់ស៊ប់ជាប់ថៃ គឺ ស្នេហ៍ដោយស្រឡាញ់ស៊ប់ជាប់ចិត្ត ។

**ស្នេហ៍_ស្នូក.**- ពាក្យនេះ មានអត្ថន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យ

ស្នេហ៍ស្និទ្ធ ។ បរិវារស័ព្ទ ស្នក អាចគន្លាស់បានជាពាក្យ ស្នូក ដោយស្រឡាញ់ចៃ គឺ ស្នេហ៍ដោយស្រឡាញ់ជោក ។

ស្នេហ៍_ស្នំ.- ពាក្យនេះមានន័យ ប្រហាក់ប្រហែលគ្នានឹងពាក្យស្នេហ៍ស្និទ្ធ ពោលគឺ សម្រាប់និយាយចំពោះសេចក្ដីស្រឡាញ់មកលើរូបខ្លួនឯង ។ បរិវារស័ព្ទ ស្នំ អាចគន្លាស់បានជាពាក្យ ស្នំមកលើរូបខ្ញុំ គឺ ស្នេហ៍មកលើរូបខ្ញុំ ។

ស្នេហា_ស្នេហ៍ហឹត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រឡាញ់ជាប់ចិត្តល្អិតល្អួត ។ ពាក្យនេះ ជាគ្រាមភាសាដែលអ្នកស្រុកច្រើនមានទម្លាប់យកមកនិយាយលេងជាធម្មតា ។ បរិវារស័ព្ទ ស្នេហ៍ហឹត អាចគន្លាស់បានជាពាក្យ ស្នេហ៍-ហឹតដោយជាប់ទាក់ទងសម្ព័ន្ធគ្នារអា គឺ ស្នេហាដោយជាប់ទាក់ទងនឹងគ្នារអឹត ។

ស្បថ_ស្បែ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ពាក្យសច្ចាប្រកាសសេចក្ដីពិតត្រង់ ។ បរិវារស័ព្ទ ស្បែ អាចគន្លាស់បានជាពាក្យ ស្បែដោយពាក្យសច្ចាប្រកាសថាមិនកត់ គឺ ស្បថដោយពាក្យសច្ចាប្រកាសថាមិនកែ ។

ស្ញ៉ែត្រ_ស្ញ៉ាន.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ញ៉ែត្រចិត្ត ស្មើគ្នា. ស្រុះចិត្តគ្នា. ស្ញ៉ែត្រអស់ពីចិត្ត ។ល។ បរិវារស័ព្ទ ស្ញ៉ាន អាចគន្លាស់បានជាពាក្យ ស្ញ៉ានដោយសាម៉ាក់ គឺ ស្ញ៉ែត្រ ដោយសមាន ។ (សមាន = ស្មើគ្នា) ។

ស្ញឹង_ស្ញាធិ៍.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សម្រឹងធ្មឹង ស្ញឹងឥតកម្រើកដោយការភាវនារំពឹងក្នុងចិត្ត (មានអាការដូច រូបស្លាប់) ។ បរិវារស័ព្ទ ស្ញឹង អាចគន្លាស់បានជាពាក្យ ស្ញឹង ធ្មឹងដូចបាត់ព្រលឹង គឺ ស្ញាធិ៍ដូចបាត់ព្រលឹង ។

ស្ញុក_ស្ញាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ញាញចាក់ ស្រែះ. ស្ញាញចាក់ស្ញុគ ។ រឿងស្ញុកស្ញាញ ។ល។ បរិវារ-ស័ព្ទ ស្ញុក អាចគន្លាស់បានជាពាក្យ ស្ញុកចាក់ស្រែះដូចសម្បាញ គឺ ស្ញាញចាក់ស្រែះដូចសំបុក ។

ស្ញួញ_ស្ញាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្គួញ ស្កាញ. ដែលចាក់ស្រែះជិត ។ រោមស្ញួញស្ញាញ ។ល។ បរិ-វារស័ព្ទ ស្ញាញ អាចគន្លាស់បានជាពាក្យ ស្ញាញចាក់ស្រែះ ស្កាញស្គួញ គឺ ស្ញួញចាក់ស្រែះស្គួញស្កាញ ។

ស្មៀន_ស្មៀ.- ស្មេរជាពាក្យខ្មែរបុរាណមានន័យថា ÷ ស្មៀនជំនួយ អ្នកសរសេរដែលបារាំងហៅថា ÷ កូពីស្ត (Copiste) បរិវា-ស័ព្ទ ស្មេរ អាចគន្លាស់បានជាពាក្យ ស្មេរអ្នកសរសៀន គឺ ស្មៀនអ្នកសរសេរ ។ ពាក្យស្មេរនេះ សូមមើលបទានុក្រមរាមកេរ្តិ៍ ទំព័រ ៦៦ អធិប្បាយពន្យល់ដោយព្រះមហាពិទូរក្រសេម. សូមមើលសាស្ត្រាក្រុងសុភមិត្រតែងជាពាក្យកាព្យ ដោយលោក ឧកញ៉ាកោសាធិបតីកៅទំព័រ១៤២ និង សាស្ត្រាសុបិនកុមារទំព័រ ១៨ និពន្ធដោយកវីសម័យបុរាណម្នាក់ ដោយពុំមានអ្នកផង ស្គាល់ឈ្មោះ ។

ស្មៅ_ព្រៅ.-ពាក្យនេះ ខ្មែរយើងច្រើននិយាយបង្គាប់ឱ្យក្មេងក្មាង ក្នុងផ្ទះដូចជាពាក្យថា ÷ មើលបោចស្មៅព្រៅឱ្យអស់ចេញ កុំទុកឱ្យនៅឧបទ្រព្យច្រើនពេក ។ល។ បើតាមការសង្កេត ពាក្យស្មៅព្រៅ ដែលខ្មែរយើងបានពោល ដូចជូនជាឧទាហរណ៍ខាងលើ នេះឃើញថា ÷ គេនិយាយសំដៅទៅត្រង់ ស្មៅដែលមានដុះនៅក្នុងភូមិឬក្នុងទីលំនៅ ។ ដូច្នេះបរិវារស័ព្ទ ព្រៅ អាចយោលទៅបានជាពាក្យ គន្លាស់មួយថា ÷ ព្រៅទីលំណប គឺ ប្របទីលំនៅ ពោលគឺ ស្មៅដែលដុះនៅប្របទីលំនៅ ។

ស្រកេក_ស្រកាក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រកាកប្រតេកប្រតាក, ស្រកាកក្រៃពេក ។ បរិវារស័ព្ទ ស្រកេក អាចគន្លាស់បានជាពាក្យ ស្រកេកប្រតេកប្រតាកក្រៃប៉ាក គឺ ស្រកាកប្រតេកប្រតាកក្រៃពេក ។

ស្រគត់_ស្រគំ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលសង្រួមឥន្ទ្រិយរមទម នឹងនួនស្ងប់ស្ងៀម ។ បរិវារស័ព្ទ ស្រគំ អាចគន្លាស់បានជាពាក្យ ស្រគំនឹងនួនរមទត់ គឺ ស្រគត់នឹងនួនរមទម ។

ស្រងូត_ស្រងាត់.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្រងូតស្ងៀមស្ងាត់, សញ្ចប់សញ្ជឹងគួរឱ្យអាណិត ។ បរិវារស័ព្ទ ស្រងាត់ អាចគន្លាស់បានជាពាក្យ ស្រងាត់ស្ងៀមស្ងូត គឺ ស្រងូតស្ងៀមស្ងាត់ ។

ស្រណេះ_ស្រណោច.-តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរ មានន័យថា ÷ នឹកភ្នកស្រណោះដល់ពេលដែលនឹកឃើញ, ធ្លាប់ទៅមកពីដើម ឬនឹកភ្នកដល់រឿងហេតុ ដែលធ្លាប់ដឹងពីមុនយូរហើយ ។ល។ បរិវារស័ព្ទ ស្រណោច អាចគន្លាស់បានជា

ពាក្យ ស្រងោចទឹកភ្នែកស្រណោះលន្លៃងលន្លោះ គឺ ស្រងេះទឹកភ្នែក ស្រណោះដោយចិត្តលន្លង់លន្លោច ។

ស្រពេច_ស្រពិល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិនជាក់លាក់, មិនប្រាកដប្រជា, របាក់របៀង ។ល។ ដំណឹងស្រពេចស្រពិល ។ល។ បរិវារស័ព្ទ ស្រពេច អាចគន្លាស់បានជាពាក្យ ស្រពេចពុំប្រាកដព្រោះច្រើនភ្លឹល គឺ ស្រ-ពិលពុំប្រាកដព្រោះច្រើនភ្លេច ។

ស្រពោន_ស្រពាប់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្ងួញ, ស្រពោនក្រៀមក្រំ, ស្រពោនជ្រប់ ។ មុខស្រពោនស្រពាប់ ។ល។ បរិវារស័ព្ទ ស្រពាប់ អាចគន្លាស់បានជាពាក្យ ស្រពាប់ក្រៀមក្រំខ្លួន គឺ ស្រពោនក្រៀមក្រំខ្លួប ។

ស្រមូញ_ស្រមាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្កួញស្កាញ, ស្ជួញស្ជាញ ។ល។ សូមមើលពាក្យស្ជួញស្ជាញ ។

ស្រមូម_ស្រមាម.-តាមវចនានុក្រម ពាក្យនេះ មានន័យចំបាំងពីរ មានន័យថា ÷ ស្រមូមមិនរាបទាប, មិនស្អាត, ស្រមេរស្រមូរ ពុកមាត់ស្រមូមស្រមាម ។ល។ បរិវារស័ព្ទ ស្រមាម អាច

គន្លាស់បានជាពាក្យ ស្រមាមចាក់ស្រែះដូចជើងក្អម គឺ ស្រមូម ចាក់ស្រែះដូចជើងក្ដាម ។

ស្រមេក_ស្រមក.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលប្រឡាក់កខ្វក់, ស្រមកក្រែពេក ។ ប្រឡាក់ស្រមេកស្រមក ។ល។ បរិវារស័ព្ទ ស្រមេក អាចគន្លាស់បានជាពាក្យ ស្រមេកប្រឡាក់កខ្វក់ក្រែប៉ក គឺ ស្រមកប្រឡាក់កខ្វក់ក្រៃពេក ។

ស្រមេវ_ស្រមូវ.- ដែលមានរោមវែងច្រើន, ស្រមូវក្រៃពេក ។ រោមស្រមេវស្រមូវ គឺ រោមក្រញេវក្រញូវ ។ បរិវារស័ព្ទ ស្រមេវ អាចគន្លាស់បានជាពាក្យ ស្រមេវច្រើនក្រញេវក្រញូវ គឺ ស្រមូវច្រើនក្រញូវក្រញេវ ។

ស្រស់_ស្រាយ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រាក់ទាក់រីករាយ ។ សម្ដីស្រស់ស្រាយ គឺ សម្ដីផ្អែមអន្លាយ ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្រាយ អាចគន្លាស់បានជាពាក្យ ស្រាយរីករាយដោយសម្ដីផ្អែមអន្លស់ គឺ ស្រសរីករាយដោយសម្ដីផ្អែមអន្លាយ ពោលគឺ រាក់ទាក់រីករាយដោយសម្ដីផ្អែមល្ហែម ។

ស្រស់_ស្រូប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បរិភោគអាហារបន្តិចបន្តួចនៅពេលព្រឹក ឬ ដោយសម្រន់ ។ តាមសេចក្តីនិយមនៃអ្នកស្រុក ពាក្យស្រស់ស្រូបបានសេចក្តីថា បរិភោគ។ បរិវារស័ព្ទ ស្រូប អាចគន្លាស់បានជាពាក្យ ស្រូបសម្រន់ដោយហាស់ គឺ ស្រស់សម្រន់ដោយហូប ពោល គឺ ហូបអាហារ ឬ បរិភោគអាហារសម្រន់ ។

ស្រឡេត_ស្រឡះ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលឥតមានអ្វីទើសទែង ឬ បិទបាំងឡើយ ។ មុខមាត់ស្រឡេតស្រឡះ, ភ្នែកស្រឡេតស្រឡះ ។ល។ បរិវារស័ព្ទ ស្រឡេត អាចគន្លាស់បានជាពាក្យ ស្រឡេតដោយគ្មានហះ គឺ ស្រឡះដោយគ្មានហេតុ ។

ស្រាក_ស្រន់.- តាមវចនានុក្រម ពាក្យនេះ បានសេចក្តីថា ÷ ស្រាកដោយបានអន់, ធូរស្បើយ ។ល។ ស្រាកស្រន់អន់ឈឺ, ភ្លៀងឥតស្រាកស្រន់ ។ បរិវារស័ព្ទ ស្រន់ អាចគន្លាស់បានជាពាក្យ ស្រន់បានអាក់ គឺ ស្រាកបានអន់ ។

ស្រាក_ស្រាន្ត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ ដែល-

អន់លំបាក, អន់នឿយហត់, អន់អស់កម្លាំង ។ល។ ស្រាក-ស្រាន្តអន់អស់កម្លាំង, អន់ឈឺ ។ល។ ច្រើននិយាយតែពីអាការជម្ងឺ ។ បរិវារស័ព្ទ ស្រាក អាចគន្លាស់បានជាពាក្យ ស្រាកអន់លំបាន គឺ ស្រាន្តអន់លំបាក ។

ស្រាក_ស្រាល.- តាមវចនានុក្រម ពាក្យនេះ បានសេចក្ដីថា ÷ ស្រាកអន់មានទម្ងន់ដូចពីមុន, បានធូរស្រាលគ្រាន់បើជាងមុន ។ បរិវារស័ព្ទ ស្រាល អាចគន្លាស់បានជាពាក្យ ស្រាលដោយពុំមានហេតុនាំឱ្យឈឺក្បាក គឺ ស្រាកដោយពុំមានហេតុនាំឱ្យឈឺក្បាល ។

ស្រុះ_ស្រួល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ យល់ព្រមជាមួយគ្នាឥតទទឹងទាស់ ។ល។ បរិវារស័ព្ទ ស្រុះ អាចគន្លាស់បានជាពាក្យ ស្រុះដោយត្រូវរ៉ូវគ្នាពុំមានខូល គឺ ស្រួលដោយត្រូវរ៉ូវគ្នាពុំមានខុស ។

ស្រួច_ស្រាល់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មោះមុត, មែនមាំ, រហ័សរហួន, ឥតទើសទាក់ ។ ប្រាជ្ញាស្រួចស្រាល់, ចំណេះស្រួចស្រាល់ ។ ពាក្យនេះច្រើនប្រើក្នុងពាក្យ.

កាព្យ ។ បរិវារស័ព្ទ ស្រាល់ អាចគន្លាស់បានជាពាក្យ ស្រាល់ ដោយមុះមុតល្អឆើតត្រកូច គឺ ស្រួចដោយមោះមុតល្អឆើតត្រកាល។

ស្រួយ_ស្រិប.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលស្រួយខ្លាំង. ស្រួយទំពាឬប្រិប១ ។ បរិវារស័ព្ទ ស្រិប អាចគន្លាស់បានជាពាក្យ ស្រិបងាយបាក់បែកប្រួយ១ គឺ ស្រួយងាយបាក់បែកប្រិប១ ។

ស្រួយ_ស្រោក.- តាមវចនានុក្រម បានសេចក្ដីថា ÷ ស្រួយខ្លាំងងាយកាច់. ងាយច្របាច់ ។ បរិវារស័ព្ទ ស្រោក អាចគន្លាស់បានជាពាក្យ ស្រោកខ្ចួយ គឺ ស្រួយខ្ទោក ។

ស្រួល_ស្រេច.- តាមវចនានុក្រម ពាក្យនេះ មានន័យចំបាទាំងពីរបានសេចក្ដីថា ÷ ស្រេចដោយស្រួលស្រេចបាច់ ។ ពាក្យនេះច្រើនប្រើក្នុងពាក្យកាព្យ។ បរិវារស័ព្ទ ស្រួល អាចគន្លាស់បានជាពាក្យ ស្រួលដោយស្រួលបាច់ គឺ ស្រេចដោយស្រួលបួល ។

ស្រើប_ស្រាល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ កើតតម្រេកទៅរកកាម ( កាម=សេចក្ដីប្រាថ្នា.ចំណង់. ទ្រព្យសម្បត្តិ

និងកិលេសដែលសត្វតែងប្រាថ្នា) ។ ត្រេកត្រអាលឬត្រេកត្រ-អាលភ្លេចខ្លួន ។ ចាស់ហើយ នៅតែស្រើបស្រាលដូចក្មេង ។ល។ បរិវារស័ព្ទ ស្រាល អាចគន្លាស់បានជាពាក្យ ស្រាល ដោយត្រេកត្រអើប គឺ ស្រើបដោយត្រេកត្រអាល ។

ស្រៀវ_ស្រស់.- តាមវចនានុក្រម បានសេចក្ដីថា ÷ ស្រស់តូចរាវល្អប្រពៃ ស្រស់តូចស្ដៀវ, ខ្ពស់ស្រឡះសមរម្យ ។ រាងស្រស់ស្រៀវ, រូបឆោមស្រស់ស្រៀវ ។ល។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្រៀវ អាចគន្លាស់បានជាពាក្យ ស្រៀវតូចស្ដស់ គឺ ស្រស់តូចស្ដៀវ ។

ស្រៀវ_ស្រាញ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ព្រឺខ្លួនខ្វាក១សង្កើសង្កាញដូចរកកល់គ្រុន ។ បរិវារស័ព្ទ ស្រាញ អាចគន្លាស់បានជាពាក្យ ស្រាញព្រឺខ្លួនសង្កើសង្កៀវ គឺ ស្រៀវព្រឺ-ខ្លួនសង្កើសង្កាញ់ ។

ស្រេច_ស្រាប.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ មាន-គ្រប់សព្វ។ បរិវារស័ព្ទ ស្រាប អាចគន្លាស់បានជាពាក្យ ស្រាប ដោយមានគ្រប់ប្រដេច គឺ ស្រេចដោយមានគ្រប់ប្រដាប់។

ស្ល_ស្លុក.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធ្វើសម្ល ។ល។ សូមមើលពាក្យ សម្លសម្លុក ។

ស្លន់_ស្លោ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ភាន់ស្មារតីដោយភ័យខ្លាំង ។ ស្លន់ធ្វើភ្នែកស្លោ ឬ ស្លន់ឆោឡោ ។ បរិវារស័ព្ទ ស្លោ អាចគន្លាស់បានជាពាក្យ ស្លោឆោឡន់ គឺ ស្លន់-ឆោឡោ ។

ស្លឹក_ស្លក់.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ប៉ផ្តឹតប៉ផ្តក់. ត្រដាបត្រដួស។ មុខភ័យស្លឹតស្លក់។ បរិវារស័ព្ទ ស្លក់ អាចគន្លាស់បានជាពាក្យ ស្លក់ប៉ផ្តក់ប៉ផ្តឹត គឺ ស្លឹតប៉ផ្តឹតប៉ផ្តក់។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ស្លើតស្លក់ ឬ ស្លែតស្លក់វិញ ។ល។

ពាក្យទាំងនេះ សូមមេត្តាយោលទៅសម្លេងខ្មែរយើងនៅ-សម័យបុរាណ ដែលមានសម្តីនិយាយវជីនជាងខ្មែរយើងសព្វថ្ងៃនេះ ។

ស្លែក_ស្លាំង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្លេកឡើងសម្បុរស្បែកហាប់ខ្លាំង. ស្លាំងពេកគ្មានឈាម ។ សាច់ស្លេក-

ស្ទាំង។ល។ បរិវារស័ព្ទ ស្លេក អាចគន្លាស់បានជាពាក្យ ស្លេកបាំង គឺ ស្លាំងពេក ។

ស្វាង្គ-ស្វាង្គា.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ ស្វាង្គ និង ស្វាង្គា បានសេចក្ដីថា : ដែលមានរូបឆោមល្អ. ប្រពៃ. សមរម្យ. បើស្រីជាស្វាង្គា។ ច្រើនប្រើក្នុងពាក្យកាព្យ ដូចខ្ញុំដកស្រង់ជូនដូចតទៅនេះ ពីក្នុងវចនានុក្រម ទំព័រ១៤៩៧។

ស្វាង្គស្វាង្គា ស្វាមីភរិយា មានភ័ព្វបវរ តាំងពីចាប់ដៃ ជាគូស្រករ មានចិត្តត្រេកអរ ចំពោះបុណ្យទាន។ល។ បរិវារស័ព្ទ ស្វាង្គា អាចគន្លាស់បានជាពាក្យ ស្វាង្គាដោយមានរូបឆោមល្អប្រពៃសមគួស្វាមីភរិយាង គឺ ស្វាងដោយមានរូបឆោមល្អប្រពៃសមគួស្វាមីភរិយា ។

ស្វាត-ស្វែង.- ពាក្យនេះ បានសេចក្ដីថា : ស្វែងដោយព្យាយាមឱ្យបានដូចបំណង។ បរិវារស័ព្ទ ស្វាត អាចគន្លាស់បានជាពាក្យ ស្វាតរកបានដោយឥតមានខែង គឺ ស្វែងរកបានដោយឥតមានខាត ពោលគឺ ស្វាតស្វែងព្យាយាមរកបានដោយពុំមានខាតប្រយោជន៍. បង់កម្លាំងច្រើន ។ល។

ស្ងិត_ស្ងាញ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ កំណាញ់ ស្វិតល្អិតល្អួតមិនងាយនឹងចាយទ្រព្យ. កំណាញ់ក្រៅតម្រា ។ កំណាញ់ស្វិតស្វាញ ។ បរិវារស័ព្ទ ស្វាញ អាចគន្លាស់បានជាពាក្យ ស្វាញ ល្អិតល្អួតដោយកំណើត គឺ ស្វិតល្អិតល្អួតដោយកំណាញ់ ។

ស្ងិត_ស្ងាយ.- ពាក្យនេះខ្មែរយើង ច្រើនប្រើហៅអ្នកដែលមានសាច់គង់. ស្វិតមិនងាយរបួសឬមុតដោយអាវុធ ។ល។ ជនសាច់គង់ស្វិតស្វាយ ។ បរិវារស័ព្ទ ស្វាយ អាចគន្លាស់បានជាពាក្យ ស្វាយរូបក្តិអន្តិរត គឺ ស្វិតរូបក្តិអន្តរាយ ។

ស្វែត_ស្វិត.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ធូរខ្លាំង. ធូរស្លែតឬធូរស្លុត ។ ក្រារុងអង្ករធូរស្វែតស្វិត. សម្តីធូរស្វែតស្វិត ។ល។ បរិវារស័ព្ទ ស្វែត អាចគន្លាស់បានជាពាក្យ ស្វែតដោយធូរស្លុត គឺ ស្វិតដោយធូរស្លែត ។

ស្វះ_ស្វែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្វះពន្លះរក. សង្វាតរក. ខំប្រឹងរកឱ្យបានដូចបំណង ។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្វះ អាចគន្លាស់បានជាពាក្យ ស្វះសង្វាតដោយចិត្តពន្លែង គឺ ស្វែងសង្វាតដោយចិត្តពន្លះ ។

(ពន្លះ=ដាច់ចិត្ត, ក្លាហាន ។ល។) ពោលគឺ លះកិច្ចការឯ-ទៀតហើយ ខំប្រឹងសង្វាតស្វែងរក ឱ្យទាល់តែបានដូចបំណង មិនគិតថាទីឆ្ងាយ ឬជាកន្លែងលំបាកដោយអាសន្នអន់ក្រក្តី ។

**ស្អាង_ស្អាត.**- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរបាន សេចក្តីថា ÷ តាក់តែង, គ្រឿងប្រដាប់ឱ្យស្អាតល្អ, តាក់តែង ដោយគ្រឿងសំអាង។ បរិវារស័ព្ទ ស្អាង អាចគន្លាស់បានជាពាក្យ ស្អាងល្អសមតាមគ្រឿងសំអាត គឺ ស្អាតល្អសមតាម គ្រឿងសំអាង ។

**ស្អាត_ស្អាន.**- ស្អាតប្រពៃ, ស្អាតបាត ។ ស្អាតស្អាតស្រួល កល្យាណ ។ល។ ច្រើនប្រើក្នុងពាក្យកាព្យ ។ បរិវារស័ព្ទ ស្អាន អាចគន្លាស់បានជាពាក្យ ស្អានដោយល្អសមជាកល្យាត គឺ ស្អាតដោយល្អសមជាកល្យាណ។ (កល្យាណ=ដែលមាន លំអ, ដែលត្រឹមត្រូវគួរសេពគប់) ។

**ស្អាត_ស្អំ.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្អាតសម រម្យ, ស្អាតមិនទាស់ភ្នែក។ កន្លែងស្អាតស្អំ, ធ្វើការស្អាតស្អំ ។ បរិវារស័ព្ទ ស្អំ អាចគន្លាស់បានជាពាក្យ ស្អំសមរ៉ាត គឺ ស្អាត

សមរម្យ ឬស្អំមិនបាច់ខាត គឺ ស្អាតមិនបាច់ខំ ពោលគឺ ស្អាត ដោយធម្មតាជាអចិន្ត្រៃយ៍ ។

ស្អិត_ស្អាង.– តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្អាង ដោយប្រពៃ, ស្អាងដោយផ្ចិតផ្ចង់អស់ពីចិត្ត។ ស្អិតស្អាងខ្លួនប្រាណ ។ សូមមើលពាក្យ សម្អិតសម្អាង ។

ស្អុយ_ស្អុះ.– តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលមានក្លិនអសោចិ៍ អ្នកផងមិនត្រូវការ, មិនរវល់ ។ កេរ្តិ៍ឈ្មោះស្អុយស្អុះ គឺ កេរ្តិ៍ឈ្មោះអាក្រក់អ្នកផងមិនរាប់រក។ បរិវារស័ព្ទ ស្អុះ អាចគន្លាស់បានជាពាក្យ ស្អុះដោយមានកេរ្តិ៍ឈ្មោះគេបង្អាប់បន្ថុយ គឺ ស្អុយដោយមានកេរ្តិ៍ឈ្មោះគេបង្អាប់បន្ថុះ ។

ស្អុះ_ស្អាប់.– តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ស្អុះព្រោះអូអាប់។ បរិវារស័ព្ទ ស្អាប់ អាចគន្លាស់បានជាពាក្យ ស្អាប់ព្រោះអូអុះ គឺ ស្អុះព្រោះអូអាប់ ។

* *
*

# ហ

ហាម_ប្រាម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឃាត់យ៉ាងតឹងតែង។ ឃាត់ដោយមានបម្រាម។ បរិវារស័ព្ទ ប្រាម អាចគន្លាស់បានជាពាក្យ ប្រាមដោយមានបម្រាប គឺ ប្រាបដោយមានបម្រាម ។

ហិច_ហក់.- តាមវចនានុក្រម ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យបាន សេចក្ដីថា ÷ ហកភ្លែតចុះភ្លែតឡើង។ បរិវារស័ព្ទ ហិច អាចគន្លាស់បានជាពាក្យ ហិចចុះឡើងផ្លក់ៗ គឺ ហក់ចុះឡើងផ្លេកៗ ពោលគឺ ហិចហក់ភ្លែតចុះភ្លែតឡើង ។

ហិច_ហើរ.-តាមវចនានុក្រម ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យបាន សេចក្ដីថា÷ ហើរឆ្វាត់ឆ្វៀលខ្ពស់ៗទាបៗ ។ បរិវារស័ព្ទ ហិច

អាចគន្លាស់បានជាពាក្យ ហិចខ្ពស់ទាបផ្ញើៗ គឺ ហើរខ្ពស់ទាបផ្ងេកៗពោល គឺ ហិចហើរ ខ្ពស់ទាបភ្លែតចុះភ្លែតឡើង ។

ហិច_ហោះ.- តាមវចនានុក្រម ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ បានសេចក្ដីថា ÷ ហោះឆ្វៀលឆ្វាត់សន្ទឹមៗ, ហោះភ្លែតចុះភ្លែតឡើង។ បរិវារស័ព្ទ ហិច អាចគន្លាស់បានជាពាក្យ ហិច ឆ្វៀលឆ្វាត់ផ្ដោះៗ គឺ ហោះឆ្វៀលឆ្វាត់ផ្ងេកៗ ពោលគឺ ហិចហោះឆ្វៀលឆ្វាត់ភ្លែតចុះភ្លែតឡើង ។

ហីន_ហោច.- តាមវចនានុក្រម ពាក្យនេះ មានន័យចំហទាំងពីរគឺ ហីននិងហោច ពោលគឺ ហីននាំឱ្យហោចឬឱ្យសូន្យ ។ល ។ បរិវារស័ព្ទ ហោច អាចគន្លាស់បានជាពាក្យ ហោចឱ្យរលីងសូន្យដូចខ្ចិន គឺ ហីនឱ្យរលីងសូន្យដូចខ្មោច ។

ហុយ_ហាយ.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សាយភាយលេចឮសុសសព្ទ។ ដំណឹងនេះហុយហាយសព្វទិសទីអស់ទៅហើយ។ បរិវារស័ព្ទ ហាយ អាចគន្លាស់បានជាពាក្យ ហាយលេចឮសាយសុយ គឺ ហុយលេចឮសុសសាយ ។

ហួង_ហែង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រក្សាគ្រប់គ្រង, ថែទាំងដោយមានគំនិតអត្តទត្តភាព គឺ ដោយមានគំនិត-

គិតកេងតែខ្លួន។ ហួងហែងសម្បត្តិទ្រព្យ។ បរិវារស័ព្ទ ហែង អាចគន្លាស់បានជាពាក្យ ហែងសម្បត្តិទុកសម្រាប់តែខ្លួនអួង គឺ ហួងសម្បត្តិទុកសម្រាប់តែខ្លួនឯង ។

ហៀវ_ហោះ.- តាមវចនានុក្រម ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ ហើយមានន័យថា ÷ ហោះលឿងល្បៀវ, ហោះផ្លែកផ្លោះច្រៀវ-ច្រៃ។ យក្សហៀវហោះ។ បរិវារស័ព្ទ ហៀវ អាចគន្លាស់បានជាពាក្យ ហៀវដោយល្បឿនលឿនប្លោះ គឺ ហោះដោយ-ល្បឿនលឿនល្បៀវ ។

ហេល_ហល ឬ ហែល_ហល.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលចេះតែមិនស្រួលតឹងពោះព្រោះបរិភោគអាហារច្រើនបណ្ដាលឱ្យធាតុខ្យល់ធាក់ច្រាលឡើង។ បរិវារស័ព្ទ ហែល អាចគន្លាស់បានជាពាក្យ ហែលដោយតឹងពោះព្រោះ-អាហារច្រើនក្រៃល គឺ ហលដោយតឹងពោះព្រោះអាហារច្រើនក្រៃល ។

ហែ_ហម.- តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ ហែអបអម-ហែចោមរោម ។ ហែហមចោមរោមជាបរិវារ ។ បរិវារស័ព្ទ-

ហាមអាចគន្លាស់បានជាពាក្យ ហាមចោមរោមដោយបរិវារអបអែ គឺ ហែចោមរោមដោយបរិវារអបអម ។

ហៅ_ហាន.- តាមវចនានុក្រម ពាក្យនេះ ច្រើនប្រើក្នុងពាក្យកាព្យ មានន័យថា ÷ ក្លាហានខ្លាំង, មោះមុត ។ ល ។ ចិត្តហៅហាន ។ បរិវារស័ព្ទ ហៅ អាចគន្លាស់បានជាពាក្យ ហៅដោយចិត្តស្លុយមោះមុតចូលស្ពាន គឺ ហានដោយចិត្តស្លុយមោះមុតចូលស្ពៅ ពោលគឺ ចិត្តក្លាហានមោះមុតហ៊ានចូលស្ពៅទៅឈមមុខ ។ល។

ហ្មប_ហ្មាយ.- អង្គុយហ្មប គឺ អង្គុយបត់ជើងផ្តេកខ្លួនទៅមុខ ដោយគោរព ដើម្បីគាល់ព្រះមហាក្សត្រ។ ខ្ញុំមិនចេះហ្មបហ្មាយអ្វីនឹងគេទេ។ បរិវារស័ព្ទ ហ្មាយ អាចគន្លាស់បានជាពាក្យ ហ្មាយដោយអង្គុយគាល់ថ្វប គឺ ហ្មបដោយអង្គុយគាល់ថ្វាយ ពោលគឺ អង្គុយគាល់ចាំបម្រើ ។

ហ្វូង_ហ្វាយ.- តាមវចនានុក្រម បានសេចក្តីថា ÷ ពួកដោយឡែកៗពីគ្នា។ បរិវារស័ព្ទ ហ្វាយ អាចគន្លាស់បានជាពាក្យ ហ្វាយដែលមាននាយចៅហ្វូង គឺ ហ្វូងដែលមាននាយចៅហ្វាយ ។

**ហ៊ត_ហោង.-** តាមវចនានុក្រម មានន័យថា ÷ ដែលស្ទាត់គួរឱ្យខ្លាច ។ល។ បរិវារស័ព្ទ ហ៊ត អាចគន្លាស់បានជាពាក្យ ហ៊តស្ទោង គឺ ហោងស្ទាត់ ។

**ហេះ_ហ៏ឬហែះ_ហ៏.-** តាមវចនានុក្រម បានសេចក្ដីថា ÷ សូរបន្លឺសម្លេងក្នុងវេលាធ្វើការ ។ល។ ជនហេះហ៏ គឺ ជនមានតែសម្ដីដោយពុំមានជួយជាកម្លាំងកាយក្នុងវេលាធ្វើការអ្វីនិមួយ ។ល។ បើលើកសែងនឹងគេមិនកើត គ្រាន់តែជួយហេះហ៏ក៏បានហើយ បរិវារស័ព្ទ ហ៏ អាចគន្លាស់បានជាពាក្យ ហ៏តែសម្ដីឡេះៗ គឺ ហេះតែសម្ដីឡូៗ ពោលគឺ មានតែសម្ដីមាត់កឡូៗប៉ុណ្ណោះ ពុំឃើញជួយបានការអ្វីជាមាំទាំ ។

* *

*

# ឡ

**ឡក-ឡាយ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ និយាយឡកដោយពាក្យលែបខាយ ។ និយាយឡកឡាយឱ្យដឹងខ្លួន ។ បរិវារស័ព្ទ ឡាយ អាចគន្លាស់បានជាពាក្យ ឡាយជាពាក្យលែបខក គឺ ឡកជាពាក្យលែបខាយ ។

**ឡក-ឡឺយ.-** និយាយដៀងដងជាពាក្យបន្លើយ ។ វាចេះតែនិយាយឡកឡឺយឱ្យខ្ញុំ។ល។ បរិវារស័ព្ទ ឡឺយ អាចគន្លាស់បានជាពាក្យ ឡឺយដោយសម្ដីបន្លក គឺ ឡកដោយសម្ដីបន្លើយ ។

**ឡាយ-ឡុង.-** វចនានុក្រមថា ពាក្យនេះ ក្លាយមកពីសៀមលេហ្លីង (លើហ្លីង) បានសេចក្ដីថា ÷ លក់របស់ដោយបើកឱកាសឱ្យ

អ្នកទិញដេញថ្លៃគ្នា អ្នកណាហ៊ានថ្លៃជាងគេ. របស់នោះបាន ទៅអ្នកនោះ។ តាមលោក សឺដេស (Cœdès) វិញក្នុងសៀវភៅភាសាខ្មែរ ក្លាយមកពីភាសាព័រទុយគ្គេ ក្នុងទស្សនាវដ្ដីវិជ្ជាស្ថាននៃប្រទេសឥណ្ឌូចិន ផ្នែកមនុស្សលោក ភាគទី៣ ឆ្នាំ ១៩៤០ ទំព័រ ៦៨ (Mots portugais passés en Cambodgien par Monsieur Cœdès. B.I.I.E.H., ១៩៤០។ tom 3, F.1.page 68.) ពាក្យឡាយឡុងនេះ ខ្មែរយើងបានខ្ចីមកពីពាក្យ ព័រទុយគ្គេ (Leilao ឡីឡាវ) ដូច្នេះពាក្យឡាយឡុងនេះ គឺ ជាពាក្យតែមួយគ្មានបរិវារស័ព្ទទេ ។

បើតាមពិតទៅពាក្យសៀម លេហ្លឹង (លេំហ្លំ ័ង) និងពាក្យខ្មែរឡាយឡុងទាំងពីរម៉ាត់នេះ សុទ្ធសឹងជាពាក្យ ក្លាយមកពីពាក្យ ព័រទុយគ្គេ ឡីឡាវ (Leilao) ទាំងអស់ព្រោះនៅក្នុងសតវត្ស ទី ១៦-១៧ មានជនជាតិ ព័រទុយគ្គេជាច្រើនបានចូលមករស់នៅ, ប្រកបវិជ្ជាជីវក្នុងប្រទេសភូមា, សៀម, ខ្មែរនិងយួន ដែលគេបានសង្កេតឃើញជាអាទិ៍ ពួកលោក

សង្ឃ កាតូលិក ទាហាន និងអ្នកជិនួញ ។

ឡុង-ឡៃ.- ជាប់ដៃ, ជាប់ចិត្តឬលង់គំនិត ។ ក្មេងនេះឃើញជាប់ឡុងឡៃនឹងស្រីផ្សារ ។ល។ បរិវារស័ព្ទ ឡៃ អាចគន្លាស់បានជាពាក្យ ឡៃព្រោះជាប់ដុង គឺ ឡុងព្រោះជាប់ដៃ ឬ ឡៃព្រោះនៅអាឡុង គឺ ឡុងព្រោះនៅអាល័យ ។

ឡូ-ឡា.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ឡូៗ ខ្លាំងៗ។ និយាយឡូឡា ។ បរិវារស័ព្ទ ឡា អាចគន្លាស់បានជាពាក្យ ឡាដោយអានាចូរ គឺ ឡូដោយអានាចារ ពោលគឺ និយាយខ្លាំងៗ ខុសបែបបទ ខុសសណ្ដាប់ធ្នាប់ ។ ពាក្យអានាចារ បានសេចក្ដីថា ÷ ការប្រព្រឹត្តខុសបែបបទសណ្ដាប់ធ្នាប់ ។

ឡូង-ឡាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ សូរស្រែកឡូងៗ ក្អេងក្អាង ។ ស្រែកឡូងឡាង។ បរិវារស័ព្ទ ឡាង អាចគន្លាស់បានជាពាក្យ ឡាងដោយសម្ដីក្អេងក្អាងរ៉ាងវូង គឺ ឡូងដោយសម្ដីក្អេងក្អាងវូងរ៉ាង ។

ឡេម-ឡើម.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលបង្ហាញមុខឱ្យឃើញមួយភ្លែតៗ. ដែលរណេបរនើបឡេមឡើម ។

ឈរឡេមឡើម។ល។ បរិវារស័ព្ទ ឡេម អាចគន្លាស់បាន ជាពាក្យ ឡេមដោយចេះរណោបរនើបវារគគឹមគគើម គឺ ឡើម ដោយចេះរណោបរនើបវារគគើមគគឹម ។

**ឡែ្យ-ឡែ្យ.**-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ក្មេងក្មាងឥតប្រយោជន៍ ឥតគោរពកោតក្រែង។ សម្ដីឡែ្យឡ្យ។ល។ បរិវារស័ព្ទ ឡែ្យ អាចគន្លាស់បានជាពាក្យ ឡែ្យក្មេងក្មាងឥតប្រយោជន៍ ដោយអួតខ្លួនថាពូករ គឺ ឡក្មេងក្មាងឥតប្រយោជន៍ ដោយអួតខ្លួនថាពូកែ។ ពាក្យឡែ្យឡ្យនេះ យើងអាចដោះស្រាយបានមួយវគ្គទៀត គឺ ឡែ្យ ក្មេងក្មាងអែមម៉ គឺ ឡក្មេងក្មាងអែម-ម៉ែ។ អ្នកខ្លះនិយាយពាក្យនេះថា ÷ ឡេ្យឡ្យវិញ ។

**ឡែ្យ-ឡ្យប់.**- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលស្រែក ឬនិយាយក្មេងក្មាង ខ្លាំងៗ នាំឱ្យឡប់។ បរិវារស័ព្ទ ឡែ្យ អាចគន្លាស់បានជាពាក្យ ឡែ្យដោយនិយាយខ្លាំងៗ ដែពប្រប់ គឺ ឡប់ដោយនិយាយខ្លាំងៗ ដែពព្រៃ ។

⁂

# ង

**អង្គាប់_អង្គើ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលរអាក់រអួលឬទទាក់ទទាមនាំឱ្យពិបាក ច្រើនលើកច្រើនដង ។ ធ្វើទុក្ខអង្គាប់អង្គើ។ បរិវារស័ព្ទ អង្គាប់ អាចគន្លាស់បានជាពាក្យ អង្គាប់វិលក្រលើ គឺ អង្គើ វិលក្រឡាប់ ពោលគឺ ស្មុកស្មាញរអាក់រអួលក្រៃពេក ។

**អង្គី_អង្គើ.-** ដែលញ័រ, រញ្ជួយ ។ បរិវារស័ព្ទ អង្គី អាចគន្លាស់បានជាពាក្យ អង្គីដូចគេក្រវី គឺ អង្គើដូចគេគ្រវី ។

**អង្គឹក_អង្គើកឬអង្គេក_អង្គើក.-** ពាក្យទាំងពីរម៉ាត់នេះ ខ្មែរយើងប្រើទៅតាមទម្លាប់អ្នកស្រុក តាមជនបទ បានសេចក្ដីថា ÷

អញ្ចួយប៉ាក់ប៉ើកឬប៉ាក់ពើក ពោលគឺ បះចុះបះឡើង។ បរិវារ-ស័ព្ទ អង្កេក អាចគន្លាស់បានជាពាក្យ អង្កេកដោយប៉ាក់ពើក តើក គឺ អង្កើកដោយប៉ាក់ពើកពេក ។

អង្គប់_អង្គុល.- តាមវចនានុក្រម បានសេចក្ដីថា ÷ ដែលខ្សឹបខ្សួលប៉ផ្ទៃបជ្រប់មុខ. ដែលកើតទុក្ខជ្រប់។ ច្រើនប្រើក្នុងពាក្យកាព្យ។ បរិវារស័ព្ទ អង្គប់ អាចគន្លាស់បានជាពាក្យ អង្គប់ដោយកើតទុក្ខជ្រុល គឺ អង្គុលដោយកើតទុក្ខជ្រប់។ មានពាក្យកាព្យខ្លះឃើញសរសេរអង្គុកអង្គុលវិញ ។

អង្គុំ_អង្គាល.- ពាក្យនេះមានន័យថា ÷ រអាររអួម. ហីនហោច ខ្មេចខ្ទី។ល។ ភ្លើងឆេះព្រៃអង្គុំអង្គាល។ បរិវារស័ព្ទ អង្គាល អាចគន្លាស់បានជាពាក្យ អង្គាលហីនហោចខ្ទេចខ្ទីអស់ដូចគេរុកផ្ដុំគឺ អង្គុំហីនហោចខ្ទេចខ្ទីអស់ដូចគេរុកឆ្នៀល ។

អណ្ដែក_អណ្ដូង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អណ្ដែតខ្ពស់ច្រឡូងលន្លោច។ បរិវារស័ព្ទ អណ្ដូង អាចគន្លាស់បានជាពាក្យ អណ្ដូងខ្ពស់ស្រឡៀត គឺ អណ្ដែតខ្ពស់ស្រឡូង ។

អន្ទះ_អន្ទែង.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ រសាប់ប្រះ-

ប្រាណ, ឡេះឡះដោយឈើចាប់ពើត, ក្តៅ, ក្រហល់ក្រហាយ។ គ្រុនក្តៅអន្ទះអន្ទែង, អន្ទះអន្ទែងចង់បានប្រពន្ធ ។ បរិវារស័ព្ទ អន្ទែង អាចគន្លាស់បានជាពាក្យ អន្ទែងរសាប់រសល់តែម្នាក់អះ គឺ អន្ទះរសាប់រសល់តែម្នាក់ឯង ។

អន្លក់_អន្លោញ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ បន្លែដែលប្រើជ្រលក់បរិភោគផ្សំជាមួយនឹងទឹកគ្រឿង ឬ ផ្អក។ល។ បរិវារស័ព្ទ អន្លោញ អាចគន្លាស់បានជាពាក្យ អន្លោញបន្តិចបន្តួចល្អិតល្អួត គឺ អន្លក់បន្តិចបន្តួចល្អិតល្អោញ ។

អន្លក់_អន្លែ.-តាមវចនានុក្រម ពាក្យនេះ មានន័យថា÷ អន្លក់ផ្សេងៗ, អន្លក់គ្រប់មុខ ។ បរិវារស័ព្ទ អន្លែ អាចគន្លាស់បានជាពាក្យ អន្លែជាផ្លែផ្កាឈើព្រៃផ្សុក គឺ អន្លក់ជាផ្លែផ្កាឈើព្រៃផ្សែ ។

អង់_អាច.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលអាចហ៊ាន, ក្លាហាន, ឥតញញើត ឥតកោតក្រែង ឥតភ្លឹក។ ចិត្តអង់អាច សម្តីអង់អាច មនុស្សអង់អាច។ ច្រើនប្រើក្នុងពាក្យកាព្យ។ បរិវារស័ព្ទ អង់ អាចគន្លាស់បានជាពាក្យ អង់ហ៊ានប្រព្រឹត្តព្រោះមានចំណាច គឺ អាចហ៊ានប្រព្រឹត្តព្រោះមានចំណង់។

អប_បេ.- តាមវចនានុក្រម បានសេចក្ដីថា ÷ សម្រួលចិត្តដោយអនុ-លោមតាម, យកចិត្តគេ។ ខ្ញុំមិនខ្ចីទៅអបបេវាធ្វើអ្វីទេ ។ បរិវារស័ព្ទ បេ នេះពុំមានសម្លេងដូលតាមពាក្យដើមដូច បរិវារ-ស័ព្ទ ទាំងពួងឯទៀត តែយើងអាចគន្លាស់កាត់ជាវគ្គមួយថា : បេចិត្តកោក គឺ បោកចិត្តគេ ពោលគឺ អែបអបដោយកល់-ល្បិចបោកបញ្ឆោតចិត្តគេតែប៉ុណ្ណោះ ។

អ័ព្ទ_អួ.- ពាក្យនេះមានន័យថា ÷ ពុំស្រឡះតឹងតែង, វិបត្តិ។ល។ មេឃអ័ព្ទអួ គឺ មេឃងងឹតរកភ្លៀង, បរិយាកាសអ័ព្ទអួ គឺ បរិ-យាកាស ចង្អៀតចង្អល់ដោយមានវិបត្តិ។ល។ បរិវារស័ព្ទ អួ អាចគន្លាស់បានជាពាក្យ អួដោយមានការពុំកាប់ គឺ អ័ព្ទ ដោយមានការពុំគួរ ពោលគឺ មានការពុំគួរគប្បី ឬ មានការ មិនល្អ ។ល។

អាក្រក់_អាក្រី.-តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ដែលមិន ល្អ, ពុំប្រសើរ, ពុំប្រពៃ។ យ័ក្សចិត្តកាចអាក្រក់អាក្រី។ បរិ-វារស័ព្ទ អាក្រី អាចគន្លាស់បានជាពាក្យ អាក្រីអប្រក់ គឺ អា-ក្រក់អប្រិយ៍ ពោលគឺ អាក្រក់ពេកក្រៃដែលអ្នកផងជៀសវាង។

**អាចារ្យ_អាចុំ.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អ្នកប្រដៅឬហាត់មារយាទ, អ្នកប្រព្រឹត្តល្អ, អ្នកបង្រៀនតម្រេះគេ ឬគ្រូបង្រៀន។ល។ រឿងរៀបមង្គលការកូនចៅយើង ត្រូវរកអាចារ្យអាចុំដែលមានតម្រេះវិជ្ជាច្រើនឱ្យគេទស្សទាយ រកពេលវេលាឱ្យ។ល។ ត្រង់នេះខ្មែរយើងចង់ពោលដោយមានបំណងថា ÷ បើទោះជាយ៉ាងដូចម្តេចយើងមិនត្រូវ ភ្លេចលោកគ្រូអាចារ្យយើងផ្ទាល់ដូច្នេះ បរិវារស័ព្ទ អាចុំ បានសេចក្តីថា ÷ អាចុំ លោកគ្រូខ្មារ គឺ អាចារ្យលោកគ្រូខ្ញុំ ។

**អុច_អាល.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ញុះញង់ចាក់រុកនាយអាយឱ្យក្តៅចិត្តខ្លាំង។ សម្តីអុចអាល។ បរិវារស័ព្ទ អាល អាចគន្លាស់បានជាពាក្យ អាលដើម្បីខឹងដាលរ៉ុច គឺ អុជដើម្បីដាលរ៉ាល។ អ្នកខ្លះសរសេរពាក្យនេះ តាមសម្លេងនិយាយវិញ គឺ អុចអាល ។

**អូង_អាង.-** បានសេចក្តីថា ÷ អូងផងអាងផង ដើម្បីឱ្យអ្នកផងញញើតកោតក្រែងដោយបញ្ចេញឫកពាលបន្តិច ដូច្នេះបរិវារស័ព្ទ អូង អាចគន្លាស់បានជាពាក្យ អូងរបៀបយូកាង គឺ អាងរបៀបយូកូង ។

**អើត_អើម.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ អើតដោយ ញញើតញញើម ងាកឆ្វេងងាកស្តាំមើលនាយអាយ ឬអើត ឡេមឡឹមចេញមិនចេញចូលមិនចូល។ ឈរអើតអើមតាមមាត់ទ្វារ។ បរិវារស័ព្ទ អើម អាចគន្លាស់បានជាពាក្យ អើមមើលដង្ហើត គឺ អើតមើលដង្ហើម ពោលគឺ អើតមើលជើងការណ៍ស្តង់ដង្ហើមមើល ។ល។

**អៀន_អន់.-** តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ នឹកខ្មាស់រួញចិត្តគំនិត, ខ្មាស់នឹកតូចចិត្តឬអន់ចិត្ត។ បរិវារស័ព្ទ អន់ អាចគន្លាស់បានជាពាក្យ អន់ដោយខ្មាស់ខ្នួរមុខព្រោះគេចម្អៀន គឺ អៀនដោយខ្មាស់ខ្នួរមុខព្រោះគេចម្អន់ ។

**អេច_អួច.-** សូមមើលពាក្យ រអេចរអួច ។

**អែប_អប.-** តាមវចនានុក្រម បានសេចក្តីថា ÷ អែបជិតជារណប។ បរិវារស័ព្ទ អប អាចគន្លាស់បានជាពាក្យ អបជារណែប គឺ អែបជារណប ឬ អបវាយស្រែប គឺ អែបវាយស្រប ពោលគឺ អែបយកជើងគេដោយពុំមានយោបល់ប្រទុស្តសារ៉ាយ។

អះ_អាង.- តាមវចនានុក្រម ពាក្យនេះ មានន័យថា ÷ ទទួលខ្លួនជាសំអាង, ទទួលខ្លួនរ៉ាប់រង ឬខុសត្រូវលើខ្លួន។ បរិវារស័ព្ទ អះ អាចគន្លាស់បានជាពាក្យ អះដោយទទួលខ្លួនជាម្ចាង គឺអាង-ដោយទទួលខ្លួនជាម្ចាស់ ពោលគឺ អះអាងដោយទទួលរ៉ាប់រង ធានាជួស ឬជាអ្នកពំនាក់ទទួលខុសត្រូវលើខ្លួនជួសគេ ។

អរ_អេក.- តាមវចនានុក្រម បានសេចក្ដីថា ÷ អរខ្លាំងស្ទើរភ្លេចខ្លួន, អរឆ្អែតឆ្អា។ ពាក្យអេកនេះ ខ្មែរយើងយកមកប្រើជា បរិវារស័ព្ទ សម្រាប់យកមកផ្សំជាមួយនឹងពាក្យ បែកអេកបែកភក់, បែកអេកបែកម៉ាម, បែកអេកបែកខុន។ ពាក្យអរអេកនេះខ្មែរអ្នកស្រុកលើច្រើនប្រើនៅឡើយ ដូចក្នុងវគ្គស្រវឹងស្រាអេក គឺ ស្រវឹងស្រាខ្លាំង។ ដូច្នេះបរិវារស័ព្ទ អេក អាចគន្លាស់បានជាពាក្យ អេកប៉រ គឺ អរពេក ។

ឧម_អាម.-ពាក្យឧមអាមនេះ ខ្មែរយើងច្រើនប្រើនៅដើមមន្តគាថា ឬបាលីនៃធម៌ព្រាហ្មណ៍ ដូចជាសូត្ររបៀនដាក់ស្នេហ៍ ។ល ។

វ៉ងគ្រូស្ទេហ៍នោះសោត គេច្រើនសម្គាល់ឃើញរហូតមកដល់-សព្វថ្ងៃនេះ ច្រើនមាននៅសល់តែគ្រូចាមដែលបុរសខ្មែរយើងច្រើនអនុលោមថា: ជាគ្រូភរបោកប្រាស់ខុសអំពីគំនិតស្រីមួយជំពូកតូចវិញ។ ដូច្នេះបរិវារស័ព្ទ អាម អាចបកស្រាយបាន-ជាពាក្យគន្លាស់ថា ÷ អាមគ្រូស្នេហ៍ចូម គឺ ឧមគ្រូស្នេហ៍ចាមពោលគឺ ឧទ្ទិសនឹករកគ្រូស្នេហ៍ចាមឱ្យជួយ ។

**-ចប់-**

* *

*



ការផ្សាយសៀវភៅនេះជា eBook បានបង្កើតឡើងដោយ

**មូលនិធិខ្មែរសម្រាប់ការសិក្សា និង ករុណាខ្មែរ**

ដើម្បីបម្រើប្រយោជន៍ជាសាធារណៈ ដោយមិនគិតកម្រៃ

ស្កេន ជា eBook ដោយ អ៊ុក ស្រីណា

ឧសភា ឆ្នាំ ២០១៥


បើលោក-លោកស្រីចង់បានសៀវភៅនេះ ឬអានបន្តទៅទៀត សូមទិញ ឬជាវពីអ្នកនិពន្ធ

ឬបណ្ណាគារដោយផ្ទាល់ដើម្បីគោរព "រក្សាសិទ្ធិ" របស់អ្នកនិពន្ធ។

យើងខ្ញុំ ពុំមានការប្រាស្រ័យទាក់ទង ដោយប្រភេទណាមួយជាមួយអ្នកនិពន្ធ ឬបណ្ណាគារទេ។



សូមអរគុណ

ខ្ទៅ យុនសំរ៉ង

ប្រធាន

មូលនិធិខ្មែរសម្រាប់ការសិក្សា



www.elibraryofcambodia.org